

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ( NEP )

# របាយការណ៍
# សន្និសីទជាតិលើកទី៦
# ស្តីពីបរិវត្តកម្មវិស័យអប់រំ

ថ្ងៃទី០៧ -០៨ ខែមេសា ឆ្នាំ២០២៥

គាំទ្រ និងឧបត្ថម្ភដោយ

# មាតិកា


I. សង្ខេបអនុសាសន៍ ឬសំណូមពររបស់វាគ្មិន និងអ្នកចូលរួម ........ 1
II. សេចក្តីផ្តើម ........ 9
III. គោលបំណង ........ 9
IV. រចនាសម្ព័ន្ធ និងវិធីសាស្ត្រ ........ 9
V. កាលបរិច្ឆេទ ទីកន្លែង និងអ្នកចូលរួម ........ 9
VI. ប្រធានបទសំខាន់ៗនៅក្នុងសន្និសីទ ........ 10
VII. លទ្ធផលរំពឹងទុក ........ 10
VIII. លទ្ធផលនៃសន្និសីទជាតិលើកទី៦ ........ 10
ថ្ងៃទី១ ថ្ងៃចន្ទ ទី៧ ខែមេសា ឆ្នាំ២០២៥ ........ 10
កម្មវិធីបើក ........ 10
សេចក្តីផ្តើមសម្រាប់កិច្ចពិភាក្សា ........ 16
កិច្ចពិភាក្សាតាមដំណោះស្រាយ ........ 25
កិច្ចពិភាក្សាដំណោះស្រាយទី១ ........ 25
កិច្ចពិភាក្សាដំណោះស្រាយទី២ ........ 39
កិច្ចពិភាក្សាដំណោះស្រាយទី៣ ........ 49
ថ្ងៃទី២ ថ្ងៃអង្គារ ទី៨ ខែមេសា ឆ្នាំ២០២៥ ........ 54
ចាក់វីដេអូសង្ខេបថ្ងៃទី១ ........ 54
ដំណោះស្រាយទី៤ ........ 54
ដំណោះស្រាយទី៥ ........ 61
ដំណោះស្រាយទី៦ ........ 67
IX. សង្ខេបចំណុចគន្លឹះសំខាន់ៗតាមប្រធានបទនៃសន្និសីទ ........ 77
X. ការអំពាវនាវសកម្មភាពពីសន្និសីទ ........ 79
XI. សុន្ទរកថាសំណេះសំណាល និងបិទកម្មវិធី ........ 82
XII. របៀបវារៈ កម្មវិធី ........ 84
XIII. បទបង្ហាញ ........ 87

## I. សង្ខេបអនុសាសន៍ ឬសំណូមពររបស់វាគ្មិន និងអ្នកចូលរួម

| ល.រ | អនុសាសន៍ ឬសំណូមពរ |
|---|---|
| ១ | - ការអនុវត្ត ត្រូវមានការប្រែប្រួលពីប្រព័ន្ធបុរាណ និងប្រភពហិរញ្ញប្បទានបែបចាស់ទៅលើដំណោះស្រាយជាមូលដ្ឋានសហគមន៍ ភាពជាម្ចាស់ការដោយរដ្ឋាភិបាល ដែលចំណាយទាប ប៉ុន្តែមានប្រសិទ្ធភាព។<br>- មានការសហការ និងការលើកកម្ពស់សមត្ថភាពរវាងNGO ម្ចាស់ជំនួយ  រដ្ឋាភិបាល និងវិស័យឯកជន។<br>- ការលើកកម្ពស់សមត្ថភាពដល់គណៈគ្រប់គ្រងសាលារៀន  និងបង្កើតបរិយាកាសសាលារៀនដែលសិស្សចង់រៀន និងឪពុកម្តាយចង់គាំទ្រ។<br>- ការជ្រើសរើស បណ្តុះបណ្តាល និងរក្សាទុកគ្រូដែលមានគុណភាព។<br>- គាំទ្រគោលនយោបាយ និងរចនាសម្ព័ន្ធដើម្បីជួយក្នុងការផ្ទេរអំណាចដល់មូលដ្ឋានក្នុងវិស័យអប់រំ ដោយធានាថារដ្ឋបាលមូលដ្ឋានមានសមត្ថភាពគ្រប់គ្រងថវិកាសាលារៀនមានប្រសិទ្ធភាព និងធានាគុណភាព។ |
| **ការលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីរបស់សាលារៀនដើម្បីពង្រឹងលទ្ធផលសិក្សារបស់សិស្ស<br>(ការចូលរួមរបស់NGO សាលារៀន អាជ្ញាធរមូលដ្ឋាន ឪពុកម្តាយ និងសហគមន៍)** | |
| ២ | - ការចុះព្រមព្រៀងជាមួយឃុំ និងសាលារៀន គឺសំខាន់ក្នុងការធានាថាការចូលរួម។  អង្គភាពត្រូវសម្របខ្លួនឱ្យសមស្របនឹងតម្រូវការអ្នកទទួលសេវា។ ការធ្វើ «បដិវត្តន៍កម្ម» បង្ហាញពីការផ្លាស់ប្តូរទៅវិធីមានដែលមិនត្រឹមតែការផ្តល់សេវាទូទៅ ប៉ុន្តែជាប្រព័ន្ធដែលអាចទុកចិត្តបាន។ មុនពេលអាណាព្យាបាលជឿជាក់លើសាលា អង្គភាពត្រូវបង្ហាញ  សក្តានុពលក្នុងការផ្លាស់ប្តូរ និងឆ្លើយតបនឹងតម្រូវការបច្ចុប្បន្ន។ ការអភិវឌ្ឍសហគមន៍ និងសាលារៀន ត្រូវការជំនួយពីជនទី៣ ដើម្បីសម្របសម្រួល និងជួយដោះស្រាយបញ្ហាដែលអាចមានឧបសគ្គ។<br>- ទោះបីជាមានឆន្ទៈក្នុងការផ្លាស់ប្តូរ  ក៏អាចមានឧបសគ្គពីគោលនយោបាយ។  ត្រូវការការកែប្រែគោលនយោបាយ ដើម្បីអនុញ្ញាតឱ្យសាលា និងសហគមន៍អភិវឌ្ឍការងារបានយ៉ាងបត់បែននិងសេរីភាព។ |
| ៣ | ដើម្បីឱ្យគណៈកម្មការគ្រប់គ្រងសាលារៀន ឬសហគមន៍ចូលរួមក្នុងការសម្រេចចិត្តរបស់សាលារៀន គួរៈ<br>- មានយន្តការចូលរួមច្បាស់លាស់នៅកម្រិតសាលារៀន និងកម្រិតថ្នាក់រៀន។ គណៈកម្មការត្រូវចូលរួមក្នុងការសម្រេចចិត្ត មិនថាគោលនយោបាយសាលារៀន ឬសកម្មភាពណាមួយ។<br>- បំប៉នសមត្ថភាពនៅក្នុងដំណាក់កាលចាប់ផ្តើម ដូចជាការបណ្តុះបណ្តាល និងការសម្របសម្រួលការប្រជុំជាដើម ប៉ុន្តែមិនត្រូវសម្រេចចិត្តជំនួសគាត់ឡើយ<br>- ការចូលរួមរបស់ភាគីនានានឹងទទួលបានលទ្ធផលល្អ  ពេលដែលមាន  តម្លាភាព  និងគណនេយ្យភាព។ ប្រសិនបើខ្វះលក្ខណៈទាំងពីរនេះ នោះភាពសហការនឹងមិនអាចកើតមានឡើយ។ ដូច្នេះ គ្រូបង្រៀនគួរតែជាអ្នកចាប់ផ្តើមដោយចូលទៅរកឪពុកម្តាយជាមុន ដែលជាជំហានដំបូងក្នុងការបង្កើតសហការ។ |
| ៤ | - ឪពុកម្តាយមិនសូវមកសាលារៀននោះទេ។ ***តើយើងអាចប្រើយន្តការមួយណា ដើម្បីផ្លាស់ប្តូរនេះ?*** ជំហានដំបូង គឺការផ្តល់ព័ត៌មានដល់ឪពុកម្តាយ ដោយត្រូវអញ្ជើញឱ្យពួកគេចូលមកសាលារៀនមុនសិន ដូចជាសកម្មភាព ចែកលទ្ធផលសិស្សតាមពិធីតូចៗ ឬចែកវិញ្ញាបនបត្រឱ្យកូនៗ។ |

| | |
|---|---|
| | - អំពីការចូលរួមរយៈពេលវែង។ យើងក៏ត្រូវគិតអំពីអាហារូបត្ថម្ភ និងកម្មវិធីអាហារនៅតាមសាលារៀន។ កម្មវិធីនេះ កំពុងអនុវត្តនៅតំបន់ខ្លះៗ។ ប្រសិនបើកូនមានអាហារ ហើយនៅសាលារៀន។ ពួកគេនឹងមិនត្រូវបានយកទៅធ្វើការនៅកន្លែងធ្វើការនោះទេ។ យើងត្រូវឱ្យមានគំនិតរួមចំពោះរឿងនេះ។ តើអ្នកដឹកនាំសាលារៀនគួរមានតួនាទីអ្វីខ្លះ និងទទួលខុសត្រូវចំពោះអ្វី? នេះជាសំណួរសំខាន់សម្រាប់ជំហានបន្ទាប់។ |
| ៥ | ការសហការជាមួយគណៈកម្មការសាលារៀនត្រូវធ្វើជាប្រចាំ ដើម្បីសិក្សា និងដោះស្រាយ បញ្ហាជាក់ស្តែងរបស់គ្រួសារសិស្ស។ ជំនួយដែលផ្តល់ដូចជា កញ្ចប់អង្ករ សាំងសម្រាប់គ្រូទៅតាមដានសិស្សនៅផ្ទះ និងការយកចិត្តទុកដាក់ត្រូវផ្តោតលើការយល់ពីបញ្ហា និងឆ្លើយតបបំផុតដល់សមត្ថភាពជាក់ស្តែងរបស់សិស្ស។ ការចុះទៅតាមដានផ្ទាល់ គឺជាការចូលទៅជួបអាណាព្យាបាលដើម្បីស្តាប់ និងឆ្លើយតបតាមបញ្ហាជាក់ស្តែងរបស់សិស្ស ដែលអាចជួយបំផ្លាញចិត្តសិស្សចង់បោះបង់ការសិក្សា។ សិស្សដែលនៅឆ្ងាយ និងមានបញ្ហាថវិកាអាចត្រូវការជំនួយ។ សាលារៀន និងគម្រោងត្រូវចូលរួម ដើម្បីអនុញ្ញាតឱ្យសិស្សរៀនដោយគ្មានការទាមទារថវិកា ដែលអាចជួយឱ្យអាណាព្យាបាលយល់ដឹង និងផ្តល់ឱកាសឱ្យកូនបានបន្តការសិក្សា។ |
| ៦ | ក្នុងការធ្វើផែនការថវិកាដល់ក្រសួង គួរពិចារណាលើលំហែមាតុភាពរបស់គ្រូ។ ពេលគ្រូឈឺ ឬមានលំហែ មិនមានអ្នកជំនួស អាចប៉ះពាល់ដល់សិស្ស។ ដូច្នេះ គួរចែកថវិកាមួយចំណែកទៅសាលា ដើម្បីអាចជួលគ្រូជំនួសបានសមស្រប ដែលជួយទប់ស្កាត់ការរំខានដល់សិស្ស និងរក្សាគុណភាពការបង្រៀន។ |
| ៧ | សូមក្រសួងនិយាយអំពីលទ្ធផលការអនុវត្ត និងទទួលស្គាល់បញ្ហាគ្រប់គ្រងទិន្នន័យសិស្សដែលធ្លាប់មាន។ ពេលនេះ ឃើញច្បាស់ពីចំណុចដែលនៅមិនទាន់ជោគជ័យ។ ចំពោះការលើកឡើងបញ្ហាប្រឈម សូមអង្គការផ្សេងៗពិចារណាឱ្យអាជ្ញាធរមូលដ្ឋានចូលរួមពេញលេញ ព្រោះពួកគាត់យល់ដឹងបញ្ហា និងអាចជួយឱ្យការអនុវត្តមានប្រសិទ្ធភាព និងទទួលបានលទ្ធផលពិតប្រាកដ។ |
| ៨ | លទ្ធផលសិក្សាសិស្សពឹងផ្អែកលើការចូលរួមរបស់ភាគីទាំងអស់ មិនត្រឹមតែសាលា និងគ្រូទេ ប៉ុន្តែមានសហគមន៍ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ។ ដើម្បីឱ្យសហគមន៍ចូលរួមមានប្រសិទ្ធភាព ត្រូវបង្ហាញឱ្យគាត់ឃើញ និងយល់អំពីសកម្មភាពដែលអង្គភាពចង់ឱ្យគាត់ចូលរួម។ ការបង្ហាញពីអ្វីដែលបានធ្វើ និងអំពាវនាវការចូលរួម ជាជំហានសំខាន់ក្នុងការបង្កើតភាពជឿជាក់ និងជម្រុញឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការអប់រំ។ |
| ៩ | នៅកម្រិតសាលារៀន នាយកសាលា គ្រូបង្រៀន និងគណៈកម្មការត្រូវសហការគ្នា រកឫសគល់បញ្ហា និងបង្កើនសមត្ថភាពសិស្សឱ្យមានលទ្ធផលសិក្សាល្អ។ នាយកសាលាជាតួអង្គសំខាន់ក្នុងការអភិវឌ្ឍគុណភាពសិក្សា។ ការអភិវឌ្ឍសមត្ថភាពនាយក ជាចំណុចសំខាន់ក្នុងការជំរុញគុណភាពសិក្សាទាំងមូលរបស់សាលា។ |
| ១០ | តេស្តស្តង់ដា មានសារៈសំខាន់ក្នុងការវាស់វែងលទ្ធផលសិក្សា ហើយត្រូវយល់ថាវាជាចំណុចចាប់ផ្តើម មិនមែនជាចំណុចបញ្ចប់នៃការចាត់ថ្នាក់ប៉ុណ្ណោះទេ។ គោលបំណង គឺដើម្បីផ្តល់ព័ត៌មានពិតប្រាកដអំពីសមត្ថភាពសិស្ស ដើម្បីកែសម្រួលការបង្រៀន និងជួយសិស្សឱ្យមានលទ្ធផលល្អឡើង។ លទ្ធផលតេស្តត្រូវបានយកមកពិភាក្សា និងវិភាគនៅក្នុងសាលា ដោយមានការចូលរួមពីគ្រប់ភាគី ដើម្បីស្វែងរកមូលហេតុ និងដោះស្រាយបញ្ហា។ លេខតេស្តនីមួយៗតំណាងឱ្យជីវិតសិស្សម្នាក់ មិនមែនជាលេខធម្មតា។ ដូច្នេះ សាលាគួរតែទទួលស្គាល់លទ្ធផលដែលបានសម្រេច ហើយបម្លែងវាជាសកម្មភាពជាប្រចាំ ដើម្បីជួយសិស្សអភិវឌ្ឍអប់រំនៅពេលក្រោយ។ |

| ភាពអាចបត់បែននៃការរៀនសូត្រសម្រាប់កុមារក្រៅសាលា៖ ការពង្រឹងការអនុវត្តថ្នាក់បំប៉នសិស្សរៀនយឺត | |
|---|---|
| ១១ | - ដើម្បីអនុវត្តបានការបង្រៀនពេញ ១ថ្ងៃបានត្រូវ៖ ១.ស្នើឱ្យគ្រូបង្រៀនចូលរួមក្នុងការអនុវត្តកម្មវិធីបង្រៀនពេញ១ថ្ងៃ ដោយលះបង់ ចែករំលែក និងគោរពសេចក្ដីសម្រេចរបស់ភាគច្រើន និងអនុវត្តច្បាប់វិន័យរបស់សាលា។ ២.ស្នើឱ្យមាតាបិតាឬអាណាព្យាបាលសិស្សចូលរួមបង់ថវិកាមូលនិធិសមធម៌ ដើម្បីគាំទ្រការអប់រំសិស្សពេញ ១ថ្ងៃ។ ៣.ស្នើសុំការគាំទ្របន្ថែមពីអង្គការដៃគូ សម្រាប់ការបណ្ដុះបណ្ដាលគ្រូបង្រៀននៅក្នុងមុខវិជ្ជាភាសាអង់គ្លេស និងផ្គត់ផ្គង់គ្រឿងបរិក្ខារ ដូចជាកុំព្យូទ័រ និងសំណង់សាលា។ នៅក្នុងនោះក៏ត្រូវសម្រួលការបង់ថវិកា ដោយលើកលែងសិស្សដែលមានប័ណ្ណក្រីក្រ និងគ្រួសារដែលមានកូនច្រើន។<br>- គណៈកម្មការគ្រប់គ្រងថវិកា ត្រូវបង្ហាញចំណូលចំណាយដល់សហគមន៍ ដើម្បីធានាពីភាពស្មោះត្រង់ និងការទទួលខុសត្រូវ។<br>- សំណូមពរចំពោះក្រសួងអប់រំ៖ បន្តការគាំទ្រ ជាពិសេសក្នុងការអនុវត្តគោលនយោបាយ បើកបង្រៀនពេញមួយថ្ងៃ និងការផ្តល់អាហារថ្ងៃត្រង់ជំនួសអាហារពេលព្រឹក។ |
| ១២ | យើងចង់ប្រែក្លាយពីកម្មវិធីមួយដែលមានដំណើរការតែរយៈពេល ២/៣ខែ ក្លាយជាកម្មវិធីសិក្សាពេញ១ថ្ងៃ ដែលអនុវត្តពេញ ១ឆ្នាំសិក្សា ដោយប្រែក្លាយការអនុវត្តកម្មវិធីបំប៉នសិស្សរៀន ២/៣ខែ មកជាការគាំទ្រនៅក្នុងប្រព័ន្ធ ដោយផ្សារភ្ជាប់ទៅនឹងកម្មវិធីថ្មីៗ។ ដើម្បីអនុវត្តយើងត្រូវ៖<br>- មានគោលការណ៍ណែនាំជាមុនសម្រាប់ការគ្រប់គ្រង និងអនុវត្តកម្មវិធី ដើម្បីអាចសហការជាមួយសាលារៀន និងអាជ្ញាធរបានប្រសើរនៅដើមការអនុវត្ត។<br>- ពង្រឹងសហការជាមួយនាយកដ្ឋាន និងដៃគូអន្តរក្រសួង ដោយបង្កើតក្រុមការងារសហការអន្តរក្រសួង ដើម្បីគាំទ្រការគ្រប់គ្រង និងអនុវត្តកម្មវិធីមានប្រសិទ្ធភាព។<br>- រៀបចំយុទ្ធសាស្ត្ររាល់កម្រិត៖ ត្រូវត្រៀមយុទ្ធសាស្ត្រច្បាស់លាស់ និងទទួលបានការចូលរួមពីស្ថាប័នពាក់ព័ន្ធទាំងអស់។<br>- ក្នុងតំបន់ដែលមានភាពលំបាកខ្លាំង ដូចជាទីតាំងជាប់បឹងទន្លេសាប គួរត្រូវការសហការជិតស្និទ្ធជាងមុន ដោយសារខ្វះធនធានបច្ចេកទេស និងមនុស្ស។ |
| ១៣ | ដើម្បីជួយកុមារនៅតំបន់ដាច់ស្រយាល គួរប្រើយុទ្ធសាស្ត្រចម្បងដូចខាងក្រោម៖<br>- គុណភាពអប់រំ៖ ផ្តោតលើការកែលម្អជំនាញអាននិងគណិតវិទ្យា បណ្តុះបណ្តាលគ្រូឱ្យមានគុណភាព និងធានាការចូលរួមសិក្សាដោយសមភាព។<br>- និរន្តរភាព៖ រៀបចំផែនការជាមួយរដ្ឋាភិបាល និងដៃគូសហការដើម្បីបន្តគាំទ្រសាលាបន្ទាប់ពីគម្រោង បណ្តុះបណ្តាលគ្រូនិងនាយកបន្ថែម និងពង្រឹងសមត្ថភាពសហគមន៍ក្នុងការគាំទ្រការអប់រំ។<br>- ការអភិវឌ្ឍ៖ សិក្សាតំបន់មានតម្រូវការ ដើម្បីសាងសង់ អភិវឌ្ឍ និងជួសជុលសាលារៀន បណ្តុះបណ្តាលគ្រូសហគមន៍ជាពិសេស និងជួយសិស្សដែលមានហានិភ័យនៃការលះបង់ការសិក្សា។ |
| ១៤ | សម្រាប់ថ្នាក់ពន្លឿននៅPSE នឹងពិចារណាលើការកំណត់អាយុ។ ត្រឹម ១២ឆ្នាំ សម្រាប់ចូលឆ្នាំទី១ បង្កបញ្ហាសម្រាប់កុមារដែលមិនដែលចូលសាលា ឬបោះបង់សិក្សាយូរ។ ត្រូវពិចារណាបង្កើតថ្នាក់បឋមបន្ថែមដូចជា ឆ្នាំទី0 សម្រាប់កុមារអាយុ ១១ឆ្នាំ ឬអ្នកខ្សោយខាងសិក្សា។ PSE ក៏នឹងបង្កើតក្រុមតម្រង់ទិសអាជីព៖ ត្រូវមាន |

| | |
|---|---|
| | ក្រុមមន្ត្រីឯកទេសជួយសិស្សតម្រង់ទិសអាជីពត្រឹមត្រូវ ដោយប្រើតេស្តវាយតម្លៃទេពកោសល្យ និងធ្វើការជាមួយអាណាព្យាបាលក្នុងដំណើរការសម្រេចចិត្តអនាគតសិក្សា។ |
| ១៥ | - ការអប់រំក្រៅប្រព័ន្ធនៅតែសំខាន់ ដើម្បីជាស្ពានសមាហរណ៍កម្មទៅសាលារៀនរដ្ឋ ដោយមានការចូលរួមរបស់សិស្ស ក្នុងការធ្វើផែនការ និងសម្រេចចិត្ត និងមានការ ផ្តល់សម្ភារៈ គាំទ្រធ្វើដំណើរ អាហារ និងថែទាំសុខភាព។<br>- ពង្រឹងការសហការជាមួយសាលារៀន និងការិយាល័យអប់រំ ដើម្បីធានាថាកុមារដែលចូលរួមកម្មវិធីអប់រំក្រៅប្រព័ន្ធអាចរួមបញ្ចូលដោគជ័យទៅក្នុងសាលារដ្ឋ។<br>- ជំរុញកម្មវិធីពន្លឿន ដើម្បីជួយកុមារដែលមានអាយុច្រើនជាងថ្នាក់សិក្សាដែលពួកគេចុះឈ្មោះ ឱ្យអាចបញ្ចប់ថ្នាក់បានលឿន។<br>- ដោះស្រាយបញ្ហាសេដ្ឋកិច្ចគ្រួសារ ដោយតម្រូវឱ្យបន្ថែមធនធាន និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់អ្នកគ្រប់គ្រងគ្រួសារ និងកុមារក្រៅសាលា។<br>- អភិវឌ្ឍយុទ្ធសាស្ត្រដល់សិស្សដែលអវត្តមានញឹកញាប់ ដោយកំណត់សិស្សងាយរងគ្រោះ និងធ្វើការតាមដាននៅថ្ងៃដំបូងនៃការអវត្តមាន និងជំរុញការចុះឈ្មោះក្មេងស្រី។<br>- ផ្សព្វផ្សាយសហគមន៍ដើម្បីស្វែងរកកុមារមានហានិភ័យខ្ពស់ និងផ្តល់អន្តរាគមន៍រហ័សទៅគ្រួសារពួកគេ។ |
| **ការពង្រឹងជំនាញគរុកោសល្យ និងចំណេះដឹងនៃមុខវិជ្ជាបង្រៀនសម្រាប់គ្រូបង្រៀន «របៀបនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនទំនើបក្នុងការរៀនកម្រិតថ្នាក់ដំបូង»** | |
| ១៦ | ដើម្បីធានាបាននូវការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូមានប្រសិទ្ធភាព និងទូលំទូលាយ ក្រសួងបានដាក់ចេញអនុសាសន៍ និងសំណូមពរធំៗដូចខាងក្រោម៖<br>- ការពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង៖ ក្រសួងបានប្តូរនាយកដ្ឋានទៅជាអគ្គនាយកដ្ឋាន ដើម្បីអាចគ្រប់គ្រងការអនុវត្តបានទូលំទូលាយជាងមុន។<br>- ជំរុញឱ្យស្ថាប័ននានាចូលរួមក្នុងប្រព័ន្ធ CPD ដើម្បីធានាគុណភាពវគ្គបណ្តុះបណ្តាល និងផ្តល់ក្រេឌីតដែលមានអត្ថប្រយោជន៍នាពេលក្រោយ។<br>- ការបណ្តុះបណ្តាលផ្អែកលើលទ្ធផលសិក្សារបស់សិស្ស៖ វគ្គបណ្តុះបណ្តាលនឹងផ្តល់នៅតំបន់ដែលសិស្សមានលទ្ធផលទាប ដើម្បីលើកស្ទួយគុណភាពគ្រូបង្រៀន។<br>- ការពង្រីកបណ្តាញផ្តល់សេវាCPD៖ តាមរយៈការលើកទឹកចិត្តសាលាគរុកោសល្យ និងវិក្រឹតការខេត្តឱ្យដាក់ពាក្យជាគ្រឹះស្ថាន CPD។<br>- នឹងសាកល្បងប្រើប្រាស់ Voucher (១០០/២០០ដុល្លារ) សម្រាប់CPD។<br>- បច្ចេកវិទ្យាថ្មីសម្រាប់ការបង្រៀន៖ បង្កើតថ្នាលអនឡាញ និងអនុវត្តការប្រើ AI ជាជំនួយក្នុងការរៀន និងការបង្រៀន។ ការចូលរួមនេះនឹងផ្តល់ក្រេឌីតជាប្រយោជន៍។<br>- ផែនការរយៈពេលវែង និងឯកសារទស្សនទាន៖ ក្រសួងកំពុងរៀបចំផែនការយុទ្ធសាស្ត្រពង្រឹងការបណ្តុះបណ្តាលគ្រូ និងការផ្តល់ឯកសារសម្រាប់គ្រូកិច្ចសន្យា។ |

| | |
|---|---|
| ១៧ | ការបង្រៀនដើម្បីការជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅកម្រិតថ្នាក់ដំបូង។ លោកផ្តល់នូវអនុសាសន៍សម្រាប់ការកែលម្អគុណភាពការបង្រៀន និងសិក្សា ដូចជា៖<br>- អនុវត្តវិធីសាស្ត្រសកម្មផ្អែកលើសិស្សជាចម្បង៖ អភិវឌ្ឍវិធីសាស្ត្រថ្មីក្នុងកម្មវិធីEGL ដោយផ្អែកលើគោលការណ៍ «គ្រូធ្វើជាគំរូ – សិស្សធ្វើ – ធ្វើជាមួយគ្នា» និងបង្កើន ឱកាសអនុវត្តសម្រាប់សិស្ស ដើម្បីជៀសវាងភាពខ្សោយក្នុងការសិក្សា។<br>- បង្កើនគុណភាពការអនុវត្តក្រោយបណ្តុះបណ្តាល៖ ១.ពង្រឹងយន្តការតាមដាន និងប្រឹក្សាគរុកោសល្យ ដើម្បីគាំទ្រគ្រូឱ្យអនុវត្តបានពេញលេញ និង២.អភិវឌ្ឍការ តេស្តសិស្សបែបអនុវត្ត ដោយទីប្រឹក្សាដើម្បីគ្រូស្វែងរកចំណុចខ្វះខាតរបស់សិស្ស និងជួយសិស្សរៀនយឺត។<br>- ការបំប៉នសមត្ថភាពគ្រូដោយបច្ចេកវិទ្យា៖ អនុវត្តកម្មវិធីប្លែនឌិត (blended learning) ដោយបញ្ចូលថ្នាលអនឡាញសម្រាប់គ្រូឧទ្ទេស និងគ្រូកិច្ចសន្យា ដើម្បីបន្ថែមសមត្ថភាពគ្រប់កម្រិត។ |
| ១៨ | គ្រូបង្រៀនមិនទាន់ទទួលបានការបណ្តុះបណ្តាលពេញលេញ ជាចន្លោះប្រហោងមួយសំខាន់។ ដើម្បីដោះស្រាយបញ្ហានេះ លោកបានផ្តល់អនុសាសន៍ចាំបាច់ចំនួនបី ដែលលោកបានអនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនភាសាអង់គ្លេស ដោយការបំពាក់បំប៉នវិធីសាស្ត្របែបទំនើប។<br>- ផលិតសម្ភារៈឧបទេសជូនគ្រូ៖ ក្រុមការងារបានយកសៀវភៅសិក្សាគោលមកពិនិត្យឡើងវិញ ដោយព្យាយាមអភិវឌ្ឍកម្មវិធីសិក្សាលម្អិត និងឯកសារគាំទ្រផ្សេងៗ ដើម្បីអាចជួយឱ្យគ្រូអនុវត្តការបង្រៀនបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។<br>- បណ្តុះបណ្តាលគ្រូបង្រៀនលើវិធីសាស្ត្រអនុវត្ត៖ ក្រោយពេលមានកម្មវិធីសិក្សាលម្អិតរួច ក៏បានចាប់ផ្តើមបណ្តុះបណ្តាលគ្រូពីវិធីសាស្ត្រដែលអាចអនុវត្តបានយ៉ាងមានប្រសិទ្ធភាពក្នុងថ្នាក់រៀន ដើម្បីធានាបាននូវគុណភាពសិក្សា។<br>- បណ្តុះស្មារតីនិងវប្បធម៌នៃការសិក្សាពេញមួយជីវិត៖ មានការអញ្ជើញគ្រូចូលរួមកម្មវិធីបណ្តុះបណ្តាលរយៈពេលមួយឆ្នាំពេញ (ស្មើនឹង៤០សប្តាហ៍ ពីរោះ១សប្តាហ៍/៣ម៉ោង)។ កម្មវិធីនេះមានការត្រួតពិនិត្យយ៉ាងតឹងរឹង និងមានក្រុមប្រឹក្សាគរុកោសល្យចុះគាំទ្រដល់គ្រូនៅសាលារៀនជាប្រចាំ។ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលរយៈពេល១ឆ្នាំ គ្រូនឹងមានការទទួលបានការគាំទ្របន្ថែមរយៈពេល១ខែទៀត ដើម្បីបង្កើនសមត្ថភាពនិងអនុវត្តជាក់ស្តែង។ |
| ១៩ | - ក្រសួងបានស្នើឱ្យបញ្ចូលកម្មវិធីEGL ទៅក្នុងការបណ្តុះបណ្តាលគ្រូ១២+២ ដើម្បីឱ្យគរុសិស្សមានមូលដ្ឋានវិធីសាស្ត្របង្រៀនភាសាខ្មែរ និងការគ្រប់គ្រងថ្នាក់មុនចេញបង្រៀន។ វាជាជំហានដែលជួយសន្សំពេលវេលា និងបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តជាក់ស្តែង។ លោកមានអនុសាសន៍សំខាន់ៗ៖ ១.ត្រូវបន្តធ្វើការរួមដំណើរជាមួយអង្គការដៃគូ ដើម្បីឱ្យកម្មវិធីសិក្សាគរុសិក្សា និងការអនុវត្ត EGL នៅសាលាមានភាពស៊ីគ្នា និងគាំទ្រគ្នា។ ២.គ្រប់ភាគីគួរតែប្រើកម្មវិធីដូចគ្នា ដើម្បីធ្វើឱ្យការចុះកម្មសិក្សា ក៏ដូចជាការវាយតម្លៃអភិវឌ្ឍន៍គ្រូកើតមានប្រសិទ្ធភាព។ ៣.ត្រូវប្រើប្រាស់ព័ត៌មានដែលប្រមូលបានពីការអនុវត្ត ដើម្បីធ្វើការឆ្លុះបញ្ចាំងនិងកែលម្អកម្មវិធីបណ្តុះបណ្តាលបន្តនាពេលអនាគត។ |

| | |
|---|---|
| | - គ្រូចេញបង្រៀនតែងមានការលំបាកក្នុងការគ្រប់គ្រងថ្នាក់ និងអនុវត្តវិធីសាស្ត្របង្រៀន។ ដូច្នេះការចុះកម្មសិក្សារបស់គរុសិស្សគួរធ្វើនៅតំបន់ឆ្ងាយ និងមានបញ្ហាជាក់ស្តែង ដូចជា៖ សាលាមានសិស្សច្រើន ខ្វះបន្ទប់ ឬសម្ភារៈដើម្បីឱ្យគាត់ទទួលបានបទពិសោធន៍ពិតប្រាកដ ដើម្បីកសាងសមត្ថភាពនិងភាពរឹងមាំក្នុងការងារ។ ហើយត្រូវមានការគាំទ្របន្តតាមបែបអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដោយមានទីប្រឹក្សាគរុកោសល្យចុះជួយ និងផ្តល់ដំណោះស្រាយជាប្រចាំ។ |
| **ការពង្រីក និងពង្រឹងការអប់រំកុមារតូច ដើម្បីឈានដល់ការសម្រេចស្តង់ដា** | |
| ២០ | ដើម្បីបង្កើនគុណភាពមត្តេយ្យសិក្សាសហគមន៍ បំពេញស្តង់ដាអប្បបរមារបស់ក្រសួងអប់រំ មានជំហានដូចជា៖ ១.បង្កើតគណៈកម្មការ និងអនុវត្តការស្វ័យវាយតម្លៃ ២.សាងសង់ ឬជួសជុលសាលា និងបរិក្ខារ WASH ៣.បណ្តុះបណ្តាលគណៈកម្មការ និងគ្រូបង្រៀន ៤.ផ្តល់សម្ភារៈសិក្សា ៥.ត្រួតពិនិត្យ និងគាំទ្រដោយក្រសួង និងអង្គភាពពាក់ព័ន្ធ ៦.បង្កើត និងបណ្តុះបណ្តាលក្រុមឪពុកម្តាយ និង៧.រៀបចំសិក្សាឆ្លុះបញ្ចាំងប្រចាំឆ្នាំ។<br><br>ការវាយតម្លៃនឹងដំណើរដោយប្រើទម្រង់លំដាប់ជាចង្វាក់ ពីគ្រូ → គណៈកម្មការ → មេឃុំ → ក្រុមប្រឹក្សាឃុំ → ការិយាល័យស្រុក → មន្ទីរ → ក្រសួង។<br><br>សូមឱ្យមានការជំរុញឱ្យសាលា សហគមន៍ សហការជាមួយអាជ្ញាធពាក់ព័ន្ធ ដើម្បីបំពេញស្តង់ដាទាំងនេះដោយគាំទ្រផ្នែកថវិកា បណ្តុះបណ្តាល និងសម្ភារៈដើម្បីធានាគុណភាព និងស្ថេរភាពរបស់សាលា និងធានាថាការវាយតម្លៃ និងឯកសារគាំទ្រត្រូវបានរៀបចំរួចជាស្រេច ដើម្បីបញ្ជូនទៅក្រសួងតាមបណ្តាញគ្រប់ជំហាន។ |
| ២១ | អនុសាសន៍ចម្បងសម្រាប់ពង្រឹងការអប់រំបរិយាបន្ន សម្រាប់កុមារដែលមានពិការភាព (CWD) ជាពិសេសតាមរយៈការលេង ដូចខាងក្រោម៖<br>- ពង្រឹងការអប់រំបរិយាបន្ន តាមរយៈការបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀនអំពីរបៀបរៀបចំល្បែងសិក្សា និងសកម្មភាពលេងឱ្យសមស្របនឹងពិការភាព<br>- បង្កើត «គ្រូបង្គោលការអប់រំបរិយាបន្ន» នៅថ្នាក់ស្រុក-អ្នកអប់រំដែលបានទទួលការ បណ្តុះបណ្តាលចុះទស្សនៈកិច្ចសាលារៀន និងផ្តល់ការបង្វឹកសម្រាប់ CWD ទៅក្នុងសកម្មភាពផ្អែកលើការលេង។<br>– លើកទឹកចិត្តដល់គំរូជំនួយពីមិត្តភក្តិ ដែលកុមារគ្មានពិការបង្រៀនឱ្យចេះយល់ចិត្ត និងជួយដល់មិត្តរួមថ្នាក់ដែលមានពិការភាពក្នុងសកម្មភាពលេង។<br>– ផ្តល់សម្ភារៈសម្រាប់លេងដែលអាចសម្របខ្លួនបាន (ឧ. បោះពុម្ពធំ ឬហ្គេមដែលមានសំលេង) សម្រាប់កុមារដែលមានពិការភ្នែក ឬចលនាតូច។<br>– ពង្រឹងការចូលរួមរបស់មាតាបិតា ដើម្បីបង្កើនផលប៉ះពាល់នៃការរៀនផ្អែកលើការលេង។ សាលារៀនគួរតែរៀបចំវគ្គបង្កើនការយល់ដឹង ដើម្បីអប់រំអ្នកថែទាំអំពីសារៈសំខាន់នៃការលេងនៅក្នុងការECD។<br>– ផ្តល់សកម្មភាពនៅផ្ទះ និងលើកទឹកចិត្តមាតាបិតាឱ្យចូលរួមក្នុងគំនិតផ្តួច ផ្តើមការសិក្សាផ្សារភ្ជាប់រវាងថ្នាក់រៀន និងនៅផ្ទះ។<br>– បញ្ចូលការរៀនតាមលេង ទៅក្នុងគោលនយោបាយអប់រំកុមារតូចរបស់កម្ពុជា។ |
| **ការគាំទ្ររបស់ឪពុកម្តាយ និងការចូលរួមរបស់សហគមន៍** | |

| | |
|---|---|
| ២២ | គោលនយោបាយសិក្សាពេញមួយជីវិតដែលបានអនុម័ត ប៉ុន្តែមិនទាន់មានផែនការសកម្មភាព ដើម្បីធានាបាននូវការអនុវត្តពេញលេញ។ ផ្អែកលើគំរូជោគជ័យ (ដូចជាមជ្ឈមណ្ឌលសិក្សាសហគមន៍ស្រែក្នុង ខេត្តកំពត)។ យើងគួរសិក្សាពង្រីកគម្រោងទៅតំបន់ផ្សេងទៀត ដែលបានបង្ហាញពីប្រសិទ្ធភាព និងអាចអនុវត្តបាន។ ការរួមបញ្ចូលកម្មវិធីបង្កើតប្រាក់ចំណូលជាផ្នែកមួយនៃការអប់រំ និងការអភិវឌ្ឍជីវភាព ដើម្បីជួយបង្រៀនជំនាញជាក់លាក់ និងបង្កើនការចូលរួមរបស់សហគមន៍។ សូមបន្តការសិក្សាលើតម្រូវការជាក់ស្តែងរបស់សហគមន៍ មុនអភិវឌ្ឍកម្មវិធីដើម្បីធានាថាសេវាអប់រំ និងសកម្មភាពអភិវឌ្ឍសមរម្យនឹងបរិបទ និងតម្រូវការនៃតំបន់នីមួយៗ។ |
| ២៣ | - ស្នើសុំគាំទ្រក្នុងការផ្តល់ឯកសារផ្លូវច្បាប់ ដូចជាសំបុត្រកំណើត ដើម្បីជួយដោះស្រាយការពន្យាពេល ក្នុងការចុះឈ្មោះសាលារៀនឱ្យបានឆាប់រហ័ស និងបើកឱកាសឱ្យបន្តការសិក្សាបានគ្រប់ពេលវេលា ដោយបន្ថែមរយៈពេលចុះឈ្មោះ ឬចុះឈ្មោះបានក្រោយថ្ងៃផុតកំណត់។<br>- សូមពិចារណាដល់ការលើកលែង ឬបន្ថយថ្លៃបន្ថែមសម្រាប់ការសិក្សា (ឧ.ថ្លៃគ្រូបង្រៀនក្រៅផ្លូវការ ឯកសណ្ឋាន) សម្រាប់កុមារក្រីក្រ និងគាំទ្រថវិកា និងធានាបាននូវនិរន្តរភាពសម្រាប់សកម្មភាព។<br>- បន្តគាំទ្រក្នុងការបណ្តុះបណ្តាលអ្នកថែទាំ និងជំនួយក្នុងការងារ ដើម្បីបង្កើនស្វ័យភាពហិរញ្ញវត្ថុ និងការចូលរួមក្នុងការអប់រំកុមារ។<br>- ជំរុញការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន និងសាលារៀនរដ្ឋ ដើម្បីពង្រឹងការសមាហរណ៍កម្មកុមារឡើងវិញ និងការគ្រប់គ្រងករណី និងរួមសហការជាមួយអង្គការនានា ដើម្បីបញ្ជូនបន្ត និងរួមចំណែកលើការអភិវឌ្ឍកម្មវិធីជាក់លាក់ សម្រាប់កុមារនៅក្នុងស្ថានភាពងាយរងគ្រោះ។ |
| ២៤ | ជាសំណូមពរ ក្នុងបរិបទបញ្ហាប្រឈមនៃការលើកកម្ពស់ការអប់រំក្រៅប្រព័ន្ធ និងការសិក្សាពេញមួយជីវិតគឺ៖<br>- រដ្ឋាភិបាលជ្រោមជ្រែងលើបញ្ហា ដូចជាល្បែងស៊ីសង ការប្រើប្រាស់គ្រឿងញៀន និងក្រុមក្មេងទំនើងក្នុងសហគមន៍ ដែលជាហានិភ័យធំដល់ការសិក្សារបស់កុមារ។<br>- ស្នើសុំគាំទ្រសម្រាប់កម្មវិធីអប់រំផ្លូវចិត្ត និងបង្កើនការយល់ដឹង សម្រាប់ទាំងសិស្ស និងឪពុកម្តាយ ដើម្បីបង្កើនភាពធន់ និងការរួមចំណែកក្នុងការអប់រំក្រៅប្រព័ន្ធ។<br>- សូមសាលារៀន និងអាជ្ញាធរមូលដ្ឋានសហការជិតស្និទ្ធជាមួយអង្គការ ដើម្បីតាមដាន សម្គាល់ និងធ្វើអន្តរាគមន៍លើកុមារដែលមានហានិភ័យឱ្យទាន់ពេលវេលា។ |
| **បរិយាបន្ន និងសមភាពយេនឌ័រក្នុងការអប់រំ<br>(ការជំរុញការអប់រំបរិយាបន្ន៖ ការលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នសម្រាប់ទាំងអស់គ្នា)** | |
| ២៥ | អនុសាសន៍សំខាន់ៗសម្រាប់ការពង្រឹងសមភាពយេនឌ័រ និងបរិយាបន្ន<br>– ពង្រីកការបណ្តុះបណ្តាលគ្រូដែលឆ្លើយតបនឹងយេនឌ័រ និងការអនុវត្ត។<br>– ដាក់បញ្ចូលគរុកោសល្យដែលឆ្លើយតបនឹងយេនឌ័រទៅក្នុងគោលនយោបាយជាតិ/របៀបវារៈ និងវិជ្ជាជីវៈគ្រូបង្រៀន កម្មវិធីអភិវឌ្ឍមានសារៈសំខាន់ណាស់សម្រាប់ការធ្វើឱ្យអ្នកអប់រំមានចំណេះដឹង និងជំនាញដើម្បីអនុវត្តការបង្រៀនឆ្លើយតបនឹងយេនឌ័រក្នុងការបង្រៀនប្រចាំថ្ងៃរបស់ពួកគេ។<br>– ការកែលម្អប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដើម្បីតាមដានសមភាពយេនឌ័រ ជាពិសេសលើការឆ្លើយតបយេនឌ័រក្នុងការនៅក្នុងអនុវត្តថ្នាក់រៀន។ |

| | |
|---|---|
| | – ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលមូលដ្ឋាន NGO និងដៃគូអភិវឌ្ឍ។<br>– លើកកម្ពស់គំរូស្ត្រីក្នុងការបង្រៀន/តួនាទីជាអ្នកដឹកនាំក្នុងការអប់រំ និងផ្ដល់សិទ្ធិអំណាចដល់ក្លឹបកុមារី និងក្រុមមាតាដែលជាភ្នាក់ងារផ្លាស់ប្ដូរនៅក្នុងសាលារៀន។ |
| ២៦ | ដើម្បីធានាថាបច្ចេកវិទ្យាអប់រំនាំឱ្យមានសមភាពយេនឌ័រ និងបរិយាបន្នៈ៖<br>- បង្រៀនជំនាញឌីជីថល/អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយតាំងពីដំបូង<br>- បណ្ដុះបណ្ដាលគ្រូឱ្យចេះប្រឈមមុខនឹងភាពលំអៀងយេនឌ័រ និងគរុកោសល្យ ឆ្លើយតបនឹងយេនឌ័រ<br>- ផ្សព្វផ្សាយតួនាទីស្ត្រីជាគំរូក្នុងបច្ចេកវិទ្យា<br>- ពង្រឹងនីតិវិធីសុវត្ថិភាពអនឡាញក្នុងប្រព័ន្ធអប់រំ និងសាលារៀន<br>- ឧបករណ៍AI និងEdTechត្រូវបានរៀបចំឡើង និងត្រួតពិនិត្យប្រកបដោយក្រមសីលធម៌ ដើម្បីមានបរិយាបន្ន។<br>- យើងត្រូវតែធានាថា បច្ចេកវិទ្យាផ្ដល់សិទ្ធិអំណាចដល់ក្មេងស្រី និងស្ត្រី មិនមែនធ្វើឱ្យពួកគេបាត់បង់ប្រយោជន៍នោះទេ។ ការធានាឱ្យស្ត្រីចូលរួមក្នុងលក្ខខណ្ឌស្មើគ្នា ក្នុងការរៀបចំការផ្លាស់ប្ដូរឌីជីថលដែលកំពុងដំណើរការរបស់ពិភពលោក នឹងធានាថាបច្ចេកវិទ្យាដំណើរការសម្រាប់មនុស្សគ្រប់គ្នា និងគាំទ្រដល់វឌ្ឍនភាពនៃការអប់រំ។ បច្ចេកវិទ្យាមិនគួរពង្រឹងរបាំងចាស់ទេ ប៉ុន្តែត្រូវបើកទ្វារថ្មី។ |
| ២៧ | - ការពង្រឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមសម្រាប់ការអប់រំ។ តាមបទពិសោធន៍ និងគម្រោងដែលបានអនុវត្ត ត្រូវអនុវត្តតាមចិត្តសាស្ត្រច្បាស់លាស់ ដែលផ្អែកលើការយល់ដឹងអំពីអំណាចវិសមភាព និងឧបសគ្គដែលកុមារ និងយុវជនងាយរងគ្រោះកំពុងប្រឈម។ អង្គភាពគួរតែចូលរួមបង្កើតបទដ្ឋាន សង្គមថ្មី បង្កើនការយល់ដឹង និងជំនាញ GEDSI ក្នុងកម្រិតសាលា សហគមន៍ និងគ្រួសារ។<br>- រដ្ឋាភិបាល និងដៃគូអភិវឌ្ឍ គួរផ្ដល់ការគាំទ្រ តាមរយៈការបង្កើតគោលនយោបាយ និងប្រព័ន្ធច្បាប់ដែលធានាសិទ្ធិឱកាសស្មើគ្នាដល់កុមារ។ ភាគីពាក់ព័ន្ធគួរបង្កើនសមត្ថភាពគ្រូ គណៈគ្រប់គ្រងសាលា និងមន្ត្រីអប់រំក្នុងការអនុវត្តសកម្មភាព GEDSI ប្រកបដោយទស្សនវិស័យ និងយុទ្ធសាស្ត្រដែលអាចវាស់វែងបាន។ |
| ២៨ | អន្តរាគមន៍ជាបន្តបន្ទាប់ សម្រាប់ការអប់រំបរិយាបន្នសម្រាប់កុមារដែលមានតម្រូវការពិសេស រួមមានដោយៈ<br>- ផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីបញ្ហាពិការភាព និងកុមារក្រៅសាលា នៅថ្នាក់ឃុំ និងសាលារៀន។<br>- ការកែលម្អបរិស្ថាន៖ ជួសជុល បង្គន់អនាម័យ ផ្លូវជម្រាល សួនកុមារ ផ្ដល់ការបណ្ដុះបណ្ដាលគ្រូ និងSMC អំពីការអប់រំបរិយាបន្ននិងការធ្វើផែនការអភិវឌ្ឍសាលា គាំទ្រសម្ភារៈ ក៏ដូចជាការធ្វើដំណើររបស់កុមារ។<br>- សកម្មភាពរៀន និងបង្រៀនថ្នាក់សមាហរណ៍កម្ម៖ ការបង្រៀនជាបុគ្គល (គ្រូម្នាក់សិស្សម្នាក់) ការចូលរួមរៀនទាំងអស់គ្នា(ការបង្រៀនក្រុមតូច) និងមណ្ឌលថែទាំ (ការអប់រំ និងការព្យាបាលដោយចលនា)។<br>- ថ្នាក់អប់រំពិសេស សមាហរណ៍កម្ម និងបរិយាបន្ន គឺមានការលំបាកដោយសារសិស្សតិច (ឧ. សិស្ស ១១ នាក់ ត្រូវការគ្រូរហូតដល់២នាក់)។ កិច្ចការនេះត្រូវការពន្យល់ និងទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងដោយលើកពីនីតិវិធី ឬលិខិតបទដ្ឋានគតិយុទ្ធផ្សេងៗដើម្បីឱ្យមានការយល់គ្នា និងអាចអនុវត្តបាន។ |
| ២៩ | មានអង្គការច្រើន ប៉ុន្តែមិនមានពាក់ព័ន្ធ និងអនុវត្តនៅក្នុងខេត្តប៉ៃលិនសោះ។ សំណូមពរពិចារណាខេត្តប៉ៃលិនផង។ ហើយមូលហេតុអ្វីបានជាការប្រមូលសិស្សដែលបោះបង់ហើយរកមិនឃើញ។ |

## II. សេចក្តីផ្តើម

សន្និសីទជាតិលើកទី៦ បានរៀបចំឡើង ដើម្បីបន្តពង្រឹងបន្ថែមលើលទ្ធផលនៃសន្និសីទជាតិមុនៗ ដោយផ្តោតលើការពិភាក្សា និងសកម្មភាពស៊ីជម្រៅជុំវិញប្រធានបទស្តីពី លទ្ធផលនៃការសិក្សា យេនឌ័រ និងបរិយាបន្ន និងការសិក្សាពេញមួយជីវិត។ វេទិកាកិច្ចសន្ទនានេះ ប្រមូលផ្តុំនូវអ្នកបង្កើតគោលនយោបាយ អ្នកអប់រំ មន្ត្រីអប់រំនៅថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំយុទ្ធសាស្ត្រ អំពីរបៀបធ្វើឱ្យការអប់រំកម្ពុជាកាន់តែមានបរិយាបន្ន និរន្តរភាព និងផលជះជាវិជ្ជមាន តាមរយៈកិច្ចពិភាក្សា និងបទបង្ហាញតាមប្រធានបទ ដែលមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិ អ្នកបង្កើតគោលនយោបាយ និងអ្នកអនុវត្តផ្ទាល់ក្នុងវិស័យអប់រំ។ កិច្ចពិភាក្សាទាំងអស់នេះ ផ្តោតទៅលើដំណោះស្រាយផ្អែកលើភស្តុតាង ការអនុវត្តល្អ និងវិធីសាស្ត្រសហការ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមសំខាន់នានាដែលនៅក្នុងវិស័យអប់រំកម្ពុជា។

## III. គោលបំណង

សន្និសីទជាតិលើទី៦នេះ រៀបចំឡើងក្នុងគោលបំណង ដើម្បីឱ្យភាគីពាក់ព័ន្ធមកពីមជ្ឈដ្ឋាននានា និងមានបទពិសោធន៍ផ្សេងៗគ្នាពី អ្នកអនុវត្តថ្នាក់ក្រោមជាតិ រហូតដល់អ្នកបង្កើតគោលនយោបាយថ្នាក់ជាតិ ដើម្បីពិភាក្សាគ្នាអំពីបញ្ហាទាក់ទងនឹងគោលនយោបាយអប់រំ និងស្វែងរកមធ្យោបាយ និងដំណោះស្រាយ និងសកម្មភាព។

## IV. រចនាសម្ព័ន្ធ និងវិធីសាស្ត្រ

សន្និសីទជាតិលើកទី៦នេះ បានរៀបចំឡើងដោយប្រើប្រាស់នូវវិធីសាស្ត្រនានា ដូចជាកិច្ចពិភាក្សាតុមូលតាមប្រធានបទ និងការធ្វើបទបង្ហាញ ដែលមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិ អ្នកបង្កើតគោលនយោបាយ និងអ្នកអនុវត្តផ្ទាល់ក្នុងវិស័យការអប់រំនៅកម្ពុជា។ កិច្ចពិភាក្សាទាំងអស់នេះ បានផ្តោតលើដំណោះស្រាយដោយផ្អែកលើភស្តុតាង ការអនុវត្តល្អ និងវិធីសាស្ត្រសហការ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមសំខាន់នានាដែលមាននៅក្នុងវិស័យអប់រំប្រទេសកម្ពុជា។

## V. កាលបរិច្ឆេទ ទីកន្លែង និងអ្នកចូលរួម

| | | |
|---|---|---|
| កាលបរិច្ឆេទ | ៖ | ថ្ងៃទី០៧ និង ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៥ |
| ទីកន្លែង | ៖ | Factory Phnom Penh |
| ចំនួនអ្នកចូលរួម និងសមាសភាព | ៖ | ១៩៥ នាក់ ស្រី ៧២នាក់ រួមមាន<br>– ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមុខងារសាធារណៈ<br>– មន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រុង និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុងស្រុកខណ្ឌ និងតំណាងរដ្ឋបាលក្រុង/ស្រុក<br>– អង្គការសង្គមស៊ីវិល និងអង្គការសមាជិកភាព|អង្គការសម្ព័ន្ធភាពក្នុងវិស័យអប់រំ<br>– គ្រូបង្រៀន នាយក/នាយិកាសាលារៀន និងអ្នកអនុវត្តផ្ទាល់<br>– ដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ តំណាងយុវជន និងអ្នកតស៊ូមតិក្នុងវិស័យអប់រំ<br>– វិស័យឯកជន និងអ្នកធ្វើការក្នុងការអភិវឌ្ឍជំនាញ |
| របៀបវារៈ និងបទបង្ហាញតាមប្រធានបទ | ៖ | ជូនភ្ជាប់។ |

## VI. ប្រធានបទសំខាន់ៗនៅក្នុងសន្និសីទ

សន្និសីទជាតិលើកទី៦ បានផ្តោតលើចំណុចសំខាន់ៗដូចខាងក្រោម៖

- ការវិភាគលើឫសគល់នៃបញ្ហានៃលទ្ធផលសិក្សារបស់សិស្ស
- កិច្ចពិភាក្សា ស្តីពីដំណោះស្រាយ៖
- ទី១៖ ការលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីរបស់សាលារៀនដែលជួយដល់ការពង្រឹងលទ្ធផលសិក្សារបស់សិស្ស
- ទី២៖ ភាពអាចបត់បែននៃការរៀនសូត្រសម្រាប់កុមារក្រៅសាលា
- ទី៣៖ ការពង្រឹងជំនាញគរុកោសល្យ និងចំណេះដឹងនៃមុខវិជ្ជាបង្រៀនសម្រាប់គ្រូបង្រៀន
- ទី៤៖ ការពង្រីក និងពង្រឹងការអប់រំកុមារតូច
- ទី៥៖ ការគាំទ្រដល់ឪពុកម្តាយ និងការចូលរួមរបស់សហគមន៍
- ទី៦៖ ការជំរុញការអប់រំបរិយាបន្ន៖ ការលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នសម្រាប់ទាំងអស់គ្នា។

***ដើម្បីឆ្លើយតបនឹងចំណុចសំខាន់ៗនេះ សន្និសីទជាតិលើកទី៦ នឹងព្យាយាមឆ្លើយនូវសំណួរមួយចំនួនដូចខាងក្រោម៖***

- តើប្រព័ន្ធអេកូឡូស៊ីរបស់សាលារៀនដែលមានដំណើរការល្អ និងមាននិរន្តរភាព អាចនាំឱ្យមាន ការកែលម្អ និងពង្រឹងការរៀនរបស់សិស្សដោយរបៀបណា?
- តើមានជម្រើសនៃការអនុវត្តការរៀនសូត្រដែលអាចបត់បែនបានអ្វីខ្លះ ដែលជួយលើកកម្ពស់ការរៀនសូត្ររបស់កុមារ ជាពិសេសកុមារក្រៅសាលា?
- តើធ្វើដូចម្តេចដើម្បីសម្រេចបាននូវការសិក្សាកម្រិតថ្នាក់ដំបូង តាមរយៈការកែលម្អជំនាញគរុកោសល្យសម្រាប់ការបង្រៀនដោយប្រើប្រាស់វិធីសាស្ត្របែបទំនើប និងប្រកបដោយភាពច្នៃប្រឌិត?
- តើយើងត្រូវសម្រេចបានអ្វីខ្លះ ដើម្បីធានាបានថាការអប់រំកុមារតូចឈានដល់ការសម្រេចបាននូវស្តង់ដាល្អ?
- តើការចូលរួមយ៉ាងសកម្មរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ ដែលអាចបង្កើតបានវប្បធម៌នៃការសិក្សាពេញមួយជីវិតយ៉ាងដូចម្តេច?
- តើមានមធ្យោបាយអ្វីខ្លះក្នុងការសម្រេចបានការលើកកម្ពស់យេនឌ័រក្នុងប្រព័ន្ធអប់រំ ហើយប្រព័ន្ធអប់រំនៅកម្ពុជាត្រូវធ្វើបែបណា ដើម្បីឈានដល់ការសម្រេចបាននូវលទ្ធផលនេះ?

## VII. លទ្ធផលរំពឹងទុក

- បានពង្រឹងគោលនយោបាយ និងអនុសាសន៍ស្តីអំពីការអប់រំបរិយាបន្ន និងការឆ្លើយតបយេនឌ័រក្នុងវិស័យអប់រំ។
- បានបង្កើនការយល់ដឹង និងអនុវត្តយុទ្ធសាស្ត្រសម្រាប់ការសិក្សាពេញមួយជីវិតនៅកម្រិតនៃការអប់រំផ្សេងៗគ្នា។
- ទទួលបាននូវដំណោះស្រាយជាក់ស្តែងដែលអាចអនុវត្តបាន និងការប្តេជ្ញាចិត្តដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស ជាពិសេសនៅក្នុងជំនាញជាមូលដ្ឋានគ្រឹះ។

## VIII. លទ្ធផលនៃសន្និសីទជាតិលើកទី៦

### ថ្ងៃទី១៖ ថ្ងៃចន្ទ ទី៧ ខែមេសា ឆ្នាំ២០២៥

### កម្មវិធីបើក

*សុន្ទរកថាស្វាគមន៍របស់ លោកស្រី ហ៊ុន បូរ៉ាមី ប្រធានក្រុមប្រឹក្សាភិបាលអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល*

ជាកិច្ចចាប់ផ្តើម តាងនាមឱ្យក្រុមប្រឹក្សាភិបាលរបស់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) លោកស្រី ហ៊ុន បូរ៉ាមី មានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកចូលរួមទាំងអស់មកកាន់សន្និសីទជាតិលើកទី៦ស្តីពី **«បរិវត្តកម្មវិស័យអប់រំ»** របស់អង្គការ NEP នាពេលនេះ។

លោកស្រីបន្តថា ការចូលរួមនាថ្ងៃនេះ គឺជាសក្ខីភាពដ៏ខ្លាំងក្លាមួយក្នុងការបញ្ជាក់ឡើងវិញ នៃការរួបរួមគ្នាក្នុងកិច្ចប្រឹងប្រែងបង្កើតអនាគតនៃការអប់រំដែលប្រកបដោយបរិយាបន្ន សមធម៌ និងផ្តល់ភាពអង់អាចដល់មនុស្សគ្រប់ៗរូប។ ពួកយើងសូមថ្លែងអំណរគុណទៅដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាតំណាងរដ្ឋាភិបាល អង្គការសង្គមស៊ីវិល សាលារៀន វិស័យឯកជន និងសហគមន៍មូលដ្ឋានចំពោះវត្តមាននៅថ្ងៃនេះ ក៏ដូចជាតួនាទីដ៏សំខាន់ដែលបានរួមចំណែកបង្កើតបរិយាកាសនៃការអប់រំដ៏ល្អប្រសើរនៅប្រទេសកម្ពុជា។ លោកស្រីរំលឹកផងដែរថា នេះគឺជាលើកទី៦ហើយ ដែលយើងបានមករួមគ្នារៀបចំសន្និសីទថ្នាក់ជាតិ ដែលជាវេទិកាសម្រាប់ការពិភាក្សា ការឆ្លុះបញ្ចាំង និងកិច្ចសហការរវាងគ្នាយ៉ាងជិតស្និទរបស់គ្រប់ភាគីពាក់ព័ន្ធក្នុងវិស័យអប់រំ។ ហើយគ្រប់ពេលដែលយើងមកជួបជុំនៅក្នុងវេទិការនេះ វាមិនត្រឹមតែធ្វើឱ្យយើងបានជួបគ្នាប៉ុណ្ណោះទេ ប៉ុន្តែវាបានរំលឹកយើងអំពីគុណតម្លៃនៃការរួបរួម ការឆ្លុះបញ្ចាំងអំពីស្ថានភាព ក៏ដូចជាការរួមគ្នាបង្កើតទិសដៅ ដែលយើងចង់សម្រេចបានទាំងអស់គ្នា។

NEP មានមោទនភាព ក្នុងនាមជាអង្គការសមាជិកភាពតែមួយគត់ ដែលផ្តោតលើវិស័យអប់រំ ដែលមានសមាជិកចំនួន ៧៨អង្គការ ដែលបានខិតខំធ្វើការនៅគ្រប់ទិសទីនៃប្រទេសកម្ពុជា ដើម្បីពង្រឹងគុណភាពអប់រំប្រកបដោយបរិយាបន្ន និងសមធម៌។ ជាង ២០ឆ្នាំកន្លងមក NEP បានដើរតួនាទីជាអ្នកសម្របសម្រួលវេទិកាសំខាន់ៗ ដែលផ្សារភ្ជាប់សំឡេងរបស់ថ្នាក់មូលដ្ឋានទៅនឹងគោលនយោបាយជាតិ ផ្សព្វផ្សាយការតស៊ូមតិដោយផ្អែកលើភស្តុតាងនៃការស្រាវជ្រាវ និងលើកកម្ពស់សិទ្ធិរបស់អ្នកសិក្សាគ្រប់ៗរូប ជាពិសេសអ្នកដែលងាយរងគ្រោះ ឬត្រូវបានគេបំភ្លេចចោល។ សន្និសីទនេះមិនមែនគ្រាន់តែជាព្រឹត្តិការណ៍មួយនោះទេ។ ដោយវាជាការបន្តនៃដំណើររួមគ្នារបស់យើងគ្រប់ៗគ្នាដែលក្នុងវេទិការនេះ យើងនឹងធ្វើការចោទសួរសំណួរ ដើម្បីរិះរកមធ្យោបាយ ចែករំលែកនវានុវត្តន៍ និងផ្តោតការយកចិត្តទុកដាក់ និងសង្កត់ធ្ងន់ទៅលើទំនួលខុសត្រូវ ក្នុងន័យធានាឱ្យបាននូវបរិវត្តកម្មវិស័យអប់រំ ដែលឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន គោរពដល់គោលការណ៍សមធម៌ និងបរិយាបន្ន ហើយកំណត់យកការសិក្សាពេញមួយជីវិតជាគោលការណ៍ចម្បង។

ប្រធានបទសន្និសីទជាតិឆ្នាំនេះគឺ **«បរិវត្តកម្មវិស័យអប់រំ»** លើកទឹកចិត្តឱ្យយើងគិតឡើងវិញអំពីយុទ្ធសាស្ត្រនៃការផ្តល់ការអប់រំ គិតពីអ្នកទទួលសេវាអប់រំ និងដើម្បីឱ្យអ្នកសិក្សាត្រៀមខ្លួនទៅនឹងពិភពលោកដែលកំពុងផ្លាស់ប្តូរ និងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ កម្មវិធីសន្និសីទរបស់យើងនឹងនាំមកនូវការពិភាក្សា ព្រមទាំងការធ្វើបទបង្ហាញរបស់គ្រប់ភាគីពាក់ព័ន្ធ ដូចជាភាគីរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល ព្រមទាំងនាយកសាលាជាដើម។

លោកស្រីបន្ថែមថា យើងនឹងធ្វើការឆ្លុះបញ្ចាំងពីបច្ចុប្បន្នភាពរបស់យើង ក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤ និងអ្វីដែលយើងត្រូវធ្វើបន្ថែម ដើម្បីធានាថាការអប់រំនៅប្រទេសកម្ពុជាមានលក្ខណៈ បរិយាបន្នពិតប្រាកដ ជាពិសេសសម្រាប់អ្នកសិក្សាដែលមានពិការភាព ក្មេងស្រីនិងស្ត្រី ជនជាតិដើម/ភាគតិច ក្រុមជនងាយរងគ្រោះ និងអ្នករងផលប៉ះពាល់ដោយសារភាពក្រីក្រ។ កម្លាំងចិត្ត និងអំណាចរបស់ NEP បានមកពីការប្តេជ្ញាចិត្តរួមគ្នារបស់សមាជិក ដៃគូ និងដើងឯកវិស័យអប់រំរបស់យើង ដែលក្នុងនោះក៏មានលោក លោកស្រីដែលមានវត្តមាននៅថ្ងៃនេះផងដែរ។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការគាំទ្ររបស់អ្នកក្នុងរយៈពេលជាង ២០ឆ្នាំកន្លងមកនេះ

លោកស្រីបានទាញចំណាប់អារម្មណ៍ថា ស្របពេលយើងសម្លឹងទៅមុខ យើងក៏នៅមើលឃើញនូវកិច្ចការជាច្រើនទៀតដែលនៅមិនទាន់សម្រេចបាន ហើយយើងមិនអាចធ្វើវាតែឯងបានទេ។ យើងសូមអំពាវនាវឱ្យលោក លោកស្រីចូលរួមដំណើរជាមួយយើង បន្តគាំទ្រ NEP ដើម្បីសម្រេចបាននូវការអនុវត្តគោលនយោបាយអប់រំប្រកបដោយប្រសិទ្ធភាព លើកកម្ពស់សំឡេងសហគមន៍ និងធានាថា គ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោល។ ចំពោះអង្គការដែលកំពុងតែធ្វើការនៅក្នុងវិស័យអប់រំ ដែលមិនទាន់ក្លាយជាសមាជិក ឬកំពុងពិចារណាក្នុងការក្លាយជាសមាជិក NEP យើងសូមអញ្ជើញយ៉ាងកក់ក្ដៅដល់លោក លោកស្រីដើម្បីចូលរួមជាផ្នែកមួយនៃគ្រួសារ NEP។ NEP មិនមែនគ្រាន់តែជាសម្ព័ន្ធមួយនោះទេ វាជាចលនាមួយដែលជំរុញ និងដឹកនាំដោយក្រុមអ្នកដែលជឿជាក់យ៉ាងមុតមាំទៅលើអំណាចនៃការអប់រំ ក្នុងការកែប្រែជីវិត និងសហគមន៍របស់ពួកគេ។ ជាសមាជិករបស់ NEP អ្នកនឹងក្លាយជាផ្នែកមួយនៃបណ្ដាញដែលផ្ដល់ការស្ដាប់ ការរៀនសូត្រពីគ្នាទៅវិញមក ពង្រឹងសមត្ថភាព និងរួមគ្នាដឹកនាំវិស័យអប់រំឱ្យកាន់តែប្រសើរឡើង។ អ្នកនឹងទទួលបានវេទិកាមួយដែលសំឡេងអ្នកផ្ដល់ការយកចិត្តទុកដាក់ទៅលើបទពិសោធន៍របស់អ្នកត្រូវបានគេគោរព និងការចូលរួមរបស់អ្នក បង្កើតឥទ្ធិពលយ៉ាងពិតប្រាកដ។

លោកស្រីបានអំពាវនាវឱ្យគាំទ្រដល់ NEP សហការនិងដើរជាមួយគ្នា និងជួយពង្រឹងស្ពាន ដែលតភ្ជាប់រវាងគោលនយោបាយអប់រំជាតិ ទៅនឹងជីវិតពិតនៅក្នុងសហគមន៍។ រួមគ្នា យើងអាចតស៊ូមតិដើម្បីការអប់រំប្រកបដោយបរិយាបន្ន លើកកម្ពស់សំឡេងនិងតម្រូវការរបស់សិស្សដែលងាយរងគ្រោះ និងបង្កើតនូវបរិយាកាសសម្រាប់គ្រូ សិស្ស ឪពុកម្ដាយ និងសហគមន៍ឱ្យបានចូលរួម។ សូមជួយយើងកសាងនូវប្រព័ន្ធអប់រំដ៏រឹងមាំ មានភាពធន់ និងប្រកបដោយបរិយាបន្នសម្រាប់អនាគតរបស់ប្រទេសកម្ពុជា ជាមួយនឹងប្រព័ន្ធអប់រំមួយដែលគ្មាននរណាម្នាក់ត្រូវបានបោះបង់ចោល ហើយអ្នកសិក្សាគ្រប់រូបមានឱកាសក្នុងការសិក្សារៀនសូត្រ និងសិក្សាពេញមួយជីវិត។

លោកស្រីសូមឱ្យសន្និសីទនេះមិនមែនគ្រាន់តែជាការពិភាក្សាទេ ប៉ុន្តែជាមូលដ្ឋានគ្រឹះនៃការអនុវត្តគោលនយោបាយ ផែនការសកម្មភាពដែលធ្វើឱ្យប្រព័ន្ធវិស័យអប់រំនៅប្រទេសកម្ពុជាកាន់តែប្រសើរឡើង។ សូមឱ្យយើងធ្វើការប្ដេជ្ញាប្រកបដោយសេចក្ដីក្លាហាន ភ្លៀវភ្លា មានសាមគ្គីភាព ជាកម្លាំងរួមមួយក្នុងបេសកកម្មរបស់យើង ។

ជាចុងក្រោយ លោកស្រី សូមអរគុណចំពោះការចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងថ្ងៃនេះ ជាពិសេស សូមអរគុណដល់សមាជិកNEP ទាំងអស់ដែលបានចូលរួមយ៉ាងសកម្មទាំងពេលវេលា និងផ្នែកហិរញ្ញវត្ថុដើម្បីឱ្យសន្និសីទជាតិ យើងនៅក្នុងថ្ងៃនេះ ប្រព្រឹត្តទៅបានយ៉ាងរលូន និងសូមឱ្យសន្និសីទនេះ ទទួលបាននូវផ្លែផ្កាប្រកបដោយអត្ថន័យ និងបន្តស្ថាបនាអនាគតដ៏ត្រចះត្រចង់សម្រាប់កុមារកម្ពុជា។

*សុន្ទរកថាស្វាគមន៍របស់ លោកស្រី Kirsty Milev នាយកពង្រឹងគុណភាពផ្នែកកម្មវិធី អង្គការទស្សនៈពិភពលោក*

លោកស្រីបានលើកឡើងនូវចំណុចសំខាន់ៗក្នុងសុន្ទរកថានោះគឺ ប្រធានបទនៃសន្និសីទ ដែលគួរជាទីចាប់អារម្មណ៍ **«ការផ្លាស់ប្ដូរវិធីសាស្ត្រនៃការអប់រំ»** ដែលមានន័យថា ជាការប្រែប្រួលយ៉ាងស៊ីជម្រៅនៅក្នុងវិធីគិតអំពីការអប់រំ—ពីវិធីបុរាណ ទៅវិធីថ្មីៗដែលមានចក្ខុវិស័យច្នៃប្រឌិត និងផ្អែកលើដំណោះស្រាយដើម្បីជំរុញឱ្យការសិក្សាពេញមួយជីវិតសម្រាប់កុមារគ្រប់រូប។

លោកស្រីក៏បានលើកឡើងពីបញ្ហាប្រឈមជាសកល និងក្នុងស្រុកផងដែរ ដូចជាការប្រែប្រួលជាសកល និងការកាត់បន្ថយជំនួយបរទេស បានបណ្ដាលឱ្យការអប់រំនឹងត្រូវបានមើលរំលង។ ការអប់រំ គឺជាអ្វីដែលជួយសង្គ្រោះជីវិត និងផ្លាស់

ប្តូរជីវិត ហើយត្រូវតែជាអាទិភាពក្នុងការអភិវឌ្ឍ។ លោកស្រីបន្ថែមថា ក្នុងប្រទេសកម្ពុជា ៤% នៃកុមារគ្រប់អាយុចូលរៀនបឋមសិក្សានៅតែខកខានការសិក្សា និងប្រហែលជា ៥៥% នៃសិស្សស្ទើរតែបោះបង់ការសិក្សាមុនអាយុ ១៧ឆ្នាំ ក៏ដូចជាបញ្ហាប្រែប្រួលអាកាសធាតុ និងការបិទសាលារៀន គឺមានឥទ្ធិពលដល់កុមារជាច្រើនលើសកលលោក។ លោកស្រីក៏បានអំពាវនាវឱ្យមានការអនុវត្ត ដោយត្រូវមានការប្រែប្រួលបន្ទាន់ពីប្រព័ន្ធបុរាណ និងប្រភពហិរញ្ញប្បទានបែបចាស់ទៅលើដំណោះស្រាយជាមូលដ្ឋានសហគមន៍ ភាពជាម្ចាស់ការដោយរដ្ឋាភិបាល វិធីសាស្ត្រដែលមានការចំណាយទាប ប៉ុន្តែមានប្រសិទ្ធភាព។ លោកស្រីក៏បានអំពាវនាវដល់សន្និសីទនេះថា គួរតែជាវេទិកាដើម្បីសិក្សា ចែករំលែក និងច្នៃប្រឌិតរួមគ្នា។ លោកស្រីសំណូមពរឱ្យះ ១.មានការសហការ និងការលើកកម្ពស់សមត្ថភាព (ត្រូវមានការសម្របសម្រួលរឹងមាំ) រវាងអង្គការសង្គមស៊ីវិល ម្ចាស់ជំនួយ រដ្ឋាភិបាល និងវិស័យឯកជន។ ២.ការលើកកម្ពស់សមត្ថភាពដល់គណៈគ្រប់គ្រងសាលារៀន។ ៣.ការជ្រើសរើស បណ្តុះបណ្តាល និងរក្សាទុកគ្រូដែលមានគុណភាព។ ៤.បង្កើតបរិយាកាសសាលារៀនដែលសិស្សចង់រៀន និងឪពុកម្តាយចង់គាំទ្រ។ ៥.គាំទ្រគោលនយោបាយ និងរចនាសម្ព័ន្ធ- គាំទ្រការអនុវត្តអនុក្រឹត្យលេខ២១៣ ដើម្បីជួយក្នុងការផ្ទេរអំណាចដល់ថ្នាក់មូលដ្ឋាននៅក្នុងវិស័យអប់រំ ដោយត្រូវធានាថារដ្ឋបាលមូលដ្ឋានមានសមត្ថភាពគ្រប់គ្រងថវិកាសាលារៀនឱ្យមានប្រសិទ្ធភាព និងធានាគុណភាពអប់រំ។

ជាចុងក្រោយ លោកស្រីបានថ្លែងអំណរគុណដល់ដៃគូទាំងអស់ ហើយរំលឹកពីសារៈសំខាន់នៃការច្នៃប្រឌិតដោយសហការជាមួយសហគមន៍ដើម្បីរក្សាឱ្យការអប់រំនៅតែជាចំណុចកណ្តាលនៃគោលនយោបាយអភិវឌ្ឍន៍នៅកម្ពុជា។

### *សុន្ទរកថាសំណេះសំណាល និងបើកកម្មវិធីដោយ ឯកឧត្តម ពុត សាមិត្ត អនុរដ្ឋលេខាធិការ តំណាងឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា*

ឯកឧត្តម បានថ្លែងថា ឯកឧត្តមមានសេចក្តីសោមនស្សរីករាយចូលរួមក្នុងពិធីបើកសន្និសីទជាតិលើកទី៦ ស្តីពីបរិវត្តកម្មវិស័យអប់រំ ដែលរៀបចំដោយអង្គការNEP ដោយបានបញ្ជាក់ជាថ្មីពីគោលបំណងនៃសន្និសីទ ដើម្បីផ្តល់ជាវេទិកាឱ្យភាគីពាក់ព័ន្ធពីមជ្ឈដ្ឋាននានា ដែលមានបទពិសោធន៍ ចាប់តាំងពីដៃគូអនុវត្តថ្នាក់មូលដ្ឋាន ដល់ថ្នាក់ជាតិ បានជួបជុំដើម្បីពិភាក្សា និងស្វែងរកដំណោះស្រាយរួមគ្នាប្រកបដោយសក្តានុពល ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃវិស័យអប់រំ និងកសាងប្រព័ន្ធអប់រំមួយដើម្បីឆ្លើយតបទៅតាមបរិបទថ្មី និងមានភាពធន់។ ឯកឧត្តមក៏បានគូសបញ្ជាក់ពីប្រធានបទ និងវាគ្មិនថាត្រូវបានជ្រើសរើស ដោយមានសមាសភាពចូលរួមពីអ្នកជំនាញចម្រុះ និងសង្ឃឹមថា វេទិកានេះនឹងនាំឱ្យមានការចែករំលែក និងទទួលបានធាតុចូលដ៏មានតម្លៃ ដើម្បីគាំទ្រដល់ការកែទម្រង់ដ៏ស៊ីជម្រៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាពិសេស គឺការកែទម្រង់នៅកម្រិតសាលារៀន ក៏ដូចជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូផងដែរ។

ជាមួយគ្នានេះដែរ ជាការឆ្លុះបញ្ចាំងពីប្រធានបទនៃសន្និសីទ ដែលទាក់ទងនឹងគំរូនៃប្រព័ន្ធអប់រំ ថាតើប្រព័ន្ធអប់រំរបស់យើងពីមុនដំណើរការយ៉ាងណា ប្រៀបធៀបនឹងបច្ចុប្បន្ន? តើវាទាមទារឱ្យយើងធ្វើអ្វីបន្ថែមទៀត? ក្រសួងអប់រំ ក៏បានរៀបចំសន្និបាតអប់រំ យុវជន និងកីឡា និងបានប្រមូលធាតុចូលបានមួយចំណែកហើយ ដើម្បីយកមកពិចារណាក្នុងការកែលម្អប្រព័ន្ធអប់រំ ដោយបានអញ្ជើញសមាសភាពដូចគ្នានឹងសន្និសីទរបស់NEPដែរ។ NEP ជាមួយនឹងអង្គការសមាជិកប្រមាណ ៧៨អង្គការ ដែលកំពុងតែធ្វើការនៅតាមមូលដ្ឋានក្នុងវិស័យអប់រំរបស់ខ្លួនក្នុងពេលនេះ ក៏ជាការប្រមូលធាតុចូលដែលមានសារៈសំខាន់បន្ថែមទៀតដើម្បីផ្តល់ជូនក្រសួងអប់រំ យុវជន និងកីឡាពិចារណា។

ឯកឧត្តមបានលើកឡើងថា ក្រសួងមានយន្តការនៃការធ្វើការងារជាមួយនឹងដៃគូអភិវឌ្ឍ ដូចជាអង្គការក្រៅរដ្ឋាភិបាល (NGO) ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ ដែលមានសមាសភាពមកពីក្រសួងពាក់ព័ន្ធ ក៏ដូចជាដៃគូអភិវឌ្ឍ

ជាពិសេសដៃគូក្រៅរដ្ឋាភិបាល ដែលធ្វើការប្រជុំជាមួយគ្នា ពីរដងក្នុងមួយឆ្នាំ។ ជាក់ស្តែង ក្រសួងអប់រំមិនអាចធ្វើការជាមួយអង្គការនីមួយៗបានទេដោយសារកត្តាពេលវេលា។ ដូចនេះមានអង្គការNEP ជាតំណាង ធ្វើការប្រមូល និងបូកសរុបជាគំនិត ទស្សនៈរួមរបស់NGO ធ្វើការក្រោមកិច្ចសហការជាមួយNEP សម្រាប់ចូលរួមជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងគម្រោងGPEរបស់ក្រសួង ជាពិសេសការចូលរួមនៅក្នុងកម្រិតតំបន់ ឬក៏អន្តរជាតិទាក់ទងទៅនឹង SDG សុទ្ធតែមានការពិគ្រោះយោបល់។ រាល់អ្វីដែលជាសំឡេង និងកង្វល់របស់NGO គឺក្រសួងបានគិតគូរពិចារណាយកមកដាក់ចូលនៅក្នុងផែនការយុទ្ធសាស្រ្តវិស័យអប់រំ ក៏ដូចជាឯកសារផ្សេងៗទៀត។

ឯកឧត្តមក៏រំលឹកផងដែរថា NEP មានបេសកម្មសំខាន់មួយគឺ ការតស៊ូមតិទាក់ទងទៅនឹងហិរញ្ញប្បទានហិរញ្ញវត្ថុសម្រាប់វិស័យអប់រំ។ ក្នុងរយៈពេល២០ឆ្នាំនេះ តើរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងវិស័យអប់រំនឹងយ៉ាងដូចម្តេចខ្លះ? មុនឆ្នាំ២០០០ ថវិកាវិស័យអប់រំ គឺមិនដល់១០%ផង។ រហូតមកដល់បច្ចុប្បន្ននេះ គឺស្ថិតក្នុងរង្វង់ប្រហែលជា១៦% ទៅ១៧%។ គ្រប់អាណត្តិរបស់រាជរដ្ឋាភិបាល តាំងពីអនុវត្តយុទ្ធសាស្រ្តចតុកោណ ត្រីកោណ និងបញ្ចកោណ គឺវិស័យអប់រំនៅតែជាអាទិភាពទី១។ អ្វីដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់គឺវិស័យអប់រំ ដែលនៅតែជាអាទិភាពទី១ ដោយផ្តោតលើការអភិវឌ្ឍមូលធនមនុស្ស។ ជាឧទាហរណ៍៖ ការលើកទឹកចិត្តគ្រូបង្រៀន តាមរយៈប្រាក់បៀវត្ស ចំណុចទាំងនេះជាជោគជ័យមួយ ហើយកម្រិតអន្តរជាតិក៏បានទទួលស្គាល់ផងដែរក្នុងរយៈពេល១០ឆ្នាំមកនេះមានការបង្កើនថវិកាដំណើរការបានលឿន និងល្អប្រសើរជាងមុន ហើយថវិកាដំណើរការសាលារៀនក៏ដូចគ្នា សាលារៀនសុទ្ធតែមានគណនីទាំងអស់។ ក្នុងនោះគ្រូបង្រៀន នាយកសាលា ក៏អាចយកថវិកាសាលារៀនទៅទិញសម្ភារៈសម្រាប់បង្រៀននិងរៀនបានផងដែរ។ មុនឆ្នាំ២០០០ សាលារៀនគ្មានថវិកាសម្រាប់ដំណើរការសាលារៀនបែបនេះទេ ដោយពឹងផ្អែកលើការចូលរួមវិភាគទានរបស់មាតាបិតារបស់សិស្សក្នុងការយកមកដំណើរការសាលារៀន។ ដូច្នេះសាលារៀន ត្រូវយកចិត្តទុកដាក់ពីវិធីសាស្រ្តបង្រៀនថ្មី ដោយការបង្រៀនមានការផ្លាស់ប្តូរពីគ្រូមជ្ឈមណ្ឌលទៅជាសិស្សមជ្ឈ មណ្ឌល ដើម្បីឱ្យសិស្សជំនាន់ក្រោយបានទទួលចំណេះដឹង ការគិតបែបស៊ីជម្រៅ ឬហៅថាជំនាញសតវត្សទី២១ ព្រមទាំងផ្លាស់ប្តូរពីការរៀនដែលផ្តោតតែទៅលើទ្រឹស្តី ឈានទៅរកការអនុវត្ត។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងដំណាក់កាលចុងក្រោយនេះ ត្រូវជំរុញឱ្យសហគមន៍ក្រោមការដឹកនាំរបស់នាយកសាលា ត្រូវជានាធ្វើយ៉ាងណាឱ្យសាលារៀនក្លាយជាម្ចាស់របស់ សហគមន៍ ដែលបម្រើឱ្យផលប្រយោជន៍សហគមន៍ ដើម្បីពិនិត្យមើលពីការរីកចម្រើន និងការអភិវឌ្ឍរបស់សហគមន៍នៃការចូលរៀនរបស់សិស្សទាំងថ្នាក់មត្តេយ្យរហូតដល់បឋមសិក្សា។ ការអប់រំនាពេលបច្ចុប្បន្ន មិនត្រឹមតែដើម្បីវាស់វែងនៃអត្រាចូលរៀន ឡើងថ្នាក់ ត្រួតថ្នាក់ និងការបោះបង់ការសិក្សា គឺត្រូវផ្តោតលើសមត្ថភាពយល់ដឹងរបស់សិស្ស បំណិនឥរិយាបថ និងអំណាននិងគណិតថ្នាក់ដំបូងនៅបឋមសិក្សា និងនៅមធ្យមសិក្សាយកចិត្តទុកដាក់ទាក់ទងនឹងការអប់រំSTEM ព្រមទាំងបញ្ហាការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីជួយកាត់បន្ថយគម្លាតនៃគុណភាពអប់រំនៅតាមតំបន់នីមួយៗ។

ក្នុងនាមថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តម បានកោតសរសើរ និងថ្លែងអំណរគុណដល់អង្គការNEP និងសមាជិកទាំងអស់ ដែលជាដៃគូសហប្រតិបត្តិការដ៏ល្អរបស់ក្រសួងអប់រំ យុវជន និងកីឡា ទាំងក្នុងការពិភាក្សាកម្រិតគោលនយោបាយ ការអនុវត្តកម្មវិធី និងការដោះស្រាយបញ្ហាប្រឈមក្នុងវិស័យអប់រំ ជាពិសេសអន្តរាគមន៍ចំគោលដៅដែលសេវាក្រសួងមិនបានទៅដល់ ជាពិសេសការបង្កើនឱកាសស្មើគ្នា ក្នុងការទទួលបានសេវាអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងឱកាសសិក្សាពេញមួយជីវិត។ ប្រធានបទនៃសន្និសីទ ពិតជាបានឆ្លើយតប និងឆ្លុះបញ្ចាំងអំពីអាទិភាព និងវត្ថុបំណងគោលនយោបាយ និងយុទ្ធសាស្រ្ត ដែលរាជរដ្ឋាភិបាលអាណត្តិទី៧នៃរដ្ឋសភា ដ៏ដូចជា

ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញ ក្នុងគោលដៅធានាបានឱកាសស្មើគ្នា ក្នុងការទទួលបានសេវាអប់រំ ដោយមិនទុកនរណាម្នាក់ចោល ដូចមានចែងនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ស្តីពីការអប់រំឆ្នាំ២០៣០។

ឯកឧត្តម ឆ្លៀតគូសបញ្ជាក់នូវអាទិភាពដែលក្រសួងបានដាក់ចេញ និងជំរុញការអនុវត្តយ៉ាងផុសផុល ព្រមទាំងចំណុចមួយចំនួនសម្រាប់សន្និសីទថ្នាក់ជាតិនេះ ធ្វើការពិភាក្សា និងស្វែងរកធាតុចូលបន្ថែម ដែលនឹងធ្វើឱ្យអាទិភាពដែលបានដាក់ចេញ អាចអនុវត្តបាន កាន់តែមានប្រសិទ្ធភាព និងផ្តល់នូវលទ្ធផលតាមការរំពឹងទុក ដូចខាងក្រោម៖

- ទី១ ឱកាសស្មើគ្នា សាលារៀនដូចគ្នា នឹងត្រូវឆ្លុះបញ្ចាំង តាមរយៈការបន្តកែទម្រង់សាលារៀនដោយផ្តោតលើការពង្រឹងសមិទ្ធផលដែលមានស្រាប់ ការជំរុញការបង្កើតសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ។ នៅក្នុងអាណត្តិទី៧ ក្រសួងបានដាក់ឱ្យអនុវត្តនូវស្តង់ដាសាលារៀនគំរូចាប់ពីមត្តេយ្យសិក្សាដល់មធ្យមសិក្សានៅទូទាំងប្រទេស ដែលពេលនេះប្រហែលជា២៣០សាលានៅគ្រប់កម្រិត។ ក្នុងរយៈពេល៥ឆ្នាំនេះ យ៉ាងហោចណាស់១០០០សាលាដែលជាប់ជាសាលារៀនស្តង់ដាគំរូ។ សាលារៀនអភិវឌ្ឍអាស្រ័យលើកត្តាធំ១៤ ដែលមានជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយសម្រាប់ការអភិវឌ្ឍសាលារៀនផ្តោតលើលទ្ធផលសិក្សារបស់សិស្ស។សាលារៀនអភិវឌ្ឍ ពឹងអាស្រ័យលើលក្ខណៈដោយឡែក ប៉ុន្តែបំពេញគ្នាទៅវិញទៅមករួមមាន៖ នាយកសាលា គ្រូបង្រៀន សិស្សនិងមាតាបិតាសិស្ស និងសហគមន៍។ ជាគោលដៅយុទ្ធសាស្ត្រ យើងទាំងអស់គ្នាត្រូវរួមគ្នាធ្វើយ៉ាងណា ១).គាំទ្រសាលារៀនឱ្យដំណើរការប្រកបដោយអភិបាលកិច្ចល្អ ២).អភិវឌ្ឍគ្រូបង្រៀនស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ៣).ជំរុញសិស្សានុសិស្សឱ្យខិតខំរៀនសូត្រ និងទទួលបាននូវបំណិនសតវត្សទី២១ និង៤).លើកទឹកចិត្តមាតាបិតាសហគមន៍ ឱ្យចូលរួមក្នុងដំណើរការអភិវឌ្ឍសាលារៀន និងការរៀនសូត្រ ស្របតាមពាក្យស្លោក ភាពជាដៃគូរដ្ឋ-សហគមន៍ដើម្បីការអប់រំ។ គោលដៅនៃកំណែទម្រង់សាលារៀនគឺ កែលម្អលទ្ធផលសិក្សារបស់សិស្ស ផ្លាស់ប្តូរវប្បធម៌សាលារៀន ពង្រឹងវិន័យ សីលធម៌ ចរិយាធម៌ សុជីវធម៌ គុណធម៌ និងឥរិយាបថល្អរបស់បុគ្គលិកអប់រំ និងសិស្សានុសិស្ស។ ជាមួយគ្នានេះ ក្រសួងជំរុញសាលារៀនក្នុងការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សា ក្នុងគោលដៅបន្ថែមម៉ោងសិក្សា យ៉ាងហោច ២ម៉ោង បន្ថែមក្នុងមួយថ្ងៃ ដោយផ្តោតលើការអភិវឌ្ឍចំណេះដឹងមូលដ្ឋាន ការអភិវឌ្ឍបំណិនជីវិតតាមមូលដ្ឋាន ក្រុមប្រឹក្សាអាជីព ការងារគម្រោង និងការអប់រំឥរិយាបថដល់សិស្សានុសិស្ស។
- ឱកាសស្មើគ្នា គ្រូបង្រៀនដូចគ្នា នឹងត្រូវឆ្លុះបញ្ចាំង តាមរយៈការអភិវឌ្ឍគ្រូបង្រៀន និងកំណែទម្រង់សាលាគរុកោសល្យ ក្នុងទិសដៅកែលម្អវិធីសាស្ត្របង្រៀន ការជំរុញការប្រើប្រាស់ បច្ចេកវិទ្យាជួយដល់ការបង្រៀន និងរៀនភាសាបរទេស និងលើកកម្ពស់ការបង្រៀន ដែលបណ្តុះសិស្សឱ្យចេះដោះស្រាយ និងផ្សារភ្ជាប់ទៅនឹងការរស់នៅប្រចាំថ្ងៃ។ គ្រូបង្រៀនជាភ្នាក់ងារដ៏សំខាន់ក្នុងការផ្លាស់ប្តូរការដឹកនាំ និងការបង្រៀនដល់អ្នកសិក្សាដើម្បីប្រែក្លាយពួកគេជាពុទ្ធិជន។ ហេតុដូចនេះ គុណភាព និងឧត្តមភាពរបស់គ្រូបង្រៀន គឺជាកត្តាគន្លឹះដើម្បីសម្រេចគោលដៅនេះ។ ក្រសួងបានដាក់ចេញនូវកំណែទម្រង់សាលាគរុកោសល្យ គឺការប្រែក្លាយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ឱ្យក្លាយជាមជ្ឈមណ្ឌលឧត្តមភាព ក្នុងការបណ្តុះបណ្តាល និងរិក្រឹតការគ្រូបង្រៀនគ្រប់កម្រិត ដើម្បីធានាបាននូវគុណភាព និងឧត្តមភាព ឆ្លើយតបនឹងតម្រូវការក្នុងបរិបទថ្មីនេះ។
- ឱកាសស្មើគ្នា លទ្ធផលស្មើគ្នា នឹងត្រូវឆ្លុះបញ្ចាំង តាមរយៈការផ្តល់ធនធានគ្រប់គ្រាន់ និងមានគុណភាពដល់ប្រព័ន្ធអប់រំ និងសាលារៀន ការគ្រប់គ្រង និងដំណើរការប្រព័ន្ធអប់រំ និងសាលារៀនស្របតាមស្តង់ដាត្រឹមត្រូវ

និងមានភាពធន់ និងការអនុវត្តយន្តការវាស់វែងលទ្ធផលសិក្សាដែលរឹងមាំ និងតម្រង់ទៅរកការជួយគាំទ្រសិស្ស។ យើងទាំងអស់គ្នាត្រូវយកចិត្តទុកដាក់ដល់ការថែទាំ និងអភិវឌ្ឍកុមារតូចតាំងពី ១០០០ថ្ងៃដំបូង ដើម្បីឱ្យពួកគេមានកាយសម្បទាគ្រប់គ្រាន់ សម្រាប់ចូលរៀននៅបឋមសិក្សា ការពង្រឹងសមត្ថភាពអំណាន និងគណិតវិទ្យានៅកម្រិតថ្នាក់ដំបូងនៅបឋមសិក្សា ការអនុវត្តកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនថ្មីនៅមធ្យមសិក្សា ការអភិវឌ្ឍបំណិនសតវត្សទី២១ ដល់យុវជន និងការដាក់ចេញវិធានការសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ជារួម វិធានការ និងយន្តការជាច្រើនត្រូវបានដាក់ចេញ និងអនុវត្ត ប៉ុន្តែការធានាវិធានការដែលបានដាក់ចេញឱ្យក្លាយជាការអនុវត្តនៅមូលដ្ឋាន និងសាលារៀនជាកត្តាដ៏សំខាន់ ដែលទាមទារឱ្យមានការយល់ដឹង ការចូលរួមគាំទ្រ និងយន្តការតាមដានច្បាស់លាស់ ពីសំណាក់បុគ្គលិកអប់រំ និងភាគីពាក់ព័ន្ធទាំងអស់។ ឯកឧត្តមសង្ឃឹមថា សន្និសីទជាតិលើកទី៦នេះ នឹងផ្តល់ឱកាសឱ្យអ្នកស្រាវជ្រាវ អ្នករៀបចំគោលនយោបាយ អ្នកអនុវត្ត អ្នកទទួលផល និងតួអង្គពាក់ព័ន្ធក្នុងវិស័យអប់រំទាំងអស់ បានឈ្វេងយល់បន្ថែម និងទទួលបាននូវការចែករំលែកឧត្តមានុវត្តន៍ និងទស្សនាទានល្អៗ ឆ្លើយតបនឹងគោលបំណងរបស់សន្និសីទ ពោលគឺ៖ ១.វិធានការដើម្បីធានាថាកុមារទាំងអស់ បានទៅសាលារៀននិងរៀនចេះ ២.ការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស តាមរយៈការបណ្តុះនូវជំនាញសិក្សាពេញមួយជីវិត មានភាពឯករាជ្យអាចស្វ័យសិក្សាដោយខ្លួនឯង ៣.ការពង្រឹងសមត្ថភាពអំណាន និងគណិតវិទ្យាកម្រិតថ្នាក់ដំបូងនៅបឋមសិក្សាដែលជាការជួយការគាំទ្រគ្រូបង្រៀនដើម្បីពង្រឹងសមត្ថភាពទាំងផ្នែកចំណេះដឹង និងវិធីសាស្ត្របង្រៀន ការវាយតម្លៃលទ្ធផលការសិក្សារបស់សិស្ស ៤.គ្រូបង្រៀនត្រូវពង្រឹងសមត្ថភាពនៃរបៀបនៃការរៀបចំតេស្តសម្រាប់សិស្ស ដើម្បីផ្លាស់ប្តូររបៀបនៃការរៀននៅក្នុងថ្នាក់រៀន ៥.ការលើកកម្ពស់អភិបាលកិច្ចសាលារៀន និង៦.ការលើកទឹកចិត្តមាតាបិតា និងសហគមន៍នៅក្នុងដំណើរការសាលារៀន និងការសិក្សារបស់កូនចៅគ្រប់រូប ។

ជាចុងក្រោយ ឯកឧត្តមក៏បានថ្លែងអំណរគុណចំពោះសហការីអង្គការNEP និងសមាជិកទាំងអស់ដែលតែងតែជួយគាំទ្រដល់វិស័យអប់រំ គ្រប់ទិដ្ឋភាព ហើយកម្មវិធីសន្និសីទលើកទី៦នេះ បានដំណើរការបានរលូន និងទទួលបានលទ្ធផល និងការរំពឹងទុកដើម្បីដាក់ជូនថ្នាក់ដឹកនាំ ក្នុងការរៀបចំដំណើរការថវិកាក្នុងឆ្នាំ២០២៦។

## សេចក្តីផ្តើមសម្រាប់កិច្ចពិភាក្សា

ដើម្បីជាការបើកនូវបុព្វបទ និងជាគំនិតសម្រាប់កិច្ចពិភាក្សា NEP បានធ្វើបទបង្ហាញមួយស្តីពី **ការវិភាគលទ្ធផលសិក្សារបស់សិស្សមិនទាន់បានល្អ** ដែលបង្ហាញដោយ **លោក យឹង គឹមហេង អ្នកសម្របសម្រួលគម្រោង** Education Out Loud (EOL) **នៃGPE របស់អង្គការ NEP។** បទបង្ហាញបានលើកឡើងនូវចំណុច៖

1. *វឌ្ឍនភាពដែលរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡាសម្រេចបាន*
   a. ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រ ការអនុម័តរបៀបវារៈសម្រាប់ SDGs ២០១៦-២០៣០
   b. ការធ្វើមូលដ្ឋានីយកម្ម SDGs នៅក្នុងបរិបទប្រទេសកម្ពុជា តាមរយៈគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs)។ SDG៤ គឺធានាការអប់រំប្រកបដោយ គុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប។

c. ការសម្រេចនូវសមិទ្ធិផលសំខាន់ៗតាមរយៈកំណែទម្រង់វិស័យអប់រំដូចជាៈ ការអនុម័តគោលនយោបាយ និងផែនការសំខាន់ៗ (ការផ្តល់អាហារតាមសាលារៀន ផែនការយុទ្ធសាស្រ្តអប់រំ ឌីជីថលសម្រាប់សាលារៀន... ផែនការយុទ្ធសាស្រ្តវិស័យអប់រំ-ESP ផែនការសកម្មភាពគ្រូបង្រៀន ផែនការសកម្មភាពសម្រាប់ការអប់រំបរិយាបន្ន និងផ្សេងៗទៀតជាដើម)។

d. ការកើនឡើងនូវការចុះឈ្មោះចូលរៀន ជាពិសេសនៅកម្រិតបឋមសិក្សា (អត្រាពិតចូលរៀនថ្មី៩៧.២%) ក្នុងឆ្នាំសិក្សា២០២៤-២០២៥ ក៏ដូចជាការកើនឡើងអត្រារួមនៃការសិក្សានៅឧត្តមសិក្សា (អាយុ១៨-២២)

e. កំណែទម្រង់សាលារៀនដើម្បីទទួលបានការរៀនមានគុណភាព ប្រកបដោយបរិយាបន្ន និងសមធម៌ (ការកើនឡើងនូវសាលារៀនគំរូ %សិស្សថ្នាក់ទី១២ ទទួលបាននិទ្ទេស A-B-C......)។

f. វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់គ្រូបង្រៀន ដូចជា ការបណ្តុះបណ្តាល កិច្ចការរិក្រឹតការ ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ការលើកកម្ពស់ជំនាញសតវត្សទី២១ សម្រាប់យុវជន ការអប់រំឌីជីថល ។ល។

2. *បញ្ហាប្រឈម*

a. %កុមារចូលរៀននៅបឋមសិក្សា ដែលបានឆ្លងកាត់មត្តេយ្យសិក្សានៅមានកម្រិត (៧៩.៧%) ខណៈអាយុ ៥ឆ្នាំ មានត្រឹម ៤៣.១% និងអាយុ ៣ឆ្នាំ មាន១៦.៧% (អត្រារួម ៣ឆ្នាំ-៥ឆ្នាំ មានត្រឹមតែ៤៣%)។

b. អត្រារួមនៃការសិក្សាកម្រិតបឋមសិក្សា ១២៤.៦% ដោយមិនទាន់សម្រេចចំណុចដៅមកត្រឹម១០៣.៥% (កុមារចូលរៀនលើសអាយុ ១៥.៩%)។

c. អត្រាត្រួតថ្នាក់នៅបឋមសិក្សាគឺ៥.៤% និងអត្រាបោះបង់ការសិក្សាសរុបពីថ្នាក់ទី១-៦ គឺ៤.១% ខណៈដែលអត្រាបោះបង់នៅកម្រិតថ្នាក់ទី៦ខ្ពស់ជាងគេ គឺ១០.៥% (ដោយសារមិនមានមូលដ្ឋានគ្រឹះរឹងមាំមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា សម្រាប់បន្តការសិក្សានៅកម្រិតមធ្យមសិក្សា ទីលំនៅឆ្ងាយពីគ្រឹះស្ថានមធ្យមសិក្សា បរិយាកាសនិងលក្ខខណ្ឌសិក្សានៅមធ្យមសិក្សា សិស្សខ្លះលើសអាយុ កត្តាសេដ្ឋកិច្ចគ្រួសារ និងឱកាសការងារ ជាកត្តាជំរុញឱ្យពួកគាត់បោះបង់ការសិក្សា)។

d. អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សានៅមានកម្រិតខ្ពស់ និងមិនទាន់ឈានដល់ចំណុចដៅ ដោយនៅមធ្យមសិក្សាបឋមភូមិ ១៥.៥% និង មធ្យមសិក្សាទុតិយភូមិ ១៣.៧%។

e. អត្រាត្រួតថ្នាក់ ក៏ត្រូវបានចាត់ទុកថាជាហេតុផលដែលរួមចំណែកដល់ការរៀនយឺតផងដែរ។ សិស្សសាលាបឋមសិក្សាធ្វើមិនសូវបានល្អទាំងផ្នែកគណិតវិទ្យា និងអំណាន (យោងតាម រង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍-SEA-PLM)។

3. *កត្តានាំឱ្យសិស្សទទួលលទ្ធផលសិក្សាមិនទាន់បានល្អ*

**កត្តាសាលារៀនៈ**

- **ថ្នាក់រៀនមានសិស្សច្រើនៈ** ថ្នាក់រៀនចង្អៀតខ្លាំង អាចរារាំងការយកចិត្តទុកដាក់របស់គ្រូ ដែលធ្វើឱ្យសិស្សពិបាកយល់គំនិតប្រកបដោយប្រសិទ្ធភាព។ នៅកម្ពុជាថ្នាក់រៀនអាចមានសិស្សពី ៤៥-៦០នាក់ ដែលខ្ពស់ខ្លាំងបើធៀបនឹងប្រទេសអាស៊ានដទៃទៀត។
- **កង្វះខាតធនធានសំខាន់ៗៈ** ដូចជាសៀវភៅសិក្សាគោល បច្ចេកវិទ្យា និងសម្ភារៈសិក្សា រឹតត្បិតសមត្ថភាពរបស់សិស្សក្នុងការចូលរួមជាមួយកម្មវិធីសិក្សា។ ហេដ្ឋារចនាសម្ព័ន្ធមិនល្អ រួមទាំងភ្លើងបំភ្លឺមិនគ្រប់គ្រាន់

ខ្យល់ចេញចូល និងកន្លែងអង្គុយ បង្កើតបរិយាកាសសិក្សាមិនស្រួលដែលអាចរំខានសិស្ស និងកាត់បន្ថយការផ្តោតអារម្មណ៍។ ទីតាំងសាលារៀនមានផលប៉ះពាល់ដល់លទ្ធផលសិក្សា។ គុណភាពនៃការអប់រំនៅសាលារៀនដាច់ស្រយាលប្រឈមមុខនឹងបញ្ហាជាច្រើនដោយសារកង្វះធនធាន។ លើសពីនេះ សាលារៀនមួយចំនួនត្រូវបានបង្ខំឱ្យបញ្ចូលគ្នានូវថ្នាក់។

- **គ្រូទទួលការបណ្តុះបណ្តាលមិនបានគ្រប់គ្រាន់៖** អាចជួបការលំបាកក្នុងការបង្រៀនមេរៀនប្រកបដោយប្រសិទ្ធភាព ឬគ្រប់គ្រងឥរិយាបថខ្លួនឯង និងសិស្សក្នុងថ្នាក់ ដែលអាចប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្សបន្ថែមទៀត។
- **វប្បធម៌សាលាអវិជ្ជមាន៖** ការបៀតបៀន ឬកង្វះការគាំទ្រ ក៏អាចប៉ះពាល់ដល់សុខុមាលភាពផ្លូវចិត្តរបស់សិស្ស និងសមត្ថភាពរបស់ពួកគេក្នុងការផ្តោតអារម្មណ៍លើការសិក្សាផងដែរ។ កត្តារួមបញ្ចូលគ្នាទាំងនេះបង្កើតបរិយាកាសអប់រំដ៏លំបាក ដែលអាចរារាំងយ៉ាងធ្ងន់ធ្ងរដល់វឌ្ឍនភាពសិក្សារបស់សិស្សបឋមសិក្សានៅកម្ពុជា និងបរិបទស្រដៀងគ្នាផ្សេងទៀត។ ការដោះស្រាយបញ្ហាទាំងនេះតម្រូវឱ្យមានវិធីសាស្ត្រដ៏ទូលំទូលាយ រួមទាំងការបែងចែកធនធានកាន់តែប្រសើរ ការបណ្តុះបណ្តាលគ្រូ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបង្កើតបរិយាកាសសិក្សាកាន់តែអំណោយផលសម្រាប់សិស្សទាំងអស់។
- **អភិបាលកិច្ចសាលា និងការបែងចែកធនធាន៖** នៅពេលដែលខ្វះតម្លាភាព គណនេយ្យភាព ភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព និងការត្រួតពិនិត្យហ្មត់ចត់ ដែលជះឥទ្ធិពលអវិជ្ជមានដល់ការអនុវត្តរបស់សិស្ស និងគ្រូ។ ការគ្រប់គ្រងថវិកាមិនល្អ និងការបែងចែកធនធានគ្មានប្រសិទ្ធភាពអាចបង្វែរថវិកាចេញពីតម្រូវការសំខាន់ៗ ដែលនាំទៅដល់ការខ្វះខាតសម្ភារៈបង្រៀន និងសិក្សា ការអភិវឌ្ឍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍវិជ្ជាជីវៈរបស់បុគ្គលិកអប់រំដែលមានសមត្ថភាព ដែលប៉ះពាល់ដោយផ្ទាល់ទៅលើបទពិសោធន៍ និងលទ្ធផលសិក្សារបស់សិស្ស។ **កង្វះតម្លាភាព និងគណនេយ្យភាព** ធ្វើឱ្យមានការលំបាកក្នុងការរៀបចំសាលារៀនឱ្យទទួលខុសត្រូវចំពោះការអនុវត្តរបស់ពួកគេ កាត់បន្ថយការជឿទុកចិត្តរបស់មាតាបិតា និងសហគមន៍ក្នុងប្រព័ន្ធអប់រំ។ ការខ្វះទំនុកចិត្តនេះអាចបង្អាក់ការវិនិយោគក្នុងវិស័យអប់រំពីភាគីពាក់ព័ន្ធទាំងនេះ។ ការដោះស្រាយបញ្ហាប្រឈមផ្នែកអភិបាលកិច្ច និងការបែងចែកធនធានមានសារៈសំខាន់ណាស់ក្នុងការបង្កើតបរិយាកាសសិក្សាដែលគាំទ្រ និងមានប្រសិទ្ធភាពសម្រាប់សិស្សទាំងអស់។

**កត្តាគ្រូបង្រៀន**

- **គុណវុឌ្ឍិ និងការបណ្តុះបណ្តាលមានកម្រិត៖** ការលើកកម្ពស់គុណវុឌ្ឍិរបស់គ្រូបង្រៀនជាវិធានការដែលត្រូវបានទទួលស្គាល់ក្នុងការលើកកម្ពស់គុណភាពនៃការអប់រំគ្រូបង្រៀន ដែលតម្រូវឱ្យមានការវិនិយោគបន្ថែមទៀតដើម្បីបំពេញតាមស្តង់ដាសម្រាប់ការផ្តល់ការអប់រំប្រកបដោយគុណភាព។
- **ការអភិវឌ្ឍវិជ្ជាជីវៈមិនគ្រប់គ្រាន់៖** គុណភាពគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈមានសារៈសំខាន់ណាស់សម្រាប់ការបង្រៀនប្រកបដោយប្រសិទ្ធភាព និងការកែលម្អលទ្ធផលសិក្សារបស់សិស្ស។ ទោះជាយ៉ាងណាក៏ដោយ ការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ កង្វះការគាំទ្រជាបន្តបន្ទាប់សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ និងការទទួលបានធនធានមានកម្រិត អាចរារាំងសមត្ថភាពរបស់គ្រូបង្រៀនក្នុងការផ្តល់ការអប់រំប្រកប ដោយគុណភាព។ ទោះបីជាកម្រិតអប់រំរបស់គ្រូបង្រៀនមានភាពប្រសើរឡើងក្នុងទសវត្សរ៍ចុងក្រោយនេះក៏

ដោយ គ្រូបង្រៀនជាច្រើននៅតែត្រូវការធ្វើឱ្យប្រសើរឡើងនូវគុណវុឌ្ឍិ ដើម្បីបំពេញតាមស្តង់ដាដែលមានចែងនៅក្នុងគោលនយោបាយគ្រូបង្រៀន និងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន។ ទិន្នន័យរបស់ក្រសួងអប់រំ ក្នុងឆ្នាំ២០២១-២០២២ គ្រូបង្រៀនបឋមសិក្សា ស្ទើរតែមួយភាគបួន មានកម្រិតអប់រំទាបជាងមធ្យមសិក្សាទុតិយភូមិ ខណៈដែលជិតពាក់កណ្តាលនៃគ្រូបង្រៀនមធ្យមសិក្សាទាំងអស់មិនទាន់ទទួលបានបរិញ្ញាបត្រដែលមានឯកទេសលើមុខវិជ្ជាដែលពួកគេបង្រៀននៅឡើយ។ គ្រូបង្រៀន មានឱកាសតិចតួចសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីបង្កើនចំណេះដឹង និងជំនាញគរុកោសល្យរបស់ពួកគេ។ យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធវិស័យអប់រំនៅថ្នាក់ខេត្ត ខណៈដែលកម្មវិធីសិក្សាកំពុងដំណើរការ និងធ្វើបច្ចុប្បន្នភាព គ្រូបង្រៀនកម្រទទួលបានការការធ្វើវិក្រឹតការពីបច្ចេកទេសបង្រៀនថ្មីៗណាស់ ហើយឱកាសមានកម្រិតក្នុងការចូលរួមវគ្គចែករំលែក ឬភ្ជាប់ជាមួយគ្រូផ្សេងទៀតដើម្បីផ្លាស់ប្តូរចំណេះដឹង ដែលនាំឱ្យពួកគេនៅបន្តប្រើវិធីសាស្ត្រហួសសម័យ។

- **គ្រូបង្រៀននៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូះ** មានតួនាទីសំខាន់ក្នុងការរៀបចំកម្លាំងបង្រៀនប្រកបដោយគុណភាពខ្ពស់ និងលើកទឹកចិត្ត។ យ៉ាងណាក៏ដោយ សមត្ថភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនក្នុងការផ្តល់ការអប់រំគ្រូបង្រៀនប្រកបដោយគុណភាព ស្របតាមស្តង់ដាអ្នកផ្តល់ការអប់រំគ្រូបង្រៀនបច្ចុប្បន្នមានកម្រិត។ នៅមជ្ឈមណ្ឌលគរុកោសល្យខេត្ត ដែលមានកម្មវិធីបណ្តុះបណ្តាលគ្រូសម្រាប់គ្រូឧទ្ទេសមិនទាន់មានសញ្ញាបត្រអនុបណ្ឌិត ឬបណ្ឌិតជាដើម។
- **គុណភាពគ្រូបង្រៀនជាប់កិច្ចសន្យាះ** គ្រូបង្រៀនជាប់កិច្ចសន្យា តែងតែទទួលការបណ្តុះបណ្តាលរយៈពេលខ្លី ដែលមិនគ្រប់គ្រាន់ក្នុងការជួយពួកគេ ក្នុងការផ្តល់ការបង្រៀនប្រកបដោយគុណភាពដល់សិស្ស។

**គម្លាតសមត្ថភាពឌីជីថលះ**

- **ឧបករណ៍បច្ចេកទេសះ** កង្វះឧបករណ៍ និងអ៊ីនធឺណិត កំពុងបង្កើតបញ្ហាសម្រាប់ការបង្ហោះចំណេះដឹង និងការយល់ដឹងអំពីវគ្គសិក្សា/ថ្នាក់។ លើសពីនេះ ឪពុកម្តាយមួយចំនួន មិនមានលទ្ធភាពក្នុងការរៀបចំប្រព័ន្ធសិក្សាឌីជីថលសម្រាប់ថ្នាក់អនឡាញ ហើយវាធ្វើឱ្យមានការលំបាកបន្ថែមទៀតសម្រាប់ក្រុមងាយរងគ្រោះ ដែលនឹងនាំមកនូវផលប៉ះពាល់អវិជ្ជមានដល់លទ្ធផលសិក្សា។
- **ជំនាញ និងសមត្ថភាពឌីជីថលះ** វាផ្តោតលើបញ្ហាប្រឈមពីកង្វះជំនាញឌីជីថល និងសមត្ថភាពតម្រូវឱ្យអនុវត្តការរៀនតាមអេឡិចត្រូនិក និងជំនាញដែលត្រូវការសម្រាប់ថ្នាក់រៀន ដើម្បីប្រើប្រាស់ឧបករណ៍ឌីជីថល និងបច្ចេកទេសប្រកបដោយប្រសិទ្ធភាពក្នុងការរៀនតាមអេឡិចត្រូនិក។
- **កង្វះការយល់ដឹងអំពីថ្នាលឌីជីថលះ** ក្រសួងអប់រំ និងដៃគូបានបង្កើតវេទិកាឌីជីថលមួយចំនួន ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំ។ កង្វះការយល់ដឹងនៅលើវេទិកាឌីជីថលទាំងនោះ ប៉ះពាល់ដល់អ្នកអប់រំ និងការសិក្សារបស់សិស្ស។ ឧទាហរណ៍៖ CPD PLP Sala Digital ប្រព័ន្ធគ្រប់គ្រងការរៀន... គ្រូបង្រៀន នាយកសាលា និងអ្នកអប់រំក្នុងតំបន់ប្រហែលជាមិនដឹងពីរបៀបស្វែងរក ចុះឈ្មោះ ឬប្រើប្រាស់ថ្នាលទាំងនេះប្រកបដោយប្រសិទ្ធភាពនោះទេ។ លើសពីនេះ វាក៏អាចមានន័យថា គាត់មិនដឹងអំពីថ្នាលទាំងនោះ ឬប្រហែលជាមិនដឹងពីរបៀបចូលប្រើ ឬប្រើប្រាស់ធនធានដែលមាននៅលើវេទិកាទាំងនេះទេ។
- **អាកប្បកិរិយានៃការទទួលយកះ** បញ្ហាប្រឈមសម្រាប់គ្រូ និងសិស្សក្នុងការទទួលយកការផ្លាស់ប្តូរឆ្ពោះទៅរកការរៀនតាមអេឡិចត្រូនិក ឬថ្នាក់អនឡាញ។ អាកប្បកិរិយាវិជ្ជមានឆ្ពោះទៅរកការរៀនតាមអេឡិចត្រូ

និក និងការរៀនដោយខ្លួនឯង គឺមានសារៈសំខាន់សម្រាប់ការរួមបញ្ចូលបច្ចេកវិទ្យាក្នុងការអប់រំតាមរយៈការតេស្ដដំបូងមួយចំនួន កត្តាខាងក្រៅដូចជាបន្ទុកការងារអាចបង្កបញ្ហាប្រឈម។

**កត្តាការចូលរួមរបស់ឪពុកម្ដាយ និងសហគមន៍**

- **ឪពុកម្ដាយកម្ពុជាជាច្រើនខ្វះការអប់រំ និងធនធានដើម្បីគាំទ្រដល់ការសិក្សា**របស់កូនៗនៅផ្ទះប្រកបដោយប្រសិទ្ធភាព។ នេះអាចបណ្ដាលឱ្យមានជំនួយមិនគ្រប់គ្រាន់ជាមួយកិច្ចការផ្ទះ និងសកម្មភាពសិក្សា ដែលជះឥទ្ធិពលអវិជ្ជមានដល់លទ្ធផលសិក្សារបស់សិស្ស។
- **ការចូលរួមរបស់មាតាបិតា និងអាណាព្យាបាល៖** ជារឿយៗមានកម្រិត ជាពិសេសសម្រាប់ឪពុកម្ដាយដែលធ្វើការនៅឆ្ងាយពីផ្ទះ ឬជាជនចំណាកស្រុក។ ស្ថានភាពនេះរឹតត្បិតសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងគ្នា និងចូលរួមក្នុងការតាមដានលទ្ធផលសិក្សា និងការសិក្សារបស់កូនពួកគេ។
- **ឧបសគ្គផ្នែកហិរញ្ញវត្ថុ៖** គឺជាឧបសគ្គចម្បងក្នុងការចុះឈ្មោះចូលរៀន និងរក្សាសិស្សឱ្យបន្តការសិក្សារបស់ពួកគេ។ គ្រួសារជាច្រើននៅក្នុងប្រទេសកម្ពុជាមានការលំបាក និងរស់នៅក្នុងភាពក្រីក្រ ដែលបណ្ដាលឱ្យកូនរបស់ពួកគេចាប់ផ្ដើមចូលរៀននៅអាយុយឺត ឬសិក្សាក្នុងស្ថានភាពក្រីក្រ។ កុមារទាំងនេះអាចត្រូវបានបង្ខំឱ្យទទួលយកការងារដែលគ្មានជំនាញដើម្បីផ្គត់ផ្គង់គ្រួសារ ដោយកាត់បន្ថយពេលវេលា និងកម្លាំងក្នុងការសិក្សារបស់ពួកគេ ដែលនាំឱ្យអវត្តមាន និងបោះបង់ការសិក្សា។ ខណៈដែលការអប់រំបឋមនៅកម្ពុជាជាផ្លូវការ គឺមិនគិតថ្លៃ។ ប៉ុន្តែកត្តាជាច្រើនរារាំងការចូលរៀន និងជោគជ័យក្នុងសាលារបស់សិស្ស។ គ្រួសារជាច្រើនប្រឈមមុខនឹងបន្ទុកហិរញ្ញវត្ថុយ៉ាងសំខាន់ ក្នុងការចំណាយទាក់ទងនឹងការអប់រំដូចជា ថ្នាក់បន្ថែម ឯកសណ្ឋាន សៀវភៅសិក្សា ការរួមចំណែកដល់ឧបករណ៍ប្រើប្រាស់ក្នុងសាលារៀន/ការផ្គត់ផ្គង់ព្រឹត្តិការណ៍ និងការដឹកជញ្ជូនជាដើម។
- **ឧបសគ្គខាងវប្បធម៌សង្គម៖** ផ្នត់គំនិត និងអាកប្បកិរិយារបស់មាតាបិតាទាក់ទងនឹងការអប់រំអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើលទ្ធផលសិក្សា។ តួនាទី និងបទដ្ឋានយេនឌ័រ ប្រពៃណីអាចកំណត់លទ្ធភាពទទួលបានការអប់រំរបស់ក្មេងស្រី ដោយសារកង្វះការយល់ដឹងអំពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃការសិក្សា។
- **បរិយាកាសក្នុងផ្ទះ៖** ដែលត្រូវបានចាត់ថ្នាក់ដោយអំពើហិង្សាក្នុងគ្រួសារ កង្វះអាហារូបត្ថម្ភ អស្ថិរភាព កង្វះលទ្ធភាពទទួលបានធនធានអប់រំប្រកបដោយគុណភាព និងអាកប្បកិរិយាសហគមន៍អវិជ្ជមានចំពោះការអប់រំអាចបង្កើតបរិយាកាសស្ត្រេស និងរំខាន។ លក្ខខណ្ឌទាំងនេះប៉ះពាល់អវិជ្ជមានដល់សមត្ថភាពរបស់កុមារក្នុងការផ្ដោតលើការសិក្សា និងសុខុមាលភាពរបស់ពួកគេ។

**កត្តាសិស្ស**

- **មិនមានការលើកទឹកចិត្តខ្លួនឯង៖** *កត្តាសិស្សខ្លួនឯងគឺជាកត្តាសំខាន់បំផុតក្នុងការធានានូវភាពជោគជ័យក្នុងការសិក្សា។ ការលត់ដំខ្លួន និងការលើកទឹកចិត្ត គឺជាការរួមចំណែកយ៉ាងសំខាន់ដល់ការអនុវត្តល្អ រួមទាំងការបណ្ដុះទម្លាប់សិក្សាល្អ បង្ហាញពីការប្ដេជ្ញាចិត្តផ្ទាល់ខ្លួន និងការរក្សាការលើកទឹកចិត្ត។
- **ការចូលរួមក្នុងថ្នាក់៖** ក៏មានសារៈសំខាន់ផងដែរសម្រាប់ភាពជោគជ័យក្នុងការសិក្សា។ ការចូលរួមទៀងទាត់ និងទាន់ពេលវេលាគឺចាំបាច់។
- **អវត្តមាន៖** ដោយសារជំងឺ ការរំលងថ្នាក់ ឬការប្ដេជ្ញាចិត្តក្នុងគ្រួសារអាចរារាំងដល់ការសិក្សា។ អត្រាអវត្តមានខ្ពស់ដោយសារបញ្ហាគ្រួសារ និងបញ្ហាសុខភាពអាចនាំឱ្យមានគម្លាតក្នុងការសិក្សា និងលទ្ធផលសិក្សា

មិនល្អ។ ខណៈពេលដែលកត្តាជុំវិញដូចជាការរំខាន អនាម័យមិនល្អ ឥទ្ធិពលពីមិត្តភ័ក្ត និងការគំរាមកំហែងក៏អាចជះឥទ្ធិពលអវិជ្ជមានដល់ការសិក្សារបស់សិស្សផងដែរ

- **សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់សិស្ស៖** ការគ្រប់គ្រងភាពតានតឹង ការថប់បារម្ភ និងការរក្សារបៀបរស់នៅដែលមានសុខភាពល្អ ព្រមទាំងសុខុមាលភាពសិស្សដូចជា៖ ពិការភាពក្នុងការសិក្សា ភាពខុសគ្នានៃការយល់ដឹង ឧបសគ្គភាសា និងបញ្ហាអារម្មណ៍ និងអាកប្បកិរិយា គឺជាបញ្ហាប្រឈមដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់លទ្ធផលសិក្សា។
- **សិស្សដែលមានពិការភាព៖** អាចប្រឈមមុខនឹងបញ្ហាសំខាន់ៗនៅក្នុងថ្នាក់រៀន។ សម្រាប់សិស្សដែលមានភាពខុសប្លែកគ្នានៃការយល់ដឹង កត្តាដូចជា IQ ទាប ឬបញ្ហានៃការចងចាំអាចបង្កការលំបាក និងប៉ះពាល់ដល់ការរៀនសូត្ររបស់ពួកគេ។ ជាងនេះទៅទៀត សិស្សមកពីជនជាតិដើមភាគតិច សិស្សដែលមិនចេះនិយាយភាសាខ្មែរ ឬមានបញ្ហាភាសាអាចប្រឈមមុខនឹងបញ្ហាទំនាក់ទំនងជាមួយមិត្តរួមថ្នាក់ និងគ្រូ។ កត្តាអារម្មណ៍ និងអាកប្បកិរិយា ដូចជាការថប់បារម្ភ ការធ្លាក់ទឹកចិត្ត និងបញ្ហាការយកចិត្តទុកដាក់ អាចរារាំងដល់ការសិក្សាបន្ថែមទៀត។
- **សិស្សដែលមានមូលដ្ឋានគ្រឹះខ្សោយ៖** អាចពិបាកក្នុងការផ្តោតអារម្មណ៍ ឬរំលងថ្នាក់ ដែលធ្វើឱ្យវាពិបាកក្នុងការឈានទៅកម្រិតខ្ពស់។ កត្តាសុខភាពដូចជាកង្វះអាហារូបត្ថម្ភ និងលក្ខខណ្ឌវេជ្ជសាស្ត្រដែលមិនបានព្យាបាលអាចរារាំងការសិក្សាប្រកបដោយប្រសិទ្ធភាព។

**ការបាត់បង់ការរៀនសូត្រ**

- **ផលប៉ះពាល់នៃជំងឺរាតត្បាត៖** ក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញការរកឃើញថ្មីគួរឱ្យព្រួយបារម្ភអំពីការបាត់បង់ការសិក្សា ក្នុងអំឡុងពេលជំងឺរាតត្បាត កូវីដ-១៩ ។ ការវាយតម្លៃការសិក្សាថ្នាក់ជាតិចុងក្រោយបង្អស់ ថ្នាក់ទី៦ បានបង្ហាញថា សិស្សបានធ្លាក់ពីក្រោយការរៀនរបស់ពួកគេ បើប្រៀបធៀបទៅនឹងការវាយតម្លៃសមមូលចុងក្រោយក្នុងឆ្នាំ២០១៦។ ភាគរយនៃសិស្សដែលបរាជ័យក្នុងការបង្ហាញពីសមត្ថភាពមូលដ្ឋានបានកើនឡើងពី ៣៤% ទៅ ៤៥% ភាសាខ្មែរ និងពី ៤៩% ទៅ ៧៤% នៅក្នុងគណិតវិទ្យា។ សាលារៀនត្រូវបានបិទរយៈពេល ២៥០ថ្ងៃ ក្នុងអំឡុងឆ្នាំ២០២០ និង២០២១។ លទ្ធផលវាយតម្លៃការសិក្សាបង្ហាញថា ទោះបីជាសិស្សទាំងអស់ជួបប្រទះការបាត់បង់ការសិក្សាបន្ទាប់ពីការបិទទាំងនេះក៏ដោយ ផលប៉ះពាល់មិនត្រូវបានបញ្ចប់នោះទេ។ ក្មេងប្រុសបាត់បង់ការរៀនសូត្រកាន់តែច្រើន ហើយធ្វើមិនបានល្អក្នុងការធ្វើតេស្ត។ ក្មេងប្រុស ៥៥% ត្រូវបានគេវាយតម្លៃថាមិនបានបំពេញជំនាញភាសាខ្មែរនៅឆ្នាំ ២០២១ ធៀបនឹង ៣៤% នៃក្មេងស្រី។ នៅក្នុងប្រទេសកម្ពុជា សិស្សចំនួន ៨% សម្រេចបានកម្រិតអប្បបរមានៃជំនាញក្នុងការអាន និង ១0% នៃសិស្សទទួលបានកម្រិតអប្បបរមានៃជំនាញគណិតវិទ្យា។
- **អវត្តមានគ្រូ និងការមកយឺត៖** រំខានដល់ដំណើរការសិក្សា និងនាំទៅដល់ការបង្រៀនដែលគ្មានប្រសិទ្ធភាព។
- **ការរៀបចំកាលវិភាគសិក្សាមិនបានគ្រប់គ្រាន់ និងការមិនអាចបញ្ចប់ការបង្រៀននៃកម្មវិធីសិក្សា** អាចទុកឱ្យមានគម្លាតយ៉ាងសំខាន់ក្នុងការសិក្សារបស់សិស្ស និងជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់ពួកគេ។
- **ការដាក់ទណ្ឌកម្មអវិជ្ជមាន (វិធានការវិន័យ)** ដូចជាការបិទទ្វារសាលារៀនដើម្បីការពារសិស្សមកយឺត ជារឿយៗនាំឱ្យសិស្សអវត្តមានកើនឡើង។

- **គ្រូបង្រៀនមិនបានរៀបចំផែនការ និងសម្ភារៈនៃវគ្គបង្រៀន** គុណភាពនៃការបង្រៀនរបស់ពួកគេក៏កាត់បន្ថយ ហើយផលប៉ះពាល់អវិជ្ជមានដល់ការចូលរួមរបស់សិស្ស និងលទ្ធផលសិក្សា។

**កុមារមិនបានឆ្លងកាត់អប់រំកុមារតូច (ECE)**

- **ការចុះឈ្មោះចូលរៀនទាប៖ ECE** មានផលប៉ះពាល់ជាវិជ្ជមានលើលទ្ធផលសិក្សានៅបឋមសិក្សា ដោយកុមារដែលបានឆ្លងកាត់មត្តេយ្យសិក្សាមានលទ្ធផលល្អប្រសើរជាងអ្នកដែលមិនបានចូលរៀន។ ECE មានសារៈសំខាន់ចំពោះលទ្ធផលសិក្សារបស់កុមារ។ យ៉ាងណាក៏ដោយ កុមារតូចៗជាច្រើននៅតែមិនទទួលបានសេវា ECE ដែលមានគុណភាពនៅកម្ពុជា។ កុមារដែលមានអាយុ ៦ឆ្នាំ ដែលសិក្សាថ្នាក់ទី១ បានឆ្លងកាត់គ្រប់ប្រភេទនៃសេវាកម្ម ECE គឺ ៧៩.៧% សម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥។
- **កង្វះហេដ្ឋារចនាសម្ព័ន្ធ និងគុណភាពនៃការអប់រំមត្តេយ្យសិក្សា៖** រួមចំណែកយ៉ាងសំខាន់ដល់លទ្ធផលសិស្សទាប។ ការចុះឈ្មោះចូលរៀនសរុបរបស់កុមារអាយុពី ៣ ទៅ ៥ ឆ្នាំរបស់កម្ពុជាក្នុងគ្រប់ប្រភេទនៃការអប់រំមាន ៤៣% ខណៈដែលអត្រាចុះឈ្មោះចូលរៀនអាយុ ៥ឆ្នាំ មាន ៧១.៥% ដោយសារតែការពង្រីកហេដ្ឋារចនាសម្ព័ន្ធកម្មវិធីអភិវឌ្ឍន៍កុមារតូចមិនឆ្លើយតបនឹងតម្រូវការ។ ការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ការថែទាំ និងការអភិវឌ្ឍកុមារដំបូងក្នុងរយៈពេល ១០០០ថ្ងៃដំបូង មិនត្រូវបានគេយកចិត្តទុកដាក់។ ហើយសមត្ថភាពបុគ្គលិកមិនទាន់ឆ្លើយតបទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិនៅឡើយទេ។ ចំនួនសាលាមត្តេយ្យនៅតែខ្វះខាត ហើយគ្រឿងបរិក្ខាររបស់វាកំណត់លទ្ធភាពចូលរៀនសម្រាប់កុមារជាច្រើន។ ជាឧទាហរណ៍ ភូមិសាស្ត្រសាលាគឺជាឧបសគ្គចម្បងមួយសម្រាប់កុមារក្នុងការចូលរៀន ជាពិសេសនៅតំបន់ជនបទ។ ខណៈពេលដែលទាំងមជ្ឈមណ្ឌលអប់រំកុមារតូច សាលាមត្តេយ្យរដ្ឋ និងសហគមន៍មានការកើនឡើង សេវាគុណភាពទាមទារឱ្យមានការធ្វើឱ្យប្រសើរឡើងបន្ថែមទៀត ជាពិសេសក្នុងចំណោមសាលាមត្តេយ្យសហគមន៍។ មានតែគ្រូបង្រៀន ៤០% ប៉ុណ្ណោះដែលបានទទួលការបណ្តុះបណ្តាលជាផ្លូវការ ហើយ ៤១% នៃសាលាមត្តេយ្យសហគមន៍បានបំពេញតាមស្តង់ដាគុណភាពជាតិ។
- សាលាមត្តេយ្យតែងតែខ្វះគ្រូដែលមានសមត្ថភាព សម្ភារៈបង្រៀន និងសិក្សាគ្រប់គ្រាន់។ **កង្វះគ្រូដែលមានសមត្ថភាព និងបណ្តុះបណ្តាល** ការណែនាំ និងបម្រើកនឹងរារាំងដល់គុណភាពនៃការអប់រំមត្តេយ្យសិក្សា។ កុមារមិនបានចូលសាលាមត្តេយ្យ ជាលទ្ធផល ពួកគេមិនបានរៀបចំសម្រាប់សាលាបឋមសិក្សា មិនដូចកុមារដែលបានចូលរៀននៅសាលាបឋមសិក្សា ហើយត្រៀមខ្លួនចូលរៀន។
- **ការត្រួតពិនិត្យ និងការគ្រប់គ្រង៖ ការត្រួតពិនិត្យខ្សោយ និងការគ្រប់គ្រងរបស់អាជ្ញាធរមូលដ្ឋានមានកម្រិត** ផលប៉ះពាល់លើការតាមដាន និងផលប៉ះពាល់នៃការសិក្សារបស់កុមារ។ SMC POE DOE នឹងរួមចំណែកដល់គុណភាព និងការអនុវត្តកម្មវិធីមត្តេយ្យសិក្សា ដូចជាការគាំទ្រ និងកិច្ចសហការពីអាជ្ញាធរ មូលដ្ឋាន ការរៀបចំផែនការ ការអនុវត្ត និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ដើម្បីធានាគុណភាពជាវិជ្ជមានសម្រាប់កុមារមត្តេយ្យសិក្សាទៅបឋមសិក្សា។

## *4. អនុសាសន៍*

**បង្កើនថវិកាជាតិនៃការអប់រំរាជរដ្ឋាភិបាលកម្ពុជា (RGC)**

ការកែលម្អលទ្ធផលសិក្សារបស់សិស្ស ត្រូវការការវិនិយោគបន្ថែម ជាពិសេសការបែងចែកថវិកាអប់រំ កែលម្អគោលនយោបាយ លើកកម្ពស់គុណភាពគ្រូបង្រៀន ដែលអាចបង្កើតប្រព័ន្ធអប់រំប្រកបដោយសមធម៌ និងប្រសិទ្ធភាព។

ដើម្បីឱ្យសម្រេចបាននូវគោលដៅអប់រំ ជាពិសេសលទ្ធផលសិក្សារបស់សិស្ស ក៏ដូចជាការសម្រេចបាននូវគោលដៅ SDG៤ ទាមទារការ វិនិយោគបន្ថែម។ យើងដឹងថាវាមិនងាយស្រួល ប៉ុន្តែវាជាអ្វីដែលត្រូវការដែលមិនអាចខ្វះបាន។ ចាប់តាំងពីកំណែទម្រង់ឆ្នាំ២០១៤។ ក្រសួងអប់រំ យុវជន និងកីឡា បានស្រូបយកចំណែក ៣.៣៨% នៃGDP មុនពេលបាត់បង់ការអូសទាញរបស់ខ្លួននៅ ២.៦២% ក្នុងឆ្នាំ២០២២ ដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ១៩ ។

## ពង្រីក និងកែលម្អការអប់រំកុមារតូច (ECE)

ពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខាររបស់ ECE។ ចំនួនសាលាមត្តេយ្យនៅតែមិនគ្រប់គ្រាន់ ហើយគ្រឿងបរិក្ខារខ្វះខាត ជាពិសេសនៅតំបន់ជនបទ។ ការបង្កើនចំនួនសាលាមត្តេយ្យសាធារណៈ និងសហគមន៍ ក៏ដូចជាការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងធនធាន អាចជួយពង្រីកលទ្ធភាពទទួលបានសេវា ECE ។ ការវិនិយោគលើការកសាងសមត្ថភាពរបស់គ្រូបង្រៀន ECE ដោយផ្តល់ឱ្យពួកគេនូវការបណ្តុះបណ្តាល និងធនធាន អាចជួយកែលម្អគុណភាពនៃកម្មវិធី ECE និងធានាថាកុមារទទួលបានបទពិសោធន៍សិក្សាដំបូងដែលមានគុណភាពខ្ពស់។ លើកកម្ពស់ការយល់ដឹង និងលើកកម្ពស់ការចូលរួមក្នុងសហគមន៍។ កុមារតូចៗជាច្រើននៅតែមិនទទួលបានសេវា ECE ប្រកបដោយគុណភាព ដោយសារកង្វះការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំកុមារតូច។

ការកែលម្អជំនាញគរុកោសល្យ និងចំណេះដឹងរបស់គ្រូបង្រៀន សាលាគួរតែលើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់ (CPD) នៅក្នុងសាលារបស់ពួកគេ ដូច្នេះគ្រូបង្រៀនអាចធ្វើឱ្យប្រសើរឡើងនូវសាលារៀនរបស់ពួកគេ និងជាពិសេសការលើកកម្ពស់ការប្រើប្រាស់វេទិកាអភិវឌ្ឍសមត្ថភាព (ថ្នាលឌីជីថល)។ កម្មវិធីពង្រឹងសមត្ថភាពគួរតែជាការរួមបញ្ចូលគ្នានៃសិក្ខាសាលា ការស្រាវជ្រាវសកម្មភាព ការសង្កេតក្នុងថ្នាក់ និងការបង្វឹក និងការបង្ហាត់បង្រៀនពីមួយទៅមួយ ដើម្បីជួយគ្រូបង្រៀនអភិវឌ្ឍ និងការអនុវត្តការបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាព។ សាលាគួររៀបចំផែនការបណ្តុះបណ្តាលក្នុងកំឡុងពេលវិស្សមកាល។ ក្រសួងអប់រំ យុវជន និងកីឡា គួរតែចេញសេចក្តីណែនាំដល់សាលារៀន ដើម្បីរៀបចំផែនការបណ្តុះបណ្តាលបែបនេះ។

## គាំទ្រគណៈកម្មាធិការគ្រប់គ្រងសាលា (SMC)

- វាមានសារៈសំខាន់ក្នុងការពង្រឹងអភិបាលកិច្ចសាលារៀន ដោយផ្អែកលើសេចក្តីសម្រេចចិត្តនៅកម្រិតមូលដ្ឋាន។ ការផ្តល់សិទ្ធិអំណាចដល់SMCជួយពង្រឹងភាពជាម្ចាស់ និងកែលម្អការឆ្លើយតបរបស់សាលារៀន។ ទោះជាយ៉ាង SMC និងអាជ្ញាធរមូលដ្ឋានក៏ប្រឈមនឹងបញ្ហាហិរញ្ញវត្ថុ ដែលកំពុងកំណត់សមត្ថភាពក្នុងការជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាព (ជាពិសេសសាលាសហគមន៍) និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់សាលារៀន ក៏ដូចជាការថែទាំ និងជួសជុល ផ្តល់សម្ភារៈបង្រៀននិងរៀន និងសេវាកម្មគាំទ្របន្ថែមដល់សិស្ស ជាពិសេសសម្រាប់សិស្សក្រីក្រ សិស្សដែលមានពិការភាព និង/ឬសិស្សដែលមានតម្រូវការពិសេស។
- ការត្រួតពិនិត្យ និងវាយតម្លៃសាលារៀន៖ អាជ្ញាធរមូលដ្ឋាន និងSMC អាចខ្វះជំនាញក្នុងការគ្រប់គ្រងថវិកា និងប្រតិបត្តិការសាលារៀនប្រកបដោយប្រសិទ្ធភាព និងធានាបាននូវការប្រើប្រាស់ធនធានប្រកបដោយតម្លាភាព និងប្រសិទ្ធភាពនោះទេ។ ពួកគេខ្វះលទ្ធភាពទទួលបានឱកាសអភិវឌ្ឍវិជ្ជាជីវៈ និងជំនាញលើផ្នែកដូចជាការគ្រប់គ្រង ការវិភាគទិន្នន័យ សហគមន៍ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ។
- SMC មានតួនាទីសំខាន់ក្នុងការតាមដានអវត្តមានរបស់សិស្ស គ្រូ និងនាយកសាលា ព្រមទាំងដោះស្រាយបញ្ហាដែលរួមចំណែកដល់ការបាត់បង់ការសិក្សា។ កិច្ចប្រជុំប្រចាំត្រីមាស គឺចាំបាច់ដើម្បីត្រួតពិនិត្យវឌ្ឍនភាព

របស់សាលាទាំងផ្នែកហិរញ្ញវត្ថុ និងសកម្មភាព។ SMC ក៏គួរតែទទួលខុសត្រូវលើការវាយតម្លៃការអនុវត្តប្រចាំឆ្នាំរបស់នាយកសាលាផងដែរ។ តម្លាភាព និងគណនេយ្យភាពនឹងជំរុញឱ្យគ្រូបង្រៀនមានការចូលរួមកាន់តែច្រើន និងធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។

## ម្ចាស់ជំនួយ/ដៃគូអភិវឌ្ឍ/ទីភ្នាក់ងារអន្តរជាតិ

- ដើរតួនាទីយ៉ាងសំខាន់តាមរយៈការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសសំខាន់ៗដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស។
- កិច្ចសហការប្រកបដោយប្រសិទ្ធភាព គឺជាគន្លឹះក្នុងការបង្កើនឥទ្ធិពល តាមរយៈការគាំទ្រដល់អង្គការក្នុងស្រុក និងប្រើប្រាស់វេទិកាអនឡាញសម្រាប់ការផ្សព្វផ្សាយអប់រំ។ ការបន្តការគាំទ្រដល់NGO គឺមានសារៈសំខាន់ណាស់ ដោយសារពួកគេធ្វើការផ្ទាល់ និងមានទំនាក់ទំនងជាមួយសហគមន៍ ហើយអាចអនុវត្តកម្មវិធីដែលស្របតាមតម្រូវការក្នុងតំបន់។
- ការជំរុញកិច្ចសហការ និងការចែករំលែកព័ត៌មានក្នុងចំណោមម្ចាស់ជំនួយ ដៃគូអភិវឌ្ឍ ទីភ្នាក់ងារអន្តរជាតិ និង NGO មានសារៈសំខាន់ណាស់ ដែលជួយសម្រួលដល់ការបង្កើតគោលនយោបាយអប់រំផ្អែកលើភស្តុតាង ធានានូវកិច្ចខិតខំប្រឹងប្រែងស្របតាមអាទិភាពជាតិ និងរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព។
- ការគាំទ្រការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល គ្រូបង្រៀន និងនាយកសាលា តាមរយៈការបណ្តុះបណ្តាល ការណែនាំ និងការចែករំលែកចំណេះដឹង គឺជាកត្តាចាំបាច់សម្រាប់ការពង្រឹងប្រព័ន្ធអប់រំ។
- ការធ្វើការស្រាវជ្រាវ និងទិន្នន័យផ្អែកលើភស្តុតាង មានសារៈសំខាន់សម្រាប់លើកកម្ពស់គុណភាព និងសមធម៌នៃការអប់រំ។ ការវាយតម្លៃការសិក្សាថ្នាក់ជាតិ គឺជាឧបករណ៍សំខាន់សម្រាប់ផ្តល់ព័ត៌មាន អំពីលទ្ធផលសិក្សារបស់សិស្ស និងឆ្លុះបញ្ចាំងពីអាទិភាពកម្មវិធីសិក្សាថ្នាក់ជាតិ។ លទ្ធផលទាំងនេះជួយឱ្យអ្នកបង្កើតគោលនយោបាយអាចកំណត់តំបន់កែលម្អ ផ្តល់ធនធាន និងការកែសម្រួលគោលនយោបាយ។
- ការបង្កើតក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃមានសារៈសំខាន់សម្រាប់ការធានាគុណភាពអប់រំ និងប្រើប្រាស់ការវាយតម្លៃការសិក្សាថ្នាក់ជាតិជាសូចនាករ នេះនឹងធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាព លើកកម្ពស់ការកែទម្រង់ការអប់រំ និងជួយសម្រួលដល់ការកែលម្អជាបន្តបន្ទាប់នៅក្នុងប្រព័ន្ធអប់រំ។

## អង្គការមិនមែនរដ្ឋាភិបាល

- ការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល ការបណ្តុះបណ្តាលគ្រូ ការអប់រំបរិយាបន្ន និងការកែលម្អលទ្ធផលសិក្សារបស់សិស្ស ក៏ដូចជាជំរុញកិច្ចសហការក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ ដូចជារដ្ឋាភិបាល សាលារៀន និងសហគមន៍ នាំទៅរកគោលដៅរួម ការប្រមូលផ្តុំធនធាន និងការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាព។
- ការសម្របសម្រួលភាពជាដៃគូដោះស្រាយបញ្ហាប្រឈមផ្នែកអប់រំដ៏ស្មុគស្មាញ។ NGO ចូលរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវស្តង់ដាសាលារៀនគំរូ ណែនាំសាលារៀនដើម្បីបង្កើនការអនុវត្ត។
- កំណត់អត្តសញ្ញាណសិស្សដែលមានការលំបាកក្នុងការសិក្សា និងផ្តល់អន្តរាគមន៍ដូចជាសិស្សរៀនយឺត និងការគាំទ្របុគ្គលជាដើម។
- ជួយសាលារៀនក្នុងការរៀបចំសម្រាប់ការធ្វើតេស្តស្តង់ដា ការវាស់វែងវឌ្ឍនភាព និងការបង្កើតផែនការដើម្បីបង្កើនសមត្ថភាពអប់រំ។

- ដោះស្រាយតម្រូវការរបស់សិស្សដែលងាយរងគ្រោះ ឬកុមារមកពីគ្រួសារជួបការលំបាកគឺជាការផ្តោតសំខាន់។ ការផ្តល់អាហារូបករណ៍ជួយសម្រាលឧបសគ្គផ្នែកហិរញ្ញវត្ថុ ធានាបាននូវសិទ្ធិទទួលបានការអប់រំស្មើគ្នា។
- លើកកម្ពស់ការយល់ដឹង និងការគាំទ្រសម្រាប់គំនិតផ្តួចផ្តើម បង្កើនការចូលរួម និងភាពជាម្ចាស់ ផ្តល់ការបណ្តុះបណ្តាលដល់SMC និងCMC ជាដើម។ ការគាំទ្រនេះធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាព និងតម្លាភាពក្នុងចំណោមគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន មាតាបិតា និងសហគមន៍ និងការទទួលខុសត្រូវចំពោះលទ្ធផលសិក្សារបស់សិស្ស។

**ប្រព័ន្ធតាមដាន និងវាយតម្លៃដ៏រឹងមាំលើការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃគោលនយោបាយអប់រំ**

នៅកម្រិតខ្ពស់នៃការរៀនសូត្រ ប្រព័ន្ធទូលំទូលាយ និងរចនាសម្ព័ន្ធត្រូវបានទាមទារដើម្បីអនុវត្តគោលនយោបាយ ផែនការសកម្មភាព ច្បាប់ ការបែងចែកធនធាន និងការវាស់វែងលទ្ធផល។ នេះទាមទារឱ្យមានប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដ៏រឹងមាំ ដើម្បីតាមដានវឌ្ឍនភាព កំណត់តំបន់កែលម្អ និងជូនដំណឹងអំពីការកែសម្រួលគោលនយោបាយ។ ការត្រួតពិនិត្យ និងការវាយតម្លៃប្រកបដោយប្រសិទ្ធភាពអាចជួយកំណត់រកមូលហេតុ ឫសគល់នៃការបាត់បង់ការសិក្សា និងអវត្តមាន ហើយជូនដំណឹងអំពីអន្តរាគមន៍គោលដៅ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ សូចនាករ ឬក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃខាងក្រោមអាចត្រូវបានពិចារណានៅកម្រិតសាលា៖ ១.ការវាយតម្លៃការសិក្សារបស់សិស្ស ២. ទិន្នន័យវត្តមាន ៣.សូចនាករការអនុវត្តរបស់គ្រូ និង៤.សូចនាករកម្រិតសាលារៀន។

## កិច្ចពិភាក្សាតាមដំណោះស្រាយ

### កិច្ចពិភាក្សាដំណោះស្រាយទី១

*ការលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីរបស់សាលារៀនដើម្បីពង្រឹងលទ្ធផលសិក្សារបស់សិស្ស (ការចូលរួមរបស់NGO សាលារៀន អាជ្ញាធរមូលដ្ឋាន ឪពុកម្តាយ និងសហគមន៍)*

សម្របសម្រួលដោយ៖ លោក ឡុង ស៊ីណា ប្រធានកម្មវិធីតស៊ូមតិ និងភាពដៃគូ អង្គការ UWS

វាគ្មិនទី១៖ លោក អឿន បូរ៉ា ប្រធានគម្រោងកម្មវិធីកុមារកម្ពុជារីករាយ អង្គការ KAPE

វាគ្មិនទី២៖ លោក សន សៅអួន នាយកសាលាបឋមសិក្សាសែងម៉ា ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង

វាគ្មិនទី៣៖ លោក ហង់ សំណាង ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង

វាគ្មិនទី៤៖ លោក ស សារិន អនុប្រធាននាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ ក្រសួងអប់រំ យុវជន និងកីឡា

វាគ្មិនទី៥៖ លោក អ៊ុត សារ៉ង នាយកផ្នែកការគ្រប់គ្រងតាមសាលារៀន អង្គការ Save the Children

| លទ្ធផលនៃកិច្ចពិភាក្សា | |
|---|---|
| សំណួរទៅ លោក ស សារិន អនុប្រធាននយកដ្ឋាន EQID<br><br>សូមលោកជួយបង្ហាញពីលទ្ធផលនៃការវាយតម្លៃនានា ជាពិសេសលទ្ធផល | លោក ស សារិន៖ ជាក់ស្តែង ក្រសួងបានរៀបចំជាក្របខណ្ឌវាយតម្លៃលទ្ធផលសិក្សាសិស្សកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ ដែលបានដាក់ឱ្យអនុវត្តចាប់តាំងពីខែមិថុនាឆ្នាំ២០១៨។ ប៉ុន្តែដោយសារតែបញ្ហាកូវីដ១៩ ទើបមិនបានផ្សព្វផ្សាយជាផ្លូវការទូលំទូលាយទេ ដោយបានត្រឹមខិតខំផ្សព្វផ្សាយក្រៅផ្លូវការ។<br><br>ដើម្បីឱ្យប្រាកដថា ការខិតខំរបស់យើងជាមួយនឹងសិស្សនៅកម្រិតសាលារៀន ថាយើងកំពុងតែបង្រៀនសិស្សប្រកបដោយគុណភាពពិតប្រាកដ មិនមែនតែគ្រាន់តែការបញ្ចប់ |

| | |
|---|---|
| តេស្តថ្នាក់តំបន់ ឬតេស្តអន្តរជាតិ ដែលប្រទេសកម្ពុជាបាននឹងកំពុងអនុវត្ត ថាតើសិស្សរបស់កម្ពុជា ទទួលបានលទ្ធផលយ៉ាងដូចម្តេចដែរ? | មេរៀនតាមសៀវភៅសិក្សាគោលតែប៉ុណ្ណោះទេ។ ក្រសួងមានវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សខ្ពស់បំផុតរបស់ប្រព័ន្ធអប់រំ គឺប្រឡងបាក់ឌុប។ ដើម្បីធានាបាននូវជោគជ័យ ក្រសួងបានរៀបចំបង្កើតជាវង្វាយតម្លៃទ្រង់ទ្រាយធំកម្រិតប្រព័ន្ធ គឺជាការវាយតម្លៃដើម្បីឆ្លុះបញ្ចាំង និងផ្តល់កិច្ចអន្តរាគមន៍សម្រាប់ជួយសិស្សទាន់ពេលវេលា ដែលមានវង្វាយតម្លៃកម្រិតថ្នាក់តំបន់SEA-PLM សម្រាប់សិស្សថ្នាក់ទី៥ និងកម្រិតអន្តរជាតិ PISA ដែលធ្វើទៅលើកុមារអាយុ ១៥ឆ្នាំ ពីថ្នាក់ទី៧ ដល់ ថ្នាក់ទី១២។ យើងក៏មានវង្វាយតម្លៃកម្រិតថ្នាក់ជាតិរៀងរាល់ ៤ឆ្នាំម្តង។ ដោយសារតែការវាយតម្លៃច្រើនពេក យើងមិនមានពេលដើម្បីយកវង្វាយតម្លៃនោះ ទៅប្រើឱ្យបានគ្រប់ជ្រុងជ្រោយ និងជួយសិស្សឱ្យមានប្រសិទ្ធិភាពខ្ពស់នៅកម្រិតថ្នាក់រៀន និងសាលារៀន យើងបានផ្អាកចាប់តាំងពីឆ្នាំ ២០២៣។ បន្តមក យើងមានវង្វាយតម្លៃកម្រិតថ្នាក់ដំបូងផ្នែកអំណាន និងគណិតវិទ្យា ដែលជាវង្វាយតម្លៃកម្រិតប្រព័ន្ធ ដើម្បីវិភាគអំពីបញ្ហាផ្សេងៗ ដែលជាមូលដ្ឋានក្នុងកិច្ចអន្តរាគមន៍ជួយគ្រូ និងប្រព័ន្ធអប់រំទាំងមូលទាន់ពេលវេលា មុនបញ្ជូនឱ្យសិស្សទៅបញ្ចប់ថ្នាក់ទី១២ ដោយជោគជ័យ ហើយក៏វាជាគុណតម្លៃនៃប្រព័ន្ធអប់រំកម្ពុជាធៀបជាមួយនឹងស្តង់ដាជាតិ តំបន់ និងអន្តរជាតិ។<br><br>វង្វាយតម្លៃនៅកម្រិតសាលារៀន យើងមានជាការប្រឡងឆមាស វង្វាយតម្លៃកម្រិតថ្នាក់រៀនគឺផ្តោតទៅលើការប្រឡងប្រចាំខែ និងការវាយតម្លៃជាប្រចាំរៀងរាល់ម៉ោងសិក្សាទាំងអស់ ដើម្បីកសាងប្រព័ន្ធវាយតម្លៃមួយមានលក្ខណៈ ពេញលេញ គ្រប់ជ្រុងជ្រោយ ហើយមានភាពប្រទាក់ក្រឡាគ្នាចាប់តាំងពីថ្នាក់រៀន សាលារៀន រហូតទៅដល់ការវិភាគកម្រិតប្រព័ន្ធ និងឈានចូលការប្រឡងបញ្ចប់ថ្នាក់ទី១២ ដោយជោគជ័យ។<br><br>ដោយឡែក លទ្ធផលសង្ខេបនៃការអនុវត្តតេស្តថ្នាក់តំបន់SEA-PLM ដែលកម្ពុជាបានគឺយើងចូលរួមចាប់តាំងពីឆ្នាំ២០១៩ មក ដែលជាជុំទី១ ដែលមាន ៦ប្រទេស។ ការចូលរួមក្នុងការធ្វើតេស្តវាយតម្លៃថ្នាក់តំបន់គោលបំណងសំខាន់ គឺទទួលបានទៅទិន្នន័យច្បាស់លាស់ ដើម្បីពិនិត្យ តាមដាន និងដើម្បីដឹងពីកម្រិតយល់ដឹងរបស់សិស្សនៅផ្នែកអំណាន សំណេរ គណិតវិទ្យា និងភាពជាពលរដ្ឋសកល ដើម្បីផ្តល់នូវកិច្ចអន្តរាគមន៍ស្របតាម ស្តង់ដាអប់រំកម្រិតថ្នាក់តំបន់។ យើងក៏អាចពង្រឹងសមត្ថភាពក្រុមការងារថ្នាក់ជាតិ គឺក្រុមការងារអនុវត្តតេស្តថ្នាក់ក្រសួង ហើយក្រុមការងារតេស្តថ្នាក់ក្រសួង មានសមត្ថភាពអនុវត្តតេស្តថ្នាក់ជាតិរបស់ខ្លួន ក៏ដូចជាមានសមត្ថភាពពង្រឹងប្រព័ន្ធវង្វាយតម្លៃទាំងថ្នាក់រាជធានីខេត្ត ក៏ដូចជាសាលារៀនផងដែរ។ ចុងក្រោយគឺយើងនឹងប្រើប្រាស់លទ្ធផលដែលទទួលបានពីការវាយតម្លៃ ដើម្បីជាមូលដ្ឋានក្នុងការកែលម្អប្រព័ន្ធអប់រំកម្រិតតំបន់អាស៊ីអាគ្នេយ៍តែម្តង។ កម្ពុជាបានរើសសាលារៀនសំណាកចំនួន ១៧៧ ហើយមានសិស្សចូលរួមសរុបប្រមាណជា ៥,៣៦៦នាក់ គ្រូបង្រៀន ៣៨០នាក់ និងមាតាបិតាសិស្សជាង៥០០០នាក់ ចូលរួមក្នុងដំណើរការធ្វើតេស្តនេះ។ ជាលទ្ធផលកម្ពុជាទាំង |

| | |
|---|---|
| | ផ្នែកអំណាន សំណេរ និងគណិតវិទ្យា យើងទទួលពិន្ទុ មិនបានដល់មធ្យមភាគសម្រាប់តំបន់អាស៊ាន ដែលទាបបំផុត ៣០០ពិន្ទុ នៅក្នុងមុខវិជ្ជានីមួយៗ។ ប៉ុន្តែយើងនៅខ្វះតែបន្តិចបន្តួចប៉ុណ្ណោះ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងកន្លងមក ជាពិសេសការចូលរួមនៅឆ្នាំ២០២៤នេះ ដែលបានអនុវត្តជុំទី២ លទ្ធផលប្រហែលជាមានការប្រែប្រួលប្រសើរ។ |
| សំណួរទៅ លោក អឿន បូរ៉ា<br>សូមលោក ជួយចែករំលែកបទពិសោធន៍ និងការអនុវត្តល្អដែលអង្គការ អ្នកបានអនុវត្ត ក្នុងការជំរុញការធ្វើការរួមគ្នារវាងអង្គការក្រៅរដ្ឋាភិបាល/ដៃគូ សាលារៀន អាជ្ញាធរ អ្នកអាណាព្យាបាល និងសហគមន៍ ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស? មុនពេលឆ្លើយសំណួរនេះ សូមលោកជួយពន្យល់បន្តិចថាតើអ្វីជាប្រព័ន្ធអេកូឡូស៊ីសាលារៀន (School Ecosystem) | លោក បូរ៉ា៖ ប្រព័ន្ធអេកូឡូស៊ី សំដៅទៅលើអន្តរទំនាក់ទំនងភាគីពាក់ព័ន្ធជាមួយនឹងសាលារៀន ដែលមានឪពុកម្តាយ អ្នកអាណាព្យាបាល សហគមន៍ អាជ្ញាធរ ឱ្យឆ្លើយតបជាមួយតបទៅនឹងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាគោលនយោបាយ។ ដើម្បីអាចធ្វើអេកូឡូស៊ីសាលារៀនបាន យើងត្រូវមើលថា តើអេកូឡូស៊ីនោះ ជាគោលនយោបាយអ្វី? ឧទាហរណ៍ ជាគោលនយោបាយសាលារៀនជំនាន់ថ្មី ស្តង់ដាសាលារៀនគំរូ ឬក៏គោលនយោបាយណាមួយដែលយើងកំពុងតែចាប់ផ្តើម ឬក៏យើងកំពុងតែធ្វើ។ គោលនយោបាយទាំងនេះ សាលារៀនបានធ្វើរួចមកហើយ ប៉ុន្តែយើងមិនបានភ្ជាប់ទំនាក់ទំនងមានន័យថា អន្តរទំនាក់ទំនងមានសារៈសំខាន់ណាស់។ តើសាលារៀនត្រូវភ្ជាប់ទំនាក់ទំនងជាមួយនឹងអាណាព្យាបាល ឬអាជ្ញាធរយ៉ាងដូចម្តេច ជាមួយនឹងប្រព័ន្ធរបស់ខ្លួនដើម្បីឱ្យសាលារៀនមានដំណើរការល្អ? ប្រសិនយើងនិយាយអំពីអេកូឡូស៊ី យើងត្រូវក្រឡេកមកមើលអ្វីជាអេកូឡូស៊ី? ក្នុងប្រព័ន្ធធម្មជាតិ គឺមានភាវៈមានជីវិត អត់ជីវិត ប៉ុន្តែវាមានទំនាក់ទំនងគ្នាដើម្បីកសាងបរិស្ថានមួយ។ ការងារសាលារៀនក៏ដូចគ្នា វាត្រូវកសាងឱ្យមានទំនាក់ទំនងទៅវិញទៅមក ធានាបាននូវនិរន្តរភាពនៃការងារ ការអប់រំ និងដំណើរការសាលារៀន។ គ្រាន់តែសាលារៀនមានដំណើរការល្អ គឺមិនទាន់គ្រប់គ្រាន់ទេ។ យើងនិយាយអំពីលទ្ធផលសិក្សារបស់សិស្ស ដូចនេះយើងត្រូវឆ្លុះបញ្ចាំងមួយទៀតលើអេកូឡូស៊ីគរុកោសល្យ។ តើគ្រូមានសមត្ថភាពដែរឬទេ? តើគ្រូទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ និងមានគុណវុឌ្ឍិដែរឬនៅ? ទោះបីជាគ្រូកិច្ចសន្យា ឬគ្រូពេញសិទ្ធិ។ ក្រឡេកមើលហេដ្ឋារចនាសម្ព័ន្ធសាលារៀន តើបានគាំទ្រទៅលើគរុកោសល្យឬទេ? តើមានបន្ទប់បង្រៀន បន្ទប់កុំព្យូទ័រ បណ្ណាល័យ បន្ទប់ពិសោធន៍ គ្រប់គ្រាន់ឬទេ? តើមានប្រព័ន្ធវាយតម្លៃច្បាស់លាស់ ដើម្បីវាយតម្លៃពីដំណើរការ និងប្រសិទ្ធិភាពដែរឬទេ? នេះជាការទំនាក់ទំនង និងអត្ថន័យរបស់អេកូឡូស៊ីសាលារៀន។<br><br>ក្រឡេកមកថា តើធ្វើដូចម្តេចដើម្បីឱ្យសហគមន៍មានការចូលរួម? ការចាប់ផ្តើមការអនុវត្តពិតជាលំបាក។ ដូចនេះយើងត្រូវមានកិច្ចព្រមព្រៀងជាមួយឃុំ និងសាលារៀន ដើម្បីធានាបាននូវការចូលរួមរបស់ពួកគាត់។ ឧទាហរណ៍ ឃុំត្រូវវិភាជថវិកាជាមួយគម្រោង។ តើសាលារៀននឹងត្រូវចូលរួមបដិភាគយ៉ាងដូចម្តេច? សម្រាប់អាណាព្យាបាលគឺត្រូវមានការប្រជុំ ដើម្បីភ្ជាប់ទំនាក់ទំនងល្អ ដោយត្រូវមានភាគីទី៣ ដឹកនាំការប្រជុំ ចុះមូលដ្ឋាន និងឱ្យសហគមន៍យល់ពីគោលបំណង និងសារៈសំខាន់នៃការចូលរួមរបស់គាត់។ |

| | |
|---|---|
| សំណួរទៅ លោក អ៊ុត សារ៉ែង នាយកផ្នែកការគ្រប់គ្រងតាមសាលារៀន អង្គការ SCI<br><br>សូមលោក ជួយចែករំលែកបទពិសោធន៍ល្អ អំពីការគ្រប់គ្រងតាមសាលារៀន តើសាលារៀន ត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីឱ្យមានការចូលរួមល្អពីគ្រប់ភាគីពាក់ព័ន្ធនៅក្នុងដំណើរការសម្រេចចិត្តរបស់សាលារៀន។ | លោក សារ៉ែង៖ លោកលើកយកជាបទពិសោធន៍។ ជាធម្មតា នៅពេលដែលយើងចង់ឱ្យដំណើរការវិមជ្ឈការ ឬវិសហមជ្ឈការ ចូលទៅដល់សហគមន៍ លុះត្រាមានសហគមន៍ចូលរួម នៅក្នុងដំណើរការសម្រេចចិត្តរបស់សាលារៀន ដែលជាធាតុសំខាន់បែបការចូលរួមនៅក្នុងកម្រិតអាចកើតឡើង។ តែយើងឃើញថា កម្រណាស់ដែលតំណាងសហគមន៍ ចូលទៅសាលារៀនសួរអំពីការសម្រេចចិត្ត និងការចូលរួមរបស់គាត់ ឬការចំណាយ ថាបានឆ្លងកាត់ពីពួកគាត់ឬទេ? យើងត្រូវសួរថា តើមានឧបសគ្គអ្វីខ្លះ ដែលពិបាកឱ្យមានការចូលរួមពីពួកគាត់? នៅបរទេស ដោយសារគេមានធនធានមនុស្សល្អ អាចជាតំណាងរាស្ត្រ វិស្វករ វេជ្ជបណ្ឌិត ឬអ្នករកស៊ី មាននៅក្នុងក្រុមប្រឹក្សាសាលារៀន ទើបធ្វើឱ្យដំណើរការល្អ។ ប៉ុន្តែយើងមិនទាន់មានធនធានដូចនេះទេ។ ដើម្បីឱ្យគាត់អាចចូលមកសាលារៀននៅក្នុងដំណើរការសម្រេចចិត្តបាន លុះណាយើងមានយន្តការអ្វីមួយ ទើបគាត់អាចចូលមកបាន។ យន្តការនេះ គឺសំដៅទៅលើថា តើគាត់ចូលមកតាមរយៈមធ្យោបាយអ្វី? តាមបទពិសោធន៍ដែលយើងបានធ្វើ ក្រសួង ក៏បានធ្វើតាំងពីដើមមក គឺមានគណៈកម្មការទ្រទ្រង់សាលារៀន ប៉ុន្តែភាគច្រើនគឺគណៈកម្មការនោះ បានត្រឹមតែជាអ្នកជួយសាលារៀនលើការកែលម្អបរិស្ថាន។ សម្រាប់ការសម្រេចចិត្តរបស់សាលារៀនគឺបានតិចតួចប៉ុណ្ណោះ។ ដូចនេះបានជា ក្រសួង បានចេញសេចក្ដីណែនាំលេខ៤៩ ស្ដីអំពី ការបង្កើត និងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន(SMC)។ បើយើងឃើញជាក់ស្ដែងទៅគឺ ការបង្កើតSMCនេះ គឺចង់ឱ្យធ្វើយ៉ាងណាឱ្យសាលារៀនមានដំណើរការគ្រប់គ្រងមួយដែលមានការចូលរួមពីតំណាងអ្នកពាក់ព័ន្ធ ដើម្បីចូលជាគណៈកម្មការមួយដែលហៅថាSMC។ ប៉ុន្តែ ប្រសិនយើងទៅមើលជាក់ស្ដែង មិនមែនមានន័យថាសាលារៀនទាំងអស់ឱ្យតែបង្កើតSMC រួចហើយគាត់អាចដំណើរការបាននោះទេ។ លោកសង្ខេបឡើងវិញថា ជារួមយើងត្រូវ៖ ទី១.ត្រូវមានយន្តការក្នុងការចូលរួម ប្រសិននៅកម្រិតសាលារៀនគឺគណៈកម្មការគ្រប់គ្រងសាលារៀន និងកម្រិតថ្នាក់រៀន គឺគណៈកម្មការគ្រប់គ្រងថ្នាក់រៀន។ ទី២.ត្រូវឱ្យគាត់ចូលរួមក្នុងដំណើរការសម្រេចចិត្ត មិនថាគោលនយោបាយសាលារៀន ឬសកម្មភាព គឺគាត់មិនទាន់មានផែនការ។ និងទី៣.ត្រូវបំប៉នសមត្ថភាពគាត់ដោយសាលារៀន មាននាយកសាលា មានគ្រូបង្រៀនត្រូវជួយនៅក្នុងដំណាក់កាលចាប់ផ្ដើម ដូចជាការបំប៉នសមត្ថភាព ការសម្របសម្រួលការប្រជុំជាដើម ប៉ុន្តែមិនត្រូវសម្រេចចិត្តជំនួសគាត់ឡើយ។<br><br>ជាចុងក្រោយ លោកចែករំលែកបទពិសោធន៍ជាក់ស្ដែងពីសាលារៀនមួយ ដែលបានបង្កើតSMCរួច និងបានអញ្ជើញពួកគាត់មកប្រជុំបានតែមួយដង ក្រោយមកពួកគាត់លែងមកប្រជុំ។ លោកលើកឡើងពីមូលហេតុថា ដោយសារតែក្រោយការបង្កើតគឺមិនបានបង្រៀន និងប្រាប់ពីតួនាទីភារៈកិច្ចរបស់SMCមានអ្វីខ្លះ? តើមានប្រយោជន៍អ្វីខ្លះ? ហើយមិនបាននាំគាត់ស្វែងយល់ទេ។ ទន្ទឹមនឹងនេះ នាំពួកគាត់ដដែកពីបដិភាគ និងការចូលជាថវិកា។ តាមការសង្កេត នៅពេលចាប់ផ្ដើមដំបូងនិយាយពីបញ្ហានេះ គឺ |

| | |
|---|---|
| | ពួកគាត់ចាប់ផ្តើមដកខ្លួនថយ ដោយសារពួកគាត់មិនទាន់បានយល់ និងក្លាយជាអ្នកសម្រេចចិត្តរួមគ្នានោះទេ។ ដូចនេះយើងត្រូវធ្វើឱ្យគាត់យល់ពីអ្វី ដែលយើងត្រូវដើររួមគ្នា មុននឹងចាប់ផ្តើមនិយាយពីថវិកា និងការរួមគ្នាសម្រេចចិត្ត។ |
| សំណួរទៅ<br>លោក ហង់ សំណាង<br>តើការិយាល័យអប់រំ យុវជន និងកីឡាស្រុក នឹងធ្វើយ៉ាងដូចម្តេច ដើម្បីអនុវត្តសេចក្តីណែនាំ និងគោលនយោបាយ ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស? | លោក ហង់ សំណាង ៖ ដើម្បីអនុវត្តសេចក្តីណែនាំ និងគោលនយោបាយ ដើម្បីលើកកម្ពស់លទ្ធផលសិក្សា គឺត្រូវផ្តោតលើលទ្ធភាពដែលយើងបាន និងកំពុងធ្វើ ដោយត្រូវពង្រឹង និងលើកកម្ពស់សមត្ថភាពរបស់នាយកនាយិកា នៅកម្រិតសាលារៀនដើម្បីឱ្យគាត់មានសមត្ថភាពពេញលេញ មានស្វ័យភាពម្ចាស់ការ ក្នុងការគ្រប់គ្រងដឹកនាំការបង្រៀនការគ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិក ក៏ដូចជាហិរញ្ញវត្ថុ។ ការធ្វើដូចនេះបាននឹងធ្វើឱ្យការសិក្សារៀនសូត្ររបស់សិស្សនៅក្នុងសាលារៀននោះ គឺមានភាពល្អប្រសើរ។<br><br>មួយទៀត ការណែនាំរបស់ក្រសួងគឺការធ្វើតេស្តស្តង់ដា ថ្នាក់ទី៣ ទី៦ជាដើម ដោយត្រូវអនុវត្តតាមការណែនាំ និងយកលទ្ធផលទាំងនោះមកធ្វើផែនការ។ សម្រាប់គ្រូបង្រៀនគឺផែនការសម្រាប់ការបង្រៀនដើម្បីកែលម្អការសិក្សា និងកែលម្អលទ្ធផលសិក្សារបស់សិស្សនៅខែបន្តបន្ទាប់។ សម្រាប់កម្រិតសាលារៀន គឺត្រូវបញ្ចូលលទ្ធផលទាំងនោះទៅក្នុងផែនការប្រតិបត្តិ ឬផែនការអភិវឌ្ឍរបស់សាលារៀន។ នៅកម្រិតការិយាល័យអប់រំគឺត្រូវពង្រឹង វិន័យរបស់គ្រូបង្រៀន គ្រូបង្រៀនត្រូវមានវិន័យ ធានាបាននូវការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ ធ្វើកិច្ចតែងការ និងត្រូវរៀបចំសម្ភារៈបង្រៀន និងប្រើប្រាស់សម្ភារៈឧបទេស ធ្វើបំណែងចែក និងអនុវត្តផែនការបង្រៀនឱ្យបានច្បាស់លាស់។ ប្រសិនបើសិស្សរៀនយឺត ការិយាល័យត្រូវឱ្យគ្រូបង្រៀន រៀបចំផែនការជួយសិស្សរៀនយឺតដោយផ្អែកលើភាសាខ្មែរ និងគណិតវិជ្ជា។ ចំពោះផ្នែកសមត្ថភាព យើងចង់ឱ្យគ្រូបង្រៀនមានសមត្ថភាពពេញលេញ និងទូលំទូលាយ។ គ្រូបង្រៀនត្រូវតែចេះសិក្សាស្រាវជ្រាវបន្ថែម ជាពិសេសអនុវត្តវិធីសាស្ត្រថ្មីៗដើម្បីគាំទ្រការបង្រៀនឱ្យកាន់តែប្រសើរ។ យើងតែងតែជំរុញលើកទឹកចិត្តគ្រូរៀនភាសាអង់គ្លេស ICT និងបច្ចេកវិទ្យាដែលជាមូលដ្ឋានឱ្យគាត់មានសមត្ថភាពធ្វើការងារប្រចាំថ្ងៃផង និងសិក្សាស្រាវជ្រាវបន្ថែមផងដើម្បីអភិវឌ្ឍខ្លួន។ ជាមួយគ្នានេះ នៅកម្រិតការិយាល័យ គឺគិតគូរពីការបំប៉ន ពីព្រោះនៅគ្រឹះស្ថានបឋមសិក្សានៅស្រុកនេះទាំងអស់ គឺមានប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា។ លទ្ធភាពរបស់មន្ត្រីគឺអាចបំប៉នបានម្តង ឬពីរដង ដោយសារមានមន្ត្រីតិច។ ប៉ុន្តែឆ្នាំក្រោយនេះ យើងគ្រោងឱ្យបាន៣ដង ដើម្បីឱ្យសម្រេចបាននូវគោលនយោបាយរបស់ក្រសួង។ មួយទៀតគឺយើងគិតពីដំណើររបស់កម្រង ដែលជាយន្តការល្អ ព្រោះកម្រងនៅជិត ដែលងាយស្រួលចែករំលែក និងជួយគ្នាទៅវិញទៅលើបទពិសោធន៍ និងការងារបច្ចេកទេស ជាពិសេសតាមរយៈការប្រជុំបច្ចេកទេស។ យើងប្រឹងប្រែងឱ្យកកម្រងដើរ ដើម្បីឱ្យគាត់ជួយសាលារៀននៅក្នុងគម្រោងរបស់ខ្លួន។ យើងក៏បានគិតគូរអំពីសេចក្តីណែនាំរបស់ក្រសួង ក្នុងការអនុវត្តម៉ោងបន្ថែម ក៏ដូចជាការរៀនពេញមួយថ្ងៃ ឬថ្នាក់បំប៉ន ដោយធ្វើ |

| | |
|---|---|
| | ទៅតាមលទ្ធភាពដែលអាចធ្វើបាន។ លទ្ធផលដែលទទួលបានគឺសាលារៀនត្រូវបញ្ចូលក្នុងផែនការសាលារៀន AOP ដើម្បីឱ្យឆ្លើយតបជាមួយលទ្ធផលសិក្សា។<br><br>សម្រាប់ថ្នាក់ការិយាល័យអប់រំស្រុកសៀមប៉ាង។ យើងបានរៀបចំការប្រលងសិស្សពូកែថ្នាក់ស្រុកផ្នែកភាសាខ្មែរ និងគណិតវិទ្យាជាច្រើនឆ្នាំហើយ ចាប់ពីថ្នាក់ទី២ ដល់ថ្នាក់ទី៦ ដើម្បីបង្ហាញឱ្យឃើញថាសិស្សដែលរៀនជាប់លេខ១ តាមសាលារៀន មានសមត្ថភាពយ៉ាងដូចម្តេច។ ការិយាល័យ ជាអ្នករៀបចំតេស្ត ហើយយកមកប្រលងថាឆ្លើយតបយ៉ាងណាដែរចំពោះគុណភាពនៃការបង្រៀន និងគុណភាពរបស់គ្រូ ដើម្បីចងក្រងទិន្នន័យបង្ហាញដល់សាលារៀន ដើម្បីរៀបចំផែនការសម្រាប់ឆ្នាំបន្តទៀត ដើម្បីឱ្យលទ្ធផលសិក្សាបានកាន់តែប្រសើរ។ នៅកម្រិតការិយាល័យក៏បានគិតគូរដល់លទ្ធភាពធ្វើតេស្តថ្នាក់ទី៣ និងទី៦ដែរ។ ប៉ុន្តែដោយមិនមានលទ្ធភាពធ្វើបានច្រើនសាលារៀន យើងអាចធ្វើពីរ ឬបីសាលារៀនក្នុងមួយឆ្នាំ សម្រាប់ជាមូលដ្ឋានផ្តល់អនុសាសន៍ ក៏ដូចជាជំរុញឱ្យសាលារៀនគិតគូរពីលទ្ធផលសិក្សារបស់សិស្ស។ ការិយាល័យក៏បានជំរុញក្នុងការប្រើប្រាស់ថ្នាលបឋម ដើម្បីជួយដល់គ្រូ សិស្ស និងឪពុកម្តាយផងដែរ ដែលជាយន្តការសំខាន់មួយក្នុងការលើកកម្ពស់គុណភាពអប់រំ។ សម្រាប់ការិយាល័យ គឺតែងយកលទ្ធផលសិក្សាដែលយើងទទួលបាននេះ មកបូកសរុបឆ្លុះបញ្ចាំងលើចំណុចខ្វះខាតរបស់គ្រូដែលគាត់ធ្វើមិនទាន់បានល្អ ដើម្បីកំណត់ទិសដៅឱ្យគាត់ដើម្បីកែលម្អឡើងវិញ។ |
| សំណួរទៅ<br>លោក សន សៅអួន<br><br>តើមានបញ្ហាប្រឈមសំខាន់អ្វីខ្លះដែលអ្នកជួបប្រទះក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស? | លោក សៅអួន ៖ សាលារៀនរបស់លោក បញ្ហាប្រឈមសំខាន់ក្នុងការលើកកម្ពស់លទ្ធផលរបស់សិស្សមាន៖ ទី១.ការចូលរួមរបស់មាតាបិតា និងសហគមន៍។ ដោយសារពួកគាត់គឺជាអ្នកដែលនៅជាមួយកុមារច្រើន ដូចនេះ គាត់ត្រូវមានតួនាទីសំខាន់ក្នុងការចូលរួម។ ប៉ុន្តែដោយសារតែភូមិសាស្ត្រ មាតាបិតាគឺគាត់មិនចេះអក្សរ ដែលនាំឱ្យការចូលរួមរបស់គាត់ គឺបានត្រឹមដាស់តឿនកូនក្នុងការមកសិក្សា និងពេលទៅផ្ទះវិញ ថាកូនបានធ្វើលំហាត់ឬអត់ ឬមានកិច្ចការផ្ទះឬទេ។ សំខាន់មួយទៀតគឺសហគមន៍ គឺជាអ្នកត្រូវចូលរួមដូចគ្នា ព្រោះសហគមន៍តួយ៉ាងដ៏សំខាន់សម្រាប់សិស្សគាត់បានយកជាគំរូតាម។<br><br>ទី១ គឺកត្តាជីវភាព។ មាតាបិតាមានជីវភាពលំបាក។ នៅពេលខែដកដំឡូង គាត់យកកូនគាត់ទៅជួយធ្វើការ។ ហើយដល់ពេលចប់ខែដំឡូង ឥឡូវចូលខែចន្ទីម្តង គាត់យកកូនគាត់ទៅជួយធ្វើការទៀត ឬយកទៅខេត្តផ្សេងទៅជួយធ្វើការ ដែលធ្វើឱ្យធ្វើអវត្តមានច្រើន ដែលនាំឱ្យការធ្វើកិច្ចការងារផ្ទះ និងការប្រឡងមិនបានលទ្ធផលល្អ ឬក៏ធ្លាក់។<br><br>មួយទៀត ទាក់ទងនឹងខ្វះអាហារូបត្ថម្ភ។ ដោយសារតែនៅភូមិជីវភាពក្រីក្រ ការហូបចុករបស់គាត់ គឺមិនបានល្អ ធ្វើឱ្យទាំងរាងកាយ និងការរីកចម្រើនផ្នែកស្មារតី ឬបញ្ញារបស់គាត់ក៏ចុះខ្សោយដែរ។ |

| | |
|---|---|
| | បន្ទាប់មកទៀត គឺទាក់ទងនឹងធនធានសាលារៀនៈ សំដៅដល់ថវិកាសាលារៀន។ ដោយសារតែសាលារៀន មានសិស្សតិចទេ ព្រោះនៅតាមព្រៃ។ ជាក់ស្ដែងឆ្នាំនេះ លោកលើកឡើងថា មានសិស្សតែចំនួន ៤៣នាក់។ សិស្សមានចំនួនតិចមែន ប៉ុន្តែលទ្ធផលនៅតែមានសិស្សធ្លាក់ដោយសារមូលហេតុខាងលើនេះ។<br><br>ក្រសួងអប់រំ បានដាក់ឱ្យមានការប្រើប្រាស់ថ្នាលបឋម ដែលត្រូវប្រើបច្ចេកវិទ្យា និងអ៊ីនធឺណិត។ ប៉ុន្តែនៅក្នុងភូមិមិនមានអ៊ីនធឺណិត មិនមានភ្លើង និងមិនមានទូរសព្ទ។ ដូចនេះការប្រើប្រាស់ថ្នាលបឋម គឺមិនអាចដំណើរការបានទេ។<br><br>បញ្ហាមធ្យោបាយ និងស្ថានភាពការធ្វើដំណើរ។ ខែប្រាំង ផ្លូវអាចធ្វើដំណើរបានធម្មតា ប៉ុន្តែដល់ខែវស្សា អ្នកដែលមកពីខាងទន្លេ គាត់មិនហ៊ានយកកូនគាត់មកទេ ខណៈដែលកូនគាត់មកខ្លួនឯងក៏មិនបាន។ អ្នកនៅឆ្ងាយគឺផ្លូវបួនគីឡូម៉ែត។ នៅពេលខែភ្លៀងគឺមកអត់បានដូចគ្នា។ ហេតុនេះ មធ្យោបាយធ្វើដំណើរគឺសំខាន់ដូចគ្នា។<br><br>ទាក់ទងនឹងសមត្ថភាពគ្រូបង្រៀនៈ សំដៅទាំងគ្រូរដ្ឋ និងគ្រូកិច្ចសន្យា។ គ្រូកិច្ចសន្យាគឺគាត់បានចូលរួមបង្រៀនមួយឆ្នាំ ហើយគាត់បានបំប៉នតែមួយឆ្នាំ ដែលមិនដូចជាការរៀននៅសាលាគរុកោសល្យ ២ឆ្នាំ ឬ ៤ឆ្នាំ ដែលនាំឱ្យសមត្ថភាពគាត់នៅមានកម្រិត។ |
| សំណួរទៅ លោក ស សារិន<br><br>តើយើងប្រើប្រាស់លទ្ធផលសិក្សារបស់សិស្សយ៉ាងដូចម្ដេច ដើម្បីកែលម្អលទ្ធផលសិក្សារបស់គាត់ឱ្យកាន់តែល្អ? ហើយសូមចែករំលែកថាតើក្រសួងមានសកម្មភាពអាទិភាពអ្វីខ្លះដើម្បីជំរុញកិច្ចការងារនេះឱ្យកាន់តែល្អ? | លោក សារិនៈ ជាការពិត ការធ្វើតេស្ត មិនមែនសម្រាប់ការចាត់ចំណាត់ថ្នាក់ថា ប្រទេសនេះល្អ ប្រទេសនោះអន់ ឬបង្ហាញថាប្រទេសណាល្អប្រសើរជាងគេឡើយ។ ប៉ុន្តែ វាគឺជាមូលដ្ឋានសម្រាប់ការកែលម្អ។ ការនាំយកលទ្ធផលតេស្ត មកបំលែងទៅជាសកម្មភាពអន្តរាគមន៍ ដើម្បីកែលម្អនោះ វាជារឿងមួយដែលពិតជាលំបាកណាស់។ មិនមែនមានតែប្រទេសកម្ពុជាប៉ុណ្ណោះទេ ដែលជួបបញ្ហានេះទេ។ ប្រទេសជុំវិញពិភពលោកក៏ជួបបញ្ហានេះដែរ។ ពួកគេក៏បំលែងលទ្ធផលតេស្ត ទៅជាចលនាកែលម្អក៏ការលំបាកដូចគ្នា។ យើងត្រូវយល់ថាតេស្តតែមួយមុខ មិនអាចកំណត់អនាគតសិស្សបានទេ។ វាជាឧបករណ៍សំខាន់ដើម្បីយល់ពីបញ្ហា និងផ្ដល់ឱកាសសម្រាប់ការកែលម្អក្នុងប្រព័ន្ធអប់រំ។ ជាសំណាងល្អសម្រាប់កម្ពុជា មានការប្រែប្រួលកើតឡើង។ យើងបានឃើញក្រុមការងារនានា បានបញ្ជាក់ថា កំពុងមានការផ្លាស់ប្ដូរលើវិធីសាស្ត្រ និងការប្រើប្រាស់លទ្ធផលតេស្ត ដើម្បីជួយសាលារៀន និងគ្រូបានអភិវឌ្ឍប្រសើរឡើង។ ដូច្នេះ ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីទាំងអស់ ដើម្បីធានាថាយើងអាចប្រើប្រាស់កម្លាំងសរុបនៅក្នុងប្រព័ន្ធអប់រំរបស់យើង។ ដំបូងត្រូវមានការចូលរួមទាំងថ្នាក់ជាតិ ថ្នាក់រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងសាលារៀនផ្ទាល់។ លើសពីនេះ ក៏ត្រូវការ ការគាំទ្រពីដៃគូអភិវឌ្ឍទាំងអស់ ដែលមានវត្តមាននៅទីនេះផងដែរ ដែលអាចបំពេញគ្នាទៅវិញទៅមក និងជួយលើកកម្ពស់ប្រព័ន្ធអប់រំឱ្យកាន់តែរឹងមាំ។ |

ដើម្បីយកលទ្ធផលតេស្តនោះទៅប្រើប្រាស់ ជាចំណុចផ្តើមនៃការកែលម្អនៅកម្រិតសាលារៀន និងថ្នាក់រៀន។ យើងត្រូវការបំពេញចន្លោះនៃព័ត៌មាន និងអភិវឌ្ឍការបកស្រាយលើព័ត៌មាននោះឱ្យបានច្បាស់។ ទោះបីជាយើងមានគោលនយោបាយជាច្រើនបង្កើតឡើងរួចស្រេចក៏ដោយ។ ឧទាហរណ៍ ថ្នាលបឋម ដែលមានគោលបំណងជំរុញការសិក្សាថ្នាក់ដំបូងជាមូលដ្ឋាន និងបន្ថែមសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា ប៉ុន្តែវាមិនអាចអនុវត្តបានប្រសើរនៅសាលាបឋមសិក្សាដែលនៅតំបន់ឆ្ងាយ។ ដូចនេះយើងមានស្តង់ដាសាលារៀនគំរូ ដែលស្តង់ដាទី១ គឺផ្អែកលើលទ្ធផលសិក្សារបស់សិស្ស។ ស្តង់ដាទី២ គឺការបង្រៀននិងការរៀន ត្រូវមានភាពច្បាស់លាស់ ត្រឹមត្រូវ តាមវិធីសាស្ត្រដែលប្រសើរ និងធានាថាសិស្សទទួលបានសិទ្ធិក្នុងការសិក្សាយ៉ាងពេញលេញ។ ស្ថានភាពត្រូវហែលទឹកឆ្លងទន្លេ ដើម្បីទៅសាលារៀន គឺពិតជាមិនងាយស្រួល។ ប៉ុន្តែអ្វីដែលសំខាន់សម្រាប់យើងក្នុងជំនាន់នេះ គឺគ្រូបង្រៀន។ តើយើងអាចជួយសិស្សទាំងនោះតាមរបៀបណា? យើងមិនអាចរំពឹងថាពួកគេឆ្លងទន្លេ ឬប្រឈមនឹងឧបសគ្គដូចមុនបានទេ។ យើងត្រូវបង្កើតលក្ខខណ្ឌសម្រាប់ពួកគេឱ្យមានឱកាសសិក្សាដូចគ្នា។ នេះហើយជាការចូលរួមរបស់យើង ក្នុងការបង្កើតប្រព័ន្ធអប់រំដែលមានគុណភាព និងសមភាពសម្រាប់គ្រប់គ្នា។ បន្ថែមពីនេះ ដើម្បីឱ្យការបង្រៀននិងការរៀនមានប្រសិទ្ធភាពគ្រប់ជ្រុងជ្រោយ មិនអាចផ្អែកតែលើគ្រូបង្រៀនម្នាក់ឯង ឬសាលារៀនតែឯងទេ។ សហគមន៍មានតួនាទីសំខាន់ក្នុងការជួយមើល ជួយគាំទ្រ និងផ្តល់ជាកម្លាំងចិត្តសម្រាប់សាលារៀន និងសិស្ស។ យ៉ាងណាមិញ លោកបានបញ្ជាក់ថា ដើម្បីឱ្យសហគមន៍មានជំនឿចិត្ត និងរួមចំណែកជួយសាលារៀន បានយ៉ាងពេញទំហឹង ត្រូវមានដំណើរការប្រតិបត្តិការនៅសាលារៀនដែលច្បាស់លាស់ និងមានប្រសិទ្ធភាព ដូចជាការចែងច្បាស់អំពីតួនាទីរបស់គ្រូបង្រៀន ការបង្រៀនមានគោលបំណង នាយកសាលាមានការគ្រប់គ្រងរដ្ឋបាលយ៉ាងច្បាស់លាស់ និងការរៀបចំឯកសារឱ្យត្រឹមត្រូវ។ ជាការពិត អ្នកទាំងអស់គ្នាកំពុងខំប្រឹងធ្វើឱ្យបានគ្រប់ជ្រុងជ្រោយ ប៉ុន្តែការអូសទាញសហគមន៍ឱ្យចូលរួមយ៉ាងសកម្ម ត្រូវចាប់ផ្តើមពីភាពច្បាស់លាស់នៅខាងក្នុងសាលារៀន ហើយបង្ហាញឱ្យសហគមន៍ឃើញនូវការអភិវឌ្ឍជាក់ស្តែង ដូចដែលលោសារ៉ង បានបញ្ជាក់ខាងលើ។ ប្រសិនជា គេមិនឃើញថាសាលារៀនធ្វើអ្វីបានច្បាស់លាស់ និងអភិវឌ្ឍជាក់ស្តែងនោះទេ សហគមន៍អាចនឹងបាត់បង់ការចូលរួម។ ប្រសិនបើយើងគិតតែពីបដិភាគក៏នឹងនាំឱ្យមានការដកខ្លួនពីការចូលរួមបន្តិចម្តងៗ។

ចុងក្រោយគឺគណនេយ្យភាព។ សាលារៀនត្រូវហ៊ានបង្ហាញពីកិច្ចការដែលខ្លួនកំពុងអនុវត្ត។ បង្ហាញពីការទទួលខុសត្រូវយ៉ាងច្បាស់លាស់ ដើម្បីឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឃើញថា សាលារៀនកំពុងធ្វើអ្វី? កំពុងខ្វះអ្វី? និងត្រូវការជំនួយអ្វី? នេះហើយជាមូលដ្ឋាននៃស្តង់ដាសាលារៀនគំរូ ដែលក្រសួងអប់រំ បានផ្តល់ជាអាទិភាពចម្បងបំផុត។ សាលារៀន គ្រូបង្រៀន និងសហគមន៍ ត្រូវសហការគ្នាបង្កើត «អេកូឡូស៊ី» ដើម្បីកសាង

| | |
|---|---|
| | កម្លាំងសរុបជួយសាលារៀន។ ការកែលម្អនេះ មិនមែនជាការងាររបស់ក្រសួងតែឯងទេ។ នេះជាយុទ្ធសាស្រ្តរួម និងកំណែទម្រង់ជាប្រព័ន្ធជាតិ ដែលសាលារៀនទាំងអស់ត្រូវបម្លែងទៅជាសាលារៀនគំរូ ដើម្បីឱ្យការបំពេញការងារមានប្រសិទ្ធភាព ងាយស្រួល និងលឿនជាងមុន។ នោះជាគន្លឹះដ៏សំខាន់ក្នុងការជួយសិស្សអនាគតរបស់យើងទាំងអស់គ្នា។ ការវិនិយោគលើវិស័យអប់រំ គឺជាការវិនិយោគលើវាសនាកូនៗជំនាន់ក្រោយ ដែលជាសង្ឃឹមតែមួយគត់ និងជាមូលហេតុដែលយើងទាំងអស់គ្នាអាចស្ថិតនៅទីនេះបាន។ |
| សំណួរ-ចម្លើយ និងធាតុចូលពីអ្នកចូលរួម៖<br><br>លោកស្រី Isabel Bokar<br><br>អ្នកប្រឹក្សារបស់ក្រសួងអប់រំ និងធ្វើការជាមួយស្ថានទូតបារាំង។ | លោកស្រីមានការចាប់អារម្មណ៍ខ្លាំង គឺគំនិតអំពី «ប្រព័ន្ធអេកូឡូស៊ី»។ លោកស្រីយល់ស្របថា វាមិនមែនជាគំនិតងាយស្រួលទេ។ ប៉ុន្តែ ប្រសិនជាយើងអាចដំណើរការជាប្រព័ន្ធសហការណ៍បែបអេកូឡូស៊ី បាន នោះនឹងអាចទទួលបានលទ្ធផលល្អជាងមុន។ ប៉ុន្តែសំខាន់ជាងគេគឺលទ្ធផលសិក្សារបស់សិស្ស—នេះគឺជាគោលបំណងសំខាន់បំផុត។ ឪពុកម្តាយមិនសូវមកសាលារៀននោះទេ តែនេះមិនមែននៅតែនៅកម្ពុជាប៉ុណ្ណោះទេ វាកើតមាននៅជាច្រើនប្រទេសផងដែរ។ ឪពុកម្តាយពេលក្មេង ខ្វះឱកាសរៀនសូត្របច្ចុប្បន្នក៏មិនសូវចូលរួមជាមួយសាលាដែរ។ សំណួរថា តើយើងអាចប្រើយន្តការមួយណាដើម្បីផ្លាស់ប្តូរនេះ? សម្រាប់លោកស្រី ជំហានដំបូង គឺការផ្តល់ព័ត៌មានដល់ឪពុកម្តាយ។ ដើម្បីអាចផ្តល់ព័ត៌មានបាន យើងត្រូវអញ្ជើញពួកគេចូលមកសាលាមុនសិន។ នៅប្រទេសខ្លះ ឃើញមានសកម្មភាពសាមញ្ញៗដូចជា៖ ចែកលទ្ធផលសិស្សតាមពិធីតូចៗ ឬចែកវិញ្ញាបនបត្រឱ្យកូនៗ។ ការធ្វើដូចនេះ អាចធ្វើឱ្យឪពុកម្តាយពេញចិត្ត ហើយចូលរួមជាមួយសាលា។ វាក៏ត្រូវផ្សព្វផ្សាយអំពីគោលបំណងនៃការមកសាលារៀនផងដែរ។ នៅចុងក្រោយ គោលបំណងនោះគឺដើម្បីទទួលបានការអប់រំដែលមានគុណភាព ដែលអាចនាំឱ្យមានការងារល្អ និងចំណូលសមរម្យ ដែលជាគោលដៅសកល។<br><br>អំពីការចូលរួមរយៈពេលវែង។ យើងក៏បានពិភាក្សាអំពីអាហារូបត្ថម្ភ និងកម្មវិធីអាហារនៅតាមសាលារៀន។ កម្មវិធីទាំងនេះ កំពុងអនុវត្តនៅតំបន់ខ្លះៗ។ វាមិនមែនការស្រមើរស្រម៉ៃទេ ប្រសិនបើកូនមានអាហារ ហើយនៅសាលារៀន។ ពួកគេនឹងមិនត្រូវបានយកទៅធ្វើការនៅកន្លែងធ្វើការនោះទេ។ ជាចុងក្រោយ គឺមានគំនិតអំពីគណៈកម្មការសាលារៀន និងតួនាទីនាយកសាលា។ លោកស្រីជឿជាក់ថា យើងត្រូវឱ្យមានគំនិតរួមចំពោះរឿងនេះ។ តើអ្នកដឹកនាំសាលារៀនគួរមានតួនាទីអ្វីខ្លះ និងទទួលខុសត្រូវចំពោះអ្វី? នេះជាសំណួរសំខាន់សម្រាប់ជំហានបន្ទាប់។ |
| លោក សូផា PSE៖ យើងត្រូវចាប់ផ្តើម (initiate action) ដើម្បីលើកកម្ពស់លទ្ធផលសិក្សា ហើយវាត្រូវការ ការចូលរួមពីអាណាព្យាបាល។ | លោក សារ៉ង៖ សារៈសំខាន់នៃការផ្លាស់ប្តូរសាលារៀន មិនអាចចាប់ផ្តើមពីសម្ភារៈ ឬបច្ចេកវិទ្យាទេ។ ប៉ុន្តែត្រូវចាប់ផ្តើមពី "គំនិត" និង "ទស្សនៈ" របស់មនុស្ស។ ទី១.បញ្ហាសម្របសម្រួលនៅក្នុងសាលារៀន៖ ប្រសិននៅសាលារៀនមានជម្លោះនាយក និងគ្រូ ឬគ្រូជាមួយសហគមន៍ នេះជាបញ្ហាដែលនាំឱ្យរាំងស្ទះនូវការរួមចំណែក។ ដូច្នេះ ដំណាក់កាលដំបូងគួរតែ "លាងបញ្ហា" ចេញពីគំនិតមនុស្សសិន។ ទី២.ការផ្លាស់ប្តូរគំនិតគឺជា |

| | |
|---|---|
| ប៉ុន្តែគាត់មិនមកចូលរួមទេ។ មើលទៅពិបាកក្នុងការចាប់ផ្តើមឬផ្លាស់ប្តូរ។ ការលើកលទ្ធផលសិក្សារបស់សិស្សត្រូវការកិច្ចការសហការ។ សំណួរគឺ៖ តើយើងគួរចាប់ផ្តើមពីណា? តើមានអនុសាសន៍ ឬចំណុចណាដែលសមរម្យសម្រាប់ចាប់ផ្តើមដំបូងសម្រាប់អេកូឡូស៊ីនៅតំបន់យើងនេះ? | គន្លងដំបូង៖ វាមិនគ្រប់គ្រាន់នឹងការយកសម្ភារៈទំនើបៗទៅដាក់នោះទេ។ ប្រសិនគ្មានការផ្លាស់ប្តូរគំនិត គ្មានអ្វីដូចបាននិយាយ បើគ្មានឆន្ទៈ ឬការយល់ដឹងពីតម្លៃនៃការចូលរួម នោះការលើកកម្ពស់គឺពិបាកខ្លាំង។ ទី៣.វិធីផ្លាស់ប្តូរគំនិត៖ ត្រូវនាំគាត់ (គ្រូ/នាយក/សហគមន៍) ទៅមើលកន្លែងដែលគេធ្វើបានល្អ។ បើគេបានឃើញផ្ទាល់ ហើយគេចាប់អារម្មណ៍ នោះជាចំណុចចាប់ផ្តើមល្អបំផុត។ ការបង្ខំ ឬប្រើអំណាចមិនអាចផ្លាស់ប្តូរបានទេ ត្រូវមានការគោរព និងការបញ្ចេញឥទ្ធិពលបែបវិជ្ជាជីវៈ។ ទី៤.តម្លៃនៃទំនាក់ទំនងនិងទំនុកចិត្ត៖ ប្រសិនសហគមន៍ជឿទុកចិត្តលើគ្រូបង្រៀន និងនាយកសាលា នោះពួកគេនឹងនាំយកអ្វីៗមកចូលរួមដោយស្ម័គ្រចិត្ត។ ប្រសិនមិនមានទំនុកចិត្តនោះទេ ដូចនេះសម្ភារៈក៏អត់អនុញ្ញាតឱ្យអភិវឌ្ឍអ្វីបានឡើយ។ ការផ្លាស់ប្តូរសាលារៀន គឺចាប់ផ្តើមពីការផ្លាស់ប្តូរគំនិតមនុស្ស មិនមែនពីសម្ភារៈ។ ចាប់ផ្តើមជាមួយការយល់ចិត្ត យល់ពីតម្លៃ និងទំនុកចិត្តជាមូលដ្ឋានសម្រាប់ភាពរួបរួម។ |
| ការចូលរួមរបស់ លោកស្រី ស្មើ អង្គការ Lotus Outreach Cambodia | ទី១.សាលាឯកជន និងសាលារដ្ឋ ក្នុងការទាក់ទងគ្រូអាណាព្យាបាល៖ សាលាឯកជននៅពេលសិស្សអវត្តមាន គ្រូនឹងទាក់ទងទៅអាណាព្យាបាលភ្លាមៗ និងមានការរៀបចំកម្មវិធីជួបប្រជុំគ្នារវាងគ្រូ និងអាណាព្យាបាល។ ជាផលល្អ ការចូលរួមរបស់អាណាព្យាបាលខ្ពស់ សិស្សមករៀនទៀងទាត់ នាំឱ្យលទ្ធផលសិក្សាល្អ។ សម្រាប់សាលារដ្ឋ៖ ទំនាក់ទំនងគ្រូ អាណាព្យាបាល មិនជាប់លាប់ ទោះបីមានប្រើក្រុមតេលេក្រាមក៏ដោយ។ អាណាព្យាបាលមិនចូលរួមសកម្ម និង អវត្តមានអាចមិនបានដឹង ឬដំណឹងទាន់ពេល។<br><br>ទី២.ការសហការជាមួយគណៈកម្មការសាលារៀន និងសហគមន៍៖ មានការសហការជាមួយគណៈកម្មការសាលារៀនជាប្រចាំ ដោយធ្វើការសិក្សាអំពីបញ្ហាជាក់ស្តែងរបស់គ្រួសារសិស្ស ផ្តល់ជំនួយដូចជា កញ្ចប់អង្ករ សាំងសម្រាប់ឱ្យគ្រូទៅតាមដានសិស្សនៅផ្ទះ និងផ្តោតលើការយកចិត្តទុកដាក់ មិនមែនជាគ្រាន់តែការបង់ថវិកា ប៉ុន្តែជាការស្វែងយល់ និងឆ្លើយតបតាមបញ្ហាជាក់ស្តែងរបស់សិស្ស។<br><br>ទី៣.ការចុះទៅតាមដានផ្ទាល់ (Home Visit)៖ មិនគ្រប់គ្រងតាមតែព័ត៌មានទេ ត្រូវទៅដល់ផ្ទះជួបអាណាព្យាបាលផ្ទាល់ តំណាងសាលារៀនឬគម្រោង អញ្ជើញទៅជួបអាណាព្យាបាលស្តាប់ និងឆ្លើយតបល្អជាង និងអាចជួយបំផ្លាញចិត្តសិស្សដែលគិតចង់បោះបង់ការសិក្សា ដែលនាំឱ្យសិស្សខ្លះបានវិលមករៀនវិញ។<br><br>ទី៤.សិស្សនៅឆ្ងាយអត់មករៀនដោយសារចម្ងាយ និងបញ្ហាថវិកា។ ប្រសិនជាសាលារៀន និងគម្រោងមានការចូលរួម និងអនុញ្ញាតឱ្យសិស្សរៀនដោយគ្មានការទាមទារថវិកា នាំឱ្យអាណាព្យាបាលយល់ដឹង និងផ្តល់ឱកាសឱ្យកូនបានបន្តការសិក្សា។ ទាំងអស់នេះនាំឱ្យមានផលប៉ះពាល់វិជ្ជមានដោយការកាត់បន្ថយអត្រាបោះបង់សិក្សា។ |

| | |
|---|---|
| សំណួរទៅលោក បូរ៉ា៖<br><br>តើមានរបៀបណាមួយដែលស្រដៀងនឹងអន្តរាគមន៍របស់សាលារៀនឯកជន ដូចដែលបានបង្ហាញនៅក្នុងការប្រជុំអាណាព្យាបាល ឬតាមរយៈកម្មវិធីផ្សេងៗ ដែលអាចជួយស្ថាបនាការផ្សារភ្ជាប់រវាងសាលារៀន និងអាណាព្យាបាលបាន? ពីព្រោះវាអះអាងពីតួនាទីដ៏សំខាន់របស់អាណាព្យាបាលក្នុងប្រព័ន្ធអប់រំ និងតម្រូវឱ្យសាលារៀនពិចារណាចំពោះវិធីសាស្ត្រដែលអាចជំរុញឱ្យមានការចូលរួមរបស់ពួកគេបានយ៉ាងសកម្ម។ | លោក បូរ៉ា បានចែករំលែកពីគំនិតផ្ទាល់ខ្លួនអំពីស្ថានភាពនេះ។ គាត់បានចាប់អារម្មណ៍ថាអ្នកចូលរួមជាច្រើនក្នុងវេទិកា មានកូនៗរៀននៅសាលារៀនឯកជន។ តាមការសង្កេតរបស់លោក មូលហេតុមួយដែលធ្វើឱ្យសិស្សភាគច្រើនធ្វើការជ្រើសរើសសាលារៀនឯកជន គឺដោយសារមានភាពជឿជាក់ពីអាណាព្យាបាល។ ជឿជាក់ថា សាលារៀននោះមានការគ្រប់គ្រងល្អ មានកម្មវិធីសិក្សាត្រឹមត្រូវ និងផ្តល់សុវត្ថិភាពដល់កូនៗ។ ជាផ្នែកមួយនៃការផ្តល់សេវាអប់រំ អង្គភាពត្រូវតែសម្របខ្លួនឱ្យបានសមរម្យនឹងតម្រូវការរបស់អ្នកទទួលសេវា។ គាត់បញ្ជាក់ថា ពេលដែលអង្គភាពណាមួយចេះធ្វើ «បដិវត្តន៍កម្ម» មានន័យថាអង្គភាពនោះកំពុងមានការផ្លាស់ប្តូរទៅក្នុងទិសវិជ្ជមាន។ ពួកគេតែងតែស្វែងរកអ្វីថ្មីៗដើម្បីឆ្លើយតបនឹងបរិបទនៃសង្គម និងតម្រូវការរបស់អាណាព្យាបាល។ វាជាការបង្ហាញថាសេវាដែលផ្តល់ឱ្យគេ មិនត្រឹមតែជាសេវាទូទៅទេ ប៉ុន្តែជាសេវាដែលបន្តសម្រួល និងរីកចម្រើនទៅជាប្រព័ន្ធដែលអាចទុកចិត្តបាន។ គាត់បានបញ្ជាក់ថា មតិរបស់លោក មិនមែនគាំទ្រប្រព័ន្ធណាមួយជាពិសេសឡើយ មិនថាសាលារដ្ឋ ឬសាលាឯកជន។ លោកគ្រាន់តែចង់បង្ហាញពីចំណុច ដែលថាមុននឹងអាណាព្យាបាលជឿជាក់លើសាលារៀនណាមួយ អង្គភាពនោះត្រូវតែបង្ហាញនូវសក្តានុពលក្នុងការផ្លាស់ប្តូរ និងឆ្លើយតបនឹងតម្រូវការបច្ចុប្បន្នជាមុនសិន។ ការកសាងជំនឿរវាងសាលារៀន និងអាណាព្យាបាល មិនមែនជាការកើតឡើងដោយចៃដន្យទេ ប៉ុន្តែជាផលិតផលនៃការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍអង្គភាព ដោយមិនចាំបាច់រង់ចាំអង្គភាពជាន់ខ្ពស់ណាដើម្បីផ្លាស់ប្តូរ។ |
| ការចូលរួមរបស់<br>លោក ប៊ុនថេង<br>អង្គការកូហ្វាល ខេត្តកំពង់ធំ | លោកសង្កេតឃើញថា បើសិនសាលារៀនដែលមាននាយក ឬគណៈគ្រប់គ្រងសាលាដែលសកម្ម និងមានចក្ខុវិស័យខ្ពស់ក្នុងការរៀបចំវិធីសាស្ត្រផ្សេងៗ ដើម្បីអញ្ជើញឱ្យសហគមន៍ចូលរួម សាលានោះអាចក្លាយជាគំរូល្អបាន។ ពិសេសគាត់ត្រូវចាប់ផ្តើមពីខ្លួនឯង ជាអ្នកគ្រប់គ្រងសាលារៀន ដោយបង្ហាញភាពសកម្ម ក្នុងការធ្វើឱ្យសាលារៀនមានសោភ័ណភាពគួរឱ្យទុកចិត្ត។ ឧទាហរណ៍ ប្រសិនអាណាព្យាបាលឃើញថាកូនរបស់ពួកគេបានចូលរៀននៅសាលារៀនមួយ ដែលមានការបង្ហាញអំពីគុណភាព សុច្ចរិតភាព និងភាពសកម្ម នោះពួកគេនឹងចូលរួមជាមួយសាលារៀននោះដោយស្ម័គ្រចិត្ត។<br><br>សម្រាប់ កត្តាគ្រូបង្រៀន លោកបានលើកឡើងពីបញ្ហា ការអវត្តមានគ្រូពេលមានបញ្ហាផ្ទាល់ខ្លួន ដូចជា លំហែមាតុភាព ឬជំងឺ ដែលប៉ះពាល់ដល់ការសិក្សារបស់សិស្ស ដោយសារមិនមានអ្នកជំនួស។ ដូច្នេះ លោកស្នើឱ្យបញ្ចូលថវិកាមួយចំណែកក្នុងកញ្ចប់ថវិកាសាលារៀន ដើម្បីជួលគ្រូបង្រៀនជំនួស ដើម្បីរក្សាគុណភាពការបង្រៀន និងការសិក្សារបស់សិស្សឱ្យប្រក្រតី។ |
| លោក ហ៊ី សំបូរ<br>ប្រធានការិយាល័យអប់រំ<br>ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី | រាល់ថ្ងៃយើងបានអនុវត្តការងារជាច្រើន ចាប់ពីកម្រិតមូលដ្ឋានរហូតដល់កម្រិតក្រសួង។ ប៉ុន្តែសំណួរមួយ គឺថាធ្វើដូចម្តេចឱ្យការសិក្សារៀនសូត្រនោះ ទទួលបានជោគជ័យពិតប្រាកដ? ស្ថានភាពការរៀនសូត្រនៅតាមតំបន់ខុសៗគ្នា ដូចជានៅខេត្តរតនគិរី មាន |

| | |
|---|---|
| | ប្រជាជនជាតិដើមតិចស្ទើរតែ ៩០%។ ខណៈដែលគម្រោង និងកម្មវិធីសាធារណៈច្រើនត្រូវបានអនុវត្ត តែការទទួលបានលទ្ធផលនៅតែមានភាពខុសគ្នា។ បើយើងមើលស្ថានភាពជាក់ស្តែង វាលំបាកណាស់។ រាល់ថ្ងៃយើងខំប្រឹងអនុវត្តកម្មវិធីរបស់ក្រសួង។ ប៉ុន្តែសាលារៀនខ្លះមានគ្រូតែ ១នាក់ ឬ២នាក់។ ជាប្រចាំ គ្រូបង្រៀន និងនាយកសាលាត្រូវមានភារកិច្ចជាច្រើន។ ពិតប្រាកដណាស់ គាត់មិនអាចចូលរួមពេញដៃពេញជើងបានទេ។ រឿងជាច្រើនណាស់ដែលខាងយើងបានខំធ្វើ ប៉ុន្តែស្ថានភាពជាក់ស្តែងគឺមិនដូចគ្នាទេ។ ភ្ជាប់នឹងនេះ ខ្ញុំចង់សួរលោកគ្រូសំណាង ទាក់ទងនឹងការប្រឡងសិស្សពូកែថ្នាក់ទី ២ ឡើងទៅ។ តើមាននីតិវិធី ឬយុទ្ធសាស្ត្រយ៉ាងដូចម្តេចក្នុងការរៀបចំ និងអភិវឌ្ឍសិស្សពូកែទាំងនេះ? សូមចែករំលែកបទពិសោធន៍ផងដែរ។ |
| ការចូលរួមរបស់ប្រធានការិយាល័យអប់រំស្រុកលំផាត់ | លោកលើកថា ប្រហែលជាក្រសួងអប់រំ អាចត្រូវហ៊ាននិយាយអំពីការពិតទាក់ទងនឹងលទ្ធផលនៃការអនុវត្ត។ ពីអតីតកាលមក យើងមានការពិបាកក្នុងការគ្រប់គ្រងទិន្នន័យស្តីពីសិស្ស—ស្ថានភាពដែលមានកម្រិតមួយ។ ប៉ុន្តែពេលនេះ វាលើកឱ្យឃើញថា តើមានចំណុចណាដែលយើងនៅមិនទាន់អនុវត្តបានជោគជ័យ? លោកថ្លែងអំណរគុណ ចំពោះការលើកឡើងនូវបញ្ហាប្រឈមបែបនេះ។ ជាពិសេស នៅក្នុងការអនុវត្តកម្មវិធីក្រៅក្រសួង អង្គការមួយចំនួននៅតែភ្លេចចំពោះសារៈសំខាន់របស់អាជ្ញាធរមូល ដ្ឋាន។ គួរឱ្យស្តាយបន្តិចក្នុងកិច្ចការងារមួយចំនួន មនុស្សសំខាន់បំផុតដូចជា លោក ឬលោកស្រីនៅឃុំ សង្កាត់ មិនត្រូវបានចូលរួម។ ពួកគាត់ជាអ្នកដែលអាចស្តាប់ ព្រមទាំងយល់ដឹងជាក់ស្តែងអំពីបញ្ហានៅមូលដ្ឋានបានល្អជាងគេ។ ដូច្នេះ លោកសំណូមពរឱ្យបណ្តាអង្គការដែលអនុវត្តកម្មវិធីទាំងនោះ សូមពិចារណា អញ្ជើញអាជ្ញាធរមូលដ្ឋានចូលរួមដោយផ្ទាល់ ដើម្បីឱ្យការងារមានប្រសិទ្ធភាព និងឆ្ពោះទៅរកលទ្ធផលពិតប្រាកដ។ |
| លោក ហង់ សំណាង ចែករំលែកបទពិសោធន៍ នីតិវិធីប្រឡងសិស្សពូកែថ្នាក់ទី២ ដល់ទី៦៖ បទពិសោធន៍ពាក់ព័ន្ធនឹងការរៀបចំ ការប្រឡងសិស្សពូកែថ្នាក់ស្រុក ដែលបានអនុវត្តកន្លងមក។ | យើងបានជ្រើសរើសសិស្សពូកែចាប់ពីថ្នាក់ទី២ ដល់ថ្នាក់ទី៦ នៅសាលាបឋមសិក្សាដោយយកតែសិស្សដែលមានចំណាត់ថ្នាក់លើបំផុត (លេខ១) ក្នុងមួយថ្នាក់។ ការរៀបចំការប្រឡងត្រូវបានបែងចែកតាមថ្នាក់ និងមានកាលបរិច្ឆេទច្បាស់លាស់សម្រាប់រៀបចំវិញ្ញាសារ។ យើងបានកំណត់សំណួរវិញ្ញាសារ និងធ្វើការប្រឡងយ៉ាងត្រឹមត្រូវ និងមានតម្លាភាព។ គណៈកម្មការដែលត្រូវចូលរួមក្នុងការរៀបចំ ក៏ត្រូវបានកំណត់ជាផ្លូវការដើម្បីធានាលទ្ធផលប្រឡងត្រឹមត្រូវ ដោយចៀសវាងអ្វីៗដែលអាចប៉ះពាល់ដល់ភាពត្រឹមត្រូវនៃលទ្ធផល។ យើងព្យាយាមបង្កើតបរិយាកាសប្រឡង ឱ្យមានសុច្ចរិតភាពខ្ពស់ដើម្បីទទួលបានលទ្ធផលពិតប្រាកដ។ បច្ចុប្បន្ននេះ យើងកំពុងសង្កេតឃើញថាការប្រឡងជម្រើសនេះបានអភិវឌ្ឍទៅមុខល្អ និងកំពុងពង្រីកការអនុវត្តសម្រាប់ឆ្នាំសិក្សាថ្មីៗ ខណៈដែលសាលារៀនផ្សេងៗក៏កំពុងធ្វើការរៀបចំលើកម្រិតនេះជាបន្តបន្ទាប់ដោយផ្តោតលើគុណភាព និងភាពត្រឹមត្រូវ។ |

| | |
|---|---|
| សំណួរពី លោក ឡឹប អង្គការHI៖ សូមលោក បូរ៉ា បញ្ជាក់ពីន័យនៃ "ជនទី៣" ដែលលើកឡើងថាគួរតែមាន ដើម្បីធ្វើឱ្យសហគមន៍ និង សាលារៀនសហការយ៉ាង ប្រសើរ។ តើជនទី៣ នោះជា នរណា និងមានតួនាទីអ្វីក្នុង ការចូលរួមសម្រួលសកម្ម ភាពសហការនៅមូលដ្ឋាន ? | លោក បូរ៉ា៖ ជនទី៣ ថាជាចលករ ឬភាគីទី៣ ដែលអាចជាអ្នកសម្របសម្រួល ឬអ្នកដឹកនាំការងារ។ ក្នុងការអភិវឌ្ឍ សហគមន៍ សាលារៀន ត្រូវមានប្រតិបត្តិករដែលល្អ។ ប៉ុន្តែជាក់ស្តែង ប្រតិបត្តិករខ្លះមិនបានដំណើរការល្អទេ។ ដូច្នេះ ដើម្បីឱ្យការងារប្រតិបត្តិទៅជោគជ័យ ត្រូវមានអ្នកដឹកនាំការងារ ឬជនទី៣ មកជួយសម្របសម្រួល។ ជនទី៣ អាចជាអ្នកមកពីអង្គការ ក្រសួង ឬអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ។ មនុស្សកណ្តាលនេះ គឺមិនមែនជាអ្នកប៉ះពាល់ផ្ទាល់នឹងបញ្ហានោះទេ ប៉ុន្តែអាចសម្របសម្រួលឱ្យភាគីទាំងពីរ ដែលប្រហែលជាមិនយល់គ្នា ឬកំពុងមានជម្លោះអាចយល់ចិត្តគ្នាបាន។ ជនទី៣ មិនមែនមកសម្រេចការសម្រេចចិត្តជំនួសនរណាម្នាក់ទេ ប៉ុន្តែគាត់មកជាអ្នកស្តាប់ ជាអ្នកយល់ពីបញ្ហា និងជួយសម្របសម្រួលឱ្យមានការយល់ព្រមរវាងភាគីទាំងអស់ ដើម្បីជំរុញឱ្យការងារសហគមន៍ និងសាលារៀនបន្តទៅមុខបានយ៉ាងមានប្រសិទ្ធិភាព។ |
| ការផ្តល់អនុសាសន៍របស់វាគ្មិនទាំងអស់៖ តើយើងគួរធ្វើយ៉ាងដូចម្តេចដើម្បីឱ្យលទ្ធផលការសិក្សារបស់សិស្សកាន់តែប្រសើរតាមរយៈប្រព័ន្ធអេកូឡូស៊ីសាលារៀន (school eco-system) ? | **លោក សន សៅអូន៖** ការបង្ហាញនូវអ្វីដែលបានធ្វើ និងការស្នើសុំឱ្យគេចូលរួម ជាផ្នែកសំខាន់ក្នុងការបង្កើតការជឿជាក់ និងការយល់ដឹងដល់សហគមន៍។ ពេលសហគមន៍បានឃើញនូវកិច្ចខិតខំប្រាកដ និងគុណភាពពីសាលា គេនឹងចូលរួមកាន់តែសកម្ម និងប្រសើរជាងមុន។ការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស គឺអាស្រ័យយ៉ាងខ្លាំងទៅលើការចូលរួមរបស់ភាគីទាំងអស់។ ការចូលរួមនេះមិនត្រឹមតែមានតួនាទីសំខាន់នៃសាលារៀន និងគ្រូបង្រៀនទេ ប៉ុន្តែរួមមាននាយកសាលា សហគមន៍ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នក្រសួងពាក់ព័ន្ធផងដែរ។ ធ្វើអ្វីដែលបង្ហាញដល់សហគមន៍ សុំគាត់ពីអ្វី យើងត្រូវបង្ហាញអំពីហ្នឹងឱ្យគាត់បានឃើញ បានដឹង។ ដូច្នេះ ថ្ងៃក្រោយគាត់នឹងចូលរួមបានកាន់តែប្រសើរជាមុន។ លោកបានបញ្ជាក់ថា សកម្មភាពណាមួយដែលអង្គភាព ឬសាលារៀនចង់ឱ្យសហគមន៍ចូលរួម គួរតែមានការបង្ហាញអំពីសកម្មភាពនោះឱ្យបានច្បាស់ ដើម្បីបង្កើតភាពជឿជាក់ និងការយល់ដឹងក្នុងសហគមន៍។ ការបង្ហាញពីអ្វីដែលបានធ្វើ និងការអំពាវនាវឱ្យសហគមន៍ចូលរួម គឺជាវិធីដ៏មានប្រសិទ្ធភាព ក្នុងការធ្វើឱ្យការចូលរួមរបស់គាត់កាន់តែមានសកម្មភាព និងចូលដល់សារសំខាន់នៃការអប់រំ។<br><br>**លោក ហង់ សំណាង៖** យើងទាំងអស់គ្នានៅកម្រិតសាលារៀន ដែលមានទាំងនាយកសាលា គ្រូបង្រៀន និងSMC ត្រូវតែខិតខំប្រឹងប្រែងសហការគ្នាឱ្យបានល្អ។ ពិសេសគឺត្រូវរកឫសគល់នៃបញ្ហាឱ្យឃើញ បន្ទាប់មកសហការគ្នាធ្វើការដើម្បីបង្កើនសមត្ថភាពសិស្ស ឱ្យគាត់ចេះ និងមានលទ្ធផលសិក្សាល្អ។ លោកបានផ្តោតលើតួអង្គសំខាន់ក្នុងការអភិវឌ្ឍគុណភាពសិក្សា គឺនាយកសាលា។ តួអង្គនេះមានអនុភាព និងតួនាទីក្នុងការដឹកនាំការងារនៅសាលារៀន។ ដូច្នេះ ប្រសិនជាយើងអភិវឌ្ឍនាយកសាលា ឱ្យមានសមត្ថភាពល្អ មានការលើកទឹកចិត្ត និងចេះដឹកនាំបានល្អ នោះគាត់នឹងអាចជួយជំរុញសមត្ថភាពគ្រូបង្រៀន និងគ្រប់គ្រងសាលារៀនបានប្រសើរឡើង។ |

**លោក អឿន បូរ៉ា៖** ការកែលម្អលទ្ធផលសិក្សា មិនអាចជោគជ័យត្រឹមតែសាលារៀនទេ តែត្រូវការជំនួយ និងការចូលរួមពីភាគីទាំងអស់។ ត្រូវមានពិភាក្សាជាបន្តបន្ទាប់ ដើម្បីបង្កើតការផ្លាស់ប្តូរ ដែលអាចឱ្យកំណើនលទ្ធផលសិក្សាបាន។ ទោះបីជា មានឆន្ទៈក្នុងការធ្វើការផ្លាស់ប្តូរ ប៉ុន្តែអ្វីដែលអាចក្លាយជាឧបសគ្គ គឺគោលនយោបាយដែលមិនទាន់បើកផ្លូវ ឬមិនអនុញ្ញាតឱ្យអនុវត្តចំពោះអ្វីដែលគេជឿថាល្អ។ លោកស្នើឱ្យពិចារណាថា យើងគួរតែពិនិត្យ និងពិភាក្សាពីកំណែទម្រង់គោលនយោបាយ ដើម្បីឱ្យសមស្របនឹងការអនុវត្តដែលអាចជួយសហគមន៍ និងសាលារៀនបានយ៉ាងមានប្រសិទ្ធភាព។ លោកជំរុញឱ្យមានការផ្លាស់ប្តូរទៅលើគោលនយោបាយឱ្យផ្តល់ឱកាស និងអំណាចដល់អ្នកអនុវត្តនៅកម្រិតសាលារៀន ដើម្បីអាចអភិវឌ្ឍ និងបត់បែនទៅតាមបរិបទពិតប្រាកដ។ លោកបញ្ជាក់ថា នេះមិនមែនជាអនុសាសន៍ ប៉ុន្តែជាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ដែលបង្ហាញពីឆន្ទៈក្នុងការបញ្ជូនសារដល់អ្នកពាក់ព័ន្ធ។

**លោក អ៊ិត សារ៉េង៖** បានបង្ហាញយ៉ាងច្បាស់ថា បើចង់ឱ្យការចូលរួមរបស់ភាគីនានា មានអត្ថន័យ និងសម្រេចបានលទ្ធផលល្អ ពាក់ព័ន្ធជាពិសេសទៅលើការបង្កើតបរិយាកាសនៃ «តម្លាភាព» និង «គណនេយ្យភាព»។ ប្រសិនបើគាត់ចូលរួមទាំងអស់គ្នា ហើយបង្ហាញពីលទ្ធផលនៃការចូលរួមដោយតម្លាភាព នោះទើបមានអត្ថន័យ។ ភាគីទាំងសងខាង គឺសាលារៀន និងសហគមន៍ឪពុកម្តាយ ត្រូវមានទាំងពីរនេះដូចគ្នា។ ប្រសិនបើគ្មាន តម្លាភាពនិងគណនេយ្យភាព អ្នកទាំងពីរនឹងមិនអាចជួបគ្នាធ្វើការរួមគ្នាបានទេ។ លោកស្នើឱ្យគ្រូបង្រៀនដាក់ខ្លួន ចូលទៅរកឪពុកម្តាយជាមុន។ ការចូលទៅរកនេះ គឺជាជំហានដំបូងនៃការកសាងការសហការ។

**លោក ស សារិន៖** តេស្តស្តង់ដា មានសារៈសំខាន់សម្រាប់ការវាស់វែងលទ្ធផលសិក្សារបស់សិស្ស។ ការធ្វើតេស្ត មិនមែនសម្រាប់បញ្ចប់តែចំណាត់ថ្នាក់របស់សិស្សទេ ប៉ុន្តែជាចំណុចចាប់ផ្តើមនៃការកែសម្រួលការបង្រៀន និងជួយឱ្យលទ្ធផលសិស្សប្រសើរឡើង។ គោលបំណងចម្បង ដើម្បីផ្តល់ព័ត៌មានដល់មន្ទីរ ស្រុក ឬក្រសួង ដែលលេខចេញពីចុងប៊ិចសិស្សនីមួយៗ។ លេខនីមួយៗតំណាងឱ្យជីវិតសិស្សម្នាក់។ លទ្ធផលត្រូវបានយកមកពិភាក្សាទៅវិញទៅមកក្នុងប្រព័ន្ធអេកូឡូស៊ីនៅសាលារៀន ដោយមានការចូលរួមរបស់នាយក គ្រូ និងគណៈកម្មការសាលារៀន ថាហេតុអ្វីសិស្សថ្នាក់មួយមានលទ្ធផលល្អជាងថ្នាក់ផ្សេង ទោះបីជាមានកម្មវិធីសិក្សា និងមុខវិជ្ជាដូចគ្នា។ ការពិភាក្សានេះនាំឱ្យមានចលនាដើម្បីបង្រៀនឱ្យបានប្រសើរឡើង និងជួយសិស្សតាមការពិត។ លោកសង្កត់ធ្ងន់ថា ត្រូវទទួលស្គាល់ និងបម្លែងជាសកម្មភាព។ សាលាគួរតែហ៊ានទទួលស្គាល់លទ្ធផលដែលទទួលបាន និងយកលទ្ធផលនោះធ្វើជាសកម្មភាពជាប្រចាំ ដើម្បីជួយសិស្សឱ្យកាន់តែមានភាពប្រសើរឡើង។ លទ្ធផលនៃតេស្តមិនមែនជាការបញ្ចប់ទេ ប៉ុន្តែជាចំណុចចាប់ផ្តើមដើម្បីសម្រេចបាននូវការអភិវឌ្ឍអប់រំជាក់ស្តែង។

## កិច្ចពិភាក្សាដំណោះស្រាយទី២

*«ភាពអាចបត់បែននៃការរៀនសូត្រសម្រាប់កុមារក្រៅសាលា៖ ការពង្រឹងការអនុវត្តថ្នាក់បំប៉នសិស្សរៀនយឺត។*

សម្របសម្រួលដោយ៖ លោក ព្រំ ឫទ្ធី អ្នកបច្ចេកទេសជំនាញអប់រំ អង្គការ WVI

វាគ្មិនទី១៖ លោក យី ខប នាយកសាលាបឋមសិក្សាប្រាសាទ ស្រុកពួក ខេត្តសៀមរាប

វាគ្មិនទី២៖ លោក យិនសៀង សុមេធ ប្រធានកម្មវិធីអប់រំ អង្គការ AEA

វាគ្មិនទី៣៖ លោក ជា ចិន្តា ប្រធានកម្មវិធីផ្នែកអប់រំ អង្គការUWS

វាគ្មិនទី៤៖ លោក សឿង សុផា នាយកផ្នែកកម្មវិធីសិក្សាទូទៅ អង្គការPSE

វាគ្មិនទី៥៖ លោក ឡុង សានរិទ្ធី នាយករង និងជានាយកសាខាប៉ោយប៉ែត អង្គការដំណក់ទឹក

| លទ្ធផលនៃកិច្ចពិភាក្សា | |
|---|---|
| បទបង្ហាញវាគ្មិនទី១<br><br>លោក យី ខប នាយកសាលាបឋមសិក្សាប្រាសាទ<br><br>ស្រុកពួក ខេត្តសៀមរាប<br><br>ធ្វើបទបង្ហាញ៖ ការអនុវត្តកម្មវិធីបង្រៀន និងរៀនពេញមួយថ្ងៃដោយប្រើប្រាស់ថវិកាមូលនិធិសមធម៌របស់មាតាបិតាសិស្ស។ | ដើម្បីឱ្យការអនុវត្តកម្មវិធីបង្រៀន និងរៀនពេញមួយថ្ងៃដោយប្រើប្រាស់ថវិកាមូលនិធិសមធម៌ប្រព្រឹត្តទៅបានរលូន។ លោកចែករំលែកចំណុចសំខាន់ៗដូចជា៖ **កត្តាខ្លួនឯង (គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ) កត្តាអង្គភាព កត្តាសហគមន៍ ផែនការបន្តរបស់សាលារៀន។**<br><br>**កត្តាខ្លួនឯង (គណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូ)៖** មើលឃើញការបង្រៀនបំប៉នជួយសិស្សរៀនយឺតគាំទ្រដោយគម្រោងFOSTER កន្លងមក ទទួលបានលទ្ធផលល្អ ចង់បានគុណភាពអប់រំកាន់តែប្រសើរឡើង ចង់ឱ្យសហគមន៍មានការចូលរួមកាន់តែល្អ លើកកម្ពស់ជីវភាពគ្រូបង្រៀន បំបាត់ការបង្រៀនគួរក្រៅម៉ោង និងបន្ថែមកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេស(ទី១-ទី៦) និងកុំព្យូទ័រ(ទី៤-ទី៦)។<br><br>**អ្នកជំរុញលើកទឹកចិត្ត**<br><br>- ក្រសួងអ.យ.ក យោងសេចក្តីណែនាំលេខ ៥៩ អយក សណន លោកបានលើកទឹកចិត្តឱ្យសាលារៀនដែលមានបន្ទប់រៀន និងគ្រូបង្រៀនសមស្របបើកបង្រៀនពេញមួយថ្ងៃដោយប្រើប្រាស់ថវិកាមូលនិធិសមធម៌<br>- ក្រសួងអ.យ.ក បានចេញលិខិតអនុញ្ញាតលេខ២៣០ អយកបស ចុះថ្ងៃទី១៥.មករា.២០២៤ អនុញ្ញាតឱ្យសាលាបឋមសិក្សាប្រាសាទបើកដំណើរការរៀន និងបង្រៀនពេញ១ថ្ងៃ ដោយប្រើប្រាស់ថវិកាមូលនិធិសមធម៌<br>- គម្រោងFOSTERក្រោមការដឹកនាំសម្របសម្រួលរបស់អង្គការ អេដ អេ អាកស្យុង (AEA) និងអង្គការខេបខេត្តសៀមរាប បានជួយបំផុសគំនិត រៀបចំបើកបង្រៀនពេញ១ថ្ងៃ ដោយប្រើប្រាស់ថវិកាមូលនិធិសមធម៌<br><br>**ការបារម្ភមុនពេលអនុវត្ត៖** ១.គ្រូបង្រៀនមិនចូលរួមអនុវត្តការបង្រៀនពេញ១ថ្ងៃ ២.មាតាបិតា ឬអាណាព្យាបាលសិស្សមិនចូលរួមបង់ថវិកាមូលនិធិសមធម៌ និង៣.សមត្ថភាព និងវិធីសាស្ត្រ បង្រៀនភាសាអង់គ្លេស លោកគ្រូអ្នកគ្រូនៅមានកម្រិត។ |

**ដំណោះស្រាយ ក្តីបារម្ភមុនចាប់ផ្តើម៖** ១.ប្រជុំលោកគ្រូអ្នកគ្រូ ប្រាប់ពីគោលបំណងការបង្រៀនពេញ១ថ្ងៃ។ ២.ប្រជុំមាតាបិតា ឬអាណាព្យាបាលសិស្សប្រាប់ពីគោលបំណងការបង្រៀនពេញ១ថ្ងៃ។ និង៣.ទំនាក់ទំនងជាមួយអង្គការដៃគូឱ្យជួយបំប៉នចំណេះដឹង និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសដល់លោកគ្រូអ្នកគ្រូ។

**កត្តាអង្គភាព៖**

ការរៀបចំបុគ្គលិក និងធនធានសម្ភារៈរបស់សាលារៀនដើម្បីបំពេញតម្រូវការនៃដំណើរការបង្រៀន និងរៀនពេញ១ថ្ងៃ ដោយជំរុញលើកទឹកចិត្តឱ្យលោកគ្រូអ្នកគ្រូមានការចែករំលែកលះបង់ និងប្រឹងប្រែងបង្រៀន ដើម្បីឱ្យសហគមន៍មើលឃើញពីលទ្ធផលបង្រៀនពេញ១ថ្ងៃ និងផ្តល់ថវិកាបន្ថែមដល់លោកគ្រូអ្នកគ្រូ ៣៦០០០០រម្នាក់ ក្នុង១ខែ។

ដំណោះស្រាយចំពោះបុគ្គលិកដែលមិនស្ម័គ្រចិត្ត ឬជំទាស់នឹងការបង្រៀនពេញ១ថ្ងៃ ដោយសំណូមពរគាត់ឱ្យគោរពមតិភាគច្រើន និងអនុវត្តច្បាប់វិន័យរបស់សាលារៀន។

**កត្តាស្ថាប័ន៖** ការរៀបចំកម្មវិធីសិក្សា៖ ១.ពេលព្រឹក អនុវត្តតាមកម្មវិធីរបស់ក្រសួងអប់រំ និងពេលរសៀលអនុវត្ត ១ថ្ងៃ ៣ម៉ោងរដ្ឋបាល ស្មើនឹង៤ម៉ោងសិក្សា (មុខវិជ្ជាភាសាខ្មែរ២ម៉ោង គណិតវិទ្យា១ម៉ោង ភាសាអង់គ្លេស១ម៉ោង) កុំព្យូទ័រ២ម៉ោង ក្នុង១សប្តាហ៍ សម្រាប់ថ្នាក់ទី៤ដល់៦។

បញ្ហាប្រឈម៖ សមត្ថភាព និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសរបស់លោកគ្រូអ្នកគ្រូមានកម្រិត ខ្វះបន្ទប់រៀន និងខ្វះកុំព្យូទ័រ។

ដំណោះស្រាយ៖ ក្រោមកិច្ចសហការសម្របសម្រួលរបស់អង្គការAEA អង្គការTDSO ជួយបំប៉នសមត្ថភាព និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសដល់លោកគ្រូ អ្នកគ្រូចំនួន ៨នាក់។ សាងសងអគារសិក្សាថ្មី ១ខ្នង ៣បន្ទប់ប្រើប្រាស់ថវិកាចូលរួមពីសហគមន៍១៧៧២០ដុល្លារ អង្គការAEA ៩៨៦០ដុល្លារ អង្គការទស្សនៈពិភពលោក ២០០០ដុល្លារ អង្គការAEA ជួយកុំព្យូទ័រ១០គ្រឿង អង្គការទស្សនៈពិភពលោកជួយកុំព្យូទ័របានចំនួន១២គ្រឿង។

**កត្តាសហគមន៍៖** ការកៀរថវិកាពីសហគមន៍ រៀបចំគណៈកម្មការគ្រប់គ្រងថវិកាមូលនិធិសមធម៌ សាលារៀនមានតម្លាភាព និងភាពស្មោះត្រង់។ បង្ហាញចំណូលចំណាយថវិកាដល់សហគមន៍ និងប្រាប់ពីផលប្រយោជន៍នៃការបង្រៀនពេញ១ថ្ងៃ(ប្រាប់ពីលក្ខខណ្ឌអនុវត្តកម្មវិធី និងកម្មវិធីសិក្សារៀនពេញ ១ថ្ងៃ)។ ក្រសួងបានប្តូរពីអាហារពេលព្រឹក មកជាអាហារថ្ងៃត្រង់ សម្រាប់គាំទ្រការបង្រៀនពេញ១ថ្ងៃ)។

យុទ្ធសាស្ត្រ ដើម្បីដោះស្រាយជាមួយសិស្សជួបការលំបាក សិស្សមានប័ណ្ណក្រីក្រ(ក្រ១ និងក្រ២) មិនតម្រូវឱ្យបង់ថវិកាមូលនិធិសមធម៌ និងគ្រួសារដែលមានកូនលើសពី ២នាក់ តម្រូវឱ្យបង់តែ ២នាក់។

| | |
|---|---|
| | **ផែនការបន្តរបស់សាលារៀន៖** ១.អង្គការAEA បានផ្តល់ជាកិច្ចសហការភាពជាដៃគូជាមួយសាលារៀន រយៈពេល ១ឆ្នាំសិក្សា។ ២.បន្តនិរន្តរភាពនៃការបង្រៀនពេញ១ថ្ងៃ ដោយប្រើប្រាស់ថវិកាមូលនិធិសមធម៌។ ៣.ទំនាក់ទំនងអង្គការដៃគូ សប្បុរសជន សាងសង់អគារសិក្សាបន្ថែម។ ៤.ទំនាក់ទំនងអង្គការដៃគូ សប្បុរសជន ស្វែងរកកុំព្យូទ័របន្ថែម។ និង៥.បើកដំណើរការបង្រៀនពេញ១ថ្ងៃ សម្រាប់ថ្នាក់មត្តេយ្យសិក្សាគ្រប់កម្រិត។ |
| បទបង្ហាញវាគ្មិនទី៥<br>លោក ឡុង សានរិទ្ធី<br>នាយករង និងជានាយកសាខា ប៉ោយប៉ែត<br>អង្គការដំណក់ទឹក (DT)<br><br>បទបង្ហាញអំពីកម្មវិធី៖ការអប់រំក្រៅប្រព័ន្ធក្នុងកម្មវិធីចំណាកស្រុកនៅប៉ោយប៉ែត។ | កម្មវិធីចំណាកស្រុកដោយសុវត្ថិភាពនៅប៉ោយប៉ែត ជាកម្មវិធីគម្រោងផ្សារភ្ជាប់គ្នារួម ដែលមានបំណងផ្តល់នូវការគាំទ្រជាបន្តបន្ទាប់ និងសេវាសម្រាប់កុមារងាយរងគ្រោះ និងគ្រួសាររបស់ពួកគេ។ គម្រោងទាំងនោះមាន៖<br>- គម្រោងកុមារចំណាកស្រុក៖ ផ្តល់ការគាំទ្រ និងការបញ្ជូនទៅកាន់អ្នកអមដំណើរ និងកុមារចំណាកស្រុកដែលវិលត្រឡប់មកវិញ និងក្រុមគ្រួសាររបស់ពួកគេ។<br>- គម្រោងមណ្ឌលសំចត៖ ផ្តល់កន្លែងសុវត្ថិភាពសម្រាប់កុមារដែលងាយរងគ្រោះ ក្រៅសាលារៀនពីសហគមន៍ (ការថែទាំ ការប្រឹក្សា លទ្ធភាពទទួលបានការអប់រំ និងការកម្សាន្ត) និងកម្មវិធី និងសេវាកម្មផ្សព្វផ្សាយសហគមន៍រួមទាំងការកំណត់អត្តសញ្ញាណ និងគាំទ្រកុមារក្រៅសាលា (OOSC) សម្រាប់ការចុះឈ្មោះចូលរៀននៅក្នុងការអប់រំក្រៅប្រព័ន្ធ និងដោយផ្ទាល់ទៅសាលារៀនរដ្ឋ។<br>- មជ្ឈមណ្ឌលថែទាំជំនួសបណ្តោះអាសន្ន៖ ផ្តល់ការគាំទ្ររយៈពេលខ្លីសម្រាប់កុមារអាយុក្រោម១៦ឆ្នាំ ដែលជាជនរងគ្រោះនៃការជួញដូរ ការរំលោភបំពាន ឬការកេងប្រវ័ញ្ច និងគាំទ្ររយៈពេលវែង សម្រាប់កុមារមិនអាចធ្វើសមាហរណ៍កម្មក្នុងគ្រួសារវិញ។<br>- គម្រោងការអប់រំក្រៅប្រព័ន្ធ៖ ផ្តល់លទ្ធភាពទទួលបានការអប់រំសម្រាប់កុមារ រួមទាំងថ្នាក់ពន្លឿន ផ្តល់ជាស្ពានសម្រាប់ការធ្វើសមាហរណ៍កម្មទៅក្នុងប្រព័ន្ធសាលារៀនរដ្ឋ។<br>- គម្រោងកសាងអនាគត៖ ដោះស្រាយអស្ថិរភាពសេដ្ឋកិច្ច ដែលជាបុព្វហេតុសំខាន់ និងជាប្រព័ន្ធនៃការធ្វើចំណាកស្រុក និងការជួញដូរគ្មានសុវត្ថិភាព និងការកេងប្រវ័ញ្ចលើកុមារ ការរំលោភបំពាន និងការធ្វេសប្រហែស ផ្តល់សេវាកម្មជាច្រើននៃការងារ និងប្រាក់ចំណូលដើម្បីគាំទ្រ និងពង្រឹងគ្រួសារដែលងាយរងគ្រោះ និងមានហានិភ័យ។<br><br>**កម្មវិធីចុះផ្សព្វផ្សាយសហគមន៍៖** ចុះទៅដល់ផ្ទះកុមារដែលងាយរងគ្រោះ និងក្រុមគ្រួសារពួកគេជាមួយនឹងព័ត៌មាន សេវាកម្ម និងការគាំទ្រ។ អន្តរាគមន៍នេះ កុមារជាង ២ពាន់នាក់ត្រូវបានអនុវត្តជារៀងរាល់ឆ្នាំដោយបុគ្គលិកសង្គម ភ្នាក់ងារសុវត្ថិភាពកុមារ និងមិត្តអប់រំមិត្ត រាប់ចាប់ពីការបង្ការ/ការពារ និងអន្តរាគមន៍សង្គ្រោះបន្ទាន់សម្រាប់ការងារតាមផ្លូវ និងកុមារដែលមានហានិភ័យខ្ពស់ រហូតដល់សកម្មភាពបណ្ណាល័យចល័តនៅក្នុងសហគមន៍។ នៅឆ្នាំ២០២៤ ក្រុមផ្សព្វផ្សាយដោយផ្ទាល់ បានទៅដល់អ្នកថែទាំ និងសមាជិកគ្រួសារ ចំនួន ៥៧៨នាក់ ដោយមានព័ត៌មាន អន្តរាគមន៍ជំនួយ និងការបញ្ជូនបន្ត។ |

**គម្រោងកសាងអនាគត៖** នៅឆ្នាំ២០២៤ បានផ្តល់សេវាសម្រាប់មនុស្ស ៤៩៤នាក់ និងគាំទ្រអតិថិជនចំនួន ២០៩នាក់ ទទួលបានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ អតិថិជនចំនួន ៥១នាក់ បានទទួលការបណ្តុះបណ្តាល និងការគាំទ្រថវិកាដើម្បីបង្កើតមុខរបរខ្នាតតូច និងមធ្យម។ ការពង្រឹងកិច្ចសហការ និងការសម្របសម្រួលបានអនុញ្ញាតឱ្យ តំណក់ទឹក កំណត់គោលដៅ និងផ្តល់សេវាដល់សមាជិកគ្រួសារ និងអ្នកថែទាំកុមារ។

**គម្រោងការអប់រំក្រៅប្រព័ន្ធ៖** តំណក់ទឹក ជឿជាក់ថា កុមារគ្រប់រូបគួរតែអាចចូលរៀននៅក្នុងប្រព័ន្ធសាលារៀនរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ កុមារជាច្រើនមកពីគ្រួសារចំណាកស្រុក ប្រឈមមុខនឹងឧបសគ្គយ៉ាងច្រើនក្នុងការចុះឈ្មោះចូលរៀន និងការបន្តការសិក្សានៅសាលារៀនរដ្ឋ ដូចជា៖ លទ្ធភាពទទួលបានការអប់រំមានកម្រិត ឬគ្មានមុខរបរ ប្រាក់ចំណូលគ្រួសារទាប កង្វះឯកសារផ្លូវការ (សំបុត្រកំណើត/កំណត់ត្រាចាក់វ៉ាក់សាំង) របួសដែលអាចប៉ះពាល់ដល់សមត្ថភាពរបស់សិស្សក្នុងការរៀនសូត្រ និងទំនាក់ទំនងសង្គម។ គោលដៅគម្រោងនេះ គឺដើម្បីផ្តល់នូវស្ពានមួយសម្រាប់កុមារក្នុងការធ្វើសមាហរណ៍កម្មទៅក្នុងសាលារៀនរដ្ឋដោយជោគជ័យ។ តំណក់ទឹក សហការ និងសម្របសម្រួលជាមួយការិយាល័យអប់រំ និងសាលារៀនរដ្ឋ ដើម្បីគាំទ្រការរួមបញ្ចូលកុមារពីកម្មវិធីសិក្សាក្រៅប្រព័ន្ធទៅសាលារៀនរដ្ឋ។ ការអប់រំក្រៅប្រព័ន្ធផ្តល់អ្វីខ្លះ?

- តំណក់ទឹក អនុវត្តតាមកម្មវិធីសិក្សាថ្នាក់ជាតិ ហើយបញ្ចូលវិធីសាស្ត្រ Essence of Learning (EoL) ទៅក្នុងវិធីសាស្ត្របង្រៀន។ កុមារដែលចុះឈ្មោះចូលរៀននៅកម្មវិធីអប់រំក្រៅប្រព័ន្ធមានភាពងាយរងគ្រោះខ្លាំង ហើយក្របខណ្ឌគរុកោសល្យ EoL ផ្តល់សិទ្ធិអំណាចដល់គ្រូក្នុងការបំប្លែងថ្នាក់រៀន ឱ្យទៅជាបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព ការចិញ្ចឹមបីបាច់ និងប្រកបដោយប្រសិទ្ធភាព។
- ផ្តល់សម្ភារៈសិក្សា ឯកសណ្ឋាន អាហារថ្ងៃត្រង់ និងមធ្យោបាយធ្វើដំណើរ
- ការគាំទ្របុគ្គលិកសង្គមសម្រាប់ការតាមដានអវត្តមាន
- សិស្សចូលរួមក្នុងការធ្វើផែនការ និងការសម្រេចចិត្ត តាមរយៈក្រុមប្រឹក្សាកុមារ
- ការសម្របសម្រួលជាមួយកម្មវិធីផ្សព្វផ្សាយសហគមន៍ និងអនាគតកុមារ ដើម្បីផ្តល់ការគាំទ្រ និងសេវាកម្មដល់គ្រួសារសិស្សនីមួយៗ
- ការផ្លាស់ប្តូរកម្មវិធីដើម្បីជួយដល់សិស្សដែលធ្វើសមាហរណ៍កម្មទៅសាលារដ្ឋ។

នៅឆ្នាំ២០២៥ កុមារ ៤២៧នាក់ អាយុពី ៦ឆ្នាំ ដល់ ១៧ឆ្នាំ បានចុះឈ្មោះនៅមជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធក្រុងប៉ោយប៉ែត (សិស្ស២៧% ចូលរៀនថ្មី)។ ៩២% នៃសិស្សដែលបានប្រឡងឆ្នាំ២០២៤ បានឆ្លងកាត់ដោយជោគជ័យ។ សិស្ស ៧១នាក់ (ស្រី២៩នា) មកពីកម្មវិធីអប់រំក្រៅប្រព័ន្ធបានធ្វើសមាហរណ៍កម្មទៅក្នុងសាលារៀនរដ្ឋថ្នាក់ទី៧ ក្នុងឆ្នាំ២០២៤។

**កម្មវិធីពន្លឿនថ្នាក់អប់រំក្រៅប្រព័ន្ធនៅក្រុងប៉ោយប៉ែត៖** កុមារជាច្រើនដែលចុះឈ្មោះចូលរៀននៅកម្មវិធីអប់រំក្រៅប្រព័ន្ធ មិនដែលចូលរៀន ឬមិនបានចូលរៀនក្នុងរយៈពេលដ៏

សំខាន់មួយ។ ជាញឹកញាប់កុមារដែលចុះឈ្មោះចូលរៀនមានអាយុច្រើនជាងអាយុដែលបានកំណត់ សម្រាប់ថ្នាក់ដែលពួកគេចុះឈ្មោះចូលរៀន ហើយនេះអាចប៉ះពាល់ដល់ការលើកទឹកចិត្ត និងសមត្ថភាពរៀនរបស់ពួកគេ។ ថ្នាក់ពន្លឿនបានបង្រួបបង្រួមកម្មវិធីសិក្សារយៈពេល ២ឆ្នាំ ទៅជា ១ឆ្នាំ ដោយផ្តល់ការពន្លឿនសម្រាប់សិស្សឱ្យឈានទៅថ្នាក់ខ្ពស់ និងបញ្ចូលទៅក្នុងសាលារៀនរដ្ឋកាន់តែលឿន។ តំណក់ទឹក ផ្តល់ជូននូវថ្នាក់ពន្លឿន ថ្នាក់ទី១&២ និងថ្នាក់ទី៣&៤។ បច្ចុប្បន្នមានកុមារ ចំនួន៤៨នាក់ បានចុះឈ្មោះក្នុងថ្នាក់ពន្លឿន (១១% នៃចំនួនកុមារសរុបដែលបានចុះឈ្មោះ)។ ៧៧% នៃកុមារដែលបានចុះឈ្មោះចូលរៀនថ្នាក់ពន្លឿនមិនបានចូលរៀនពីមុនមកទេ។ កុមារ ៧៣% ចុះឈ្មោះក្នុងកម្មវិធីចំណាកស្រុកដោយសុវត្ថិភាពនៅក្រុងប៉ោយប៉ែត។

**បញ្ហាប្រឈម**

- សិស្សបានបោះបង់ការសិក្សាពីកម្មវិធីអប់រំក្រៅប្រព័ន្ធក្នុងឆ្នាំ២០២៤ គឺ១១.៨៣%។
- កត្តាសម្ពាធសេដ្ឋកិច្ច ដែលបណ្តាលឱ្យមានការកើនឡើងនៃការចល័តការងារ ឬជំពាក់បំណុលគេ។ គ្រួសារដែលមានចំណូលទាបកំពុងបន្តរងឥទ្ធិពលដោយផលប៉ះពាល់សេដ្ឋកិច្ចនៃកូវីដ១៩ និងការកើនឡើងអត្រាអតិផរណាឆ្នាំ២០២២។ នៅក្នុងការវាស់វែងលទ្ធផលក្នុងខែធ្នូ ឆ្នាំ២០២៤ គ្រួសារចំនួន ៣៣% ដែលត្រូវបានស្ទង់មតិ បានឆ្លើយតបថាពួកគេមានប្រាក់ចំណូលមិនគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការគ្រួសារជាមូលដ្ឋានសម្រាប់ទីជម្រក អាហារ ការអប់រំ។ល។
- នៅចុងឆ្នាំ២០២៤ សិស្ស ៦០% នៅថ្នាក់ទី៦ ត្រូវបានចុះឈ្មោះសម្រាប់រយៈពេល ៤ឆ្នាំ ឬច្រើនជាងនេះ។
- មុនឆ្នាំ២០២៤ កម្មវិធីមិនគ្រប់គ្រាន់ដែលកំណត់គោលដៅសម្រាប់ភាពធន់នឹងសេដ្ឋកិច្ចគ្រួសារ។ កម្មវិធីពន្លឿនមិនគ្រប់គ្រាន់នៅក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ
- ការចុះឈ្មោះក្មេងស្រីមានកម្រិតទាប។ ៤៤.៧% នៃសិស្សដែលបានចុះឈ្មោះក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ គឺជាក្មេងស្រី។
- កត្តាអាកប្បកិរិយាសង្គម និងវប្បធម៌ ជារឿយៗក្មេងស្រីអាចត្រូវបានគេរំពឹងថានឹងមើលថែប្អូនស្រីតូចៗ។

**ការអប់រំក្រៅប្រព័ន្ធ - យុទ្ធសាស្ត្រក្នុងឆ្នាំ២០២៥**

- ការតាមដានអវត្តមាននឹងត្រូវបានសម្របសម្រួល និងកំណត់គោលដៅកាន់តែ ច្រើន។ តំណក់ទឹក នឹងតាមដានការចូលរួម ដើម្បីកំណត់អត្តសញ្ញាណសិស្សដែលអវត្តមានញឹកញាប់ (ដែលងាយរងគ្រោះបំផុត) ហើយនឹងតាមដាននៅថ្ងៃដំបូងនៃអវត្តមាន។
- ការបង្កើនធនធាន និងការសរសេរកម្មវិធីនៅគម្រោងអនាគតកុមារ និងបន្តពង្រឹងការសម្របសម្រួលជាមួយគម្រោងអប់រំក្រៅប្រព័ន្ធ និងក្រុមផ្សព្វផ្សាយសហគមន៍ ដើម្បីកំណត់គោលដៅ និងបញ្ជូនគ្រួសារដែលមានដើមទុនសេដ្ឋកិច្ច និងសង្គមទាបខ្លាំង។

| | |
|---|---|
| | - ថ្នាក់ពន្លឿនសម្រាប់ថ្នាក់ទី៣ និងទី៤ ក្នុងឆ្នាំ២០២៥<br>- តំណាក់ទឹក នឹងតាមដាន និងវិភាគទិន្នន័យបែងចែកយេនឌ័រសម្រាប់ឆ្នាំ២០២៥ សម្រាប់ក្មេងស្រី នៅក្នុងគម្រោងអប់រំក្រៅប្រព័ន្ធ និងការចុះឈ្មោះដោយផ្ទាល់ដើម្បីកំណត់កត្តាដែលប៉ះពាល់ដល់ការចុះឈ្មោះការចូលរៀន និងការអនុវត្តការសិក្សា។<br>- តំណាក់ទឹក នឹងទាក់ទងទៅអង្គការផ្សេងទៀតដែលអនុវត្តកម្មវិធីអប់រំក្នុងខេត្តបន្ទាយមានជ័យ ដើម្បីពិភាក្សាអំពីនិន្នាការ និងបញ្ហាប្រឈមសម្រាប់ការរក្សាទុកសិស្ស និងបង្កើតរូបភាពកាន់តែច្បាស់អំពីស្ថានភាពនៅក្នុងខេត្ត។ |
| បទបង្ហាញវាគ្មិនទី៣<br><br>លោក ជា ចិន្តា ប្រធានកម្មវិធីផ្នែកអប់រំ អង្គការUWS<br><br>ធ្វើបទបង្ហាញអំពី៖<br><br>យុទ្ធសាស្ត្រ Zero Poverty Education។ | UWS ជាស្ថាប័នអន្តរជាតិមិនរកផលចំណេញ ដែលបានបង្កើតឡើងនៅឆ្នាំ ២០០៨ ដើម្បីផ្តល់ឱ្យកុមារដែលរស់នៅតំបន់ដាច់ស្រយាល និងក្រុមងាយរងគ្រោះទទួលបានឱកាសអប់រំប្រកបដោយគុណភាព និងបរិយាបន្ន។ UWS សហការជាមួយដៃគូ សហគមន៍ និងរដ្ឋាភិបាល ដើម្បីបង្កើតសាលារៀន បណ្តុះបណ្តាលគ្រូ និងពង្រឹងប្រព័ន្ធអប់រំ។ បច្ចុប្បន្ននេះ UWS កំពុងដំណើរការនៅតំបន់ជនបទនៃប្រទេសនេប៉ាល់ កម្ពុជា មីយ៉ាន់ម៉ា និងម៉ាដាហ្គាស្កា ដើម្បីផ្តល់ការសិក្សាដែលមានគុណភាព និងបង្កប់វប្បធម៌អប់រំក្នុងសហគមន៍សម្រាប់ជំនាន់មនុស្សអនាគត។<br><br>នៅកម្ពុជា UWS បានសាងសង់សាលារៀនចំនួន១៣៦ បានផ្ទេរសាលាចំនួន ៦៦ ទៅឱ្យរដ្ឋាភិបាល និងការគាំទ្រដំណើរការបន្តសម្រាប់សាលារៀនដែលសកម្មចំនួន៧២ ដែលចំនួនសិស្សទទួលបានការគាំទ្រពីកម្មវិធីចំនួន១០,៧៥៩នាក់ ដែលអនុវត្តនៅ៧ខេត្ត។<br><br>ចក្ខុវិស័យ UWS គឺចង់ឃើញកុមារនៅគ្រប់ទីកន្លែងបានសម្រេចនូវគោលបំណង ឬក៏សក្តានុពលរបស់ខ្លួនតាមរយៈការអប់រំ។ ហើយអ្វីដែលជា បេសកកម្ម គឺចង់ឃើញថាយើងធ្វើការយ៉ាងណា ដើម្បីលើកទឹកចិត្តឱ្យកុមារតាមតំបន់ដាច់ស្រយាលបានសម្រេចនូវចក្ខុវិស័យ ឬក៏សក្តានុពលរបស់ខ្លួនតាមរយៈការអប់រំ។ UWS មានបេសកកម្ម ជួយឱ្យកុមារនៅតំបន់ដាច់ស្រយាលទទួលបានការអប់រំដែលមានគុណភាព តាមរយៈការអភិវឌ្ឍសាលារៀននិងការចូលរួមរបស់សហគមន៍។ ដើម្បីសម្រេចបាននូវគោលដៅនេះ យើងបានដាក់ចេញយុទ្ធសាស្ត្រចម្បងដូចខាងក្រោម៖<br><br>• **គុណភាពអប់រំ៖** ផ្តោតលើការកែលម្អគុណភាពអប់រំតាមរយៈទិសដៅសំខាន់៣៖ *មូលដ្ឋានការរៀន៖* ពង្រឹងជំនាញអាន និងគណិតវិទ្យា ជាគន្លឹះសំខាន់សម្រាប់ការរៀនបន្តរបស់កុមារ។ *គុណភាពបង្រៀន៖* សាលារៀនដែលកសាងស្ថិតនៅតំបន់ដាច់ស្រយាល បណ្តាលឱ្យមានការលំបាកក្នុងការជ្រើសរើសគ្រូ។ បានជ្រើសគ្រូសហគមន៍ និងផ្តល់ការបណ្តុះបណ្តាលបែបវិជ្ជាជីវៈ និងបង្រៀនតាមមុខវិជ្ជា។ *ការចូលរួមស្មើគ្នា៖* ធ្វើការលើបញ្ហាយេនឌ័រ និងបរិយាបន្ន ដើម្បីធានាថាសិស្សទាំងអស់មានឱកាសសិក្សាដោយស្មើគ្នា។ |

| | |
|---|---|
| | • **និរន្តរភាព៖** ធ្វើការជាមួយដៃគូនានា ដើម្បីធានាថាការអភិវឌ្ឍការអប់រំនឹងបន្តនិរន្តរភាពដោយៈ ការធ្វើផែនការជាមួយរដ្ឋាភិបាល និងអង្គការដៃគូ ដើម្បីបន្តគាំទ្រសាលារៀនបន្ទាប់ពីគម្រោងបញ្ចប់។ បង្កើនសមត្ថភាពគ្រូ និងនាយកសាលាដោយផ្តល់វគ្គបណ្តុះបណ្តាលបន្ថែម។ ពង្រឹងសមត្ថភាពសហគមន៍ ជាពិសេស SMC និងក្រុមអាណាព្យាបាលក្នុងការគាំទ្រការអប់រំ។<br>• **ការពង្រីក និងអភិវឌ្ឍ៖** បន្តសិក្សាតំបន់ដែលមានតម្រូវការ ក្នុងការអភិវឌ្ឍបន្ថែម ដើម្បី៖ ១.សាងសង់ និងជួសជុលអគារសិក្សា នៅកន្លែងដែលមានតម្រូវការ ២.បណ្តុះបណ្តាលគ្រូបន្ថែម ជាពិសេសគ្រូសហគមន៍ដែលមិនទាន់មានសញ្ញាបត្រផ្លូវការជាគ្រូបង្រៀន ៣.ជួយសិស្សដែលមានហានិភ័យក្នុងការបោះបង់សិក្សាដោយសម្គាល់តាមការអវត្តមាន និងស្ថានភាពគ្រួសារ ៤.ផ្តល់សម្ភារៈសិក្សាបន្ថែមសម្រាប់សិស្សដែលគ្មានលទ្ធភាពទិញបាន។<br>• Zero Education Poverty៖ គម្រោងថ្មីមួយដែលយើងនឹងចាប់ផ្តើមក្នុងពេលខាងមុខ មានឈ្មោះថា Zero Education Poverty ដែលមានគោលបំណងបន្តការបង្កើតឱកាសអប់រំដល់កុមារទាំងអស់ ចូលរួមជាមួយដៃគូសហការទាំងអស់ក្នុងតំបន់ ដើម្បីសម្រេចគោលដៅរួម ប្រើប្រាស់បទពិសោធន៍ដែលបានសម្រេចជោគជ័យ ដើម្បីអនុវត្តក្នុងសាលារៀនថ្មីៗនាពេលក្រោយ។<br><br>លោកបន្ថែម៖ UWS តែងតែធ្វើកិច្ចពិភាក្សាជាប្រចាំជាមួយគ្រូបង្រៀន និងសហគមន៍ ដើម្បីវាយតម្លៃលទ្ធផលការងារ និងកំណត់តម្រូវការថ្មីៗ។ យើងជឿជាក់ថាការអប់រំ គឺជាគន្លឹះដ៏សំខាន់បំផុតសម្រាប់ការផ្លាស់ប្តូរជីវិតកុមារ។ |
| បទបង្ហាញវាគ្មិនទី៤<br>លោក សឿង សុផា<br>នាយកផ្នែកកម្មវិធីសិក្សាទូទៅ អង្គការPSE<br>ធ្វើបទបង្ហាញពីកម្មវិធីពន្លឿន | លោកចែករំលែកពីកម្មវិធីពន្លឿន សម្រាប់ក្រុមគោលដៅកុមារដែលនៅតាមគំនរសំរាម។ ដោយសារអត្រាកុមារដែលនៅក្រៅសាលាខ្ពស់ ដែលភាគច្រើនរៀនយឺត មិនបានរៀន ឬមួយក៏ជាអ្នកបោះបង់ ដែលយើងហៅថាជាឆ្នាំ។ កម្មវិធីពន្លឿននេះ គឺជាកម្មវិធីមួយក្នុងក្របខណ្ឌរបស់ PSE ដែលធ្វើការបញ្ចូលគ្នារវាងកម្មវិធីសិក្សា២ឆ្នាំឱ្យមករៀនតែ១ឆ្នាំ ដោយចំណាយពេលតែ ៣ឆ្នាំ អាចចប់បឋមសិក្សា។ ប៉ុន្តែ ការកំណត់កម្រិតអាយុមានបញ្ហា គឺយើងយកតែអាយុតែ ១២ឆ្នាំទេ។ កុមារមានអាយុ ១២ឆ្នាំ ពេលដែលគាត់ចូលមករៀនគឺយើងពន្លឿន គាត់អាចរៀនទៅដល់ថ្នាក់ទី៩ គាត់អាចត្រឡប់ចូលទៅសាលារដ្ឋវិញ។<br><br>យើងអនុវត្តរយៈពេលប្រហែលជាង ២០ ឆ្នាំមក មានការលំបាកខ្លាំង នៅពេលដែលយើងយកកុមារដែលមានអាយុ ១២ ឆ្នាំចូលមករៀននៅថ្នាក់ទី១ ហៅឆ្នាំទី១។ គាត់ពិបាកពិបាកតាំងពី ចំណេះដឹង ឥរិយាបថ ពិបាកគ្រប់បែបយ៉ាង។ គាត់មិនមានបំណិននៃការសិក្សាទេ។ ដូចនេះ ២ឆ្នាំមុន យើងបានបង្កើតឆ្នាំមួយទៀត គឺឆ្នាំទី0 ព្រោះយើងមាន ឆ្នាំទី១ ដល់ ទី៤។ យើងបង្កើតឆ្នាំទី0 សម្រាប់តែក្មេងអាយុ១១ឆ្នាំ ហើយគាត់រៀនខ្សោយបំផុត ឬមួយជាមនុស្សដែលបោះបង់ពីការសិក្សាយូរ ឬមួយក៏គាត់អត់ដែលបានចូលសាលារៀន |

| | |
|---|---|
| | តែម្តង។ យើងធ្វើវាដូចជាថ្នាក់មត្តេយ្យសម្រាប់ក្មេងជំទង់ ដែលយកម៉ូដែលមួយគេហៅ Magnet School ដែលគេប្រើនៅក្នុងសហរដ្ឋអាមេរិក ឬហៅថាសាលារៀនដែកធក់។<br><br>មកដល់ថ្នាក់ទី៩ គាត់មានផ្លូវបំបែក ដោយសារអាយុច្រើន។ ដូចលោកគ្រូខាងដំណាក់ទឹក យើងមានដល់ ២០ឆ្នាំជាងទៀត ដែលចូលមកមិនទាន់ចេះកាន់ប៊ិចផង។ ធ្វើបែបនេះ យើងពន្លឿនមកដល់ថ្នាក់ទី៩ គឺយើងឱ្យជម្រើសគាត់ ២ដោយឱ្យគាត់អាចរៀនចប់អាចឡើងមករៀនទី៩ ឬគាត់ទៅរៀនជំនាញក៏បានតាមការចង់របស់គាត់។ ប៉ុន្តែយើងមានលក្ខខណ្ឌដែរ កាលណាគាត់អាយុច្រើន គឺលើកទឹកចិត្តគាត់ទៅជំនាញច្រើនជាង។ នៅឆ្នាំទី៤ ឃើញថាអាយុគាត់លើសពី ១៥ឆ្នាំហើយ។ យើងដឹងច្បាប់ការងារ គឺ ១៥ឆ្នាំ គាត់អាចធ្វើការងារបានហើយ។ យើងសិក្សាវិធីមួយ យើងបំបែកវាដោយយកម៉ូឌែលរបស់ក្រសួង គឺបំបែកជា២។ ក្រសួងបំបែកថ្នាក់សង្គម និងថ្នាក់វិទ្យាសាស្ត្រ។ ប៉ុន្តែយើងបំបែកសិស្សដែលត្រៀមខ្លួនទៅបន្តការសិក្សានៅចំណោះទូទៅ ទៅថ្នាក់ទី៩ ដល់ទី១២ ឬមហាវិទ្យាល័យ និងក្មេងដែលសម្រេចចិត្តមិនបន្ត ដោយងាកទៅរកការងារអាជីព។ យើងនឹងបណ្តុះបណ្តាលគាត់ សម្រាប់តែត្រៀមតែទៅជំនាញ។<br><br>យើងកំពុងសិក្សាថែមទៀត ដោយចង់ទៅបំបែកនៅថ្នាក់ទី៣ ឆ្នាំទី៣ ដើម្បីត្រៀមខ្លួន។ ប៉ុន្តែដើម្បីហែកកម្មវិធីនេះបាន យើងត្រូវការក្រុមការងារមួយចំនួន ឬហៅថាក្រុមតម្រង់ទិស។ យើងត្រូវតម្រង់ទិសអាជីពថា គាត់ចង់ទៅណា គាត់ចូលចិត្ត ទេពកោសល្យអ្វី។ យើងមានតេស្តវាយតម្លៃទេពកោសល្យ។ មិនធ្វើត្រឹមតែប៉ុណ្ណឹងទេ យើងធ្វើការជាមួយនឹងអាណាព្យាបាលទៀត ពីព្រោះបើមិនអញ្ចឹងទេយើងមិនអាចធ្វើបានទេ។ |
| បទបង្ហាញវាគ្មិនទី២<br><br>លោក យិនសៀង សុមេធ ប្រធានកម្មវិធីអប់រំ<br><br>អង្គការ AEA | អង្គការAEA ជាមួយដៃគូប្រមាណជាង៣០អង្គការ កំពុងរួមគ្នាអនុវត្ត គម្រោងភាពជាដៃគូផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ការនៅកម្ពុជា។ បន្ថែមពីនេះ ក៏មានកម្មវិធីគម្រោងផ្សេងផងដែរ ដែលកំពុងតែអនុវត្តផ្តោតការយកចិត្តទុកដាក់ទៅដល់សាលាបឋមសិក្សាគោលដៅប្រមាណ ១៧០០សាលារៀន ទូទាំងប្រទេស។ លោកបានធ្វើការឆ្លុះបញ្ចាំងឡើងវិញបន្តិចតាមពិតនៅក្នុងបទបង្ហាញដោយក្រុមការងារNEP ក៏ដូចជាបទបង្ហាញដោយវាគ្មិនផ្សេងៗទៀត គឺបានលើកឡើងលើបញ្ហាជាច្រើន ដែលធ្វើឱ្យប៉ះពាល់ដល់ការសិក្សារបស់កុមារ។ លទ្ធផលនៃការសិក្សារបស់កុមារ ក៏ដូចជាប៉ះពាល់ទៅដល់សមធម៌នៃការចូលរៀន ក៏ដូចជាការសិក្សាប្រកបដោយគុណភាពនៅកម្រិតបឋមសិក្សា។ ក៏ប៉ុន្តែនៅក្នុងនេះលោកយកតែចំណុចមួយ ដោយសារប្រធានបទរបស់គឺពាក់ព័ន្ធនឹងការគាំទ្រទៅដល់កុមារដែលជាសិស្សរៀនយឺត មិនបានល្អប្រសើរទៅតាមអ្វីដែលក្រសួងបានកំណត់។<br><br>ការសិក្សាស្រាវជ្រាវមួយដែលបានធ្វើមុនឆ្នាំ២០១៥ ពាក់ព័ន្ធនឹងការអនុវត្តម៉ោងសិក្សានៅកម្ពុជា ជាពិសេសពាក់ព័ន្ធនឹងការអនុវត្តម៉ោងរៀន គឺមិនទាន់បានឆ្លើយតបទៅនឹងអ្វីដែលជាគោលការណ៍កំណត់នៅក្នុងកម្មវិធីសិក្សា។ ក្រសួងបានកំណត់ថាក្នុងមួយសប្តាហ៍ត្រូវបង្រៀន ២៥ម៉ោង តែការអនុវត្តបានតែខ្ទង់ ១៨ម៉ោង ដែលជាចំណុចមួយអាចធ្វើឱ្យប៉ះ |

ពាល់ទៅដល់ដំណើរការនៃការសិក្សា។ ប្រសិនជាយើងមើលទៅក្នុងក្របខណ្ឌកម្មវិធីសិក្សា ដែលក្រសួងអប់រំ ទើបតែបានដាក់ចេញនៅក្នុងអាណត្តិមុន ជាពិសេសនៅពេលដែលកម្មវិធីសិក្សាត្រូវបានកែសម្រួលឡើងវិញនៅខ្ទង់ឆ្នាំ២០១៦ ដោយ១សប្តាហ៍ត្រូវបង្រៀន ៣០ម៉ោង ក្នុង១ឆ្នាំសិក្សាយ៉ាងតិចឱ្យបាន ១០៥០ម៉ោង។ ទោះបីជាកម្រិតនេះ នៅក្នុងកម្រិតមួយទៀតបើប្រៀបធៀបទៅនឹងស្តង់ដា ដែលអង្គការUNESCO បានកំណត់ក្នុងរង្វង់ ១២០០ម៉ោង តែយើងគិតថាជាចំនួនមួយអាចទទួលយកបាន។ ក្រសួងបានកំណត់ការបង្កើនម៉ោងសិក្សា តាមរយៈកម្មវិធីសិក្សាថ្មី។ កំឡុងកូវីដ១៩ បញ្ហាប្រឈម គឺប្រហែលជា ៥០០ម៉ោងជាង ត្រូវបានបាត់បង់ ទាំងទៅលើអ្នកផ្តល់ ក៏ដូចជាអ្នកទទួលបានសេវាអប់រំ។ AEA រួមជាមួយនឹងដៃគូ បានធ្វើការជាមួយនឹងក្រសួងអប់រំ ធ្វើការពិភាក្សា ដើម្បីផ្តល់នូវកម្មវិធីពិសេសមួយ ដោយឡែកក្រៅពីកម្មវិធីបំប៉នសិស្សរៀនយឺតដែលក្រសួងមាន។ យើងបានធ្វើការពិភាក្សា ជាពិសេសជាមួយនឹងនាយកដ្ឋានបឋមសិក្សា ដើម្បីអនុញ្ញាតចេញជាគោលការណែនាំសម្រាប់ការអនុវត្តថ្នាក់បំប៉នសិស្សរៀនយឺត ដែលជួយទៅដល់សិស្សរៀនយឺត ក៏ដូចជាជួយទៅដល់សាលាក្នុងការអនុវត្តកម្មវិធីសិក្សាបន្ថែម។ តាមរយៈការផ្តល់ការអនុញ្ញាត គឺយើងបានធ្វើការជាមួយនឹងសាលារៀនគោលដៅនៅក្នុងខេត្តចំនួន១១។ យើងបានអនុវត្តនៅក្នុងរង្វង់ ២ខែទៅ៣ខែ នៅក្រោយឆមាសទី១។ ហេតុអ្វី បានជាយើងអនុវត្តនៅក្រោយឆមាសទី១? គឺយើងចង់បានទិន្នន័យថា តើមានកុមារប៉ុន្មាននាក់ ក្រោយចប់ឆមាសទី១ នៅរៀនយឺតនៅឡើយ។

ការអនុវត្តគឺ ៣ម៉ោងក្នុង១ថ្ងៃ និង ៥ថ្ងៃក្នុង១សប្តាហ៍ ដោយផ្តោតទៅលើសាលារៀនដែលមានសក្តានុពលដែលអាចមានបន្ទប់ អាចមានគ្រូស្ម័គ្រចិត្តនៅក្នុងការធ្វើសកម្មភាពការងារនេះបាន។ យើងអាចពិនិត្យមើលលទ្ធផលជារួមបាននៅក្នុងឆ្នាំទី១ ដែលយើងបានរួមគ្នាសហការអនុវត្ត គឺយើងមានក្មេងដែលជាសិស្សរៀនយឺត ក្រោយពីអនុវត្តមានបម្រែបម្រួលដោយយោងបានលទ្ធផលតេស្ត។ នៅក្នុងការធ្វើតេស្តដើមគ្រា គឺមានកុមាររហូតទៅដល់ ៦០% ដែលរៀនយឺត។ ប៉ុន្តែនៅក្រោយពេលដែលបញ្ចប់រយៈពេល ៧ខែ ក្រៅម៉ោងសិក្សា ឃើញថាលទ្ធផលមានការប្រែប្រួល កុមារនៅសល់ប្រហែល២១% ដែលរៀនយឺត។ នេះគឺជាលទ្ធផលទី១ នៅក្នុងឆ្នាំទី១ ដែលយើងបានធ្វើការវាស់វែង។

ចំពោះការចំណាយ គ្រូទទួលប្រាក់ឧបត្ថម្ភបន្ថែមដែលយើងផ្តល់ឱ្យគឺតិច។ ប្រសិនជាយើងធ្វើការវិភាគទៅ កុមារដែលនៅក្នុងថ្នាក់រៀនមានចន្លោះពី ៣៥នាក់ ទៅ ៤០នាក់ ក្នុងមួយថ្នាក់។ ហើយគ្រូម្នាក់ យើងផ្តល់ប្រាក់លើកទឹកចិត្តតែ ៣២ម៉ឺនរៀល ក្នុងមួយខែ។ មានន័យថាកម្មវិធីចំណាយក្នុង១ថ្ងៃអស់ប្រហែល ៥០០រៀល/កុមារម្នាក់។ ទាំងនេះអាចជាមូលដ្ឋានមួយ សម្រាប់អភិបាល/រងស្រុក មន្ទីរ និងស្រុកពាក់ព័ន្ធផ្សេងទៀត ឬក៏ដូចជាអង្គការដៃគូអាចយកធ្វើជាមូលដ្ឋានសម្រាប់ការពិចារណាបាន។

| | |
|---|---|
| | ការអនុវត្តកម្មវិធីសិក្សាម៉ោងបន្ថែម ២ម៉ោង/មួយថ្ងៃ ដែលក្រសួងបានកំណត់។ យើងនឹងព្យាយាមបន្តការគាំទ្រ ដោយសហការជាមួយនឹងដៃគូអនុវត្តគម្រោងរបស់យើង ក៏ដូចជាសាលារៀនក្នុងការធ្វើការងារនេះ ដើម្បីធានាថាអ្វីដែលជាការខិតខំប្រឹងប្រែងមិនត្រូវបញ្ចប់ ហើយនឹងក្លាយទៅជាកម្មវិធីមួយដែលមាននិរន្តរភាព។ យើងចង់ប្រែក្លាយពីកម្មវិធីមួយដែលមានដំណើរការតែរយៈពេល ២/៣ខែ ក្លាយជាកម្មវិធីសិក្សាពេញ១ថ្ងៃ ដែលអនុវត្តពេញ១ឆ្នាំសិក្សា។ យើងបានពិភាក្សាជាមួយដៃគូអនុវត្តដែរថា យើងនឹងប្រែក្លាយការអនុវត្តកម្មវិធីបំប៉នសិស្សរៀនយើង ២/៣ខែ នេះមកជាការគាំទ្រនៅក្នុងប្រព័ន្ធ ដោយផ្សារភ្ជាប់ទៅនឹងកម្មវិធីថ្មីៗ ជាពិសេសថ្នាលបឋម ដែលក្រសួងទើបតែបានផ្សព្វផ្សាយអនុវត្ត។ |
| សំណួរពីអ្នកចូលរួម<br><br>តើមានកត្តាប្រឈមសំខាន់ៗអ្វីខ្លះ នៅក្នុងការអនុវត្តថ្នាក់ពន្លឿន ជាពិសេសអនុវត្តយ៉ាងដូចម្ដេចនៅក្នុងតំបន់ដាច់ស្រយាល? | លោក សាម៉េតៈ បញ្ហាប្រឈមចម្បង ផ្ដើមពីការគ្រប់គ្រងរបស់សាលារៀន។ ដូច្នេះ ត្រូវមានគោលការណ៍ណែនាំជាមុន ដើម្បីអាចសហការជាមួយសាលារៀន និងអាជ្ញាធរបានល្អ។ ចាប់ផ្ដើមពីរដ្ឋបាលរបស់សាលារៀន។ យើងធ្វើការងារជាមួយនាយកដ្ឋានបឋមសិក្សាដោយជំហានដំបូងគឺការរៀបចំគោលការណ៍ណែនាំ សម្រាប់ការអនុវត្ត។ អង្គការដៃគូរបស់យើង ក៏បានចូលរួមក្នុងកិច្ចសហការនេះ ដែលសង្កត់ធ្ងន់លើក្រុមការងារអន្តរក្រសួង និងអង្គការដៃគូ ដើម្បីអាចជួយក្នុងការគ្រប់គ្រង និងការអនុវត្តឱ្យមានប្រសិទ្ធភាព។ សម្រាប់ការអនុវត្តផ្ទាល់ វាមិនមែនជារឿងសាមញ្ញទេ្បីយ។ យើងត្រូវមានការរៀបចំយុទ្ធសាស្ត្រ ក៏ដូចជាការចូលរួមពីស្ថាប័នពាក់ព័ន្ធ។ ការអនុវត្តទទួលបានជោគជ័យ និងពង្រីកឱ្យបានទូលំទូលាយ ត្រូវមានការចូលរួមរបស់សាលា និងក្រុមការងារដៃគូ។ ជាពិសេស នៅតំបន់ដែលជួបការលំបាក ដូចជាខេត្តជាប់បឹងទន្លេសាប ដែលខ្វះខាតធនធានបច្ចេកទេស និងធនធានមនុស្ស។ ការអនុវត្តនៅតំបន់ទាំងនេះ មានសញ្ញាបង្ហាញពីការលំបាកច្រើន ហើយត្រូវការសហការណ៍យ៉ាងជិតស្និទ្ធជាងមុន។ ឧទាហរណ៍ នៅពេលយើងអនុវត្តនៅក្នុងរដូវទឹកជំនន់។ តំបន់ទឹកឡើង ក្លាយជាឧបសគ្គធំសម្រាប់ការអនុវត្តកម្មវិធីបំប៉ន និងការសិក្សាពេញម៉ោង។ ដូច្នេះយើងត្រូវការពិចារណាពីបញ្ហាប្រឈមសម្រាប់ភូមិសាស្ត្រនេះផងដែរ។<br><br>លោក យី ឧបបានៈ យើងមានដាក់លក្ខខណ្ឌអនុគ្រោះ ដើម្បីជួយសិស្សដែលជួបបញ្ហាប្រឈម។ សម្រាប់គ្រួសារក្រីក្រ និងគ្រួសារដែលមានកូនរៀនលើសពី ២នាក់ យើងមិនបានយកថវិកាលើកូនលើសពី២នាក់ដែរ។ យើងបានអនុគ្រោះសិស្ស ៩០នាក់ ដោយមិនទាមទារថវិកាពីគ្រួសារ។ ពេលអាណាព្យាបាល ឃើញថាសាលាជួយដល់កូនៗ សេចក្ដីស្មោះត្រង់ នេះធ្វើឱ្យគាត់មានឆន្ទៈចូលរួម និងគាំទ្រថវិកាកាន់តែច្រើនផងដែរ។<br><br>លោក សូផាៈ យើងកំពុងអនុវត្តជួយកុមាររៀនយឺតនៅសាលារៀនរដ្ឋ គឺបែបហៅពន្លឿនក្រៅក្របខណ្ឌ។ យើងបានបង្កើតកម្មវិធីមួយហៅថាកម្មវិធីបណ្ដុំ។ កម្មវិធីបណ្ដុំ គឺឱ្យសិស្សទាំងអស់ដែលរៀនយឺតធ្វើតេស្ត។ បន្ទាប់មកយើងចាប់ផ្ដើមបង្កើតកម្មវិធីថ្មីមួយ គឺយកមូលដ្ឋានគោលរបស់អំណាន គណិតវិទ្យា និងមុខវិជ្ជាផ្សេងៗដាក់ជាជុំៗ ដោយបង្រៀនគាត់លើមូលដ្ឋានគ្រឹះ ឬអ្វីដែលគាត់មិនទាន់មាន។ ប្រសិនជាគាត់នៅតែតាមមិនទាន់ទៀត យើង |

| | |
|---|---|
| | មានកម្មវិធីមួយទៀតគឺ Poll Out Project (POP) គឺទាញគាត់ចេញពីបណ្ដុំនោះទៀត ដោយយកគាត់ទៅបណ្ដុះបណ្ដាលផ្ដាច់តែម្ដង។ រួចហើយ យកគាត់ចូលក្នុងបណ្ដុំវិញ។ |
| សំណួរពី លោក ប៉ា ស៊ីថា<br>អនុប្រធានមន្ទីរអេ.យ.ក ខេត្តរតនគិរី។ តើ PSE ធ្វើការតែជាមួយកុមារមានអាយុចាប់ពី ១១ឆ្នាំឡើង? ចុះកុមារដែលក្រោមអាយុនេះ ដែលមិនបានចូលរៀន ហេតុអ្វី បានជាមិនបានយកចិត្តទុកដាក់ ឬត្រូវបោះបង់ពួកគាត់ចោល? | លោក ស៊ីថា៖ តើត្រូវធ្វើដូចម្ដេចដើម្បីឱ្យមានការចូលរួម និងឯកភាពផ្ទៃក្នុងនៅក្នុងអង្គភាពមួយ? ដើម្បីឱ្យមានការចូលរួម និងឯកភាពផ្ទៃក្នុងសំខាន់បំផុតគឺថ្នាក់ដឹកនាំឬប្រធានអង្គភាព ប្រសិនជាសាលា គឺនាយក ដែលមានសមត្ថភាព។ ត្រូវមានមេដឹកនាំ ជានាំមុខក្នុងការរៀបចំការសម្រេចចិត្ត។<br>លោក សុផា៖PSE មិនមែនធ្វើការតែជាមួយកុមារអាយុ ១១ឆ្នាំឡើងនោះទេ។ យើងជួយកុមារចាប់តាំងពីអាយុ ៣ឆ្នាំ មកម្លេះ។ ប៉ុន្តែនៅទីនេះ យើងនិយាយអំពីកម្មវិធីពន្លឿន។ បានជាលោក មិនលើកមកនិយាយ។ PSE មានកម្មវិធីផ្សេងទៀតដូចជា កម្មវិធីសហគមន៍ Daycare ដែលជួយមើលថែកុមារ ដើម្បីឱ្យឪពុកម្ដាយអាចចេញទៅធ្វើការ។ PSE មានកម្មវិធីមើលថែ រហូតឈានដល់មេត្តេយ្យដែលផ្ដល់អាហារថ្ងៃត្រង់ទៀតផង។ ប៉ុន្តែក៏មានការប្រឈមផងដែរ ដោយត្រូវប្ដូរពេលសិក្សាតាមកម្មវិធីសិក្សារបស់រដ្ឋ។ PSE ក៏បានបង្កើតកម្មវិធីផ្សេងៗទៀតផងដែរ ដូចជាឆ្នាំទី0 សម្រាប់កុមារដែលមានអាយុ ៨-៩ឆ្នាំ ជាដើម។ |
| លោកស្រី Maya បានផ្ដល់ជាជាតុចូលគឺ មានអង្គការក្រៅរដ្ឋាភិបាលបានអនុវត្តកម្មវិធីច្រើនដែលទទួលបានផលល្អក្នុងការជួយសិស្សរៀនយឺត ឬសិស្សដែលមានបញ្ហា។ ប៉ុន្តែទាំងនេះវាជាទំនួលខុសត្រូវធំរបស់រដ្ឋាភិបាល ថាតើយើងអាចបញ្ចូលវាទៅកម្មវិធីរបស់រដ្ឋបានយ៉ាងដូចម្ដេច? | លោក សាម៉េត ឆ្លើយ៖ NGO ត្រូវដឹងថា យើងនៅកន្លែងណា ហើយរដ្ឋាភិបាលនៅកន្លែងណា? តើរដ្ឋាភិបាលត្រូវការឱ្យយើងជួយកន្លែងណា? សម្រាប់ AEA យើងចាប់ផ្ដើមដោយស្វែងរកការគាំទ្រពីអ្នកតស៊ូមតិ អ្នកដែលធ្វើការនៅក្នុងវិស័យអប់រំ ដើម្បីឱ្យគាត់ផ្ដល់ការគាំទ្រ ដោយសារយើងធ្វើការលើការគាំទ្រលើប្រព័ន្ធ ហើយការគាំទ្រទាំងអស់នោះ គឺមានការគាំទ្រពីថ្នាក់ដឹកនាំ និងថ្នាក់ក្រោមជាតិផងដែរដូចជាមន្ទីរ ការិយាល័យ និងសាលារៀន។<br>ជំហានបន្ទាប់ យើងធ្វើការពង្រឹងលើអ្វីដែលមានស្រាប់ ដោយមិនព្យាយាមបង្កើតអ្វីដែលថ្មីនោះទេ។ ឧទាហរណ៍ ក្រសួងមានកញ្ចប់សម្រាប់បង្រៀនសិស្សរៀនយឺត ដូចនេះយើងព្យាយាមជំរុញឱ្យកញ្ចប់បំប៉នសិស្សរៀនយឺតនោះ អាចប្រើប្រាស់បាន។ យើងរៀនសូត្រពីអ្វីដែលមានស្រាប់ ដើម្បីពិនិត្យមើលភាពខ្លាំង និងខ្សោយរបស់វា។ មួយទៀតគឺត្រូវគិតពីប្រសិទ្ធភាពនៃការចំណាយ។ |

## កិច្ចពិភាក្សាដំណោះស្រាយទី៣

*ការពង្រឹងជំនាញគរុកោសល្យ និងចំណេះដឹងនៃមុខវិជ្ជាបង្រៀនសម្រាប់គ្រូបង្រៀន*

*«របៀបនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនទំនើបក្នុងការរៀនកម្រិតថ្នាក់ដំបូង»*

សម្របសម្រួលដោយ៖ លោក ស៊ឹម សុចិន្ត្រា

វាគ្មិនទី១៖ លោក ចាន់ តុលា ប្រធាននាយកដ្ឋានកិច្ចការវិក្រឹតការ ក្រសួងMOEYS

វាគ្មិនទី២៖ លោក សៅ ប៊ុនធឿន ប្រធានគម្រោងស្បៀងអាហារសម្រាប់ការអប់រំ អង្គការWorld Education

វាគ្មិនទី៣៖ លោក សុន ណាត នាយកប្រតិបត្តិ អង្គការTDSO

វាគ្មិនទី៤៖ លោក ចាន់ សុខអៀង ប្រធានជាន់ខ្ពស់កម្មវិធីអំណាន អង្គការRoom to Read

| លទ្ធផលនៃកិច្ចពិភាក្សា | |
|---|---|
| សំណួរទៅ លោក ចាន់ តុលា ប្រធាននាយកដ្ឋានកិច្ចការវិក្រឹតការ ក្រសួងMOEYS<br><br>តើមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន? ហើយក្រសួងមានវិធានការអ្វីខ្លះ ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ | ដើម្បីដោះស្រាយបញ្ហាលទ្ធផលសិក្សារបស់សិស្ស មិនមែនកម្មវិធីតែ១មុខអាចដោះស្រាយបានទេ។ កិច្ចពិភាក្សានេះ ផ្តោតលើការបណ្តុះបណ្តាល និងគុណភាពគ្រូបង្រៀន។ ដើម្បីឱ្យកំណែទម្រង់គុណភាពវិស័យអប់រំសម្រេចបាន គឺអាស្រ័យលើកត្តាធំៗចំនួន៤ គឺ៖ ១.ចាប់ផ្តើមពីសិស្ស ដោយធ្វើឱ្យសិស្សស្រលាញ់ការសិក្សា ២.ចាប់ផ្តើមពីគ្រូបង្រៀន និងការសិក្សារបស់សិស្ស ៣.បរិស្ថានសាលារៀនល្អ និង៤.សមត្ថភាពគ្រូបង្រៀន និងនាយកសាលា។<br><br>យោងតាមទិន្នន័យឆ្នាំ២០២៣ គ្រូបង្រៀនប្រមាណ ៦៣% មិនទាន់មានបរិញ្ញបត្រដែលមិនទាន់គ្រប់ស្តង់ដានោះទេ។ ជិត ១/៤ នៃគ្រូបឋមសិក្សា និងជិត១/២នៃគ្រូមធ្យមសិក្សាមិនទាន់គ្រប់ស្តង់ដាជាតិ។ គ្រូនៅសាលាបណ្តុះបណ្តាលប្រហែល៧០% មិនទាន់មានបរិញ្ញាបត្រជាន់ខ្ពស់ ដែលទាមទារឱ្យមានការដំឡើងគុណវុឌ្ឍ និងអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។<br><br>**បញ្ហាប្រឈមក្នុងការអនុវត្ត**<br><br>- នាយកដ្ឋានថ្មី៖ នាយកដ្ឋាននៅមិនទាន់គ្រប់គ្រងទិន្នន័យអង្គការ ឬស្ថាប័ន និងនាយកដ្ឋានដែលបណ្តុះបណ្តាលគ្រូ។ សម្រាប់ក្រសួងនៅមានការបណ្តុះបណ្តាលជាន់គ្នា ដែលមិនមានការទទួលស្គាល់ច្បាស់លាស់។ សម្រាប់ការបណ្តុះបណ្តាលទាមទាមឱ្យឆ្លើយតបតាមអ្នករៀនដូចជាសម្រាប់គ្រូបង្រៀន គឺស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ហើយសម្រាប់នាយកសាលា គឺស្តង់ដានាយក។<br>- ការយល់ដឹងអំពី ការអភិវឌ្ឍគន្លងអាជីពជាប្រចាំ (CPD) គឺមិនទាន់មានការយល់ដឹងទូលំទូលាយនៅឡើយទេ។ សំខាន់មួយទៀត គឺមិនសូវមានធនធានថវិកា សម្រាប់ការអនុវត្ត ឬការបណ្តុះបណ្តាល។<br>- ប្លែនឌិត៖ ដែលនៅមិនទាន់បានទូលំទូលាយទេ ស្របពេលគ្រូបង្រៀនចេញមក ហើយនៅតំបន់ឆ្ងាយ គឺមិនមានអ៊ីនធឺណិត។<br>- យន្តការនៃលើកទឹកចិត្ត៖ យើងមានច្បាប់ និងគោលនយោបាយ ប៉ុន្តែមិនទាន់មានប្រាក់លើកទឹកចិត្ត ដែលទាមទារឱ្យមានការឯកភាពជាអន្តរក្រសួង។ គ្រូបង្រៀនត្រូវធ្វើCPDដោយខ្លួនឯង (១០០ម៉ោង/ឆ្នាំ) ប៉ុន្តែមិនទាន់គ្រប់គ្រាន់ទេ។<br>- ចំនួនវគ្គសិក្សា៖ តើសាលាបណ្តុះបណ្តាលគ្រូបានត្រៀមខ្លួនរួចរាល់ហើយឬនៅសម្រាប់ផ្តល់ការបណ្តុះបណ្តាល។<br>- ប្រព័ន្ធត្រួតពិនិត្យ និងតាមដាន៖ នាយកដ្ឋានមិនអាចចុះទៅមើលគ្រប់វគ្គ ឬការបណ្តុះបណ្តាលទាំងអស់បានទេ។ ដូចនេះស្នើរតាមមន្ទីរ និងការិយាល័យយល់ដឹងពីកិច្ចការនេះ ដែលទាមទារឱ្យមានការបំពាក់បំប៉នសមត្ថភាពរបស់ពួកគេ។<br><br>**ដើម្បីដោះស្រាយនូវអនុសាសន៏ទាំងអស់នោះ៖**<br><br>- ក្រសួងតម្លើងនាយកដ្ឋាន ទៅជាអគ្គនាយកដ្ឋាន ដើម្បីធ្វើការបានគ្រប់ជ្រុងជ្រោយ។ |

| | |
|---|---|
| | - ជំរុញឱ្យអ្នកពាក់ព័ន្ធចូលមកអនុវត្តក្នុងប្រព័ន្ធទាំងអស់គ្នា ដើម្បីជានាគុណភាពនៃវគ្គ និងទទួលបានក្រេឌីត។ ក្រេឌីតមានអត្ថប្រយោជន៍ពេលក្រោយ។ សម្រាប់ពេលខាងមុខ យើងនឹងពិចារណា លើការផ្តល់វគ្គអភិវឌ្ឍគ្រូបង្រៀន ផ្អែកលើលទ្ធផលសិក្សារបស់សិស្ស ដោយផ្តល់វគ្គសិក្សានៅតំបន់ដែលសិស្សទទួលបានលទ្ធផលសិក្សាទាប ដើម្បីលើកកម្ពស់គុណវុឌ្ឍគ្រូបង្រៀន ដើម្បីដោះស្រាយបញ្ហាទាំងនោះ។<br>- ក្រសួងនឹងពង្រីកវិសាលភាពនៃការអនុវត្តទូទាំងប្រទេស និងពង្រីកចំនួនអ្នកផ្តល់សេវាCPD តាមរយៈការពង្រឹងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ដោយលើកទឹកចិត្តឱ្យពួកគាត់ដាក់ពាក្យស្នើសុំជាគ្រឹះស្ថានបណ្តុះបណ្តាលCPD។<br><br>លោកបានលើកពីការបណ្តុះបណ្តាល និងការពង្រីកសេវាបណ្តុះបណ្តាល គឺជួបនូវបញ្ហាហិរញ្ញវត្ថុ ជាពិសេសនៅកម្រិតសាលារៀន។ ក្រសួងនឹងសាកល្បងដាក់ឱ្យមានការប្រើប្រាស់ Voucher ក្នុងទំហំទឹកប្រាក់កំណត់ណាមួយ (១០០/២០០ដុល្លា) សម្រាប់ការអភិវឌ្ឍសមត្ថភាព ដែលប្រើប្រាស់បានក្នុងលក្ខខណ្ឌអភិវឌ្ឍសមត្ថភាពតែប៉ុណ្ណោះ។<br><br>បច្ចុប្បន្ន ដើម្បីកាត់បន្ថយការចំណាយ និងប៉ះពាល់ម៉ោងបង្រៀន ក្រសួងបានបង្កើតថ្នាលអនឡាញមួយចំនួន ដើម្បីឱ្យគ្រូអាចរៀន និងធ្វើការនៅលើថ្នាលនោះតែម្តង។ លើសពីនេះគឺការប្រើប្រាស់បច្ចេកវិទ្យាAI សម្រាប់ជួយក្នុងការរៀននិងបង្រៀន តាមរយៈការពង្រឹងប្រឹក្សាគរុកោសល្យដោយការផ្តល់ជាក្រេឌីត ដោយមានការវាយតម្លៃ និងលើកទឹកចិត្តនាពេលក្រោយ។ សម្រាប់គ្រូកិច្ចសន្យា ក្រសួងកំពុងរៀបចំឯកសារទស្សនទានក្នុងការបណ្តុះបណ្តាល។ ក្រសួងក៏នឹងរៀបចំផែនការរយៈពេលវែង សម្រាប់ការពង្រឹងការអនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀន ខណៈដែលនាយកដ្ឋានក៏នឹងពង្រឹងសមត្ថភាពខ្លួនផងដែរ។ |
| សំណួរទៅលោកសៅប៊ុនធឿន<br><br>ប្រធានគម្រោងស្បៀងអាហារសម្រាប់ការអប់រំ<br><br>អង្គការWorld Education<br><br>សូមលោក ចែករំលែកបទពិសោធន៍ក្នុងការបង្រៀន ក្នុងការជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅកម្រិតថ្នាក់ដំបូង | យើងបានជជែកពីបញ្ហា និងដំណោះស្រាយលើលទ្ធផលសិក្សារបស់សិស្ស។ ប្រសិនបើសិស្សមិនចេះ វាអាចមិនមែនជាកំហុសរបស់សិស្សទេ ប៉ុន្តែជាការទទួលខុសត្រូវរបស់អ្នកអនុវត្ត និងរបស់យើងទាំងអស់គ្នា។ លោកបានចែករំលែកពីរបៀបថែរក្សាគុណភាពបង្រៀន និងរៀន។ អ្នកពាក់ព័ន្ធបានអនុវត្តកម្មវិធីច្រើន ដើម្បីបំពេញចំណុចខ្វះខាត។ លោកបានលើកយកវិធីសាស្ត្រដែលអាចអនុវត្តបាននៅក្នុងសម័យកាលនេះ ដោយសង្កត់ថាមិនមានវិធីសាស្ត្រណាដែលល្អឥតខ្ចោះ និងអាចអនុវត្តបាននៅគ្រប់សម័យកាល គ្រប់បរិបទ និងគ្រប់កាលទេសៈណាទេ។ លោកបានលើក២ឧទាហរណ៍៖ បច្ចុប្បន្ន យើងត្រូវធ្វើដូចម្តេច ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន។ ការបង្រៀនត្រូវធានាថាយើងអនុវត្តការរៀនបែបយកសិស្សជាមូលដ្ឋាននៃការអនុវត្ត ដែលជាវិធីសាស្ត្រសកម្មដូចដែលយើងកំពុងធ្វើក្នុងកម្មវិធីកញ្ចប់អំណាន។ ក្នុងកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងយើងបានប្រើវិធីសាស្ត្រ និងគោលការណ៍ថ្មី សម្រាប់ការបង្រៀន និងរៀនដែលបានរំលេចនិងគ្របដណ្តប់ដល់ការជួយសិស្សរៀនយឺត ដោយប្រើគោលវិធីចំនួន៣ គឺ៖ ១.គ្រូបង្រៀនធ្វើជាគំរូគ្រប់សកម្មភាពដែលបង្រៀន ២.គ្រូនាំសិស្សធ្វើ និង៣.ធ្វើជាមួយគ្នា។ វិធីល្អ មិន |

| | |
|---|---|
| | ប្រាកដថាជួយសិស្សបានទេ។ វិធីសាស្ត្រល្អ គឺវិធីសាស្ត្រដែលសិស្សមានឱកាសអនុវត្ត។ កាលណាសិស្សខ្វះការអនុវត្ត នោះនឹងនាំឱ្យសិស្សខ្សោយ។ ការរៀនបែបសកម្ម និងការចូលរួម ជាវិធីសាស្ត្រទំនើប ដែលអាចជួយសិស្សក្នុងកម្រិតខ្ពស់មួយ។<br><br>ក្នុងការអនុវត្ត ពិតជាមានចន្លោះប្រហោង ត្រូវមានការតាមដាន។ ឧទាហរណ៍៖ ប្រហែល ៦០% នៃគ្រូបង្រៀនមិនបានអនុវត្ត ក្រោយកទទួលបានការបណ្តុះបណ្តាល។ ហេតុអ្វីគាត់មិនអនុវត្ត? ទាក់ទងនឹងផ្នត់គំនិត ឥរិយាបទនៃការបង្រៀន ដោយសារវិធីសាស្ត្រថ្មីត្រូវការមានអ្នកគាំទ្រ តែយើងមិនមានយន្តការក្នុងការពិនិត្យតាមដាន។ តើយន្តការចុះគាំទ្រមាននៅគ្រប់ទីកន្លែងដែរឬទេ? ប្រសិនជាមិនមានយន្តការនៃការប្រឹក្សាគរុកោសល្យ នោះការអនុវត្តនឹងមិនបានពេញលេញ ដែលជាចំណុចចន្លោះប្រហោង។ យន្តការនៃការពិនិត្យតាមដាន និងប្រឹក្សាគរុកោសល្យ នេះជួយដល់គ្រូបង្រៀនរបស់យើង។<br><br>ការធ្វើតេស្ត (Asesessment)៖ មិនមែនសំដៅដល់ការធ្វើតេស្តស្តង់ដានោះទេ។ វាសំដៅដល់ទីប្រឹក្សាគរុកោលស្យដែលចុះគាំទ្រដល់គ្រូ ធ្វើតេស្តសិស្សចំនួន៤នាក់ ក្រោយពីការចុះពិនិត្យតាមដានគ្រូបង្រៀន។ មូលហេតុ នៃការធ្វើតេស្តនេះ គឺដើម្បីស្វែងរកថាសិស្សនោះនៅមានចំណុចខ្វះខាតអ្វី ដើម្បីគ្រូរកវិធីជួយគាត់។ នេះជាវិធីជួយសិស្សរៀនយឺត។<br><br>ការបំប៉នសមត្ថភាពគ្រូបង្រៀន៖ យើងបានរៀបចំកម្មវិធីប្លែនឌិត។ វាមានប្រសិទ្ធភាព និងកាត់បន្ថយចំណាយ។ គ្រូឧទ្ទេសចូលរៀនតាមអនឡាញ ដោយគ្រូឧទ្ទេសនេះ គឺនៅកម្រិតកម្រង និងយកទៅបំប៉នគ្រូបង្រៀននៅក្នុងកម្រង។ ដូច្នេះ គ្រូកិច្ចសន្យាដែលសមត្ថភាពមានកម្រិតឬគ្រូថ្មី មានឱកាសក្នុងការកសាង សមត្ថភាពដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបង្រៀននិងរៀន ហើយដើម្បីឆ្លើយតបទៅនឹងលទ្ធផលសិក្សារបស់សិស្ស។ |
| សំណួរទៅលោក សុន ណាត នាយកប្រតិបត្តិ អង្គការTDSO<br><br>TDSO ធ្វើការយ៉ាងជិតស្និតជាមួយគ្រូបង្រៀន តើលោកបានរកឃើញវិធីសាស្ត្រច្នៃប្រឌិត ឬកាអនុវត្តល្អអ្វីខ្លះក្នុងការបំពាក់បំប៉នគ្រូដែលកំពុងបង្រៀនតាមវិធីសាស្ត្របែបទំនើប? | លោក សុន ណាត៖ មុនឆ្លើយលោកចង់វិលត្រលប់ទៅរកសេចក្តីផ្តើមបន្តិច ដែលថាគ្រូបង្រៀនប្រមាណ៦០%មិនបានអនុវត្តវិធិសាស្ត្រថ្មី ក្រោយពីទទួលបានការបណ្តុះបណ្តាល ដែលជាតួលេខគួរឱ្យបារម្ភមួយ។ TDSO សូមចែករំលែកពីបទពិសោធន៍ និងអ្វីដែលយើងបានធ្វើ។ TDSO ធ្វើការតែជាមួយគ្រូភាសាអង់គ្លេសថ្នាក់ទី៤ដល់ទី៦។ ក្រសួងមានកម្មវិធីសិក្សាភាសាអង់គ្លេសសម្រាប់ថ្នាក់ទី៤ដល់ទី៦។ ប៉ុន្តែគ្រូបង្រៀនគឺមិនទាន់ទទួលបានការបណ្តុះបណ្តាលនោះទេ ដែលនេះជាចំណុចចន្លោះប្រហោងមួយ។<br><br>លោកបានផ្តល់នូវចំណុចចែករំលែកចំនួនបី៖<br><br>- ផលិតសម្ភារៈឧបទេស៖ ក្រុមការងារបានយកសៀវភៅគោលមកពិនិត្យមើលសៀវភៅសិក្សាគោល និងព្យាយាមអភិវឌ្ឍកម្មវិធីសិក្សាលំអិតតាមសៀវភៅសិក្សាគោលនោះ និងឯកសារមួយចំនួនទៀត ដើម្បីទៅគាំទ្រការបង្រៀន។<br>- ក្រោយពីមានកម្មវិធីសិក្សាលំអិតទាំងនោះហើយ គឺយើងបណ្តុះបណ្តាលគ្រូបង្រៀន ពីវិធីសាស្ត្រដើម្បីឱ្យគាត់ធ្វើយ៉ាងម៉េចអាចអនុវត្តបាន។ |

| | |
|---|---|
| | - បណ្តុះស្មារតីនិងវប្បធម៌នៃការសិក្សាពេញមួយជិវិតតាមរយៈចំណុចសំខាន់ៗ២៖<br>○ អញ្ជើញគាត់ឱ្យមកទទួលការបណ្តុះបណ្តាលជាមួយយើង រយៈពេល១ឆ្នាំពេញ ស្មើនឹង៤០សប្តាហ៍ ១សប្តាហ៍៣ម៉ោង ដែលមានភាពតឹងរឹង<br>○ យើងមានក្រុមប្រឹក្សាគរុកោសល្យដើម្បីចុះជួយគាត់នៅតាមសាលារៀន។ ក្រោយមកយើងក៏នៅជួយគាត់ក្នុង១ខែម្តង ក្រោយពី១ឆ្នាំ។ |
| សំណួរទៅ៖<br>លោក ចាន់ សុខអៀង<br>ប្រធានជាន់ខ្ពស់កម្មវិធីអំណាន<br>អង្គការRoom to Read<br>លោកបានធ្វើការ ក្នុងរៀបចំការបញ្ចូលវិធីសាស្ត្រ និងកម្មវិធីថ្មីៗនៃកម្រិតថ្នាក់ដំបូងទៅក្នុងកម្មវិធីបណ្តុះបណ្តាលគរុសិស្ស តើលោកមើលឃើញថានេះបំពេញបន្ថែមដល់ការពង្រឹងសមត្ថភាពរបស់គ្រូបង្រៀនយ៉ាងដូចម្តេច?<br>តើមានការអនុវត្តល្អអ្វីខ្លះ? | កញ្ចប់អំណានថ្នាក់ដំបូង (EGL) ត្រូវបានបង្កើតឡើងដោយការចូលរួមរបស់ក្រសួង និងអង្គការមួយចំនួន។ បន្ទាប់ពីបានអនុវត្តមួយរយៈពេល ឃើញថាទទួលបានប្រសិទ្ធភាពក្នុងការជួយសិស្ស។ ដូចនេះ ក្រសួងបានសម្រេចដាក់បញ្ចូលកម្មវិធីEGL ទៅក្នុងកម្មវិធីបណ្តុះបណ្តាលគរុកោសល្យ។ យើងបានរៀបចំសរសេរកម្មវិធីសិក្សាលំអិត សម្រាប់កម្មវិធីសិក្សា ១២+២ ដោយបានកាត់បន្ថយទ្រឹស្តី។ ហើយបានព្យាយាមយកកម្មវិធីសិក្សាសិស្ស ដែល EGL បានអនុវត្តនៅតាមសាលាបឋមសិក្សាមកដាក់បញ្ចូល ដើម្បីឱ្យស៊ីគ្នានៅក្នុងឆ្នាំ២០១៩ និងបានរៀបចំឱ្យក្លាយជាក្រេឌីត។ ហេតុអ្វីការរៀបចំកម្មវិធីសិក្សាគរុកោសល្យ ទាក់ទងនឹងគ្រូដែលបានចេញបង្រៀន? ហេតុផល គឺវាបានបំពេញគ្នាយ៉ាងខ្លាំង។ គរុសិស្សដែលត្រូវចេញទៅបង្រៀននឹងមានមូលដ្ឋាននៃវិធីសាស្ត្របង្រៀនភាសាខ្មែរ និងការគ្រប់គ្រងថ្នាក់រួចជាស្រេចដែលនឹងធ្វើឱ្យចំណេញពេលវេលា ដោយមិនបាច់ត្រូវចំណាយពេលក្នុងការបណ្តុះបណ្តាលមូលដ្ឋានគ្រឹះនៃភាសាខ្មែរទៀត ហើយអាចទុកពេលវេលាក្នុងការប្រឹងប្រែងរៀបចំចំណេះដឹងនោះ មកប្រើប្រាស់ក្នុងថ្នាក់ ជាជាងត្រូវចំណាយពេលរៀនឡើងវិញ។<br>តើអ្វីជាមេរៀនដែលយើងរៀនបានពីការអនុវត្តល្អ នៃការបន្សុីគ្នានេះ?<br>- ធ្វើឱ្យមានការយល់គ្នា នឹងស៊ីគ្នាបានល្អរវាងការបង្រៀន និងកិច្ចការងារវិក្រឹតការ និងស៊ីគ្នាជាមួយអង្គការដៃគូដែលនឹងអនុវត្តកម្មវិធីដូចគ្នា<br>- ការចុះកម្មសិក្សាគឺមានភាពល្អប្រសើរ ដោយកម្មវិធីដូចគ្នា គឺគ្រូបង្រៀនឈរថ្នាក់អាចជួយគរុសិស្សបានពេលចុះកម្មសិក្សា<br>- ពេលប្រើកម្មវិធីដូចគ្នា គឺធ្វើឱ្យវគ្គនៃការរៀនសូត្រ និងការទទួលយកអាចឱ្យយើងទៅប្រមូលព័ត៌មានពីពួកគាត់បាន។ គឺយើងអាចប្រមូលព័ត៌មានពីការអនុវត្តរបស់គាត់មកឆ្លុះបញ្ចាំង ដើម្បីកែលម្អកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលបន្តទៀត ដើម្បីពង្រឹងប្រព័ន្ធអប់រំ ក៏ដូចជាលទ្ធផលសិក្សារបស់សិស្ស។ |
| អ្នកចូលរួម៖ អាណាព្យាបាលលើកថា កូនគាត់ខ្ជិលរៀនដោយសារ នៅសាលាមិនសប្បាយ។ ដូចនេះ គាត់មិនចង់រៀន។សប្បាយ ទើបគាត់ចង់រៀន។ ប្រហែលជាការ | - លោក សុខអៀង៖ បានចំបែកសំណួរនេះជាពីរ៖ ទី១. ថ្នាក់មត្តេយ្យធ្វើឱ្យគាត់សប្បាយ ហើយចង់រៀន គឺត្រឹមត្រូវ។ ព្រោះថាកម្រិតមត្តេយ្យ ភាគច្រើនមិនទាន់ផ្តោតខ្លាំង ដូចនេះការសប្បាយមិនមែនខុសនោះទេ។ ប៉ុន្តែ ប្រសិនជាគាត់ចូលថ្នាក់ទី១ ហើយ មិនធ្វើឱ្យគាត់មិនសប្បាយ គឺត្រូវពិនិត្យឡើងវិញ។ នៅក្នុងកម្មវិធីសិក្សាទាំងនោះ បានបង្កប់នូវសកម្មសប្បាយ និងការលេងផងដែរ។ ប៉ុន្តែយើងមិនដឹងប្រាកដថា គ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាលទាំងនោះ បានយកទៅប្រើប្រាស់ឬទេ។ ដូចនេះវាឆ្លុះ |

| | |
|---|---|
| បង្រៀនធ្វើឱ្យគាត់ធុញពេញ ទើបបានជាសិស្សមិនចង់រៀន។ តើធ្វើដូចម្ដេច ទើបគ្រូធ្វើឱ្យសិស្សចង់រៀន? ឧទាហរណ៍៖ កម្រិតមត្តេយ្យសិក្សា ធ្វើឱ្យគាត់សប្បាយ គាត់ចង់រៀន ទោះឡើងថ្នាក់ទី១ ក៏គាត់ចង់មករៀនថ្នាក់មត្តេយ្យវិញ។ | បញ្ចាំងដែលលើកថា ៦០% នៃគ្រូទទួលបានការបណ្ដុះបណ្ដាល ហើយមិនប្រើប្រាស់។<br>- លោក ប៊ុនធឿន៖ និយាយអំពី Pedagogical Eco-System (A pedagogical ecosystem refers to the interconnected system of elements within a learning environment that work together to support student learning.) នៅសាលារៀន។ សួរថា តើសាលារៀនបានបង្កើតកម្មវិធីបន្ថែម សម្រាប់ធ្វើឱ្យសិស្សចូលចិត្តមកសាលារៀនឬទេ? កន្លែងនេះហើយ ដែលយើងបានជជែកគ្នានៅក្នុងដំណោះស្រាយទី១។ តើមានសិល្បៈឬទេ? មានក្លឹបសិក្សាឬទេ? មានកន្លែងកីឡាឬទេ? មានការសិក្សាបែបគម្រោងឬទេ? និងមានសកម្មភាព បន្ថែមអ្វីផ្សេងៗឬទេ? ទាំងអស់នេះជាចំណុចដែលខ្វះខាតនៅក្នុងផ្នែកអេកូឡូស៊ីនៅសាលារៀន។ |
| សំណួរទៅកាន់វាគ្មិនទាំងអស់ឱ្យជួយបញ្ជាក់បន្ថែម<br><br>«តើយើងអាចកែសម្រួលកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនឱ្យកាន់តែស៊ីសង្វាក់ជាមួយនឹងបញ្ហាប្រឈមជាក់ស្ដែងនៅក្នុងថ្នាក់រៀនជាពិសេសនៅតំបន់ដែលដាច់ស្រយាល ឬតំបន់ដែលខ្វះធនធាន?» | - **លោក តុលា៖** នៅក្នុងCPD ផ្ដោតលើតម្រូវជាក់ស្ដែងនៅសាលារៀន។ ដូចនេះ បានជាយើងមាន PLP (Profressional Learning Plan) ផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់គាត់ថាតើគាត់ត្រូវការអ្វី តើគាត់ចង់រៀនអ្វី ហើយវិធីសាស្ត្ររៀនយ៉ាងដូចម្ដេច?<br>- **លោក សុនណាត៖** ការប្រឹក្សាគរុកោសល្យ គឺជាកិច្ចការសំខាន់ណាស់។<br>- **លោក ប៊ុនធឿន៖** ការចូលរួមពីសហគមន៍គឺជារឿងសំខាន់។ ការខូតខាត និងបាត់បង់សៀវភៅជំនួយសិស្សដែលធ្វើឱ្យខ្វះ និងមិនអាចដំណើរការបាន។ ដូចនេះសហគមន៍នឹងចូលរួមចំណែកក្នុងការបំពេញបន្ថែមនូវអ្វីដែលខ្វះខាត។<br>- **លោក សុខអៀង៖** នៅតំបន់ជនបទ ឬថ្នាក់មានសិស្សច្រើន ធ្វើឱ្យគ្រូបង្រៀនថ្មីជួបការលំបាក។ គរុសិស្សគួរចុះកម្មសិក្សាទៅតំបន់ឆ្ងាយ និងមានស្ថានភាពជាក់ស្ដែងដូចជាសាលារៀនមានសិស្សច្រើន ខ្វះថ្នាក់ និងខ្វះខាតសម្ភារ ដើម្បីឱ្យគាត់អាចដកស្រង់បទពិសោធន៍ ជាជាងនៅតែទីប្រជុំជន ឬតំបន់ដែលមានស្ថានភាពងាយស្រួលទេ។ មួយវិញទៀត គឺការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គឺគួរមានទីនប្រឹក្សាគរុកោសល្យចុះជួយគាត់។ |

## ថ្ងៃទី២៖ ថ្ងៃអង្គារ ទី៨ ខែមេសា ឆ្នាំ២០២៥

### ចាក់វីដេអូសង្ខេបថ្ងៃទី១៖

*ក្រុមការងារNEP ចាក់វីដេអូសង្ខេបសន្និសីទថ្ងៃទី១។*

### ដំណោះស្រាយទី៤៖

*ការពង្រីក និងពង្រឹងការអប់រំកុមារតូច ដើម្បីឈានដល់ការសម្រេចស្តង់ដា*

វាគ្មិនទី១៖ យន្តការគាំទ្រមត្តេយ្យសិក្សាសហគមន៍ដើម្បីឈានដល់ស្តង់ដាអប្បបរមារបស់ក្រសួងអប់រំ យុវជន និងកីឡាបង្ហាញដោយ លោកស្រី ញ៉ែម សុម៉ាលី អ្នកជំនាញផ្នែកអប់រំកុមារតូច សមាគមបណ្ដុះកុមារ។

វាគ្មិនទី២៖ «**ការវាស់វែងលទ្ធផលការរៀនតាមរយៈការលេងសម្រាប់កុមារដែលមានពិការភាព (CDW)**»

បង្ហាញដោយ លោកស្រី ស៊ូ សុធានី មន្ត្រីជាន់ខ្ពស់ផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ អង្គការ ស៊ីអារអែស (CRS)

| លទ្ធផលនៃកិច្ចពិភាក្សា | |
|---|---|
| បទបង្ហាញវាគ្មិនទី១៖<br><br>លោកស្រី ញ៉ែម សុម៉ាលី<br><br>អ្នកជំនាញផ្នែកអប់រំកុមារតូច សមាគមបណ្តុះកុមារ<br><br>យន្តការគាំទ្រមត្តេយ្យសិក្សាសហគមន៍ដើម្បីឈានដល់ស្តង់ដាអប្បរមារបស់ក្រសួងអប់រំ យុវជន និងកីឡា | លោកស្រីបង្ហាញថា រដ្ឋាភិបាលកម្ពុជា បាននឹងកំពុងខិតខំគាំទ្រមត្តេយ្យសិក្សាសហគមន៍ ខណៈដែលមានការកើនឡើងលើការយល់ដឹង និងការគាំទ្រពីក្រុមប្រឹក្សាឃុំចំពោះសេវាអប់រំកុមារតូច។ អត្រាចុះឈ្មោះរៀននៅមត្តេយ្យសហគមន៍បានកើនឡើង។ យ៉ាងណាមិញ សាលារៀនមួយចំនួន ប្រឈមមុខនឹងបញ្ហាគ្រឿងបរិក្ខារ និងធនធានមិនគ្រប់គ្រាន់សម្រាប់គាំទ្រដំណើរការ។ វាមានអត្ថប្រយោជន៍ណាស់ ដែលមត្តេយ្យសិក្សាសហគមន៍បំពេញតាមស្តង់ដាអប្បបរមា របស់ក្រសួង ដូចជា៖ ទទួលបានការទទួលស្គាល់ផ្លូវការពីក្រសួង មានឱកាសទទួលថវិកាជំនួយ (រដ្ឋាភិបាល NGO សហគមន៍) កែលម្អគុណភាពបង្រៀននិងការរៀន រក្សាទុកគ្រូបង្រៀន និងធានាស្ថេរភាពមត្តេយ្យសិក្សាសហគមន៍។<br><br>**ជំហានសំខាន់ៗមួយចំនួន ដែលមត្តេយ្យសិក្សាសហគមន៍ ត្រូវបំពេញស្តង់ដាអប្បបរមា៖**<br><br>- ជំហានទី១៖ បើកដំណើរការ/បង្កើតគណៈកម្មការ និងស្វ័យវាយតម្លៃ និងរៀបចំផែន<br>- ជំហានទី២៖ សាងសង់/ជួសជុលសាលារៀន កន្លែងលេងកុមារ របង និងសាងសង់/ជួសជុលបរិក្ខារWASH ( ធុងទឹកភ្លៀង អណ្តូង បង្គន់ កន្លែងលាងដៃ....... )<br>- ជំហានទី៣៖ បណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ និងគណៈកម្មការគ្រប់គ្រង និងគ្រូបង្រៀន<br>- ជំហានទី៤៖ ផ្តល់សម្ភារៈបង្រៀននិងសម្ភារៈរៀនមត្តេយ្យសិក្សាសហគមន៍គោលដៅ<br>- ជំហានទី៥៖ទី១.សហការជាមួយមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក/ក្រុង ដើម្បីត្រួតពិនិត្យ និងផ្តល់ការគាំទ្រគ្រូបង្រៀន។ ទី២.រៀបចំកិច្ចប្រជុំបច្ចេកទេស ប្រចាំត្រីមាសសម្រាប់គ្រូនៅមត្តេយ្យសិក្សាសហគមន៍។ និងទី៣.គាំទ្រគ្រូក្នុងការធ្វើការវាយតម្លៃ លើការរៀនសូត្ររបស់កុមារអាយុ៥ឆ្នាំ នៅមត្តេយ្យសិក្សាសហគមន៍គោលដៅ។<br>- ជំហានទី៦៖ ១.ធ្វើឱ្យដំណើរការឡើងវិញ ឬបង្កើតក្រុមឪពុកម្តាយ និងក្រុមអ្នកថែទាំ ២.ពិនិត្យ រៀបចំ កែសម្រួល និងបោះពុម្ពសម្ភារៈអប់រំមាតាបិតា និង៣.បណ្តុះបណ្តាលគ្រូបង្គោល (TOT) និងបណ្តុះបណ្តាលបន្តទៅក្រុមស្នូលមាតាបិតា ស្តីពីសមាហរណ៍កម្មសេវាអភិវឌ្ឍកុមារតូច។<br>- ជំហានទី៧៖ រៀបចំសិក្សាឆ្លុះបញ្ចាំងប្រចាំឆ្នាំជាមួយក្រុមប្រឹក្សាឃុំ និងភាគីពាក់ព័ន្ធ ដើម្បីពិនិត្យផែនការសកម្មភាពដែលបានគ្រោងទុកក្នុងសាលានៅក្នុងឆ្នាំដំបូង។<br><br>**ដំណើរការវាយតម្លៃសាលាមត្តេយ្យសិក្សាសហគមន៍រួមមាន៖**<br><br>- គ្រូមត្តេយ្យសិក្សាសហគមន៍ធ្វើការវាយតម្លៃដោយប្រើទម្រង់លេខ២១<br>- ពិនិត្យ និងពិភាក្សាជាមួយគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍<br>- មេឃុំរាយការណ៍ទៅក្រុមប្រឹក្សាឃុំ ➔ក្រុមប្រឹក្សាឃុំរៀបចំកិច្ចប្រជុំ ដើម្បីពិភាក្សាលទ្ធផលការវាយតម្លៃ ➔ដំណើរចូលទៅកាន់ការិយាល័យអប់រំស្រុក-ក្រុង ➔បន្តទៅមន្ទីរអប់រំ ហើយបញ្ជូនទៅក្រសួងអប់រំ។ |

| | |
|---|---|
| | **តើមានឯកសារគាំទ្រអ្វីខ្លះ ?**<br>- ទម្រង់ពាក្យស្នើសុំជាមួយរបាយការណ៍ស្វ័យវាយតម្លៃ<br>- បញ្ជីឈ្មោះកុមារសិក្សា<br>- ប្រវត្តិរូបគ្រូបង្រៀន<br>- បញ្ជីវត្តមានគណៈគ្រប់គ្រងសាលារៀន (ក្នុងកិច្ចប្រជុំស្វ័យវាយតម្លៃ)<br>- បញ្ជីឈ្មោះសមាជិកគណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍។<br><br>លោកស្រីបញ្ជាក់ថា សាលាមត្តេយ្យសិក្សាសហគមន៍ ដែលមានគុណភាព គឺពិន្ទុចាប់ពី ៦៥% ឡើងទៅ ហើយមិនទាន់មានគុណភាពគឺពិន្ទុក្រោម ៦៥%។ |
| លោកស្រី ពៅ វណ្ណា៖ ក្រសួងមានគោលនយោបាយការសិក្សាពេញមួយជីវិត។ តើអ្នកធ្វើការជាមួយមត្តេយ្យសហគមន៍ អាចរួមបញ្ចូលដល់ការសិក្សាសហគមន៍យ៉ាងណា? | លោកស្រី សុមាលី៖ កុមារអាចរៀនបានគ្រប់ទីកន្លែង។ នៅពេលកុមារមានពេលទំនេរ គឺគាត់អាចចូលរួមជួយសាលាមត្តេយ្យសហគមន៍បាន។ ក្រៅពីនោះ មាតាបិតាសិស្សក៏អាចជួយដល់ការសិក្សារបស់សិស្សបានផងដែរ ។ ឆ្លុះបញ្ចាំងមកវិញ គឺសហគមន៍ទាំងអស់មានភាពរួមគ្នា ដើម្បីជួយឱ្យកុមារទទួលបានការអភិវឌ្ឍពេញលេញ និងការបណ្តុះនៅដើមដំបូង ជួយឱ្យគាត់មានភាពស៊ាំ ជាមួយនឹងការរស់នៅប្រចាំថ្ងៃ និងការប្រាស្រ័យទាក់ទងជាមួយសហគមន៍របស់ពួកគាត់។ |
| បទបង្ហាញវាគ្មិនទី២៖<br><br>លោកស្រី ស៊ូ សុធានី<br><br>មន្ត្រីជាន់ខ្ពស់ផ្នែកតាមដានត្រួតពិនិត្យ និងវាយតម្លៃ<br><br>អង្គការ ស៊ីអារអែស (CRS) | លោកស្រីបានបង្ហាញពី៖ ការវាស់វែងលទ្ធផលនៃការរៀនផ្អែកលើការលេងសម្រាប់កុមារមានពិការភាព។<br><br>**សេចក្តីផ្តើម និងសារតោះ** ប្រហែល ១៥% នៃកុមារកម្ពុជា អាយុពី ២–៩ ឆ្នាំ មានពិការភាព ប៉ុន្តែមានតែ ០.០៤% ប៉ុណ្ណោះបានចូលរៀននៅសាលារៀន។ គ្រូជាច្រើននៅតែមានចំណេះដឹង និងបទពិសោធន៍ទាបក្នុងការគាំទ្រកុមារដែលមានពិការភាព (CWD) ឱ្យបន្តការរៀន។ ការចូលរៀននៅថ្នាក់មត្តេយ្យសិក្សា និងការអប់រំបរិយាបន្នសម្រាប់ CWD គឺជាអាទិភាពរបស់រាជរដ្ឋាភិបាល ប៉ុន្តែការពង្រីកការងារនេះ ត្រូវបានរារាំងដោយការខ្វះថវិកាធនធានមនុស្ស និងសមត្ថភាពបច្ចេកទេស។<br><br>CRS និងនាយកដ្ឋានអប់រំពិសេស បានដឹកនាំបង្កើតធនធានអប់រំបរិយាបន្នសម្រាប់កុមារតូច ដើម្បីប្រើប្រាស់ជាសាធារណៈនៅថ្នាក់ជាតិ។ ក្រសួងអប់រំក៏បានផ្តល់អាទិភាពដល់ការអប់រំបរិយាបន្នផ្អែកលើការលេង និងការចូលរួមរបស់ CWD។ CRS គាំទ្រការផ្លាស់ប្តូរនេះតាមរយៈការបង្កើត និងអនុវត្តឧបករណ៍បណ្តុះបណ្តាលគ្រូ និងការចុះគាំទ្រជាក់ស្តែង។ ***«ការលេងមិនមែនជាពេលសម្រាកពីការរៀនទេ ប៉ុន្តែជាវិធីសាស្ត្រដែលកុមាររៀន!»***<br><br>**អន្តរាគមន៍៖** អន្តរាគមន៍ការអប់រំបរិយាបន្នថ្នាក់ជាតិ ដើម្បីលើកកម្ពស់ការចូលរួមរបស់ CWD នៅកម្រិតថ្នាក់ក្រោមជាតិ កម្រិតកម្មវិធីមត្តេយ្យសិក្សា (២០១៥ ដល់ ២០២៥)៖<br><br>– បង្កើតសេចក្តីណែនាំ ស្តីពីការកំណត់អត្តសញ្ញាណកុមារមានពិការភាព |

| | |
|---|---|
| | – បង្កើតគំរូឧបករណ៍លេង និងសៀវភៅណែនាំ<br>– វីដេអូណែនាំសម្រាប់គ្រូបង្រៀនមត្តេយ្យសិក្សា<br>– បណ្តុះបណ្តាលគ្រូបង្គោលប្រចាំខេត្ត (PoEs) ២៤ ខេត្ត ដើម្បីរៀបចំផែនការ និងការបណ្តុះបណ្តាលបន្ត។<br><br>ការគាំទ្របន្ថែមពី CRS ក្នុងខេត្ត ៤ (ក្រចេះ កំពង់ធំ កំពង់ចាម ព្រៃវែង) រយៈពេល ៧,៥ ខែ (ឆ្នាំ២០២៤) - កុមារច្រើនជាង ២២០០នាក់ នៅក្នុង ៧៣ថ្នាក់ ក្នុងខេត្តចំនួន៤ នេះ។<br><br>– បណ្តុះបណ្តាលគ្រូ ៧៨ នាក់ នៅសាលារៀនចំនួន ៣៨<br>– ទស្សនកិច្ចប្រឹក្សា ចុះជួយចំនួន៥ដង<br>– ផ្តោតទៅលើការដាក់បញ្ចូលកុមារមានពិការភាព ក្នុងវិធីសាស្ត្រផ្អែកលើការលេង<br><br>**គោលដៅនៃអន្តរាគមន៍**<br><br>– ដើម្បីលើកកម្ពស់បរិយាបន្នការរៀន តាមរយៈការលេងនៅមត្តេយ្យសិក្សា<br>– ពង្រឹងការត្រៀមចូលសាលារៀនរបស់កុមារដែលមាន និងគ្មានពិការភាព<br>– គាំទ្រគ្រូបង្រៀន ជាមួយនឹងការបណ្តុះបណ្តាល និងសម្ភារៈ<br>– ជំរុញការអនុវត្តការរៀន តាមរយៈការលេងក្នុងផែនការសិក្សាប្រចាំសប្តាហ៍<br><br>**គោលបំណងនៃការសិក្សាចុងគ្រា**<br><br>– វាយតម្លៃប្រសិទ្ធភាពនៃការរៀន តាមរយៈការលេងដែលបានអភិវឌ្ឍ និងអនុវត្តដោយ CRS លើការរៀន និងការអភិវឌ្ឍរបស់ក្មេងប្រុស និងក្មេងស្រី ដែលមាន និងគ្មានពិការភាព។<br>– បង្កើតភស្តុតាងអំពីឥទ្ធិពល និងសក្តានុពលនៃការពង្រីកវិធីសាស្ត្ររៀនតាមការលេងដែលមានបរិយាបន្ន។<br><br>**សំណួរស្រាវជ្រាវ**<br><br>– តើការចូលរួមក្នុងកម្មវិធីរៀនតាមការលេងដែលមានបរិយាបន្ន ដោយប្រើឧបករណ៍លេង និងល្បែងពីCRS/ក្រសួងអប់រំ មានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយការត្រៀមសម្រាប់ចូលសាលារបស់កុមារមានអាយុ ៣ឆ្នាំ ទៅ ៥ឆ្នាំ ដែលមាន និងគ្មានពិការភាព?<br>– តើការគាំទ្រដោយផ្ទាល់ (ការបណ្តុះបណ្តាល និងការបណ្តុះបណ្តាលបន្ត) នៅសាលារៀនដែលមានអន្តរាគមន៍ ផ្តល់លទ្ធផលការត្រៀមសម្រាប់ចូលសាលារៀនល្អជាងសាលារៀនដែលមិនទទួលការគាំទ្រដែរឬទេ?<br>– តើវិធីសាស្ត្ររៀន តាមការលេងដែលមានបរិយាបន្ន បានជួយឱ្យកុមារពិការមានអាយុមត្តេយ្យសិក្សា អាចចូលរួមសកម្មភាពក្នុងថ្នាក់បានកាន់តែល្អដែរឬទេ? |

**វិធីសាស្ត្រនៃការស្រាវជ្រាវ**

- ការរៀបចំវិធីសាស្ត្រវាយតម្លៃ
  - វិធីសាស្ត្រ quasi-experimental
    - បែងចែកជាក្រុមអន្តរាគមន៍ និងក្រុមប្រៀបធៀប
    - ប្រៀបធៀបលទ្ធផលរបស់សាលារៀនក្នុងក្រុមអន្តរាគមន៍ (ដែលមានការចូលរួមក្នុងការរៀនតាមការលេង + ទទួលការគាំទ្រដោយផ្ទាល់យ៉ាងខ្លាំង) ជាមួយសាលារៀនក្រុមប្រៀបធៀប (មានតែការចូលរួមក្នុងការរៀនតាមការលេងប៉ុណ្ណោះ)
    - ប្រៀបធៀបលទ្ធផលរបស់សាលារៀនក្នុងក្រុមទាំងពីរ (PBL) ជាមួយលទ្ធផល IDELA សកល
    - ប្រៀបធៀបលទ្ធផលរបស់កុមារពិការជាមួយកុមារមានសុខភាពល្អទូទៅ និងតាមវិស័យ IDELA
- វិធីសាស្ត្របរិមាណវិស័យ៖ ប្រើឧបករណ៍ IDELA ដើម្បីវាស់សមត្ថភាពកុមារតាមផ្នែក និងការស្ទង់មតិគ្រូ (ចំណេះដឹង ទស្សនៈ និងការអនុវត្ត)។
- វិធីសាស្ត្រទិន្នន័យគុណវិស័យ៖ សំភាសន៍ជាផ្ទាល់ជាមួយគ្រូបង្រៀន តំណាង PoE និង DoE ដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី និងមន្ត្រីក្រសួងអប់រំ។

**សំណាក និងដែនកំណត់**

- ការប្រមូលទិន្នន័យដើមគ្រា៖ នៅចុងខែមករា និងដើមខែកុម្ភៈ ឆ្នាំ២០២៤។ សិស្សចូលរួម៖ ៥៨៧នាក់ ស្រី២៧៧នាក់ មានCWD ៨០នាក់។
- ការប្រមូលទិន្នន័យចុងគ្រា៖ ធ្វើក្នុងខែកញ្ញា ឆ្នាំ២០២៤ សិស្សចូលរួម ៤៨០នាក់ ស្រី២២៩នាក់ (CWD ៤៩នាក់) គ្រូ៨៣នាក់ តំណាង PoE/DoE ៨នាក់ និងក្រសួងអប់រំ ២នាក់។
- ដែនកំណត់៖ ទំហំសំណាកតូច មិនមែនជ្រើសតាមបែបចៃដន្យ រយៈពេលអនុវត្តកម្មវិធីខ្លី ទិន្នន័យគុណភាពប្រមូលតែពេលចុងគ្រា ដើម្បីយល់អំពីភាពជោគជ័យ បញ្ហាប្រឈម និងចន្លោះប្រហោងសម្រាប់កែសម្រួលកម្មវិធីនាពេលអនាគត ការស្ទង់មតិគ្រូធ្វើចុងគ្រាប៉ុណ្ណោះ (គ្មានទិន្នន័យប្រៀបធៀបនឹងដើមគ្រា)

**លទ្ធផលសិក្សាសំខាន់ៗអំពីកុមារ**

- លទ្ធផលការប្រៀបធៀបរវាងក្រុមអន្តរាគមន៍ និងក្រុមប្រៀបធៀប។ ទិន្នន័យដើមគ្រា៖ ក្រុមអន្តរាគមន៍មានលទ្ធផលទាបជាង (៣៨%) បើប្រៀបធៀបនឹងក្រុមប្រៀបធៀបប្រមាណ (៤៣%)។ ប៉ុន្តែនៅចុងគ្រា ក្រុមអន្តរាគមន៍បានហក់មកខ្ពស់វិញ ហើយភាពខុសគ្នានេះ បានកាត់បន្ថយមកត្រឹមតែ ២%ប៉ុណ្ណោះ។

- គ្រូបង្រៀននៅសាលារៀនក្រុមអន្តរាគមន៍ បានរាយការណ៍ថា ពួកគេមានជំនឿចិត្តកាន់តែខ្ពស់ ក្នុងការបញ្ចូលការរៀនតាមការលេង និងមានអត្រាអនុវត្តក្នុងថ្នាក់រៀនកាន់តែខ្ពស់ផងដែរ។
- ក្រុមអន្តរាគមន៍មានលទ្ធផលការរៀនកែលម្អកើនឡើងពី ៣៨% ទៅ ៥៤% (+១៦%) ក្នុងរយៈពេល ៧.៥ ខែ។ ការប្រៀបធៀបលទ្ធផលរវាងក្រុមអន្តរាគមន៍ និងក្រុមគ្មានអន្តរាគមន៍បង្ហាញថា ក្រុមអន្តរាគមន៍មានការកែលម្អ ១៥% ខណៈក្រុមប្រៀបធៀបមានការកែលម្អ ១២%។ ទោះបីជាលទ្ធផលកែលម្អបង្ហាញពីអត្ថប្រយោជន៍ យ៉ាងណាក៏ដោយ ភាពខុសគ្នានេះត្រូវបានចាត់ទុកថា ជាផលប៉ះពាល់តិចតួច។
- លទ្ធផលប្រៀបធៀបរវាងក្មេងស្រី និងក្មេងប្រុស
    - Baseline៖ ក្មេងស្រីបានពិន្ទុខ្ពស់ជាងក្មេងប្រុសគ្រប់ផ្នែក ទោះបីជាភាពខុសគ្នាមិនសូវធំក៏ដោយ។ នៅពេល Endline៖ ទាំងក្មេងស្រី និងក្មេងប្រុសបានអភិវឌ្ឍឡើង ខណៈក្មេងស្រីមានការកែលម្អល្អជាងបន្តិច។
    - លទ្ធផលក្នុងផ្នែកផ្សេងៗ៖ អក្សរសាស្ត្រ៖ ក្មេងស្រីឡើង១២%, ក្មេងប្រុសឡើង១០%។ គណិតវិទ្យា៖ ក្មេងស្រីឡើង១៤% ក្មេងប្រុសឡើង១២%។ ការអភិវឌ្ឍសង្គម-អារម្មណ៍៖ ក្មេងស្រីឡើង១៥% ក្មេងប្រុសឡើង១៣%។ លទ្ធផលចុងក្រោយបង្ហាញថាក្មេងស្រីមានការកែលម្អខ្លាំងជាងក្មេងប្រុស។
- ការរកឃើញផ្នែកគុណភាពលើCWD
    - CWDមានកំណើនយឺត ដោយសារបរិបទផ្លូវកាយ ចំណេះដឹង ឬបញ្ញាសង្គម។
    - បើទោះបីជាមានការលំបាក CWD អាចទទួលបានអត្ថប្រយោជន៍ពីការសិក្សាតាមរយៈការលេង
    - នៅបីករណីផ្សេងគ្នា គ្រូរាយការណ៍ថា CWD បានចាប់ផ្ដើមរីករាយក្នុងការទៅសាលាឡើងវិញ បន្ទាប់ពីការណែនាំការសិក្សាដោយការលេង។

**សេចក្ដីសន្និដ្ឋាន៖** ការរៀនផ្អែកលើការលេង បានបង្ហាញពីផលប៉ះពាល់វិជ្ជមានច្បាស់លាស់លើការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារ បើប្រៀបធៀបនឹងការអភិវឌ្ឍធម្មជាតិ។ ពិន្ទុ IDELA ទាំងមូលបានកើនពី៤១% ទៅ៥៤% (+១៣%) ដែលលើសពីការរំពឹងទុកធម្មជាតិ (+៧%)។ ក្មេងស្រីបានបង្ហាញពីការរីកចម្រើនលើការអភិវឌ្ឍសង្គម-អារម្មណ៍ និងការធ្វើចលនាខ្លាំងជាង។ ក្រុមអន្តរាគមន៍ មានកំណើនលើការសិក្សាខ្លាំងជាងក្រុមប្រៀបធៀប ជាពិសេសផ្នែកលេខ (១៥% ធៀបនឹង ១២%) និងចលនា (១៧% ធៀបនឹង ១៤%)។ ចំពោះ CWD មានកំណើនគួរឱ្យកត់សម្គាល់—ការអភិវឌ្ឍសង្គម-អារម្មណ៍កើនពី ២៩% ទៅ ៤៨%។ ជាពិសេស CWDs ដែលមានបញ្ហាស្ដាប់ និងបញ្ញាបានកំណើន IDELA ខ្ពស់បំផុត (+១៨% និង +១៩%)។ ការរៀនដោយផ្អែកលើការលេងបានជំរុញឱ្យ

| | |
|---|---|
| | CWDs ចូលរួមសកម្មភាពក្នុងថ្នាក់យ៉ាងសកម្ម។ គ្រូបានបញ្ជាក់ថា ពួកគេរីករាយនឹងការរៀន និងសកម្មភាពរៀនផ្អែកលើការលេង ជាពិសេសផ្នែកអក្សរ និងលេខ។ ការបង្កើនអន្តរកម្មជាមួយមិត្តភក្តិត្រូវបានឃើញកើនឡើង តាមរយៈសកម្មភាពលេងដែលអនុញ្ញាតឱ្យ CWDs ចូលរួមក្នុងជីវិតថ្នាក់រៀនជារៀងរាល់ថ្ងៃ។<br><br>**សំណើអនុសាសន៍**<br><br>- ពង្រឹងការអប់រំបរិយាបន្នសម្រាប់ CWD តាមរយៈការបង្កើតការបណ្តុះបណ្តាលដែលតម្រូវសម្រាប់គ្រូបង្រៀនអំពីរបៀបរៀបចំល្បែងសិក្សា និងសកម្មភាពលេងឱ្យសមស្របនឹងពិការភាពផ្សេងៗគ្នា (ឧ. ពិការភ្នែក និង ការនិយាយ)<br>- បង្កើត «គ្រូបង្គោលការអប់រំបរិយាបន្ន» នៅថ្នាក់ស្រុក-អ្នកអប់រំដែលបានទទួលការបណ្តុះបណ្តាលចុះទស្សនៈកិច្ចសាលារៀន និងផ្តល់ការបង្វឹកសម្រាប់ CWD ទៅក្នុងសកម្មភាពផ្អែកលើការលេង។<br>- លើកទឹកចិត្តដល់គំរូជំនួយពីមិត្តភ័ក្តិ ដែលកុមារគ្មានពិការត្រូវបានបង្រៀនឱ្យចេះយល់ចិត្ត និងជួយដល់មិត្តរួមថ្នាក់ដែលមានពិការភាពក្នុងសកម្មភាពលេង។<br>- ផ្តល់សម្ភារៈសម្រាប់លេងដែលអាចសម្របខ្លួនបាន (ឧ. បោះពុម្ពធំ ឬហ្គេមដែលមានសំលេង) សម្រាប់កុមារដែលមានពិការភ្នែក ឬចលនាតូច។<br>- ពង្រឹងការចូលរួមរបស់មាតាបិតា ដើម្បីបង្កើនផលប៉ះពាល់នៃការរៀនផ្អែកលើការលេង។ សាលារៀនគួរតែរៀបចំវគ្គបង្កើនការយល់ដឹង ដើម្បីអប់រំអ្នកថែទាំអំពីសារៈសំខាន់នៃការលេងនៅក្នុងការអប់រំកុមារតូច។<br>- ផ្តល់សកម្មភាពនៅផ្ទះ និងលើកទឹកចិត្តមាតាបិតាឱ្យចូលរួមក្នុងគំនិតផ្តួចផ្តើមការសិក្សានៅសាលា ដើម្បីជួយផ្សារភ្ជាប់គម្លាតរវាងថ្នាក់រៀន និងការសិក្សានៅផ្ទះ។<br>- កម្រិតគោលនយោបាយ៖<br>  • ដើម្បីរក្សាភាពជោគជ័យរបស់ខ្លួន សូមបញ្ចូលការរៀនតាមលេងទៅក្នុងគោលនយោបាយអប់រំកុមារតូចរបស់កម្ពុជា។<br>  • ការដោះស្រាយការបណ្តុះបណ្តាលគ្រូ ធនធាន និងការចូលរួមរបស់មាតាបិតាអាចបង្កើតក្របខណ្ឌបរិយាបន្ន ដោយបំពាក់ឱ្យអ្នកអប់រំជាមួយនឹងវិធីសាស្ត្រដែលត្រូវបានឯកភាព ដើម្បីផ្តល់ការអប់រំមត្តេយ្យសិក្សាប្រកបដោយបរិយាបន្ន ជាពិសេសសម្រាប់ CWD។ |
| សំណួរអ្នកចូលរួម៖ តើការអន្តរាគមន៍ ផ្តោតលើកុមារអាយុប៉ុន្មាន? ហេតុអ្វីជ្រើសរើសយកក្រុមអាយុនេះ និងប្រើឧបករណ៍ IDEALA | លោកស្រី ស៊ូ សុធានី៖ ការអន្តរាគមន៍ផ្តោតលើកុមារអាយុ ៣ឆ្នាំ ទៅ ៥ឆ្នាំ។ ហើយជ្រើសរើសយកឧបករណ៍ IDELA Tool ដោយសារតែវាជាឧបករណ៍ធ្វើការវាស់វែង ទៅលើលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់កុមារតូចជាលក្ខណៈសកល។ យើងជឿថាឧបករណ៍នេះនឹងជួយការស្រាវជ្រាវទទួលបានលទ្ធផលដែលជាក់ស្តែង និងមានវិសាលភាពធំដែលអាចជឿទុកចិត្តបាន។ IDELA Tool ប្រើសម្រាប់សិស្សកុមារទូទៅ ប៉ុន្តែយើងបានសហការជាមួយ |

| | |
|---|---|
| សម្រាប់វាស់វែងសិស្សដែលមានពិការភាព? | នាយកដ្ឋានរបស់ក្រសួងធ្វើឱ្យឧបករណ៍នេះ សមស្របទៅនឹងសិស្សដែលមានពិការភាពបានដូចគ្នា ដោយអនុវត្តផ្អែកលើស្ថានភាពរបស់កុមារ។ |
| លោក ផាត ពីខេត្តសៀមរាប បានលើកឡើងថា នៅតំបន់របស់ខ្ញុំ មានការខ្វះខាតជំនាញច្រើន ហើយការលេងធ្វើឱ្យកុមារសប្បាយតាមរយៈ Emotional Development និងSocial Development។ តើប្រើពេលរយៈពេលប៉ុណ្ណាក្នុងការអង្កេត ដើម្បីដឹងពីការវិវត្តរបស់គាត់? | លោកស្រី ស៊ូ សុធានី៖ សម្រាប់CWD ការសិក្សារបស់គាត់មានការកើនឡើងគួរឱ្យមានការកត់សម្គាល់ខ្លាំង គឺទាក់ទងទៅនឹង Social Developmet និង Emotional Development មានដល់ទៅ២២%។ ការអង្កេតតាមរយៈឧបករណ៍ IDELA Tool យើងមានកម្រងសំណួរចំនួន ៨សំណួរក្នុងការវាស់វែង។ ហើយការសួរពួកគាត់តាមរយៈគ្រូរបស់គាត់ និងតាមរយៈការអន្តរាគមន៍របស់ពួកយើង។ |
| លោកស្រី គន្ធា អង្គការHI<br>តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យសាលារៀនអត់អន្តរាគមន៍មានការកើនឡើងខ្ពស់ជាងសាលារៀនដែលបានអន្តរាគមន៍? | ការអន្តរាគមន៍ត្រូវបានបែងចែកជា ២ ដំណាក់កាល ដោយសហការជាមួយនាយកដ្ឋានអប់រំពិសេស និងកុមារតូច ក្នុងការផលិតឧបករណ៍ដូចជាល្បែងអប់រំបរិយាបន្ន។ បន្ទាប់ពីផលិតរួច ឧបករណ៍ទាំងនេះត្រូវបានបម្លែងជាកម្មសិទ្ធិរបស់ក្រសួង និងបានបណ្តុះបណ្តាលគ្រូបង្គោលនៅ២៤ខេត្តក្រុង។ ឧបករណ៍ទាំងនេះត្រូវបានអាប់ឡូតលើគេហទំព័ររបស់ក្រសួង ដើម្បីធានាបាននូវការចូលដំណើរការទូទាំងប្រទេស។<br>គ្រូបង្គោលបានយកសម្ភារៈ និងល្បែងអប់រំបរិយាបន្នទៅចែករំលែក និងបណ្តុះបណ្តាលបន្ថែមនៅថ្នាក់ក្រោមជាតិនៅខេត្តរបស់ខ្លួន។ ទោះបីយើងមិនអាចវាយតម្លៃបានច្បាស់ថាការផ្សព្វផ្សាយនោះមានប្រសិទ្ធភាពកម្រិតណា ប៉ុន្តែយើងអាចមើលឃើញតាមឯកសារ និងឧបករណ៍អប់រំបរិយាបន្ន ដែលក្រសួងបានដាក់ចេញ ហើយបញ្ជាក់ថា មានសាលាជាច្រើនក្រៅតំបន់អន្តរាគមន៍ បានចាប់ផ្តើមប្រើប្រាស់ផងដែរ។ |

## **ដំណោះស្រាយទី៥៖**

### ***ការគាំទ្ររបស់ឪពុកម្តាយ និងការចូលរួមរបស់សហគមន៍***

វាគ្មិនទី១៖ Transformative Learning: A cost- Effective Model for Community Mindset

បង្ហាញដោយ លោកស្រី ពៅ វណ្ណា នាយិកាប្រចាំប្រទេស អង្គការ DVV អន្តរជាតិកម្ពុជា

វាគ្មិនទី២៖ លោកស្រី ខឹម សូឡី អ្នកសម្របសម្រួលកម្មវិធីកសាងអនាគត អង្គការមិត្តសម្លាញ់

វាគ្មិនទី៣៖ លោកស្រី ស៊ឹង ចាក់ ប្រធានផ្នែកប្រតិបត្តិការ អង្គការផ្កាយសមុទ្រកម្ពុជា (ISF Cambodia)

| លទ្ធផលនៃកិច្ចពិភាក្សា | |
|---|---|
| បទបង្ហាញវាគ្មិនទី១៖<br>លោកស្រី ពៅ វណ្ណា<br>នាយិកាប្រចាំប្រទេស<br>អង្គការ DVVI ប្រចាំកម្ពុជា<br>Pilot Project on Transforming Community Learning Centers (CLCs) and Youth Center into Lifelong Learning Centers (LLLCs) 2021-2023 | លោកស្រីបង្ហាញថា អង្គការឌីវីអន្តរជាតិ (DVVI) បានអនុវត្តគម្រោងសាកល្បង ស្តីពីការកែប្រែមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលយុវជនឱ្យទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។ DVVI គឺជាអង្គការពីប្រទេសអាល្លឺម៉ង់។ បច្ចុប្បន្នមានអាយុជាង ៥៨ឆ្នាំ និងផ្តោតលើការលើកកម្ពស់អប់រំមនុស្សពេញវ័យ និងបង្កើនសមត្ថភាពមនុស្សគ្រប់វ័យក្នុងសង្គម។ នៅកម្ពុជា DVVI បានសហការជាមួយក្រសួងអប់រំ តាំងពីឆ្នាំ២០១៦ ដើម្បីជួយអភិវឌ្ឍការអប់រំក្រៅប្រព័ន្ធ និងលើកកម្ពស់ការសិក្សាពេញមួយជីវិត។<br><br>លោកស្រីបន្តថា គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត បានចុះហត្ថលេខាដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំ២០១៩។ ក្នុងនាមជាអ្នកផ្តួចផ្តើម DVVI បានចាប់ផ្តើមគម្រោងសាកល្បងរយៈពេល ៣ឆ្នាំ (២០២១-២០២៣) ដើម្បីបំលែងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលយុវជនឱ្យទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។ គោលបំណង គឺជំរុញឱ្យមជ្ឈមណ្ឌលទាំងនេះអាចផ្តល់សេវាអប់រំជាវៀងរហូតសម្រាប់មនុស្សគ្រប់វ័យ ដោយផ្អែកលើតម្រូវការពិតនៃសហគមន៍។<br><br>ជម្រើសទីតាំង និងដំណើរការអនុវត្ត៖ ការជ្រើសរើសធ្វើឡើងដោយផ្អែកលើកត្តាចម្បងបី៖ ១.បេះដូងរបស់អ្នកគ្រប់គ្រងត្រៀមចូលរួម ២.ទីតាំងអាចសម្របសម្រួលសកម្មភាពអប់រំបាន និង៣.មានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន និងសហគមន៍។ សកម្មភាពគម្រោងឆ្នាំ២០២១-២០២៣៖ ទាក់ទងនឹងបច្ចេកវិទ្យា៖ ផ្តល់កុំព្យូទ័រ និងបណ្តុះបណ្តាលកុំព្យូទ័រដល់មជ្ឈមណ្ឌលសិក្សា ទោះស្ថិតនៅតំបន់ដាច់ស្រយាល។ កម្មវិធីបង្កើនប្រាក់ចំណូល៖ បង្កើតឱកាសធ្វើរកចំណូលក្នុងសហគមន៍ ដូចជា កសិកម្ម កាត់ដេរ ដាំផ្សិត បើកថតកូពី ជាដើម។ កម្មវិធី "Counselling" នៅឆ្នាំទី២៖ ផ្តល់យោបល់ យុទ្ធសាស្ត្រប្រកបដោយច្នៃប្រឌិតដល់យុវជន ក្នុងតំបន់ជនបទក្នុងការបង្កើតគម្រោងជាមួយគំនិតច្នៃប្រឌិត។ ទាំងអស់នេះ គឺយើងបានការសិក្សាតម្រូវការពិតសហគមន៍មុនដំណើរការអភិវឌ្ឍ។<br><br>ជាលទ្ធផល មជ្ឈមណ្ឌលសិក្សាសហគមន៍ស្រែក្នុង (ខេត្តកំពត) ត្រូវបានក្រសួងអប់រំទទួលស្គាល់ថាជាគំរូសម្រាប់មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតនៅកម្ពុជា។ អំពើនេះបញ្ជាក់ថាការងាររបស់យើងជាប្រសិទ្ធិភាព និងអាចពង្រីកបានទៅតំបន់ផ្សេងទៀត។ លោកស្រីមានប្រសាសន៍បន្ថែមថា លោកគ្រូ អ្នកគ្រូជាច្រើននៅតាមមជ្ឈមណ្ឌលបានលើកឡើងពី បញ្ហាជីវភាពរស់នៅដែលមិនងាយស្រួល ដូច្នេះការជួយបង្កើតការងារនឹងនាំឱ្យមានអានុភាពចូលរួមកាន់តែខ្ពស់។ ឧទាហរណ៍ ការចិញ្ចឹមមាន់ ដាំបន្លែ និងផលិតផលបច្ចេកវិទ្យា បានជួយប្រើប្រាស់ជាផ្នែកមួយនៃកម្មវិធីអប់រំនិងជីវភាពសង្គម។ នាពេលអនាគតយើងនឹងបន្តពង្រីកគម្រោងនេះទៅតំបន់ផ្សេងៗ និងបន្តសហការជាមួយក្រសួងអប់រំ និងស្ថាប័នជាតិ ដើម្បីរួមចំណែកក្នុងការបង្កើតប្រព័ន្ធសិក្សាដែលមានគុណភាព សមស្រប និងសមរម្យសម្រាប់ប្រជាជនគ្រប់វ័យនៅទូទាំងប្រទេស។ |

| | |
|---|---|
| បទបង្ហាញវាគ្មិនទី២៖<br><br>ការគាំទ្រពីមាតាបិតា និងការចូលរួមរបស់សហគមន៍<br><br>លោកស្រី ខឹម សូឡី<br><br>អ្នកសម្របសម្រួលកម្មវិធីកសាងអនាគត<br><br>អង្គការមិត្តសម្លាញ់ | លោកស្រី បានធ្វើបទបង្ហាញថា អង្គការមិត្តសម្លាញ់ ជាកម្មវិធីដំបូងរបស់អង្គការ Friends-Internationalតាំងពីឆ្នាំ១៩៩៤ ដែលអនុវត្តនៅរាជធានីភ្នំពេញ ដោយមានអ្នកទទួលផលផ្ទាល់ចំនួន១៨,៦៣៣ នាក់ត្រូវបានគាំទ្រក្នុងឆ្នាំ២០២៤។ កម្មវិធី កសាងអនាគត៖ ការអប់រំ។ មានក្រុមគោលដៅជាក្រុមមានបំណុលខ្ពស់ អ្នកប្រើប្រាស់គ្រឿងញៀនឬគ្រឿងស្រវឹង ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពាន អ្នកមានមុខរបរដែលមានជំនាញទាបនិងមានហានិភ័យ និងអ្នកដែលមានការអប់រំនិងបទពិសោធន៍វិជ្ជាជីវៈទាប។<br><br>កម្មវិធី គឺបានប្រើប្រាស់វិធីសាស្ត្រពហុភាគីពាក់ព័ន្ធ ដូចជា៖ អ្នកថែទាំសាលារៀនរដ្ឋ NGO ជាដៃគូ សមាជិកសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។<br><br>លោកស្រីបានបង្ហាញពីការធ្វើការជាមួយអ្នកថែទាំតាមរយៈ ការបំបែករបាំងសង្គម និងសេដ្ឋកិច្ច គឺ ១.ការអភិវឌ្ឍជំនាញមាតាបិតា៖ បង្កើនការយល់ដឹង និងបណ្តុះបណ្តាលលើប្រធានបទជាច្រើនសម្រាប់កុមារ ឱ្យរីកចម្រើនក្នុងបរិយាកាសដែលគ្មានគ្រោះថ្នាក់។ ២.ជំនួយសម្រាប់ការអប់រំ៖ ការគាំទ្រជាមួយនឹងការចុះឈ្មោះសាលារៀន ការគាំទ្រសម្ភារៈ ឯកសារច្បាប់ ការប្រជុំឪពុកម្តាយ ការតាមដានបន្ត។ ៣.ស្វ័យភាពផ្នែកហិរញ្ញវត្ថុ៖ ការអភិវឌ្ឍជំនាញបច្ចេកទេស និងការគាំទ្រការងារជាមួយនឹងជំនាញផ្លាស់ប្តូរការអប់រំបន្ថែម។<br><br>លោកស្រី ក៏បានបង្ហាញពីការចូលរួមសហគមន៍៖ ការពង្រឹងការចូលរួមនៅក្នុងតំបន់។ នៅទីនេះមានកិច្ចការសំខាន់ៗចំនួនបួនគឺ៖ ១.ភ្នាក់ងារសុវត្ថិភាពកុមារ៖ ការជ្រើសរើស/បណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តសហគមន៍តាមតំបន់។ ២.សាលារៀនសាធារណៈ៖ ទំនាក់ទំនងដ៏រឹងមាំជាមួយគ្រូ និងនាយកសាលាដើម្បីជួយសម្រួលដល់ការធ្វើសមាហរណ៍កម្មឡើងវិញ។ ៣.អាជ្ញាធរមូលដ្ឋាន៖ ការកសាងសមត្ថភាព ការគ្រប់គ្រងករណីរួមគ្នាសម្រាប់កុមារងាយរងគ្រោះ ការគាំទ្រជាមួយឯកសារផ្លូវច្បាប់ ប័ណ្ណក្រីក្រ និងការចូលរួមយ៉ាងសកម្មនៅក្នុងព្រឹត្តិការណ៍សហគមន៍។ ៤.NGO ផ្សេងទៀត៖ ការសម្របសម្រួល ការបញ្ជូនបន្ត និងគម្រោងទូទៅជាមួយអង្គការផ្សេងទៀត (រួមទាំងដៃគូ ៣PC)។<br><br>សមិទ្ធិផលក្នុងឆ្នាំ២០២៤<br><br>– បានផ្សព្វផ្សាយដល់បុគ្គលចំនួន ១៤,៥០៣នាក់ តាមរយៈយុទ្ធនាការចុះឈ្មោះចូលរៀននៅសាលារៀន<br>– កុមារថ្មីចំនួន ៨៧៩ នាក់ ត្រូវបានសមាហរណ៍កម្មទៅក្នុងសាលារៀនរដ្ឋ<br>– កុមារចំនួន ១,៩៣៩ នាក់ បានទទួលការគាំទ្រដើម្បីបន្តនៅក្នុងសាលារៀន<br>– អ្នកថែទាំចំនួន ២១២នាក់ បានចុះឈ្មោះក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ<br>– អ្នកថែទាំចំនួន ៣០៥ នាក់ ត្រូវបានដាក់ឱ្យធ្វើការ<br>– ភ្នាក់ងារសុវត្ថិភាពកុមារសកម្មចំនួន ៧៤៥ នៅរាជធានីភ្នំពេញ |

| | |
|---|---|
| | បញ្ហាប្រឈម និងដំណោះស្រាយ<br>– ការពន្យាពេលឯកសារផ្លូវច្បាប់៖ សាលារៀនមួយចំនួនទាមទារសំបុត្រកំណើត ដែលបណ្តាលឱ្យមានការពន្យារពេលក្នុងដំណើរការចុះឈ្មោះ<br>– ថ្លៃបន្ថែមសម្រាប់ការសិក្សា៖ គ្រួសារខ្លះត្រូវតស៊ូដើម្បីរ៉ាប់រងថ្លៃគ្រូបង្រៀនក្រៅផ្លូវការ ឯកសណ្ឋានសាលារៀន<br>– ឱកាសចុះឈ្មោះមានកំណត់៖ កុមារដែលខកខានថ្ងៃផុតកំណត់នៃការចុះឈ្មោះ (១ ខែ) ត្រូវរង់ចាំរហូតដល់ឆ្នាំសិក្សាបន្ទាប់<br>– ថវិកាមានកំណត់៖ សកម្មភាពពឹងផ្អែកលើមូលនិធិ និងជំនួយពីខាងក្រៅ។ |
| សំណួរពី លោក យ៉េកះ គ្រួសារដែលជាប់បំណុលត្រូវចេញទៅរកស៊ី ដែលប៉ះពាល់ដល់កូន ហើយកុមារញៀនថ្នាំ ក៏បង្កបញ្ហាច្រើនដែរ។ ដូចនេះតើមានវិធីបែបណាដើម្បីឱ្យក្រុមគាត់ចូលរួម? ឬតើមានសេវាកម្មអ្វីខ្លះ? | លោកស្រី សូឡឺះ យើងមានបើកករណី ដែលយើងវាយតម្លៃពីបញ្ហារបស់គាត់។ នៅពេលរកឃើញបញ្ហាច្រើន ថាតើយើងនឹងដោះស្រាយបញ្ហាណាមុន? តើត្រូវផ្តល់វគ្គបណ្តុះបណ្តាល ឬគាំទ្រអ្វីមុន? ឧទាហរណ៍ បង្រៀនគាត់ពីអ្វីជាបំណុល ប្រភេទបំណុលជាដើម។ Firend International គាត់មានផលិតសម្ភារៈដែលលោកគ្រូអ្នកគ្រូអាចទាក់ទងដើម្បីស្នើសុំសម្ភារៈសម្រាប់បង្រៀនបាន។<br><br>ការធ្វើការជាមួយក្រុមគោលដៅ គឺត្រូវរកពេលឬជួបគាត់ពេលដែលគាត់មិនប្រើប្រាស់ និងសហការជាមួយអ្នកពាក់ព័ន្ធ និងធ្វើការជាជំហានៗ ដែលមានការគាំទ្រសេវាផ្សេងៗ។ ក្នុងករណីធ្ងន់ធ្ងរដែលទាមទារការព្យាបាល ត្រូវបញ្ជូនទៅមន្ទីរពេទ្យសម្រាប់ទទួលការព្យាបាល។ |
| លោក ឡឹប ពី HI៖ សម្រាប់ការចុះឈ្មោះមានកំណត់រយៈពេល១ខែ ប្រសិនជាចុះឈ្មោះយឺត ត្រូវរងចាំដល់១ឆ្នាំ។ សូមមេត្តាជួយបញ្ជាក់បន្ថែម អាចវាគ្មិន ឬអ្នកពាក់ព័ន្ធនៅទីនេះ។ | លោកស្រី តាមបទពិសោធន៍របស់មិត្តសម្លាញ់ គឺដូចនេះមែន ប្រសិនជាយឺត១ខែឬ ២ខែយ៉ាងយូរ ត្រូវរងចាំចុះឈ្មោះដល់ឆ្នាំក្រោយ។<br><br>មន្ទីរខេត្តសៀមរាប៖ ក្រសួងបច្ចុប្បន្នបានបញ្ជាក់ថា ឥលូវនេះការចុះឈ្មោះមិនមានលក្ខខណ្ឌពេលវេលាទេ នៅថ្នាក់កម្រិតបឋម បើទោះបីជាការផ្ទេរ ពីខេត្តណាទៅខេត្តណា គឺមិនពិបាកទៅមន្ទីរឬក្រុងស្រុកទេ។ គឺអាចទៅចុះផ្ទាល់នៅសាលារៀនតែម្តង។ សម្រាប់ឯកសារបើមានក៏មាន ប្រសិនជាមិនមានគឺអាចចូលរៀនសិនហើយសំបុត្រកំណើត ឯលិខិតស្នាមអាចមកតាមក្រោយ។ |
| បងទបង្ហាញវាគ្មិនទី៣៖<br><br>លោកស្រី ស៊ីង ចាប៉<br><br>ប្រធានផ្នែកប្រតិបត្តិការ<br><br>អង្គការផ្កាយសមុទ្រកម្ពុជា (ISF Cambodia) | លោកស្រីបង្ហាញថា ISF ចាប់ផ្តើមនៅឆ្នាំ២០០៦ តាមរយៈកម្មវិធីអប់រំ កម្មវិធីបាល់ទាត់ និងកម្មវិធីអភិវឌ្ឍន៍សហគមន៍ ដែលបានធ្វើការជាមួយកុមារក្រៅសាលារៀន។ តាមរយៈកម្មវិធីអប់រំ យើងមានកម្មវិធីពន្លឿន (catch up) បន្ទាប់មកធ្វើសមាហរណ៍កម្មពួកគាត់ទៅសាលារៀនវិញ។ ការគាំទ្រពួកគាត់គឺចាប់ពីកម្មវិធីពន្លឿនរហូតដល់ពួកគាត់ចប់មហាវិទ្យាល័យ។ សម្រាប់កម្មវិធីបាល់ទាត់ដែលផ្តល់ឱកាសដល់យុវជន និងកុមារចូលរួមលេងកីឡា និងពង្រឹងសមត្ថភាពតាមរយៈបាល់ទាត់ផងដែរ។<br><br>មួយវិញទៀត តាមរយៈកម្មវិធីអភិវឌ្ឍន៍សហគមន៍ គឺមានកម្មវិធីចំនួន៤ទៀត គឺ |

| | |
|---|---|
| ការគាំទ្រពីមាតាបិតា និងការចូលរួមរបស់សហគមន៍ | 1. កម្មវិធីបណ្ណាល័យ ដែលមានគោលបំណងបង្កើនទម្លាប់នៃការអាន<br>2. កម្មវិធីបង្រៀនកាត់ដេរ ទៅកាន់ក្រុមគោលដៅ<br>3. កម្មវិធីអក្ខរកម្មមនុស្សពេញវ័យ<br>4. កម្មវិធីផលិតសាប៊ូ ដែលលើកកម្ពស់អនាម័យទៅក្នុងក្រុមគោលដៅ<br><br>ទស្សនៈវិស័យ គឺចង់ឃើញសង្គមមួយដែលរួចផុតភាពក្រីក្រ និងវិសមភាព។ បេសកកម្មរបស់យើងគឺបង្កើននូវលទ្ធភាពនៃការចូលរៀន ទទួលបានការអប់រំ ការថែទាំសុខភាព និងការលេងកីឡា ធ្វើឱ្យកុមារក្រីក្រ និងសហគមន៍របស់ពួកគេអាចចាកចេញពីភាពក្រីក្រ។<br><br>មកដល់បច្ចុប្បន្ននេះ មានកុមារនិងយុវជនចំនួនប្រមាណ១០០០នាក់ទទួលផលពីកម្មវិធីអប់រំនិងការគាំទ្រការងារ ប្រមាណ៤០០០ គ្រួសារនិងសមាជិកសហគមន៍ នៅក្នុងគម្រោងអភិវឌ្ឍន៍សហគមន៍ និងយុវជនប្រមាណ២០០០០នាក់ក្នុងកម្មវិធីបាល់ទាត់។<br><br>ផលជះសំខាន់ៗពីកម្មវិធីការចូលរួមរបស់ឪពុកម្តាយ និងសហគមន៍ក្នុងការលើកម្ពស់ការអប់រំក្រៅប្រព័ន្ធ និងការសិក្សាពេញមួយជីវិត។<br><br>• បច្ចុប្បន្ន មានកុមារ៧៧៥នាក់ (ស្រី៣៨៤) នៅក្នុងកម្មវិធីអប់រំ<br>    ○ បច្ចុប្បន្ន សិស្សានុសិស្សចំនួន ៧៧៥ នាក់ (ស្រី៖ ៣៨៤ នាក់ ប្រុស៖ ៣៩១ នាក់) កំពុងស្ថិតក្រោមការគាំទ្រកម្មវិធីអប់រំ។<br>• ទាំងនេះគឺជាទិន្នន័យសំខាន់ៗនៅក្នុងកម្មវិធីអប់រំពេញមួយឆ្នាំ ២០២៤៖<br>    ○ Catch-Up៖ សិស្ស ៩៦% បានចូលរៀនជាទៀងទាត់ និងបានប្រឡងជាប់ប្រចាំឆ្នាំ ហើយបានជាប់ទៅថ្នាក់បន្ទាប់។ មានតែ ២% នៃសិស្សដែលបានបោះបង់ចោល។<br>    ○ សាលារៀនរដ្ឋ៖ ៩៣% នៃសិស្សចូលរៀនទៀងទាត់។ ថ្នាក់ទី៩៖ សិស្ស ៧១នាក់ (៩១%) ប្រឡងថ្នាក់ជាតិ & ថ្នាក់ទី១២៖ សិស្សចំនួន ៣២ នាក់ (៧៣%) ប្រឡងថ្នាក់ជាតិ។ ក្នុងចំណោម ៤៤ នាក់ សិស្ស ៤១ នាក់ (៩៣%) បន្តទៅសាកលវិទ្យាល័យនៅឆ្នាំ ២០២៥ (ភាគច្រើនបានចុះឈ្មោះរួចហើយ)។ ពេញមួយឆ្នាំ សិស្ស ២៧ នាក់ (៥.៨%) បានឈប់ពីការសិក្សា។ សិស្ស ១៨ នាក់បានបោះបង់ពីកម្មវិធី ISF ទាំងស្រុង ខណៈពេល ៩នាក់ សម្រេចចិត្តផ្លាស់ទៅស្វែងរកការងារ។<br>    ○ នៅឆ្នាំ២០២៤ មានសិស្សចំនួន ៦៨ នាក់ ហើយចាប់តាំងពីខែមករា ឆ្នាំ ២០២៥ មក សិស្សសរុបចំនួន ១០៣ នាក់កំពុងសិក្សានៅសកលវិទ្យាល័យ។ លើសពីនេះទៀត ឆ្នាំនេះនិស្សិត ៦នាក់បានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ។ |

| | |
|---|---|
| | ○ សិស្សចំនួន ២២ នាក់ ដែលកំពុងស្ថិតក្រោមការគាំទ្រការងារ៖ ៣ នាក់ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ ៨ នាក់ក្នុងការប្រឹក្សាយោបល និង ១១ នាក់នៅក្នុងការងារ។<br><br>បញ្ហាប្រឈម ក្នុងការលើកកម្ពស់ការអប់រំក្រៅប្រព័ន្ធ ឬការសិក្សាពេញមួយជីវិត គឺសិស្ស ISF មួយចំនួន ជាពិសេសអ្នកដែលសមាហរណ៍កម្មនៅក្នុងសាលារៀនរដ្ឋ មានទំនាក់ទំនងជាមួយមិត្តភាពមិនល្អ ដែលនាំឱ្យអវត្តមាន ការជក់បារី និងអាកប្បកិរិយាមិនល្អ។ គ្រួសារមួយចំនួនមានជាប់ពាក់ព័ន្ធនឹងល្បែងស៊ីសង និងការប្រើប្រាស់គ្រឿងញៀនផងដែរ ដូចដែលបានសង្កេតឃើញតាមរយៈការចុះសួរសុខទុក្ខដល់ផ្ទះ និងការផ្តល់យោបល់ពីអាជ្ញាធរមូលដ្ឋាន និងអ្នកជិតខាង។ ពួកគេតែងតែអវត្តមាន បន្ទាប់មកពួកគេឈប់រៀន។<br><br>សកម្មភាពសំខាន់ៗដើម្បីដោះស្រាយបញ្ហាប្រឈម៖ ក្រុមការងាររបស់យើងសហការជាមួយសាលារៀន ឪពុកម្តាយ និងសហគមន៍ ដើម្បីតាមដានសិស្សដែលមានហានិភ័យ និងផ្តល់ការប្រឹក្សាទាន់ពេលវេលា។ យើងធ្វើការតាមដានជាប្រចាំលើសុខុមាលភាពផ្លូវចិត្ត ការអនុវត្តការសិក្សា និងស្ថានភាពគ្រួសាររបស់សិស្ស សម្រាប់ការធ្វើអន្តរាគមន៍ដំបូង។ យើងរៀបចំវគ្គអប់រំ ការប្រឹក្សា និងកម្មវិធីលើកកម្ពស់ការយល់ដឹងសម្រាប់ទាំងសិស្ស និងឪពុកម្តាយ។ ទោះជាយ៉ាងណា រដ្ឋាភិបាលនៅតែមានសារៈសំខាន់ក្នុងការធ្វើអន្តរាគមន៍លើល្បែងស៊ីសង គ្រឿងញៀន និងក្រុមក្មេងទំនើងក្នុងសហគមន៍។ |
| អ្នកចូលរួម៖ តើមានវិធីសាស្ត្រអ្វី ដើម្បីវាយតម្លៃថាកុមារ ឬយុវជនជ្រើសរើសជំនាញឬមុខវិជ្ជាត្រូវនឹងគាត់? | លោកស្រី៖ យើងមានការផ្តល់សេវាប្រឹក្សាអាជីព ដើម្បីឱ្យប្រាកដថាគាត់ចង់ធ្វើអ្វី និងរៀនអ្វីដែលជាចំណង់ចំណូលចិត្តរបស់គាត់។ ប៉ុន្តែមិនមែនធ្វើតែម្តងទេ គឺវាត្រូវមានជំហានច្រើនក្នុងការប្រឹក្សាអាជីព។ ទន្ទឹមនេះយើងក៏បានជជែកគ្នាអំពីទីផ្សាការងារដែរ ថាអ្វីដែលគាត់រើសត្រូវនឹងចំនង់ចំណូលចិត្ត ហើយនឹងទីផ្សាការងារបច្ចុប្បន្ន តាមរយៈកម្រងសំណួរ។ |
| លោក ស្រី PSE៖ យើងបានជួយសិស្សតាមវិធីផ្សេងៗ។ ប៉ុន្តែពេលជួយច្រើន គេយល់ថាវាជាបន្ទុករបស់NGO ពេលមានបញ្ហា ឬសិស្សរៀនខ្សោយ។ តើមានវិធីសាស្ត្រអ្វីក្នុងការធ្វើការជាមួយនាយកដើម្បីគាត់ធ្វើការដោយពេញចិត្ត កុំឱ្យដាក់បន្ទុកគ្នាទៅវិញទៅមក? មិនមែនសាលារៀនទាំងអស់ទេ គឺមួយចំនួនប៉ុណ្ណោះ។ | លោកស្រី ចា៎ះពិតណាស់យើងបានជួបបញ្ហាទាំងនោះ។ ប៉ុន្តែយើងអាចធ្វើការជាមួយឪពុកម្តាយ និងព្យាយាមធ្វើការជាមួយសាលារៀន ដើម្បីឱ្យយល់ពីស្ថានភាពនៃគ្រួសារសិស្ស លក្ខខណ្ឌជីវភាពផ្សេងៗ។ យើងនៅតែបន្តធ្វើការដោយភាពអត់ធ្មត់ និងធ្វើតាមតួនាទីរៀងៗខ្លួនដើម្បីឱ្យមានការយោគយល់គ្នាទាំងផ្នែកសហគមន៍ សាលារៀន អាណាព្យាបាល និងអ្នកពាក់ព័ន្ធផ្សេងៗ។ |

## ដំណោះស្រាយទី៦៖

***បរិយាបន្ន និងសមភាពយេនឌ័រក្នុងការអប់រំ***

***ការជំរុញការអប់រំបរិយាបន្ន៖ ការលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នសម្រាប់ទាំងអស់គ្នា***

វាគ្មិនទី១៖ ការលើកកម្ពស់សមធម៌យេនឌ័រ និងការអប់រំបរិយាបន្ននៅក្នុងសាលារៀនជនបទ

បង្ហាញដោយ លោកស្រី ជួន ដារីត អ្នកជំនាញផ្នែក GESSI អង្គការUWS

វាគ្មិនទី២៖ Technology on Her Terms: gender and inclusion in education under digital transformation by Ms. Yuan Xu, Education Analyst, UNESCO Phnom Penh

វាគ្មិនទី៣៖ លោកស្រី តិល ចាន់ឌី Gender Equality Disability and Social Inclusion, អង្គការChildFund

វាគ្មិនទី៤៖ ការអប់រំបរិយាបន្នសម្រាប់កុមារដែលមានតម្រូវការពិសេស បង្ហាញដោយលោក ផែង សំណាង នាយកប្រតិបត្តិ អង្គការDDSP

| លទ្ធផលនៃកិច្ចពិភាក្សា | |
|---|---|
| បទបង្ហាញវាគ្មិនទី១៖<br><br>លោកស្រី ជួន ដារីត<br><br>អ្នកជំនាញផ្នែក GESSI<br><br>អង្គការUWS<br><br>ការលើកកម្ពស់សមធម៌យេនឌ័រ និងការអប់រំបរិយាបន្ននៅក្នុងសាលារៀនដាច់ស្រយាល។ | ទាក់ទងនឹងប្រធានបទ លោកស្រីបានលើកចំណុចសំខាន់ៗរួមមាន៖<br><br>- បញ្ហាប្រឈមដែលយើងបានជួបប្រទះក្នុងការធ្វើការជាមួយសាលារៀននៅតំបន់ដាច់ស្រយាលនៅនប្រទេសកម្ពុជា<br>- វិធីសាស្ត្រដែលUWSធ្វើការឆ្លើយតបទៅលើបញ្ហាទាំងអស់នោះ<br>- អនុសាសន៍ និងសំណូមពរដើម្បីលើកកម្ពស់យេនឌ័រ និងបរិយាបន្នក្នុងវិស័យអប់រំ<br>- ផែនការបន្ទាប់។<br><br>គោលដៅរបស់UWS គឺសហគមន៍ជនបទដាច់ស្រយាល ស្ថិតនៅចម្ងាយច្រើនគីឡូម៉ែត្រពីទីប្រជុំជន។ ឧបសគ្គជារួម ដែលយើងបានជួបប្រទះកន្លងមក គឺសហគមន៍នៅដាច់ដោយឡែក និងផ្ទះមួយៗនៅឆ្ងាយពីគ្នាដែលផ្ទះនីមួយៗ មានកុមារដែលត្រូវការទទួលបានការអប់រំ។ ដើម្បីឱ្យពួកគាត់ទទួលបានការអប់រំ UWS បានសងសង់សាលារៀន។ ឧបសគ្គមួយទៀតគឺ ភាពក្រីក្រដែលពួកគាត់នៅតំបន់ដាច់ស្រាយាលដែលយើងពិបាកទៅដល់ ហើយត្រូវបានបំភ្លេច ខណៈពួកគេគាត់ប្រើប្រាស់ភាសាច្រើនប្រភេទក្នុងការទំនាក់ទំនង។ UWS បានដោះស្រាយដោយបណ្តុះបណ្តាលគ្រូបង្រៀន គ្រូសហគមន៍ និងគ្រូរដ្ឋ ទាំងក្របខណ្ឌ និងកិច្ចសន្យាដើម្បីឱ្យពួកគាត់បង្រៀនកុមារមានប្រសិទ្ធភាព និងគុណភាព។ យើងក៏បានផ្តល់វគ្គបណ្តុះបណ្តាលទាក់ទងនឹងយេនឌ័រ និងមានបរិយាបន្ន។<br><br>ឧបសគ្គមួយទៀត គឺផ្នត់គំនិត និងវប្បធម៌ដែលបង្កឱ្យមានហានិភ័យ និងប៉ះពាល់ដល់សុខសុវត្ថិភាព និងអនាគតរបស់កុមារ ដូចជាការរៀបការវ័យក្មេង ការឱ្យតម្លៃនៃការសិក្សាទាបពិសេសកុមារី។ មួយវិញទៀតគឺកង្វះអនាម័យ និងការយល់ដឹងពីការមករដូវរបស់កុមារី។ ដូចនេះ យើងបានធ្វើការជាមួយនឹងសហគមន៍ឱ្យបានយលពីតម្លៃនៃការសិក្សា និងការអប់រំសម្រាប់ក្មេងស្រី។ យើងបានបង្កើតឱ្យមានក្រុមឪពុកម្តាយ និងធ្វើការជាមួយក្រុម |

ប្រឹក្សាកុមារី ដើម្បីបង្រឹងការអប់រំ និងលើកកម្ពស់កិច្ចការងារទាំងអស់នេះ នៅក្នុងសាលា។ យើងក៍បានផ្តល់ និងកែលម្អប្រព័ន្ធទឹកស្អាត និងអនាម័យនៅក្នុងសាលាដែលបានគិតគូរដល់ការឆ្លើយតបយេនឌ័រដាក់លាក់ផងដែរ។

លោកស្រីបានបង្ហាញពីពិន្ទុយុត្តភាព(Gender parity score) នៃយេនឌ័រនៅសាលាគោលដៅ UWS ទាក់ទងនឹងយេនឌ័រគឺ០.៩៥។ ពិន្ទុនេះនឹងស្មើគ្នារវាងក្មេងប្រុសនិងក្មេងស្រីប្រសិនឡើងដល់១។ សម្រាប់សមាមាត្រសិស្ស-គ្រូ៖ ២១:១ បានន័យថានៅសាលាដាច់ស្រយាលគឺគ្រូ១នាក់ បង្រៀនសិស្សតែ២១នាក់ប៉ុណ្ណោះ។ ប៉ុន្តែមានភាពច្របូកច្របល់ដោយសារ ២១នាក់ នេះ មិនមែនបង្រៀនតែក្នុងមួយថ្នាក់ទេ គឺរៀនថ្នាក់គួប តែមួយថ្នាក់។ ថ្នាក់ខ្លះមានសិស្សតែ ១០នាក់ ឬ១០ជាង ក្នុងកម្រិតថ្នាក់ផ្សេងគ្នា តែរៀនក្នុងបន្ទប់តែមួយ។

ការបង្រៀនដែលឆ្លើយតបនឹងយេនឌ័រ គឺលើកកម្ពស់សមភាពយេនឌ័រក្នុងថ្នាក់រៀន ដើម្បីធានាថាកុមារី និងកុមារាមានឱកាសស្មើគ្នាក្នុងការរៀន ការចូលរួម និងទទួលបានជោគជ័យ តាមរយៈការដោះស្រាយភាពលំអៀង ផ្នត់គំនិត និងឧបសគ្គក្នុងការអប់រំ។ ការបង្រៀនឆ្លើយតបយេនឌ័រ ជួយបន្ថយគម្លាតយេនឌ័រក្នុងការអប់រំ (ដូចជាការចុះឈ្មោះចូលរៀន ការរក្សាកុមារនៅក្នុងសាលា ក៏ដូចជាលទ្ធផលសិក្សា) ផ្តល់អំណាចដល់ក្មេងស្រីឱ្យបន្តនៅក្នុងសាលា និងជោគជ័យក្នុងការសិក្សា បំបែកផ្នត់គំនិតនិងបង្កើតសមភាពសង្គម និងគាំទ្រក្មេងប្រុសនិងក្មេងស្រីដើម្បីអភិវឌ្ឍជំនាញលើសពីតួនាទីយេនឌ័រប្រពៃណី។

ជាតុសំខាន់នៃការបណ្តុះបណ្តាលគ្រូទាក់ទងនឹងឆ្លើយតបយេនឌ័រ មានដូចជា៖

- ការយល់ដឹងអំពីយេនឌ័រ៖ ដើម្បីឱ្យគ្រូមានជំនាញ ការយល់ដឹងអំពីយេនឌ័រដើម្បីទទួលស្គាល់ និងលុបបំបាត់ការរើសអើងក្នុងថ្នាក់រៀន។
- វិធីសាស្រ្តបង្រៀនតាមយេនឌ័រ៖ ការលើកទឹកចិត្តឱ្យមានការចូលរួមស្មើៗគ្នាដោយមានបរិយាបន្ន និងការជៀសវាងពីកត្តាយេនឌ័រ (ឧ.ក្មេងប្រុសពូកែគណិតវិទ្យា ក្មេងស្រីគឺពូកែក្នុងការអាន)។
- កម្មវិធីសិក្សា និងសម្ភារៈដោយមិនលំអៀង៖ ការប្រើប្រាស់ធនធានបង្រៀនដែលតំណាងឱ្យភេទទាំងពីរស្មើគ្នានៅក្នុងសៀវភៅសិក្សា រឿង និងការពិភាក្សាក្នុងថ្នាក់។
- អន្តរកម្ម និងការចូលរួមក្នុងថ្នាក់រៀន៖ ធានាថាទាំងក្មេងប្រុស និងក្មេងស្រីទទួលបានស្មើគ្នាការយកចិត្តទុកដាក់ និងឱកាសដើម្បីសួរសំណួរ បញ្ចេញមតិ និងដឹកនាំសកម្មភាព។
- បរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព និងបរិយាបន្ន៖ ធានានូវការការពារពីយេនឌ័រ អំពើហិង្សា ការរើសអើង ការដាក់ទណ្ឌកម្មលើរាងកាយ និងការមិនរាប់បញ្ចូលដោយផ្អែកលើពិការភាព ការលើកកម្ពស់សុខុមាលភាពផ្លូវអារម្មណ៍ និងផ្លូវកាយសម្រាប់សិស្សទាំងអស់។

ចន្លោះប្រហោង និងបញ្ហាប្រឈមក្នុងការឆ្លើយតបការបណ្តុះបណ្តាលគ្រូះ

- ការបណ្តុះបណ្តាលមានកំណត់សម្រាប់គ្រូបង្រៀនផ្នែកឆ្លើយតបយេនឌ័រ
- ផ្នត់គំនិត គរុកោសល្យ ជាពិសេសសម្រាប់គ្រូបង្រៀននៅមិនទាន់ទទួលយកជាពិសេសនៅតំបន់ដាច់ស្រយាល ដែលឆ្លើយតបនឹងយេនឌ័រដោយសារតែជំនឿវប្បធម៌ចាក់ឫសយ៉ាងជ្រៅ។
- តម្រូវការសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃកាន់តែប្រសើរឡើងនៃប្រសិទ្ធភាពបណ្តុះបណ្តាល។
- មេដឹកនាំស្ត្រីតិចតួចះ កង្វះគំរូសម្រាប់ក្មេងស្រី។

វិធីសាស្ត្រមួយទៀត គឺការកែលម្អ និងការដំឡើងឧបករណ៍ទឹកស្អាតអនាម័យដែលមេត្រីដើម្បីធានាថាសាលារៀនមានសុវត្ថិភាពខាងរាងកាយសម្រាប់ក្មេងស្រី គឺជាអាទិភាពមួយ។ យើងផ្តោតលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន ដោយការផ្តល់ការគាំទ្រអនាម័យពេលមករដូវ និងគោលនយោបាយការពារកុមារ ដើម្បីបង្កើតបរិយាកាសសុវត្ថិភាព ដែលក្មេងស្រីមានអារម្មណ៍ថាត្រូវបានគាំទ្រ។

ចំណុចមួយទៀតគឺ ការចូលរួមរបស់ក្រុមមាតា សហគមន៍មូលដ្ឋានដើម្បីលើកកម្ពស់សមភាពយេនឌ័រ។ សហគមន៍មូលដ្ឋាន គឺជាចំណុចកណ្តាលនៃការបង្កើតការផ្លាស់ប្តូរយូរអង្វែង។ យើងចូលរួមជាមួយឪពុកម្តាយ អ្នកដឹកនាំ និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀតនៅគ្រប់ដំហាននៃដំណើរការ។ UWS លើកទឹកចិត្តមាតាបិតា ឱ្យដើរតួនាទីយ៉ាងសកម្មក្នុងការគ្រប់គ្រងសាលារៀន និងការសម្រេចចិត្តក្នុងការអប់រំ។ តាមរយៈក្រុមមាតាបិតារបស់យើង ឪពុកម្តាយទទួលបានចំណេះដឹង និងការគាំទ្រពួកគេ ត្រូវការតស៊ូមតិសម្រាប់ការអប់រំកូនស្រីរបស់ពួកគេ។ ក្លឹបកុមារីនៅក្នុងសាលារៀន ផ្តល់កន្លែងសុវត្ថិភាពសម្រាប់ក្មេងស្រីដើម្បីបញ្ចេញកង្វល់ បង្កើតទំនុកចិត្ត និងតស៊ូមតិសម្រាប់តម្រូវការរបស់ពួកគេ។

**អនុសាសន៍សំខាន់ៗសម្រាប់ការពង្រឹងសមភាពយេនឌ័រ និងបរិយាបន្ន**

- ពង្រីកការបណ្តុះបណ្តាលគ្រូដែលឆ្លើយតបនឹងយេនឌ័រ និងការអនុវត្ត។
- ដាក់បញ្ចូលគរុកោសល្យដែលឆ្លើយតបនឹងយេនឌ័រទៅក្នុងគោលនយោបាយជាតិ/របៀបវារៈ និងវិជ្ជាជីវៈគ្រូបង្រៀន កម្មវិធីអភិវឌ្ឍមានសារៈសំខាន់ណាស់សម្រាប់ការធ្វើឱ្យអ្នកអប់រំមានចំណេះដឹង និងជំនាញដើម្បីអនុវត្តការបង្រៀនឆ្លើយតបនឹងយេនឌ័រក្នុងការបង្រៀនប្រចាំថ្ងៃរបស់ពួកគេ។
- ការកែលម្អប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដើម្បីតាមដានសមភាពយេនឌ័រ រីកចម្រើន ជាពិសេសលើការឆ្លើយតបយេនឌ័រក្នុងការនៅក្នុងអនុវត្តថ្នាក់រៀន។
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលមូលដ្ឋាន NGO និងដៃគូអភិវឌ្ឍ។

| | |
|---|---|
| | - លើកកម្ពស់គំរូស្ត្រីក្នុងការបង្រៀន/តួនាទីជាអ្នកដឹកនាំក្នុងការអប់រំ និងផ្តល់សិទ្ធិអំណាចដល់ក្លឹបកុមារី និងក្រុមមាតាដែលជាភ្នាក់ងារផ្លាស់ប្តូរនៅក្នុងសាលារៀនដាច់ស្រយាល។<br>- បន្តធ្វើឱ្យសាលាប្រសើរឡើង ដើម្បីបំពេញតាមស្តង់ដាសុវត្ថិភាព និងបរិយាបន្ន។ |
| បទបង្ហាញដោយវាគ្មិនទី២៖<br><br>លោកស្រី Yuan Xu, Education Analyst,<br><br>អង្គការUNESCO<br><br>Technology on Her Terms (បច្ចេកវិទ្យាក្នុងដៃស្ត្រី)៖ យេនឌ័រ និងការអប់រំបរិយាបន្នក្រោមបរិបទនៃការប្រែប្រួលឌីជីថល | លោកស្រីធ្វើបទបង្ហាញអំពីទំនាក់ទំនងរវាងយេនឌ័រ បរិយាបន្ន និងបម្រែបម្រួលឌីជីថលក្នុងវិស័យអប់រំ និងភាពរីកចម្រើនរបស់ពិភពលោក ក្នុងការកាត់បន្ថយភាពវិសមភាពយេនឌ័រក្នុងការអប់រំ។ ចាប់ពីឆ្នាំ២០០៩ ប្រទេសភាគច្រើនបានសម្រេចគោលដៅនៃភាពសមភាពយេនឌ័រ ក្នុងការចូលរៀនបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ និងឆ្នាំ២០១៣ ក៏សម្រេចបានចំពោះថ្នាក់មធ្យមសិក្សាទុតិយភូមិផងដែរ។ ភាពរីកចម្រើននេះបញ្ជាក់ពីការប្តេជ្ញារបស់រដ្ឋាភិបាលជាច្រើន ដោយមានប្រទេសចំនួន ៣៦% បានកំណត់គោលដៅជាតិអំពីបញ្ហានេះ។<br><br>លោកស្រី បានបញ្ជាក់ថា ក្នុងផ្នែកលទ្ធផលសិក្សាថា សិស្សស្រីកំពុងបង្ហាញប្រសិទ្ធភាពលើសសិស្សប្រុសជាពិសេសក្នុងផ្នែកអំណាន។ ទិន្នន័យ PISA ឆ្នាំ ២០២២ បង្ហាញថាសម្រាប់សិស្សប្រុស ១០០ នាក់ដែលមានជំនាញអានល្អ នៅចុងថ្នាក់មធ្យមសិក្សាបឋមភូមិ មានសិស្សស្រីចំនួន ១១៥ នាក់ដែលមានជំនាញដូចគ្នា។ បន្ថែមពីនេះ ទិន្នន័យឆ្នាំ ២០២៣ បង្ហាញថា វិសមភាពអក្ខរកម្មយេនឌ័រ សម្រាប់មនុស្សពេញវ័យក៏កំពុងកាត់បន្ថយផងដែរ ដោយស្ត្រីគ្របដណ្តប់បាន ៥៦%។<br><br>ទោះជាមានភាពស្មើគ្នាមួយចំនួនក៏ដោយ វាមិនបញ្ជាក់ថាស្មើទាំងអស់នោះទេ។ សិស្សស្រីនៅតំបន់ជនបទ និងគ្រួសារក្រីក្រនៅតែជួបប្រទះនឹងរនាំងនៃការទទួលបានអប់រំ។ ជាក់ស្តែង បណ្តាសាលាបឋមជាច្រើននៅអាស៊ីកណ្តាល អាស៊ីខាងត្បូង និងអាស៊ីខាងកើត នៅតែខ្វះបង្គន់ដែលបែបចែកភេទ ច្រើនជាង២០%។ ក្នុងកម្រិតអនុវិទ្យាល័យ និងសាកលវិទ្យាល័យ ការចូលរៀនក៏មានការកើនឡើងយ៉ាងខ្លាំងក្នុងទសវត្សរ៍ចុងក្រោយ ប៉ុន្តែសិស្សស្រីនៅតែមានឱកាសតិចជាងសិស្សប្រុសក្នុងការធ្វើសិក្សាអន្តរជាតិ។ ការសិក្សាបង្ហាញថាទោះជាស្ត្រីគ្របដណ្តប់នៅកម្រិតបឋមសិក្សា តែថយចុះនៅកម្រិតខ្ពស់ៗ៖ ៩៦% នៅថ្នាក់មត្តេយ្យ ៧៦% នៅបឋម ៥៩%នៅមធ្យម និងត្រឹមតែ ៤៤%នៅថ្នាក់ខ្ពស់ជាងនេះ។<br><br>លោកស្រីបន្តអំពីបច្ចេកវិទ្យា គឺជាកំពុងផ្លាស់ប្តូរការអប់រំ។ បច្ចេកវិទ្យាបានធ្វើឱ្យការអប់រំកាន់តែបើកចំហរ និងមានភាពបត់បែន ស្របនឹងការអភិវឌ្ឍនៃវេទិកាអនឡាញ កម្មវិធីស្វ័យប្រវត្តិ និងការអប់រំជាបុគ្គល។ បច្ចេកវិទ្យាបានជួយបង្កើនសេរីភាព សមត្ថភាពវិភាគ និងគ្រប់គ្រង ដោយប្រើការសិក្សាភាពសម្រួលជាមួយ AI ការពិនិត្យសមត្ថភាពសិស្ស និងការប្រើឧបករណ៍ច្នៃប្រឌិតដូចជា gamification និងវីដេអូ។ យ៉ាងណាមិញ ស្ត្រីជាច្រើននៅតែមិនទាន់ស្ថិតនៅក្នុងផ្នែកឌីជីថលនៅឡើយ។ ក្នុងឆ្នាំ២០២៣ បុរស ៨១% មានទូរស័ព្ទដៃ បើប្រៀបធៀបនឹងស្ត្រីត្រឹម ៧៥% ប៉ុណ្ណោះ។ ជាពិសេស ក្នុងប្រទេសក្រីក្រ ដោយមាន |

| | |
|---|---|
| | គម្លាត ១៧%។ លើសពីនេះ ការប្រើអ៊ីនធឺណិត ក៏បង្ហាញភាពខុសគ្នា៖ បុរស ៧០% ខណៈស្ត្រីមានត្រឹមតែ ៦៥% ប៉ុណ្ណោះ ដែលប្រើអ៊ីនធឺណិត។<br><br>ការចូលរួមរបស់ស្ត្រីក្នុងវិស័យ STEM នៅការកម្រិត។ ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយ ចំនួនស្ត្រីរៀនបរិញ្ញាបត្រ STEM នៅតែជាប់ត្រឹម ៣៥%។ ការជ្រើសរើសវិជ្ជាជីវៈបានរងឥទ្ធិពលពីផ្នត់គំនិត និងបទដ្ឋានចាស់បុរាណ។ ទិន្នន័យឆ្នាំ ២០១៩ បង្ហាញថា សិស្សស្រីគ្មានទំនុកចិត្តលើគណិតវិទ្យាដូចសិស្សប្រុសទេ។<br><br>ជំនាញឌីជីថលក៏មានភាពខុសគ្នា៖ សម្រាប់បុរស ១០០នាក់ ដែលមានជំនាញក្នុងកម្មវិធី spreadsheet មានស្ត្រីត្រឹម ៨២នាក់។ សម្រាប់ជំនាញកម្មវិធីសរសេរកូដ មានត្រឹមតែស្ត្រី ៥០នាក់ សម្រាប់បុរស ១០០នាក់។ ក្នុងវិស័យបច្ចេកវិទ្យា AI៖ ត្រឹមតែ ២០% ជាស្ត្រីក្នុងតួនាទីបច្ចេកទេស ១២% ជាអ្នកស្រាវជ្រាវ AI និងតែ ៥% ប៉ុណ្ណោះជាអ្នកអភិវឌ្ឍកម្មវិធី software។<br><br>បញ្ហាជាច្រើនក៏កើតឡើងនៅផ្នែកហានិភ័យឌីជីថលចំពោះសិស្សស្រី។ ប្រព័ន្ធផ្សព្វផ្សាយសង្គមពង្រឹងបទដ្ឋានយេនឌ័រ៖ ក្មេងស្រីត្រូវបានប៉ះពាល់នឹងមាតិកាដែលបង្គ្រោះថ្នាក់ស្តង់ដារាងកាយមិនប្រាកដប្រជា និងគំរូអាជីព។ អំពើហិង្សាផ្អែកលើយេនឌ័រតាមអ៊ីនធឺណិត៖ ក្មេងស្រីប្រឈមមុខនឹងការគំរាមកំហែងតាមអ៊ីនធឺណិត ការចែករំលែករូបភាពដែលមិនមានការស្នើសុំ និងកាន់តែខ្លាំងឡើង ការរំលោភបំពានក្លែងក្លាយដែលបង្កើតដោយ AI រួមទាំងនៅក្នុងការកំណត់សាលារៀនផងដែរ។<br><br>តើការអប់រំអាចធានាបាននូវសមភាពបច្ចេកវិទ្យា និងបរិយាបន្នដោយរបៀបណា? ដើម្បីធានាថាបច្ចេកវិទ្យាអប់រំ នាំឱ្យមានសមភាពយេនឌ័រ និងបរិយាបន្នលោកស្រីបានផ្តល់អនុសាសន៍ចម្បងៗដូចជា៖<br><br>- បង្រៀនជំនាញឌីជីថល/អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយតាំងពីដំបូង<br>- បណ្តុះបណ្តាលគ្រូបង្រៀនឱ្យចេះប្រឈមមុខនឹងភាពលំអៀងយេនឌ័រ និងលើករុកោសល្យដែលឆ្លើយតបនឹងយេនឌ័រ<br>- ផ្សព្វផ្សាយតួនាទីស្ត្រីជាគំរូក្នុងបច្ចេកវិទ្យា<br>- ពង្រឹងនីតិវិធីសុវត្ថិភាពអនឡាញក្នុងប្រព័ន្ធអប់រំ និងសាលារៀន<br>- ត្រូវប្រាកដថាឧបករណ៍ AI និង EdTech ត្រូវបានរៀបចំឡើង និងត្រួតពិនិត្យប្រកបដោយក្រមសីលធម៌ ដើម្បីឱ្យមានបរិយាបន្ន។<br><br>លោកស្ត្រីក៏បានលើកឡើងអំពីគម្រោងរបស់អង្គការ UNESCO នៅកម្ពុជា ស្តីពីយេនឌ័រ និងបរិយាបន្នក្នុងវិស័យអប់រំផងដែរ។<br><br>- GPE-KIX៖ សមភាពយេនឌ័រ និងការផ្តាច់ខ្លួនរបស់កុមារពីការអប់រំនៅកម្ពុជា។ |

| | |
|---|---|
| | - គម្រោងស្រាវជ្រាវផ្អែកលើភស្តុតាងជាសាកល ដែលមានប្រទេសសាកល្បងចំនួនបី រួមទាំងប្រទេសកម្ពុជា។គោលដៅគឺដើម្បីឱ្យមានគំរូអន្តរាគមន៍ ដែលអាចធ្វើមាត្រដ្ឋានបាន ដើម្បីដោះស្រាយបទដ្ឋាននៃភាពជាបុរសដែលមានគ្រោះថ្នាក់ រក្សាក្មេងប្រុសជំទង់ឱ្យចូលរួមក្នុងសាលារៀន និងលើកកម្ពស់សមភាពយេនឌ័រ។<br>- ការអភិវឌ្ឍនាពេលខាងមុខ៖ ការអភិវឌ្ឍគោលការណ៍ណែនាំគរុកោសល្យបម្រែបម្រួលយេនឌ័រដែលត្រូវសាកល្បង។<br>- កម្មវិធីអក្ខរកម្មនៅក្នុងរោងចក្រ (Factory Literacy Programme-FLP) សម្រាប់អក្ខរកម្ម និងការផ្តល់សិទ្ធិអំណាចដល់កម្មការិនីរោងចក្រកាត់ដេរ។ ដើម្បីបំពាក់ឱ្យកម្មកររោងចក្រនូវការអាន ការសរសេរលេខ និងជំនាញ ដើម្បីគាំទ្រការទំនាក់ទំនង និងការអនុវត្តការងារប្រចាំថ្ងៃរបស់ពួកគេ។ អង្គការUNESCO និងក្រសួងអប់រំ បានបង្កើត FLP តាំងពីឆ្នាំ២០១៦។ អ្នកសិក្សា-តាមរយៈការរៀននៅកន្លែងធ្វើការ នឹងទទួលបានវិញ្ញាបនបត្របញ្ចប់ការសិក្សាដែលស្មើនឹងថ្នាក់ទី៤ឬទី៦ ដើម្បីបន្តការសិក្សាបន្ថែមទៀតនៅគ្រឹះស្ថានអប់រំផ្លូវការឬក្រៅផ្លូវការ។ អ្នកសិក្សាលើសពី ៣,៥៩០នាក់ មកពីរោងចក្រច្រើនជាង ២៥បានទទួលអត្ថប្រយោជន៍ពីគម្រោង ដែលក្នុងនោះជាង ៩៥.២% គឺជាស្ត្រី។<br><br>លោកស្រី ក៏បានលើកអំពីការចូលរួមផ្សេងទៀត ក្នុងការដោះស្រាយហានិភ័យឌីជីថលដល់ក្មេងស្រីក្នុងការអប់រំ ដូចជា៖<br><br>- ក្រមសីលធម៌នៃការវាយតម្លៃការត្រៀមខ្លួន AI សម្រាប់កម្ពុជា។<br>- ដំណើរការនៅឆ្នាំ២០២៤ ដោយCADT និងUNESCO សហការជាមួយMPTC និងក្រសួងពាក់ព័ន្ធចំនួន២៦ និងអ្នកពាក់ព័ន្ធផ្សេងទៀត។<br>- ការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការពិចារណាលើក្រមសីលធម៌ជាស្នូលនៃការអនុម័ត AI<br>- ក្របខ័ណ្ឌចំណេះដឹងផ្នែកឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន<br>- ការគាំទ្ររបស់UNESCOចំពោះ MPTC ដើម្បីចាប់ផ្តើមក្របខ័ណ្ឌសមត្ថភាពឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន (DMIL) ដំបូងបង្អស់របស់កម្ពុជានៅឆ្នាំ២០២៤<br>- ការអភិវឌ្ឍនាពេលខាងមុខនៃ ICT និង ក្របខ័ណ្ឌសមត្ថភាពAI សម្រាប់គ្រូបង្រៀនជាលើកដំបូងរបស់កម្ពុជា។<br>- ផែនទីបង្ហាញផ្លូវយុទ្ធសាស្ត្រ សម្រាប់ការរួមបញ្ចូលក្របខ័ណ្ឌសមត្ថភាព AI និង ICT របស់កម្ពុជាសម្រាប់គ្រូបង្រៀនទៅក្នុងការអប់រំគ្រូបង្រៀន និងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ (CPD) ដោយមានបរិយាបន្នជាគោលការណ៍ស្នូល។<br>- ការបង្កើតមជ្ឈមណ្ឌលច្នៃប្រឌិត EdTech នាពេលខាងមុខនៅក្នុងវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ (TEI) |

| | |
|---|---|
| | - ជាមួយនឹងអាណត្តិនៃ CPD ឈានមុខគេសម្រាប់ការបង្កើនជំនាញ AI និង ICT និងការផ្តល់នូវភាពជាអ្នកដឹកនាំការគិតលើការផ្លាស់ប្តូរឌីជីថលក្នុងការអប់រំ ជាមួយនឹងការពង្រឹងសមត្ថភាពស្រាវជ្រាវលើ AI និង ICT ក្នុងការអប់រំស្របតាមគោលការណ៍ណែនាំបរិយាបន្ន និងយេនឌ័ររបស់អង្គការUNESCO។<br><br>ចុងបញ្ចប់ លោកស្រីបានផ្តល់សារសំខាន់មួយគឺ *«យើងត្រូវតែធានាថា បច្ចេកវិទ្យាផ្តល់សិទ្ធិអំណាចដល់ក្មេងស្រី និងស្ត្រី មិនមែនធ្វើឱ្យពួកគេបាត់បង់ប្រយោជន៍នោះទេ។ ការធានាឱ្យស្ត្រីចូលរួមក្នុងលក្ខខណ្ឌស្មើគ្នា ក្នុងការរៀបចំការផ្លាស់ប្តូរឌីជីថលដែលកំពុងដំណើរការរបស់ពិភពលោក នឹងធានាថាបច្ចេកវិទ្យាដំណើរការសម្រាប់មនុស្សគ្រប់គ្នា និងគាំទ្រដល់វឌ្ឍនភាពនៃការអប់រំ។ បច្ចេកវិទ្យាមិនគួរពង្រឹងរបាំងចាស់ទេ ប៉ុន្តែត្រូវបើកទ្វារថ្មី។»* |
| បទង្ហាញដោយវាគ្មិនទី៣៖<br>លោកស្រី តិល ចាន់ឌី<br>អង្គការឆាលហ្វាន កម្ពុជា<br>ពង្រឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមសម្រាប់ការអប់រំកម្រិតបឋមសិក្សា។ | លោកស្រីបានគូសបញ្ជាក់ពីទស្សនវិស័យរបស់អង្គការឆាលហ្វានគឺ ពិភពលោកមួយគ្មានភាពក្រីក្រដែលកុមារ និងយុវជនទាំងអស់អាចនិយាយថា «ខ្ញុំមានសុវត្ថិភាព ខ្ញុំទទួលបានការអប់រំ ខ្ញុំចូលរួមចំណែក ខ្ញុំមានអនាគត» និងមានបេសកកម្ម «យើងជាដៃគូដើម្បីបង្កើតការផ្លាស់ប្រែដល់សហគមន៍ និងប្រព័ន្ធដែលអាចឱ្យក្រុមកុមារ និងយុវជនងាយរងគ្រោះក្នុងភាពចម្រុះទាំងអស់ មានការយល់ដឹង និងអនុវត្តសិទ្ធិរបស់ពួកគេ»។<br><br>សម្រាប់ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ លោកស្រីបង្ហាញថា ជាទស្សនទានក្នុងការដោះស្រាយវិសមភាពនៃទំនាក់ទំនងអំណាចដោយផ្អែកលើ យេនឌ័រ ជាតិពន្ធុ ពិការភាព ទីតាំងភូមិសាស្ត្រ ភាសា វណ្ណៈ និងបញ្ហាផ្សេងៗទៀត។ ដើម្បីធ្វើការលើកស្ទួយសមភាពក្នុងទំនាក់ទំនងអំណាច ការធានាសិទ្ធិ ឱកាសស្មើគ្នា និងការគោរពដល់សមភាពសង្គមសម្រាប់មនុស្សគ្រប់រូប ដោយមិនមានការរើសអើងក្នុងសង្គម។<br><br>**ការផ្លាស់ប្រែលក្ខណៈ៖** ក្រុមដែលងាយរងគ្រោះ ជាពិសេសកុមារី កុមារមានពិការភាពរីករាយក្នុងការទទួលបានសេវា និងការអប់រំស្មើៗគ្នាក្នុងសង្គម ។<br><br>**បញ្ហា៖** កុមារមួយចំនួនមិនអាចទៅសាលារៀន ឬ មិនទទួលបានលទ្ធផលសិក្សាល្អដោយសារអត្តសញ្ញាណយេនឌ័រ និងពិការភាពរបស់ពួកគេ។<br><br>**ឫសគល់បញ្ហា៖** វិសមភាពអំណាចដោយផ្អែកលើយេនឌ័រ ពិការភាព ជាតិពន្ធុ ទ្រព្យធន ទីតាំងភូមិសាស្ត្រ ល.ល។ ដែលកុមារត្រូវបានផាត់ចេញ ឬ មិនទទួលបានការអប់រំ។<br><br>ក្របខណ្ឌGEDSI ក្នុងការអនុវត្តកម្រិតស្ថាប័ននិងកម្មវិធី<br>- យល់ដឹង (GEDSI Aware) ៖ ដាក់បញ្ចូល GEDSI នៅក្នុងផ្នែកណាមួយនៃសកម្មភាព ការគិតគូពីកុមារី កុមារា និងCWD។<br>- GEDSI ដែលលក្ខណៈការឆ្លើយតប (GEDSI Responsive)៖ កំណត់អត្តសញ្ញាណកុមារដែលងាយរងគ្រោះ/កុមារដែលខ្វះឱកាស➔ដកឧបសគ្គក្នុងដំណើរការ |

ចូលរួម/ផ្តល់ការចូលរួមសម្រាប់កុមារដោយជាក់លាក់ ➔គៀងគរការចូលរួមពីគ្រួសារ សហគមន៍ លើកម្ពស់សមភាពយេនឌ័រ និងបរិយាបន្ន ➔ពង្រឹងការយល់ដឹង និងជំនាញផ្នែក GEDSI ➔ផ្សារភ្ជាប់ជាមួយការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលលើGEDSI។

**GEDSI ដែលមានលក្ខណៈផ្លាស់ប្រែ**

- កំណត់បទដ្ឋានយេនឌ័រ ពិការភាព និងទំនាក់ទំនងអំណាច។
- កិច្ចសន្ទនាសហគមន៍លើបទដ្ឋានសង្គម ផ្លាស់ប្តូរអាកប្បកិរិយា។
- ភាពជាដៃគូ និងការតស៊ូមតិក្នុងដាក់បញ្ចូល GEDSI នៅក្នុងផែនការគោលនយោបាយ។ ធ្វើការវាស់ វែងចំពោះការផ្លាស់ប្តូរ។
- ក្របខណ្ឌGEDSI ក្នុងវិស័យអប់រំ៖ **១.ពង្រឹងប្រព័ន្ធអប់រំសាលារៀន និងអភិបាលកិច្ច សម្រាប់ការបង្រៀន និងការរៀន ប្រកបដោយបរិយាបន្ន៖** ប្រព័ន្ធអប់រំសាលារៀន ផ្តល់សេវាដោយស្មើភាពគ្នា, កំណត់ឱកាស និងធនធានសម្រាប់កុមារដែលងាយរងគ្រោះដើម្បីទទួលបានការអប់រំប្រកបដោយបរិយាបន្ន។ **២.ការគាំទ្រពីគ្រួសារ និង សហគមន៍ដើម្បីធ្វើឱ្យមានភាពល្អប្រសើរជុំវិញការចូល និងលទ្ធផលសិក្សា៖** ភាពវិជ្ជាមាននៃការអនុវត្តយេន ឌ័របង្កឱ្យកុមារដែលងាយរងគ្រោះទទួលបានសិទ្ធិអប់រំ និងការចូលរួមស្មើគ្នា។ និង**៣.កុមារទទួលបានសេវាអប់រំជាមូលដ្ឋាន ជាមួយនឹងលទ្ធផលសិក្សាល្អប្រសើរ៖** ក្រុម/កុមារដែលងាយរងគ្រោះ ត្រូវបានលើកម្ពស់ និងផ្តល់នូវធនធាន សម្ភារៈសម្រាប់ការសិក្សា។

**យុទ្ធសាស្ត្រ GEDSI ក្នុងវិស័យអប់រំ**

- ធ្វើការកំណត់នៅឧបសគ្គ, ស្វែងយល់អំពីអំណាច។
- ដៅចំណុច និងឱកាសដើម្បីការផ្លាស់ប្រែ។
- កិច្ចពិភាក្សាសហគមន៍អំពី យេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។
- អនុវត្តគម្រោងដែលផ្តោតសំខាន់លើសមភាពយេនឌ័រ ពិការភាព បរិយាបន្នសង្គមដែលមានសុចនាករច្បាស់លាស់ក្នុងការវាស់វែង។

***គម្រោង៖ ពង្រឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមកម្រិតបឋមសិក្សា (១១ សាលារៀនគោលដៅ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង)។*** គោលដៅនៃគម្រោង គឺលើកម្ពស់សុវត្ថិភាព និងការអប់រំបរិយាបន្ននៅសាលារៀនគោលដៅ ដើម្បីធ្វើឱ្យមានភាពល្អប្រសើរលើលទ្ធផលធំៗបី៖ ១.លើកកម្ពស់ការបង្រៀន ការរៀនបែបបរិយាបន្ន និងលទ្ធផលសិក្សារបស់សិស្សមានពិការភាព និងមិនមានពិការភាព។ ២.ពង្រឹងសមត្ថភាព គណៈគ្រប់គ្រងសាលារៀន លើការសិក្សាប្រកបដោយបរិយាបន្ន និងសុវត្ថិភាព។ និង៣.សហការ ជាមួយអាណាព្យាបាល និងអាជ្ញាធរក្នុងការគាំទ្រដល់កុមារដែលមានពិការភាព។

| | |
|---|---|
| | **ក្រុមគោលដៅនៃគម្រោង៖**<br>**សាលារៀន៖** មន្ត្រីអប់រំ ការិយាល័យស្រុក នាយកសាលា គ្រូបង្រៀន សិស្សកុមារដែលមានពិការភាព កុមារី ក្រុមប្រឹក្សាកុមារ ទីប្រឹក្សាកុមារី។<br>**សហគមន៍៖** អាជ្ញាធរថ្នាក់ស្រុក ឃុំ គកនក អាជ្ញាធរ មេភូមិ អ្នកស្ម័គ្រចិត្តសហគមន៍ អង្គការតំណាងជនមានពិការភាពថ្នាក់ស្រុក។<br>**គ្រួសារ៖** អាណាព្យាបាលសិស្សដែលមានពិការភាព។<br>សកម្មភាពគម្រោងពង្រឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម គឺកម្រិតនៃការផ្លាស់ប្រែ GEDSI ក្នុងវិស័យអប់រំទាក់ទងនឹង ចំណេះដឹងនិងសមត្ថភាព បទដ្ឋានសង្គម និងការអនុវត្ត ធនធាន និងប្រព័ន្ធ (គោលនយោបាយ ច្បាប់ស្ថាប័ន)។ |
| បទបង្ហាញវាគ្មិនទី៤៖<br>លោក ផែង សំណាង<br>នាយកប្រតិបត្តិ អង្គការDDSP<br>ការអប់រំបរិយាបន្នសម្រាប់កុមារដែលមានតម្រូវការពិសេស | អង្គការសេវាអភិវឌ្ឍន៍ជនពិការ (DDSP) ជាNGOក្នុងស្រុកដែលបានចុះបញ្ជីនៅឆ្នាំ ២០០៣ ដែលគោរព និងលើកកម្ពស់ឯករាជ្យភាពរបស់ជនដែលមានពិការភាព និងសហគមន៍របស់ពួកគេ តាមរយៈវិធីសាស្ត្រសហគមន៍ផ្អែកលើការអភិវឌ្ឍបរិយាបន្ន Community-Based Inclusive Development (CBID-Approach)។ DDSP បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរការអប់រំនៅក្នុងខេត្តពោធិសាត់ ដោយជួយសាលារៀនអនុវត្តការអប់រំបរិយាបន្ន និង ការបង្កើតថ្នាក់សមាហរណ៍កម្មសម្រាប់កុមារមានពិការសតិបញ្ញា និងជំងឺអូទីស្សឹម។ គិតត្រឹមឆ្នាំ២០២៥ DDSP បានចុះឈ្មោះសិស្ស ១១៥នាក់ (ស្រី៤១) នៅ ៨ ថ្នាក់សមាហរណ៍កម្ម និងសិស្ស ២២៩៦នាក់ (ស្រី ១១១៥នាក់) ក្នុង ២៩៥ ថ្នាក់អប់រំបរិយាបន្ន។<br>វិធីសាស្ត្រដែល DDSP ធ្វើចាប់ផ្តើមដោយការកំណត់អត្តសញ្ញាណពិការភាព និងការចុះឈ្មោះកុមារដែលមានពិការភាព (លើកកម្ពស់ការយល់ដឹងអំពីពិការភាព ការវាយតម្លៃឧបសគ្គ និងបញ្ហាកុមារក្រៅសាលារៀន)។ ផ្អែកលើតម្រូវការបុគ្គល កុមារត្រូវបានចុះឈ្មោះក្នុងថ្នាក់បរិយាបន្នដោយមានការគាំទ្រដាចាំបាច់ ឬថ្នាក់សមាហរណ៍កម្មសម្រាប់កុមារដែលមានពិការភាពសតិបញ្ញា និងជំងឺអូទីស្សឹម។ លើសពីការអប់រំមូលដ្ឋាន DDSP ក៏ផ្តល់ឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលបរិយាបន្ន (Inclusive Training Centre-ITC) របស់ខ្លួនផងដែរ។<br>លោកបង្ហាញថា ដើម្បីទទួលបានជោគជ័យ DDSP បានធ្វើអន្តរាគមន៍ជាបន្តបន្ទាប់ដោយ៖<br>- ផ្សព្វផ្សាយការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាពិការភាព និងកុមារក្រៅសាលា៖ ធ្វើឡើងនៅថ្នាក់ឃុំ និងសាលារៀន។<br>- ការកែលម្អបរិស្ថានសាលារៀន (បរិស្ថានកុមារមេត្រី)៖ ជួសជុលសាលាឡើងវិញនូវបង្គន់អនាម័យ ផ្លូវជម្រាល និងសួនកុមារដែលមានបរិយាបន្ន ផ្តល់ការបណ្តុះ |

| | |
|---|---|
| | បណ្តុះបណ្តាលដល់គ្រូបង្រៀនអំពីការអប់រំបរិយាបន្ន បណ្តុះបណ្តាលគ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន អំពីការធ្វើផែនការអភិវឌ្ឍសាលារៀន។<br>- ការគាំទ្រកុមារ (សម្ភារៈរៀន និងការធ្វើដំណើរ)<br>- សកម្មភាពរៀន និងបង្រៀនថ្នាក់សមាហរណ៍កម្មៈ ការបង្រៀនជាបុគ្គល (គ្រូម្នាក់សិស្សម្នាក់) ការចូលរួមរៀនទាំងអស់គ្នា(ការបង្រៀនក្រុមតូច)<br>- មណ្ឌលថែទាំ (ការអប់រំ និងការព្យាបាលដោយចលនា)។<br>- ការសហការ និងគាំទ្រពីមន្ទីរនិងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា។<br><br>លោកក៏បានបន្តបង្ហាញពី ការបើកផ្លូវទៅកាន់ការអប់រំ (ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលបរិយាបន្ន)។ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបង្កើតមុខរបរៈ ១.ការអប់រំវិជ្ជាជីវៈបច្ចេកទេសនិងការបណ្តុះបណ្តាល (ជំនាញកាត់ដេរ មូលដ្ឋានកុំព្យូទ័រ និងថ្នាក់ភាសាអង់គ្លេស) និង២.ការបង្កើតការងារតាមរយៈផ្លាស្ទិច-ផលិតផលកែច្នៃ។<br><br>**អន្តរាគមន៍ទាំងនេះ មានផលជះនៃកិច្ចសហប្រតិបត្តិការជាមួយផ្នែករដ្ឋាភិបាល ដូចជាៈ**<br><br>មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា<br><br>- ការចែករំលែកកន្លែងសម្រាប់ការិយាល័យរបស់ DDSP ក្នុងប្រតិបត្តិការសកម្មភាព<br>- ការផ្តល់គ្រឿងបរិក្ខារ និងសកម្មភាពអនុវត្តរួមគ្នាជាមួយ DDSP នៅក្នុងស្រុកគោលដៅ។<br>- ជំនួយអន្តរាគមន៍សម្រាប់បុគ្គលដែលមានតម្រូវការពិសេស ដូចជា រទេះរុញ សំបកឈើ និងឧបករណ៍ជំនួយផ្សេងៗទៀត។<br>- ការចូលរួមរបស់ DDSPs ជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) នៅថ្នាក់ក្រោមជាតិ។<br><br>មន្ទីរអប់រំ យុវជន និងកីឡា<br><br>- ផ្តល់ធនធានមនុស្សសម្រាប់ការបណ្តុះបណ្តាលស្តីពីការអប់រំបរិយាបន្ន<br>- ការត្រួតពិនិត្យរួមគ្នាជាមួយ DDSP ក្នុងការលើកកម្ពស់ថ្នាក់បរិយាបន្ន ទៅក្នុងសាលារៀនរដ្ឋ។<br>- បញ្ចុះបញ្ចូលការគាំទ្រសម្រាប់ការផ្តល់ជូនបន្ទប់រៀន ដើម្បីដំណើរការថ្នាក់បរិយាបន្ននៅក្នុងសាលារៀនរដ្ឋ និងសំណើគ្រូបង្រៀនកិច្ចសន្យា។<br><br>**បញ្ហាប្រឈម**<br><br>- កង្វះមុខងារគ្រូបង្រៀនក្នុងការបង្រៀនកុមារដែលមានពិការភាព<br>- គ្រួសារ និងសហគមន៍មិនយល់ពីសារៈសំខាន់នៃការអប់រំសម្រាប់CWD |

| | |
|---|---|
| | - គ្រូបង្រៀនយល់ថាលទ្ធផលទាប និងត្រួតថ្នាក់ គឺជាកេរ្តិ៍ឈ្មោះរបស់សាលារៀន និងបុគ្គលិកបង្រៀន<br>- ការអនុវត្តថ្នាក់បរិយាបន្ន គឺត្រូវបានដាក់បញ្ចូលនៅក្នុងស្ថិតិទិន្នន័យប្រចាំឆ្នាំរបស់សាលារៀន។<br>- កង្វះសូចនាករការអប់រំបរិយាបន្ន សម្រាប់ស្តង់ដាការអនុវត្តរបស់សាលារៀន។<br>- នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន គឺមានទស្សនៈថ្មីលើការអប់រំបរិយាបន្ន ដោយសារតែទើបរួមបញ្ចូលគ្នារវាងនាយកដ្ឋានអប់រំពិសេស និងអប់រំក្រៅប្រព័ន្ធ។ |
| ការចូលរួមរបស់អ្នកចូលរួម អំពីការប្រើប្រាស់គ្រូសម្រាប់ថ្នាក់បង្រៀនសិស្សដែលមានពិការភាព | ការិយាល័យអប់រំស្រុកពួក លើកឡើងពីការបន្សុីគ្នារបស់កុមារដែលមានពិការភាពសម្រាប់កុមារដែលមានកម្រិតសម្រាប់ថ្នាក់អប់រំពិសេស ថ្នាក់សមាហរណ៍កម្ម និងថ្នាក់បរិយាបន្ន គឺមានការលំបាកដោយសារសិស្សតិច(ឧទាហរណ៍ សម្រាប់សិស្សថ្នាក់សមាហរណ៍កម្ម១១នាក់ ត្រូវការប្រើប្រាស់គ្រូរហូតដល់២នាក់ ដែលលើសនិយាម)។ កិច្ចការនេះត្រូវការពន្យល់ និងទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែង ដោយលើកពីនីតិវិធី ឬលិខិតបទដ្ឋានគតិយុទ្ធផ្សេងៗដើម្បីឱ្យមានការយល់គ្នា និងអាចអនុវត្តបាន។ |
| លោក លូ លុយ អភិបាលរងស្រុកសាលាក្រៅ ខេត្តប៉ៃលិន | លោកលើកឡើងថា មានអង្គការច្រើនដែលនៅក្នុងសន្និសីតនេះ ប៉ុន្តែមិនមានពាក់ព័ន្ធ និងអនុវត្តនៅក្នុងខេត្តប៉ៃលិនសោះ។ លោកសូមសំណូមពិចារណាខេត្តប៉ៃលិនផង។<br><br>សំណួរលោកគឺ មូលហេតុអ្វីបានជាការប្រមូលសិស្សដែលបោះបង់ហើយ គឺរកមិនឃើញ។ ដូចនេះសូមអ្នកចូលរួមជួយផ្តល់យោបលផង។ ដោយសារពេលវេលា សូមអ្នកចូលរួមជួយឆ្លើយនៅពេលក្រោយ។ |

## IX. សង្ខេបចំណុចគន្លឹះសំខាន់ៗតាមប្រធានបទនៃសន្និសីទ

*លោកស្រី Florence May Cortina (Maya), Education Out Loud Coordinator, Asia South Pacific Association For Basic And Education (ASPBAE)*

ចំណុចនៃការចាប់ផ្តើមដំបូង គឺផ្អែកលើវិធីសាស្ត្រផ្អែកលើដំណោះស្រាយ។ បញ្ហាត្រូវបានបង្ហាញ និងកំណត់ដើម្បីឱ្យសន្និសីទស្វែងរកដំណោះស្រាយ ក្នុងស្មារតីនៃការបង្កើតថ្មី ការសម្របសម្រួល ស្មារតីនៃកិច្ចសហការ និងសាមគ្គីភាព។ ប៉ុន្មានឆ្នាំចុងក្រោយនេះ យើងបានឃើញពីការកើនឡើងនៃការចូលរៀនរបស់កុមារនៅក្នុងសាលារៀន ដែលជាភស្តុតាងដែលបង្ហាញថាយុទ្ធនាការចុះឈ្មោះ និងអន្តរាគមន៍ផ្សេងទៀតមានប្រសិទ្ធភាព។ ក៏ប៉ុន្តែ បញ្ហាដែលត្រូវកត់សម្គាល់គឺការបោះបង់ការសិក្សា និងអត្រាបញ្ចប់ការសិក្សា។ នេះយោងតាម ការវាយតម្លៃការសិក្សា ដែលបង្ហាញថាយើងមានបញ្ហាទាក់ទងនឹងលទ្ធផលសិក្សា។

**ដំណោះស្រាយទី១៖** ការលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីរបស់សាលារៀនដើម្បីពង្រឹងលទ្ធផលសិក្សារបស់សិស្ស? (ការចូលរួមរបស់NGO សាលារៀន អាជ្ញាធរមូលដ្ឋាន ឪពុកម្តាយអ្នកអាណាព្យាបាល និងសហគមន៍)។

មានទិដ្ឋភាពទូលំទូលាយនៃការអប់រំ/សាលារៀនជាប្រព័ន្ធអេកូឡូស៊ី ដែលរួមមានភាគីពាក់ព័ន្ធផ្សេងៗគ្នា ហើយភាគីពាក់ព័ន្ធទាំងនេះស្ថិតនៅក្នុងអន្តរទំនាក់ទំនង ហេដ្ឋារចនាសម្ព័ន្ធ និងគោលនយោបាយ និងកម្មវិធី។ តាមទស្សនៈទូលំទូលាយនេះ យើងកំពុងជ្រើសរើសវិធីសាស្ត្រសង្គមទាំងមូល ដោយគូសបញ្ជាក់ពីការចូលរួមរបស់សហគមន៍ (កាលពីមុន យើងឃើញតែសាលារៀន គ្រូបង្រៀន ឪពុកម្តាយ និងសិស្សប៉ុណ្ណោះ)។ តួនាទីសំខាន់របស់នាយកសាលាជាអ្នកសម្របសម្រួល ដើម្បីទាក់ទាញការចូលរួមយ៉ាងសកម្មរបស់មាតាបិតា និងសហគមន៍នៅក្នុងអភិបាលកិច្ចសាលារៀនដែលជាតួនាទីកាន់តែធំសម្រាប់អាជ្ញាធរមូលដ្ឋាន ជាពិសេសជាមួយនឹងគោលនយោបាយវិមជ្ឈការនាពេលថ្មីៗនេះ។

សម្រាប់រដ្ឋាភិបាល ក្រសួងត្រូវសម្របសម្រួល និងធ្វើការរួមគ្នា ដូចជា៖ ក្រសួងអប់រំ ធ្វើការជាជាមួយក្រសួងសុខាភិបាលសម្រាប់ផ្នែកសុខភាព និងអាហារូបត្ថម្ភ ប្រសិនជាយើងត្រូវថែរក្សាសុខុមាលភាពសិស្ស និងសូម្បីក្រសួងកំពុងធ្វើការលើវិស័យការងារក៏ដោយ ព្រោះការអប់រំត្រូវបានផ្សារភ្ជាប់ទៅនឹងការងារដែលទទួលបាន និងការងារសមរម្យ។

**ដំណោះស្រាយទី២៖** ភាពអាចបត់បែននៃការរៀនសូត្រសម្រាប់កុមារក្រៅសាលារៀន។ ការពង្រឹងការអនុវត្តថ្នាក់បំប៉នសិស្សរៀនយឺត។ ប្តូរតាមលំនាំពីការតឹងរឹង មកអាចបត់បែនបាន ដូចជា អន្តរកម្មរវាងការអប់រំផ្លូវកាយ និងការអប់រំក្រៅផ្លូវការសម្រាប់អ្នកដែលត្រូវបានទុកចោល។ វាជាការល្អក្នុងការក្រឡេកមើលបទពិសោធន៍ ហ្វីលីពីនដែលពួកគេបានបង្កើតប្រព័ន្ធរៀនជំនួស (ALTERNATIVE LEARNING SYSTEM- ALS) ដែលវាបានបង្កើតសិស្សដែលបញ្ចប់ថ្នាក់បឋមសិក្សា និងវិទ្យាល័យដូចជា Manny Pacquiao ដែលជាអ្នកប្រដាល់ហ្វីលីពីន ដ៏ល្បីល្បាញ។

**ដំណោះស្រាយទី៣៖** ការពង្រឹងជំនាញគរុកោសល្យ និងចំណេះដឹងនៃមុខវិជ្ជាបង្រៀនសម្រាប់គ្រូបង្រៀន។ របៀបនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនទំនើបក្នុងការរៀនកម្រិតថ្នាក់ដំបូង។ ការផ្លាស់ប្តូរតាមលំនាំ៖ សិស្សមជ្ឈមណ្ឌល-ការមើលឃើញសិស្សជាអ្នកសិក្សាសកម្ម មិនមែនជាអ្នកដែលនឹងគ្រាន់តែស្រូបយកចំណេះដឹងដែលផ្តល់ដោយគ្រូនោះទេ។

- ការផ្តល់អាទិភាពដល់ការបណ្តុះបណ្តាលគ្រូ – ការបណ្តុះបណ្តាល (ដើម្បីកែលម្អការបង្រៀនគណិតវិទ្យា វិទ្យាសាស្ត្រ អំណាន និងការអប់រំឌីជីថល) ត្រូវបានផ្តល់ក្រេឌីតដែលនឹងផ្លាស់ប្តូរ ទៅជាការលើកទឹកចិត្តសម្រាប់គ្រូបង្រៀន។ ការគាំទ្រក៏ត្រូវបានផ្តល់ឱ្យផងដែរ ទាក់ទងនឹងការរិះគ្រឹតការ និងការចុះជួយជាប្រចាំ។ សម្រាប់ជំហានបន្ទាប់ វាជាការល្អក្នុងការស្វែងយល់អំពី៖
- ការគាំទ្រការសិក្សាទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងឧបករណ៍
- ការអប់រំបម្រែបម្រួលយេនឌ័រ និងការអប់រំបរិយាបន្ន - ដើម្បីបំបែកបទដ្ឋានយេនឌ័រ និងគំរូដែលបង្កគ្រោះថ្នាក់ និងផ្សព្វផ្សាយតម្លៃនៃការគោរព សមភាពយេនឌ័រ និងការដាក់បញ្ចូលក្នុងសង្គម។
- ការអប់រំអំពីការប្រែប្រួលអាកាសធាតុដែលនាំទៅដល់សកម្មភាពដែលទាក់ទងនឹងអាកាសធាតុ។

**ដំណោះស្រាយទី៤៖** ការពង្រីក និងពង្រឹងការអប់រំកុមារតូច ដើម្បីឈានដល់ការសម្រេចស្តង់ដា។ ការផ្លាស់ប្តូរ នៃការគិតរបស់យើងទាំងអស់គ្នា។ យើងធ្លាប់មើលថាការអប់រំកុមារតូចគ្រាន់តែជាការអប់រំបន្ថែមដែលមិនចាំបាច់នោះទេ។ ប៉ុន្តែ ឥឡូវយើងចាត់ទុកវាជាផ្នែកមួយនៃការកសាងនូវមូលដ្ឋានគ្រឹះដ៏រឹងមាំល្អនៃការអប់រំ។ យ៉ាងណាមិញ វាទាមទារឱ្យបង្កើតការអន្តរាគមន៍ និងកម្មវិធីផ្ទាល់ខ្លួនសម្រាប់កុមារដែលមានតម្រូវការពិសេស។ ជាឧទាហរណ៍៖ ការរៀនផ្អែកលើការលេងសម្រាប់កុមារដែលមានពិការភាព។

**ដំណោះស្រាយទី៥៖** ការគាំទ្ររបស់ឪពុកម្ដាយ និងការចូលរួមរបស់សហគមន៍។ ការផ្លាស់ប្ដូរនៃការគិតរបស់យើងទាំងអស់គ្នា៖ យើងធ្លាប់ចាត់ទុកឪពុកម្ដាយ អ្នកអាណាព្យាបាលគឺជាគ្រូបង្រៀនដំបូងរបស់កូនៗរបស់ពួកគេ ប៉ុន្តែឥឡូវនេះ យើងទទួលស្គាល់ថាឪពុកម្ដាយ អ្នកអាណាព្យាបាលគឺជាអ្នកសិក្សា ដូច្នេះហើយទើបយើងមើលឃើញពីសារៈសំខាន់នៃការមានកម្មវិធីអប់រំសម្រាប់មនុស្សពេញវ័យ និងការសិក្សាពេញមួយជីវិត។ ដូចនេះ យើងក៏ត្រូវបង្កើតអន្តរាគមន៍ជាក់លាក់សម្រាប់ឪពុកម្ដាយ អ្នកអាណាព្យាបាល និងក្រុមគ្រួសារជាពិសេសសម្រាប់ក្រុមដែលងាយរងគ្រោះ ដូចជាជនចំណាកស្រុក អ្នកដែលប្រកបរបរពេស្យាចារ ឬរស់នៅតាមផ្លូវ និងអ្នកដទៃទៀត។

**ដំណោះស្រាយទី៦៖** ការជំរុញការអប់រំបរិយាបន្ន៖ ការលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នសម្រាប់ទាំងអស់គ្នា។ ការផ្លាស់ប្ដូរវិធីសាស្រ្តនៃការអប់រំ៖ យើងធ្លាប់គិតពីយេនឌ័រ និងបរិយាបន្នគ្រាន់តែជាចំណុចបន្ថែម ឬការពិពណ៌នាដែលលំអិតដែលមិនសំខាន់។ ប៉ុន្តែបច្ចុប្បន្ននេះ យើងបានទទួលស្គាល់ពីសារៈសំខាន់នៃការយល់ដឹងការបញ្ជ្រាបយេនឌ័រ និងបរិយាបន្នសង្គមនៅក្នុងការអប់រំ។ ហើយនេះត្រូវបានអនុវត្តនៅក្នុងវដ្តទាំងមូលនៃការស្រាវជ្រាវឈានដល់ការធ្វើផែនការ ការអនុវត្ត និងការត្រួតពិនិត្យនិងវាយតម្លៃជាដើម។ វាអាចត្រូវបានគេមើលឃើញនៅក្នុងហេដ្ឋារចនាសម្ព័ន្ធ ប្រសិនបើយើងបំពេញតាមស្តង់ដាWASH ប្រសិនបើមានផ្លូវជម្រាលសម្រាប់ជនពិការ។ វាត្រូវបានគេមើលឃើញផងដែរនៅក្នុងគរុកោសល្យនិងកម្មវិធីសិក្សា។ យើងក៏បានរៀនសូត្រដែរថា យើងត្រូវទៅដល់តំបន់ជនបទដាច់ស្រយាល រកមើលចំណុចប្រសព្វនៃយេនឌ័រ និងពិការភាព ចូលរួមជាមួយអ្នកដែលមានតម្រូវការពិសេស ហើយត្រូវដឹងថាបច្ចេកវិទ្យាគឺជាយេនឌ័រ។

ជារួម សម្រាប់ដំណោះស្រាយទាំងអស់ខាងលើ យើងមានការអនុវត្តល្អ។ ប៉ុន្តែ តើយើងធ្វើវាបន្ត និងពង្រីកការអនុវត្តល្អនោះដោយរបៀបណា? យើងត្រូវដោះស្រាយតម្រូវការសម្រាប់ការផ្ដល់ហិរញ្ញប្បទានអប់រំ។ ហើយនេះជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល។ ជាឧទាហរណ៍ ប្រហែលជារដ្ឋាភិបាលអាចគាំទ្រNGO ដែលធ្វើការងារបានល្អ ប៉ុន្តែNGO គួរតែរក្សាឯករាជ្យភាព និងស្វ័យភាព ព្រោះនេះជាបរិយាកាសសម្រាប់ការបង្កើតថ្មី។

## X. ការអំពាវនាវសកម្មភាពពីសន្និសីទ

### *លោក ម៉ាក ដាម៉ាអែល សមាជិកក្រុមភិបាលអង្គការNEP និងជានាយកអង្គការTDSO និងលោក វន សំភាស់ នាយកប្រចាំប្រទេសរបស់អង្គការAEAកម្ពុជា*

*១. លោក ម៉ាក ដាម៉ាអែល សមាជិកក្រុមភិបាលអង្គការNEP និងជានាយកអង្គការTDSO*

លោកបានចាប់ផ្ដើម ដោយសកម្មភាពមានឥទ្ធិពលខ្លាំងមួយ ដោយដើរកាត់ក្នុងសាល និងនិយាយជាមួយសំលេង "ទិក...តាក់...ទិក...តាក់..." ហើយស្នើឱ្យអ្នកចូលរួមក្រោកឈរតាមសម្លេងនីមួយៗ។ នៅពេលមានមនុស្សប្រហែល១០នាក់ឈរ សកម្មភាពនេះបានក្លាយជារូបភាពសង្កត់សំខាន់មួយដែលបង្ហាញពីមាត្រដ្ឋាននៃបញ្ហា។ "ទិក" តំណាងឱ្យកុមារដែលចូលរៀន ដោយមានសុបិន្តអនាគតខ្លាំងក្លា ខណៈដែល "តាក់" បង្ហាញពីកុមារដែលបានបោះបង់ការសិក្សា។ តាមរយៈការបើកឆាកដ៏ លោកបានបង្ហាញពីស្ថានភាពដ៏គួរឱ្យព្រួយបារម្ភ និងបន្ទាន់នៃវិស័យអប់រំនៅកម្ពុជា។

ទោះបីជាបានមានការរីកចម្រើនយ៉ាងច្រើន ក្នុងការចុះឈ្មោះរៀននៅថ្នាក់បឋមសិក្សា—ដោយស្ទើរតែស្មើនឹង ៩៨% ក៏ដោយ ក៏អត្រាបញ្ចប់ថ្នាក់បឋមសិក្សានៅតែទាប ប្រហែល ៨០% ប៉ុណ្ណោះ។ នេះមានន័យថា ម្នាក់ក្នុងចំណោមកុមារ៥

នាក់គឺមិនបានបញ្ចប់ថ្នាក់បឋមសិក្សានោះទេបាន។ លោកបានបញ្ជាក់ថា ទិន្នន័យទាំងនេះមិនមែនជាស្ថិតិធម្មតា នោះទេ ប៉ុន្តែជាកុមារជាក់ស្តែង ដែលមានសុបិន្តតែមិនទទួលបានឱកាស។

នៅក្នុងថ្នាក់អនុវិទ្យាល័យ ស្ថានការណ៍កាន់តែធ្ងន់ធ្ងរ ពីព្រោះអត្រានៃការចាកចេញពីសាលាខ្ពស់ ជាពិសេសនៅក្នុងតំបន់ជនបទ និងសហគមន៍ងាយរងគ្រោះ។ លោកបន្តថា រាល់ចំនួនទាំងនេះ តំណាងឱ្យរឿងពិតៈ ក្មេងស្រីម្នាក់ត្រូវបោះបង់ការសិក្សាដើម្បីជួយផ្គត់ផ្គង់គ្រួសារ ក្មេងប្រុសម្នាក់ដែលមិនអាចទិញសម្ភារៈសិក្សា និងសិស្សដែលមានបញ្ហាក្នុងការសិក្សាប៉ុន្តែមិនទទួលបានការគាំទ្រ។

លោកទទួលស្គាល់ពីការខិតខំបែបអនុវត្តរបស់អង្គការ និងការពង្រឹងប្រព័ន្ធអប់រំរបស់រដ្ឋ ដែលរួមមានការកែលម្អហេដ្ឋារចនាសម្ព័ន្ធ សិក្ខាសាលាគ្រូបង្រៀន ការផ្តល់អាហារូបករណ៍ និងការអប់រំនៅកម្រិតថ្នាក់ដំបូងជាដើម។ ទោះជាយ៉ាងណា លោកបានព្រមានថា វាជាសកម្មភាពមិនគ្រប់គ្រាន់នោះទេ។ វិបត្តិគ្រប់ជ្រុងជ្រោយ ជាពិសេសការកាត់បន្ថយជំនួយអន្តរជាតិ និងបំលាស់ប្តូរនយោបាយសកល បានធ្វើឱ្យប្រព័ន្ធគាំទ្រ ដែលមានស្រាប់ កាន់តែងាយរងការបាក់បែក។ ការកាត់បន្ថយជំនួយពីប្រទេសដូចជាសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស សហភាពអឺរ៉ុប និងស្វីស កំពុងរំខានដល់ជីវភាពគ្រួសារជាច្រើន និងគំរាមដល់សាលារៀនជាច្រើន ជាហេតុធ្វើឱ្យអត្រាចាកចេញប្រហែលកើនឡើង។

បើទោះបីមានឆន្ទៈក្នុងការយល់ថាពិបាកក្នុងការប្រឈមនឹងបញ្ហានេះ លោកបានអំពាវនាវឱ្យរកកម្លាំងចិត្តជំនួសនឹងការបោះបង់។ លោកបានអំពាវនាវឱ្យស្ថាប័នជារដ្ឋ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល គ្រូបង្រៀន និងគ្រួសារទាំងអស់សហការគ្នាដោយមានឆន្ទៈរួម។ សារៈសំខាន់ គឺមិនមាននរណាម្នាក់ត្រូវបានបោះបង់ចោលទេ។ វាជាការទទួលខុសត្រូវសាធារណៈកម្រិតខ្ពស់ ក្នុងការមិនអនុញ្ញាតឱ្យកុមារណាម្នាក់ត្រូវបាត់បង់ឱកាស។

លោកបានផ្តល់អនុសាសន៍ ឱ្យមានការគិតវិញអំពីរបៀបគ្រប់គ្រងហិរញ្ញប្បទានវិស័យអប់រំ ការពង្រឹងប្រព័ន្ធក្នុងស្រុកដើម្បីអាចឈររឹងបានមុខនឹងភាពអស្ថេរភាពនៃជំនួយក្រៅប្រទេស និងការគំនិតបង្កើតវិធីសាស្ត្រថ្មីៗដែលមានប្រសិទ្ធិភាពខ្ពស់ និងចំណាយទាប ដើម្បីកាត់បន្ថយអត្រាបោះបង់កាសិក្សា។ លោកក៏ស្នើឱ្យបង្កើនការផ្តោតលើការស្តាប់សំឡេងរបស់កុមារ និងការចូលរួមយ៉ាងពេញលេញរបស់សហគមន៍ក្នុងការរួមបង្កើតដំណោះស្រាយ។

ទីបញ្ចប់ លោកសង្ឃឹម និងជឿជាក់ថា ការផ្លាស់ប្តូរវិធីសាស្ត្រនៃការអប់រំ នេះ មិនមែនជារឿងលំបាកទេ ប៉ុន្តែជារឿងត្រូវធ្វើ។ លោកបានអះអាងថា កុមាររាល់គ្នាមិនមែនត្រឹមតែចូលរៀនប៉ុណ្ណោះទេ ប៉ុន្តែត្រូវបញ្ចប់ការសិក្សា ដើម្បីបន្តបង្កើតអនាគតរបស់ខ្លួន និងរួមចំណែកក្នុងការអភិវឌ្ឍជាតិកម្ពុជា។

### *២. លោក វន សំភាស់ នាយកប្រចាំប្រទេសរបស់អង្គការAEAកម្ពុជា*

លោកបានជម្រាបជូនអង្គពិធីទាំងមូលថា ខាងក្រោមនេះគឺជាបញ្ជីនៃការអំពាវនាវ សម្រាប់សកម្មភាពពីសន្និសីទជាតិលើកទី៦ ស្តីពីការបរិវត្តកម្មវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ដែលតម្រូវទៅតាមតួអង្គនៃប្រព័ន្ធអេកូឡូស៊ីជាច្រើនដូចជារដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអ្នកដទៃផ្សេងៗទៀត។ អំពាវនាវនីមួយៗសំដៅទៅលើតួអង្គជាក់លាក់មួយ ដើម្បីធានានូវទំនួលខុសត្រូវច្បាស់លាស់ និងជំហានដែលអាចធ្វើសកម្មភាពបាន។

១ រដ្ឋាភិបាលៈ បង្កើនការវិភាជថវិកា និងធនធានដើម្បីធានាបាននូវការរួមបញ្ចូលយេនឌ័រ ពិការភាព និងកុមារក្រៅសាលា ខណៈដែលការលើកកម្ពស់បរិយាកាសសិក្សាប្រកបដោយសុវត្ថិភាពសម្រាប់សិស្សទាំងអស់។

២ រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានៈ រួមគ្នាធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាលារៀន ដើម្បីធានាថាសិស្សទាំងអស់មានលទ្ធភាពទទួលបានសម្ភារៈបរិក្ខារគ្រប់គ្រាន់ប្រកបដោយសុវត្ថិភាព ដែលគាំទ្រដល់បរិយាកាសសិក្សាប្រកបដោយប្រសិទ្ធភាព។

៣ ក្រសួងអប់រំ និងក្រសួងពាក់ព័ន្ធៈ គាំទ្រអ្នកអប់រំ និងបុគ្គលិកសិក្សាទាំងអស់ដោយផ្តល់នូវធនធានប្រកបដោយគុណភាព ដែលលើកកម្ពស់លទ្ធផលសិក្សា និងជំរុញវប្បធម៌អប់រំបរិយាបន្ន ។

៤ អគ្គនាយកដ្ឋានអប់រំ

- អនុវត្តក្របខណ្ឌវាយតម្លៃស្តង់ដា ដើម្បីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សឱ្យបានទៀងទាត់ និងធានានូវគណនេយ្យភាពនៅក្នុងស្ថាប័នអប់រំ។
- រួមបញ្ចូលការអប់រំអំពីការប្រែប្រួលអាកាសធាតុទៅក្នុងមុខវិជ្ជាស្នូល លើកកម្ពស់ការយល់ដឹង និងការយល់ដឹងអំពីបញ្ហាបរិស្ថានក្នុងចំណោមសិស្សានុសិស្ស។

៥ សាលារៀន និងគ្រូបង្រៀនៈ បង្កើត និងពង្រឹងការអនុវត្តគោលនយោបាយ ដោយសហការជាមួយសិស្សដើម្បីបង្កើតបរិយាកាសគាំទ្រ ដែលលើកទឹកចិត្តដល់ការសិក្សា និងការលើកទឹកចិត្ត។

៦ អាជ្ញាធរមូលដ្ឋានៈ គាំទ្រការបង្កើតមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងគំនិតផ្តួចផ្តើមបញ្ចប់ការប្រើប្រាស់ថ្នាំញៀនក្នុងសហគមនិងសាលារៀន បើកបរិយាកាសដែលជំរុញលទ្ធផលសិក្សា និងផ្តល់ធនធានអប់រំសម្រាប់ឱកាសសិក្សាសម្រាប់កុមារ និងមនុស្សពេញវ័យ។

៧ ម្ចាស់ជំនួយ/ដៃគូៈ វិនិយោគលើគំនិតផ្តួចផ្តើមអក្ខរកម្មឌីជីថលទូទាំងប្រទេស គម្រោងផ្តល់មូលនិធិដែលបំពាក់សាលារៀនជាមួយនឹងឧបករណ៍ចាំបាច់ និងការបណ្តុះបណ្តាលសម្រាប់លទ្ធផលសិក្សាប្រកប ដោយប្រសិទ្ធភាព និងការរួមបញ្ចូលបច្ចេកវិទ្យា។

៨ NGO និងម្ចាស់ជំនួយៈ ផ្តល់អាហារូបករណ៍ និងថវិកាសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន សម្របសម្រួលការបណ្តុះបណ្តាលជាប្រចាំ និងការកែលម្អការអនុវត្តការបង្រៀន។

៩ NGO ៖ បង្កើតកម្មវិធីគំរូ និងមានវិសាលភាពសម្រាប់គាំទ្រកំណែទម្រង់វិស័យអប់រំ យកចិត្តទុកដាក់សិស្សដែលជួបការលំបាក កុមារក្រៅសាលារៀន ដោយសហការជាមួយសហគមន៍មូលដ្ឋាន និង អាជ្ញាធរដើម្បីផ្តល់ការគាំទ្រ និងធនធានសមស្រប។

១០ NGO និងរដ្ឋាភិបាលៈ ពង្រីកសេវាការពារកុមារនៅក្នុងសាលារៀន អនុវត្តប្រព័ន្ធដែលអាចទុកចិត្តបានសម្រាប់ការរាយការណ៍ និងឆ្លើយតបចំពោះករណីអំពើហិង្សា និងការរំលោភបំពាន។

១១ វិស័យឯកជន

- បរិច្ចាគឧបករណ៍បច្ចេកវិទ្យា និងធនធានដល់សាលារៀន បង្កើនឱកាសសិក្សាឌីជីថលសម្រាប់សិស្ស និងគ្រូបង្រៀន។
- បង្កើតភាពជាដៃគូជាមួយសាលារៀនដើម្បីបង្កើតកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដែលស្របតាមស្តង់ដាឧស្សាហកម្ម បំពេញតម្រូវការការងារក្នុងស្រុក និងគាំទ្រក្រុមសិស្សដែលជួបការលំបាក

១២ ស្ថាប័នសាសនា៖ តស៊ូមតិសម្រាប់គុណតម្លៃបរិយាបន្ន និងការពង្រឹងឥរិយាបថវិជ្ជមានក្នុងបរិបទអប់រំតាមរយៈកម្មវិធីសហគមន៍ និងគំនិតផ្តួចផ្តើមផ្សព្វផ្សាយសន្តិភាពរវាងមនុស្ស និងមនុស្សសត្វ បរិស្ថាន។

១៣ យុវជន និងអ្នកមានឥទ្ធិពល៖ ដឹកនាំយុទ្ធនាការ និងគម្រោងការយល់ដឹងដែលផ្តោតលើចីរភាព និងសិទ្ធិអប់រំ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម និងការចូលរួមសហគមន៍ដើម្បីបំផុសការផ្លាស់ប្តូរ។

១៤ ពិចារណាឡើងវិញនូវវិធីសាស្ត្រ ចំពោះការផ្តល់ហិរញ្ញប្បទានអប់រំនៅក្នុងការវិវត្តន៍ជាក់ស្តែងថ្មីៗនាពេលបច្ចុប្បន្ននេះ។

១៥ ពង្រឹងប្រព័ន្ធគាំទ្រក្នុងស្រុក ដើម្បីទប់ទល់នឹងការប្រែប្រួលនៃមូលនិធិពីខាងក្រៅ និងលើកកម្ពស់ការចូលរួមសហគមន៍ ជាដៃគូពេញលេញក្នុងការបន្តការសិក្សា។ លើសពីនេះ ស្តាប់ និងទទួលយកនូវអ្វីដែលកុមារបានលើកឡើងខ្លួនឯង អំពីដែលអាចជួយពួកគេឱ្យនៅក្នុងសាលារៀន

១៦ បង្កើតការឆ្លៃប្រឌិតថ្មីជាមួយនឹងអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពលើការចំណាយ ដែលដោះស្រាយដោយផ្ទាល់នូវកត្តាបោះបង់ការសិក្សារបស់សិស្ស។

## XI. សុន្ទរកថាសំណេះសំណាល និងបិទកម្មវិធី

*ឯកឧត្តម ពុត សាមិត្ត អនុរដ្ឋលេខាធិការ តំណាងឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា*

ឆ្លៀតក្នុងឱកាសនេះឯកឧត្តម បានថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ដែលបានចំណាយពេលវេលានឹងបញ្ចេញនូវបទពិសោធន៍ ក៏ដូចជាចំណេះដឹងរបស់ខ្លួនក្នុងការចូលរួមនៅក្នុងសន្និសីទនេះ រហូតដល់ទទួលបាននូវលទ្ធផលគួរជាទីគាប់ប្រសើរ។ ក្នុងឱកាសនេះ ឯកឧត្តមបានឆ្លើយតបទៅនឹងបញ្ហាសន្និសីទក្នុងថ្ងៃនេះ ក្នុងនោះក្រសួងក៏បានឃើញបញ្ហាដូចក្នុងសន្និសីទនេះដែរ ១).បញ្ហាសិស្សបោះបង់ការសិក្សា ២).គម្លាតយេនឌ័រក្នុងវិស័យអប់រំ ៣).លទ្ធផលសិក្សារបស់សិស្សតាមរយៈការចូលរួមការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៅក្នុងថ្នាក់តំបន់ ៤).លទ្ធផលវាយតម្លៃសិស្សកម្រិតអន្តរជាតិ(PISA)ក្នុងនោះកម្ពុជាបានចូលរួមបានពីរលើក ក្នុងឆ្នាំ២០១៧ និង២០២២ ក្នុងពេលកូវីត ជាបន្តទៀតនឹងគ្រោងធ្វើជាលើកទី៣ ក្នុងខែមិថុនា នឹងចាប់ផ្តើមប្រមូលទិន្នន័យនៃការធ្វើតេស្តកម្រិតអន្តរជាតិទៅលើសិស្សដើម្បីធ្វើការវាយតម្លៃ។ ជាកិច្ចបន្ទាប់ ឯកឧត្តមនឹងដាក់របាយការណ៍សង្ខេបទៅឧទ្ទកាល័យ ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពិនិត្យមើល និងត្រូវរួមគ្នាដោះស្រាយបែបណាបន្តទៀត?

ជាចុងក្រោយឯកឧត្តមមានការប្តេជ្ញាចិត្ត ដែលមានមន្ត្រីក្នុងក្រសួងអប់រំ ទាំងនៅថ្នាក់កណ្តាល នៅតាមមន្ទីរការិយាល័យអប់រំស្រុក ជាពិសេសសាលារៀន ប្តេជ្ញាចិត្តរួមគ្នាធ្វើយ៉ាងណា ដោះស្រាយបញ្ហាដែលបានរកឃើញ ដូចប្រសាសន៍លោក MARK បានលើកឡើង «អនាគតក្មេង គឺជាអនាគតប្រទេសជាតិ» ហើយសង្ឃឹមថា កម្ពុជានឹងប្តេជ្ញារួមគ្នាទាំងNGO និងដៃគូពាក់ព័ន្ធទាំងអស់ ដើម្បីជួយលើកកម្ពស់វិស័យអប់រំឱ្យកាន់តែមានភាពធន់។

តាងនាមឱ្យថ្នាក់ដឹកនាំ ក្រសួងនឹងគាំទ្រនិងសហការគ្នាបន្តទៀត ដើម្បីបណ្តុះបណ្តាលយុវជនជំនាន់ក្រោយឱ្យទទួលបាននូវចំណេះដឹង ឥរិយាបថ និងមានសីលធម៌ នឹងរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិនាពេលអនាគត ដែលនាំឱ្យកម្ពុជាអាចសម្រេចនូវក្តីស្រម៉ៃនៅឆ្នាំ២០៣០ ឱ្យក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងនៅឆ្នាំ

២០៥០ឱ្យក្លាយជាប្រទេសដែលមានការអភិវឌ្ឍ។ ឯកឧត្តម ក៏បានបន្ថែមនូវមតិយោបល់ផ្ទាល់ខ្លួន ស្តីពីនាយកសាលា ដែលដើរតួនាទីសំខាន់ ថាតើអាចបង្កើតនូវមជ្ឈមណ្ឌលមួយ សម្រាប់បណ្តុះបណ្តាលពង្រឹងសមត្ថភាពជាអ្នកដឹកនាំរបស់នាយកសាលា? តើដៃគូNGO មានបេសកម្មដូចគ្នា អាចប្រមូលធនធានគ្នាបែបណា? ដើម្បីបង្កើតទៅជាកន្លែងបណ្តុះបណ្តាលមួយ ដែលនេះជាអាទិភាពមួយ និងជាកត្តាគន្លឹះមួយដែលនាំឱ្យមានការប្រែប្រួលប្រែក្លាយទ្រឹស្តី ឬឧត្តមានុវត្តន៍អាចយកទៅអនុវត្តបាន។ ហើយពេលបច្ចុប្បន្នកំពុងតែពង្រឹងនូវគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងបានកែលម្អកម្មវិធីបណ្តុះបណ្តាល ព្រមទាំងតម្លើងគុណវុឌ្ឍគ្រូបង្រៀន និងរៀបចំប្រព័ន្ធ(CPD) ដែលកំពុងតែដំណើរការបានល្អហើយ។ ដោយឡែកបញ្ហាការធ្វើវិក្រឹតការ ឬសុក្រឹតការ នាយកសាលា នេះជារឿងមួយដែលអ្នកចូលរួម និងដៃគូទាំងអស់ ដែលនៅក្នុងសន្និសីទជាតិនៅទីនេះ គួរពិចារណា តើគួររៀបចំបែបណា? ដើម្បីផ្តល់ឱកាសឱ្យនាយកសាលា។

ឯកឧត្តមក៏នឹងរួមចំណែកជាខ្លឹមសារមួយ សម្រាប់បណ្តុះបណ្តាលតាមរយៈការសិក្សានៅតាមតំបន់ក្នុងការបង្រៀនគាត់ជាទ្រឹស្តីនៃការអប់រំ និងកម្មវិធីសំខាន់ៗនៃកម្មវិធីអប់រំ មុននឹងទទួលការបណ្តុះបណ្តាលនាយកសាលា ត្រូវសិក្សាពីស្ថានភាពសាលារៀនឱ្យបានច្បាស់លាស់ពីបញ្ហាដែលមាន ដើម្បីយកមកធ្វើជាករណីសិក្សាក្នុងការសិក្សាអប់រំដែលពេលបញ្ចប់ការបណ្តុះបណ្តាល អាចបង្កើតបានជាគម្រោងមួយយកទៅអនុវត្តក្រោយពេលទទួលការបណ្តុះបណ្តាល។

## XII. របៀបវារៈ កម្មវិធី

# សន្និសីទជាតិលើកទី៦
# បរិវត្តកម្មវិស័យអប់រំ

| **ថ្ងៃទី១៖ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៥** | |
|---|---|
| **ម៉ោង** | **របៀបវារៈ/ប្រធានបទ** |
| ០៧:០០-០៨:០០ | ការចុះឈ្មោះរបស់ភ្ញៀវកិត្តិយស និងអ្នកចូលរួម |
| ០៨:០០-០៨:០៥ | គោរពភ្លេងជាតិ នៃព្រះរាជាណាចក្រកម្ពុជា |
| ០៨:០៥-០៨:១០ | សុន្ទរកថាស្វាគមន៍ដោយលោកស្រី **ហ៊ុន ម៉ូរ៉ាធី** ប្រធានក្រុមប្រឹក្សាភិបាលអង្គការNEP |
| ០៨:១០-០៨:១៥ | សុន្ទរកថាស្វាគមន៍ដោយលោកស្រី Kirsty Milev, Programme Quality Director, អង្គការWVI |
| ០៨:១៥-០៩:០០ | សុន្ទរកថាសំណេះសំណាល និងបើកកម្មវិធីដោយ **ឯកឧត្តម ពុត សាមិត្ត អនុរដ្ឋលេខាធិការ តំណាង** ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ០៩:០០-០៩:១៥ | ថតរូបអនុស្សាវរីយ៍ |
| ០៩:១៥-០៩:៣០ | **សម្រាក និងអាហារសម្រន់** |
| ០៩:៣០-១០:០០ | ការកំណត់ប្រធានបទសម្រាប់កិច្ចពិភាក្សា៖ **ការវិភាគលទ្ធផលសិក្សារបស់សិស្ស**<br>**បទបង្ហាញដោយ៖ លោក យឹង គឹមហេង អ្នកសម្របសម្រួលគម្រោងEOL អង្គការNEP** |
| ១០:០០-១២:០០ | **ដំណោះស្រាយទី១ កិច្ចពិភាក្សា៖ «ការលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីរបស់សាលារៀនដើម្បីពង្រឹងលទ្ធផលសិក្សារបស់សិស្ស? (ការចូលរួមរបស់NGO សាលារៀន អាជ្ញាធរមូលដ្ឋាន ឪពុកម្តាយ និងសហគមន៍)»**<br>សម្របសម្រួលដោយ៖ លោក ឡុង ស៊ីណា ប្រធានកម្មវិធីតស៊ូមតិ និងភាពដៃគូ អង្គការ UWS<br>វាគ្មិនទី១៖ លោក អឿន បូរ៉ា ប្រធានគម្រោងកម្មវិធីកុមារកម្ពុជារីករាយ អង្គការ KAPE<br>វាគ្មិនទី២៖ លោក សន សៅអួន នាយកសាលាបឋមសិក្សាសែងម៉ា ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង<br>វាគ្មិនទី៣៖ លោក ហង់ សំណាង ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង<br>វាគ្មិនទី៤៖ លោកស្រីបណ្ឌិត ពុត និស្ស័យ ប្រធាននាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ ក្រសួងMOEYS<br>វាគ្មិនទី៥៖ លោក អ៊ុត សារ៉ង នាយកផ្នែកការគ្រប់គ្រងតាមសាលារៀន អង្គការ Save the Children<br>សំណួរ&ចម្លើយ |
| ១២:០០-១៣:៣០ | **សម្រាកអាហារថ្ងៃត្រង់** |
| **លទ្ធផលសិក្សារបស់សិស្ស** | |

| | |
|---|---|
| ១៣:៣០-១៥:០០ | **ដំណោះស្រាយទី២៖ កិច្ចពិភាក្សា៖ «ភាពអាចបត់បែននៃការរៀនសូត្រសម្រាប់កុមារក្រៅសាលា៖ ការពង្រឹងការអនុវត្តថ្នាក់បំប៉នសិស្សរៀនយឺត។**<br>សម្របសម្រួលដោយ៖ លោក ព្រំ ឬទ្ធី អ្នកបច្ចេកទេសជំនាញអប់រំ អង្គការ WVI<br>វាគ្មិនទី១៖ លោក ឃី ឧប នាយកសាលាបឋមសិក្សាប្រាសាទ ស្រុកពួក ខេត្តសៀមរាប<br>វាគ្មិនទី២៖ លោក យិនសៀង សុមេធ ប្រធានកម្មវិធីអប់រំ អង្គការ AEA<br>វាគ្មិនទី៣៖ លោក ជា ចិន្តា ប្រធានកម្មវិធីផ្នែកអប់រំ អង្គការUWS<br>វាគ្មិនទី៤៖ លោក សឿង សុផា នាយកផ្នែកកម្មវិធីសិក្សាទូទៅ អង្គការPSE<br>វាគ្មិនទី៥៖ លោក ឡុង សានរិទ្ធី នាយករង និងជានាយកសាខាប៉ោយប៉ែត អង្គការដំណក់ទឹក<br>សំណួរ&ចម្លើយ |
| ១៥:០០-១៥:៣០ | សម្រាក និងអាហារសម្រន់ |
| ១៥:៣០-១៧:០០ | **ដំណោះស្រាយទី៣៖ ការពង្រឹងជំនាញគរុកោសល្យ និងចំណេះដឹងនៃមុខវិជ្ជាបង្រៀនសម្រាប់គ្រូបង្រៀន**<br>**កិច្ចពិភាក្សា៖ «របៀបនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនទំនើបក្នុងការរៀនកម្រិតថ្នាក់ដំបូង»**<br>សម្របសម្រួលដោយ៖ លោក ស៊ឹម សុចិន្ត្រា ប្រធានជាន់ខ្ពស់ផ្នែកបណ្តុះបណ្តាល អង្គការWorld Education<br>វាគ្មិនទី១៖ លោក ចាន់ តុលា ប្រធាននាយកដ្ឋានកិច្ចការរិក្រឹតការ ក្រសួងMOEYS<br>វាគ្មិនទី២៖ លោក សៅ ប៊ុនធឿន ប្រធានគម្រោងស្បៀងអាហារសម្រាប់ការអប់រំ អង្គការWorld Education<br>វាគ្មិនទី៣៖ លោក សុន ណាត នាយកប្រតិបត្តិ អង្គការTDSO<br>វាគ្មិនទី៤៖ លោក ចាន់ សុខអៀង ប្រធានជាន់ខ្ពស់កម្មវិធីអំណាន អង្គការRoom to Read<br>សំណួរ&ចម្លើយ |
| **ថ្ងៃទី២៖ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៥** | |
| **ម៉ោង** | **របៀបវារៈ/ប្រធានបទ** |
| ០៧:០០-០៧:៣០ | ការចុះឈ្មោះរបស់ភ្ញៀវកិត្តិយស និងអ្នកចូលរួម |
| ០៧:៣០-០៧:៤០ | ចាក់វីដេអូសង្ខេបថ្ងៃទី១ |
| ០៧:៤០-០៨:៣០ | **ដំណោះស្រាយទី៤៖ ការពង្រីក និងពង្រឹងការអប់រំកុមារតូច ដើម្បីឈានដល់ការសម្រេចស្តង់ដា**<br>វាគ្មិនទី១៖ Mechanism to Support Community Preschool Meet Minimum Standard of MoEYS<br>បង្ហាញដោយ លោកស្រី ញ៉ែម សុម៉ាលី អ្នកជំនាញផ្នែកអប់រំកុមារតូច សមាគមបណ្តុះកុមារ<br>វាគ្មិនទី២៖ Measure Learning Outcomes from a Play-Based Learning for Children with Disabilities<br>បង្ហាញដោយ លោកស្រី Sou Sotheany មន្ត្រីជាន់ខ្ពស់ផ្នែកMEAL អង្គការCRS<br>(១៥នាទី បទបង្ហាញ និង ១០នាទី សំណួរ&ចម្លើយ) |
| ០៨:៣០-០៩:៤៥ | **ដំណោះស្រាយទី៥៖ កិច្ចពិភាក្សាស្តីពី «ការគាំទ្ររបស់ឪពុកម្តាយ និងការចូលរួមរបស់សហគមន៍»**<br>វាគ្មិនទី១៖ Transformative Learning: A cost- Effective Model for Community Mindset |

| | |
|---|---|
| | បង្ហាញដោយ លោកស្រី ពៅ វណ្ណា នាយិកាប្រចាំប្រទេស អង្គការ DVV អន្តរជាតិកម្ពុជា<br>វាគ្មិនទី២៖ លោកស្រី Khem Solie អង្គការ Mith Samlanh<br>វាគ្មិនទី៣៖ លោកស្រី Soeng Chanra ប្រធានផ្នែកប្រតិបត្តិការ អង្គការ ISF Cambodia<br>(១៥នាទី បទបង្ហាញ និង ១០នាទី សំណួរ&ចម្លើយ) |
| ០៩:៤៥-១០:០០ | **សម្រាក និងអាហារសម្រន់** |
| **បរិយាបន្ន និងសមភាពយេនឌ័រក្នុងការអប់រំ** | |
| ១០:៥០-១១:៣០ | **ដំណោះស្រាយទី៦៖ កិច្ចពិភាក្សាស្តីពី «ការជំរុញការអប់រំបរិយាបន្ន៖ ការលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នសម្រាប់ទាំងអស់គ្នា»**<br>វាគ្មិនទី១៖ លោកស្រី ជួន ដារីត អ្នកជំនាញGESSI អង្គការUWS<br>វាគ្មិនទី២៖ Technology on Her Terms: gender and inclusion in education under digital transformation by Ms. Yuan Xu, Education Analyst, UNESCO Phnom Penh<br>វាគ្មិនទី៣៖ Ms. Tel Chandi, Gender Equality Disability and Social Inclusion, ChildFund<br>វាគ្មិនទី៤៖ Inclusive education for children with special needs by Mr. Pheng Samnang, Executive Director, DDSP<br>(១៥នាទី បទបង្ហាញ និង ១០នាទី សំណួរ&ចម្លើយ) |
| ១១:៣០-១២:០០ | **កម្មវិធីបិទ**<br>• សង្ខេបចំណុចគន្លឹះសំខាន់ៗនៃសន្និសីទ៖ លោកស្រី Florence May Cortina (Maya), Education Out Loud Coordinator, Asia South Pacific Association For Basic And Education (ASPBAE)<br>• ការអំពាវនាវសកម្មភាព៖ Mr. Mark Desmaele, Board of Director of NEP and Director of TDSO<br>• ការអំពាវនាវសកម្មភាព៖ Mr. Vorn Samphors, Country Director, Aide et Action International<br>សុន្ទរកថាសំណេះសំណាល និងបិទកម្មវិធីដោយ **ឯកឧត្តម ពុត សាមិត្ត អនុរដ្ឋលេខាធិការ តំណាងឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** |

សូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីក្នុងករណីចាំបាច់។

# XIII. បទបញ្ជាញ

**Scan here for the Sixth National Conference on Transforming Education Paganism Materials**

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល | NGO Education Partnership

www.nepcambodia.org
info@nepcambodia.org
+855 12 224 775
https://t.me/NEPComms
ផ្ទះលេខ ១១០ ផ្លូវលេខ ១២BT សង្កាត់បឹងទំពន់
ខណ្ឌមានជ័យ រាជធានីភ្នំពេញ